ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Court Suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Apr-2011, 09:12
CMS/CFO: Uch Arun

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីលើ "បណ្តឹងសាទុក្ខ", កាំង ហ្គេកអ៊ាវ ហៅ ឌុច**

**សាធារណៈ**

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក

**ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១**

**ម៉ោង ០៨:៥៨នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រីម ជាប្រធាន

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម ម៉ូតូ ណូហ្គូជិ
*(Judge Motoo NOGUCHI)*

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត
*(Judge Agnieszka KLONOWIECKA-MILART)*

ចៅក្រម យ៉ា ណារិន

ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហ៍
*(Judge Chandra Nilhal JAYASINGHE)*

ចៅក្រម ម៉ុង មន្នីចរិយា (បម្រុង)

ចៅក្រម ផ្លូរិន ម៉ុមបា (បម្រុង)
*(Judge Florence Mumba)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ

លោក គ្រីស្តូហ្វឺ ម៉ាក រីយ៉ាន
*(Mr. Christopher Mark Ryan)*

លោក ផន ធឿន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក ពេជ សម្បត្តិ

លោក សេង ប៊ុនឃាង

**មេធាវីការពារជនត្រូវចោទ កាំង ហ្គេកអ៊ាវ:**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ទី ស្រ៊ីនណា

លោក ខារីម ខាន *(Mr. Karim Khan)*

លោកស្រី ស៊ីលឃី ស្ទួតហ្ស៊ីនស្គី
*(Ms. Silke Studzinsky)*

លោក ហុង គឹមសួន

លោក គឹម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ម៉ាទីន ហ្សាកកាំង
*(Ms. Martine Jacquing)*

លោក ហ្វីលីព *កាណុន (Mr.Philippe Canonne)*

លោកស្រី អេលីហ្សាប៊េត រ៉ាបេសាន់ដ្រាតាណា
*(Ms. Elisabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម គង់ ស្រ៊ុម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម យ៉ា ណារិន | ខ្មែរ |
| ចៅក្រម អាកនីស្កា ក្លូណូវីកកា មីទ្បាត | អង់គ្លេស |
| លោក ខារីម ខាន | អង់គ្លេស |
| លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្តី | អង់គ្លេស |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក កង ឫទ្ធារី | ខ្មែរ |
| លោកស្រី ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក ហ្វីលីព កាណុន | បារាំង |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ផន ធឿន (ក្រឡាបញ្ជី) | ខ្មែរ |
| លោក ស៊ា ម៉ៅ (មន្ត្រីច្បាប់) | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| | |

# កិច្ចដំណើរការនីតិវិធី

[០៨:៥៨:២៥]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះតុលាការកំពូលប្រកាសបន្តសវនាការលើបណ្តឹងសាទុក្ខ។ នៅថ្ងៃនេះ គឺបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ លោកក្រឡាបញ្ជី តើគូភាគី និងមេធាវីអញ្ជើញមកគ្រប់ចំនួនទេ?

**លោក ស៊ា ម៉ៅ៖**

សូមគោរពជម្រាបប្រសាសន៍ឯកឧត្តមប្រធាន, នៅថ្ងៃនេះ គឺថាភាគីមានវត្តមានគ្រប់ចំនួន ក៏ប៉ុន្តែខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គឺអវត្តមានពីររូប គឺលោកមេធាវី អាឡាំង វ៉ែនណឺ ហើយនិងលោកស្រីមេធាវី អេលីហ្សាប៉េត រ៉ាបេសាន់ដ្រាតាណា តំណាងក្រុមមួយ និងក្រុមបី មិនបានអញ្ជើញមកទេ។ ប៉ុន្តែ ខាងដើមបណ្តឹងរដ្ឋប្បវេណី ជាលក្ខណៈបុគ្គលនោះ គឺមកចំនួនប្រាំបីរូបនៅថ្ងៃនេះ គឺមានលោកស្រី ហ៊ឹម មុំ, លោក លី ហ៊ា, លោក គោត ខន, លោក ម៉ម សុធា, លោក ឈុំ ស៊ីថា, លោក ជុំ ស៊ីវ៉ាត, អ្នកស្រី អ៊ឹម សុន្ទី ហើយនិង លោកស្រី ភឹង ស៊ុនថារី។ គឺក្រៅពីហ្នឹង គឺភាគីមានវត្តមានគ្រប់។

សូមអរគុណ។

[០៩:០០:៥៧]

**ប្រធានអង្គជំនុំ៖**

មើលម្តងទៀត គឺអំមិញហ្នឹង គឺខាងមេធាវី គាត់លើកដៃ គាត់បានន័យថា គាត់ចូល។

**លោក ស៊ា ម៉ៅ៖**

អំមិញនេះ សូមទោសលោកស្រីមេធាវី អេលីហ្សាប៉េត រ៉ាបេសាន់ដ្រាតាណា ហ្នឹង គាត់អញ្ជើញមក ប៉ុន្តែអំមិញអត់ឃើញគាត់។ បាទ, សូមទោស គាត់អញ្ជើញមក។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង យើងបន្តចូលដល់ការអានរបាយការណ៍របស់សហចៅក្រមរបាយការណ៍។ សូមអញ្ជើញលោកចៅក្រមអានរបាយការណ៍អំពីបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញ!

[០៩:០១:៣៩]

**ចៅក្រម យ៉ា ណារិន៖**

បាទ, សូមអរគុណលោកប្រធាន។ យោងតាមដីកាចាត់តាំងចៅក្រម សហចៅក្រមរបាយការណ៍របស់ប្រធានតុលាការកំពូល របាយការណ៍សម្រាប់ឋានៈដើមបណ្តឹងរដ្ឋប្បវេណី។

នៅពេលចាប់ផ្តើមជំនុំជម្រះលើសំណុំរឿង០០១ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩៣នាក់ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលយក ហើយអនុវត្តឲ្យចូលរួមក្នុងដំណើរការនីតិវិធី។ នៅពេលប្រកាសសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៤នាក់ ដោយសារមិនបានបង្ហាញភស្តុតាងឲ្យបានត្រឹមត្រូវតាមបទដ្ឋានតម្រូវ។

[០៩:០២:២២]

ការបដិសេធចោលនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៤នេះ អង្គជំនុំជម្រះសាលាដំបូងសំអាងលើហេតុផលមួយ ឬច្រើនក្នុងចំណោមហេតុផលទាំងបីដូចខាងក្រោម៖

ក) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានអះអាងថាខ្លួនជាជនរងគ្រោះដោយផ្ទាល់នៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយ កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅមន្ទីរស-២១ និង\ឬ ២៤ មិនអាចបង្ហាញភស្តុតាងឲ្យបានត្រឹមត្រូវទៅតាមបទដ្ឋានតម្រូវនោះទេ។

ខ) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានអះអាងថាខ្លួនជាជនរងគ្រោះដោយសារការបាត់បង់សាច់ញាតិជិតស្និទ្ធនៅសន្ទីរស-២១ ឬស-២៤ នោះមិនបានបង្ហាញភស្តុតាងស្របតាមបទដ្ឋានតម្រូវនៅអាទិភាពនៃជនរងគ្រោះផ្ទាល់នៃឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានផ្តន្ទាទោស និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញភស្តុតាងអំពីភាពសាច់ញាតិ ឬមានចំណងពិសេសនៃសេចក្តីស្រឡាញ់ ឬការរស់នៅក្នុងបន្ទុកទាក់ទិនទៅនឹងជនរងគ្រោះផ្ទាល់នៃមន្ទីរស-២១ ឬស-២៤ នោះទេ។

[០៩:០៣:៣៨]

**សារណាបណ្តឹងសាទុក្ខ៖**

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ក្រុម២ និងក្រុម៣ សរុបចំនួន២២នាក់ បានលើកទឡ្ហីករណ៍នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនចំនួនបួនចំណុច ដើម្បីប្រឆាំងនឹងការច្រាលចោលរបស់អង្គជំនុំជម្រះសាលាដំបូង លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេដូចខាងក្រោម៖

ក) អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសឆ្គងលើអង្គច្បាប់ ដោយអនុវត្តនូវនីតិវិធីដែលមានពីរដំណាក់កាលក្នុងការសម្រេចសេចក្តី លើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺដំបូងនៅពេលចាប់ផ្តើមជំនុំជម្រះក្តី ហើយបន្ទាប់មកនៅពេលចេញសាលក្រម។

ខ) អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសឆ្គងលើអង្គច្បាប់ ក្នុងការសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុវត្តនូវបទដ្ឋានដែលមានលក្ខណៈតឹងរ៉ឹងពេក។

[០៩:០៤:៣៥]

គ) អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសឆ្គងលើអង្គច្បាប់ ដោយអនុវត្តនូវបទដ្ឋានមួយចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានចែងក្នុងច្បាប់ ឬវិធានផ្ទៃក្នុងនោះទេ។ ពិសេស អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំដោយតម្រូវឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមែនជាអ្នករស់រានមានជីវិតពីមន្ទីរស-២១ ឬស-២៤ និងមិនមែនជាសមាជិកគ្រួសារនៃជនរងគ្រោះផ្ទាល់នៃមន្ទីរស-២១ ឬស-២៤ ឱ្យបង្ហាញថាជាសាច់ញាតិ ឬចំណងពិសេសនៃសេចក្តីស្រឡាញ់ ឬការរស់នៅក្នុងបន្ទុកដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះផ្ទាល់។

ឃ) ដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យអន្តរាយដល់ដំណើរការនីតិវិធីដែលប្រកបដោយយុត្តិធម៌ ដោយសារការខកខានមិនបានជូនដំណឹងជាមុនដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនូវបទដ្ឋានដែលខ្លួនបានយកអនុវត្តនៅក្នុងសេចក្តីសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម។

[០៩:០៥:៤១]

ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ក្រុម២ និងក្រុម៣ បានធ្វើសំណើមកអង្គជំនុំជម្រះតុលាការកំពូលសុំដាក់ភស្តុតាងបន្ថែម ដើម្បីគាំទ្រលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកសំណើទាំងនេះ។

**ចម្លើយតបៈ**

គ្មានចម្លើយតបណាមួយត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលឡើយ។

នៅក្នុងសវនាការលើបណ្តឹងសាទុក្ខនេះ អញ្ជើញតំណាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ក្រុម២ និងក្រុម៣ ធ្វើការរៀបរាប់លម្អិតបន្ថែមទៀត អំពីទឡ្ហីករណ៍របស់ខ្លួន។ ជាពិសេស ទាក់ទងទៅនឹងបទដ្ឋានសមស្រប មូលដ្ឋានច្បាប់ ហើយនិងការជូនដំណឹងដែលខ្លួនរំពឹងទុកចង់បានពីអង្គជំនុំជម្រះសាលាដំបូង។

[០៩:០៦:២៩]

**បញ្ហាសម្រាប់សំណង សាលក្រមសាលាដំបូងៈ**

ពាក់ព័ន្ធនឹងសំណង អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យចងក្រងសេចក្តីថ្លែងសុំអភ័យទោស និងការទទួលខុសត្រូវ ដែល កាំង ហ្កេកអ៊ាវ ហៅ ឌុច បានធ្វើឡើងនៅអំឡុងពេលសវនាការ ហើយបង្គាប់ថា កម្រងនេះត្រូវដាក់លើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក ក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីសាលក្រមនេះចូលជាស្ថាពរ។

២) លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានទទួលយកការទាមទាររួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសុំបញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិដែលបានស្លាប់នៅមន្ទីរស-២១ ក្នុងសាលក្រមសាលាដំបូង។

៣) អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោល នូវការទាមទារសំណងផ្សេងៗទៀតទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:០៧:២០]

**សារណាបណ្តឹងសាទុក្ខៈ**

ការទាមទារសំណងនៅក្នុងពេលសវនាការរួមមានៈ

ក) ការចងក្រង និងការផ្សព្វផ្សាយពាក្យសម្តីសុំអភ័យទោស ដែលធ្វើឡើងដោយ កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅក្នុងអំឡុងពេលសវនាការ និងចងក្រងមតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី។

ខ) បង្គាប់ឲ្យជនជាប់ចោទសរសេរលិខិតទៅរាជរដ្ឋាភិបាលកម្ពុជា ដោយស្នើសុំឲ្យអភ័យទោសជាផ្លូវរដ្ឋ និងថ្លៃចូលទស្សនាមន្ទីរស-២១ ជើងឯក មួយផ្នែកត្រូវយកមកប្រើប្រាស់ជាសំណង។

[០៩:០៧:៥៧]

គ) ការសាងសង់បូជនីយដ្ឋាននៅស-២១ និងជើងឯក។ ការប្រែក្លាយមន្ទីរ-- ការប្រែក្លាយព្រៃស ទៅជាកន្លែងបូជនីយដ្ឋាន។ ការដាក់ឈ្មោះជនរងគ្រោះនៅតាមអគារសាធារណៈចំនួន១៧ និងប្រារព្ធពិធីរំឮក ព្រមទាំងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលទស្សនាកន្លែងរំឮកដោយឥតគិតថ្លៃ។

ឃ) ការផ្តល់នូវសេវាថែទាំវេជ្ជសាស្ត្រខាងផ្លូវកាយ និងផ្លូវចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី។ និង

ង) ការផលិតផ្សព្វផ្សាយនូវឯកសារសោតទស្សន៍ ស្តីអំពីការជំនុំជម្រះក្តី រួមទាំងវិធានការអប់រំនានា។

[០៩:០៨:៣៧]

ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានស្នើសុំទទួលស្គាល់ឋានៈជាជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីថា ជាសំណង ជាទម្រង់មួយនៃសំណង។

ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ មិនបានប្តឹងសាទុក្ខលើការច្រានចោលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការទាមទារសំណងផ្សេងៗទៀតនោះទេ។

ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានប្តឹងសាទុក្ខប្រឆាំងទៅនឹងការច្រានចោលរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការទាមទារសំណង ដោយសំអាងលើហេតុដូចខាងក្រោម៖

ក) អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងផ្នែកច្បាប់ ដោយពុំបានផ្តល់នូវសំអាងហេតុគ្រប់គ្រាន់ក្នុងការដោះស្រាយលើការទាមទារសំណង។ ពិសេស មិនបានភ្ជាប់នូវកាលវិភាគរបស់ខ្លួនទៅនឹងសំណើសុំនានា។

[០៩:០៩:២៤]

ខ) អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងផ្នែកច្បាប់ ដោយតម្រូវឲ្យមានភាពជាក់លាក់ក្នុងកម្រិតមួយដែលមិនបានចែងនៅក្នុងច្បាប់វិធានផ្ទៃក្នុង ឬបទដ្ឋានអន្តរជាតិ។ ដូចជាការទាមទារការសាងសង់បូជនីយដ្ឋាននៅស-២១ និងជើងឯកជាដើម។ ភាគីបណ្តឹងសាទុក្ខបានលើកឡើងថា កាតព្វកិច្ចចុងក្រោយក្នុងការផ្តល់សំណង មានលក្ខណៈសមស្របសម្រាប់ភាគីដែលរងព្យសនកម្មជាសមត្ថកិច្ចរបស់តុលាការ។

គ) អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងលើផ្នែកអង្គច្បាប់ និងអង្គហេតុ ដោយមិនបានវិភាគ ឬធ្វើការសម្រេចលើការទាមទារសំណងមួយចំនួន។ ដូចជាការទាមទារឲ្យជនជាប់ចោទសរសេរលិខិតទៅរាជរដ្ឋាភិបាលកម្ពុជា ស្នើសុំឲ្យធ្វើការសុំអភ័យទោសជាផ្លូវរដ្ឋ ឬការចូលរួមក្នុងនីតិវិធីនៃការ

ផ្តល់សំណង ការទាមទារសុំចូលទស្សនាកន្លែងរំឭកដោយឥតគិតថ្លៃ សម្រាប់ជនរងគ្រោះ និងការទាមទារឲ្យដាក់ឈ្មោះជនរងគ្រោះនៅតាមអគារសាធារណៈ។

[០៩:១០:៣០]

ឃ) អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងផ្នែកច្បាប់ ដោយផ្តល់និយមន័យមិនបានត្រឹមត្រូវលើពាក្យសំណងផ្លូវចិត្ត និងសមូហភាព។ ដោយធ្វើការវាយតម្លៃលើការទាមទារសំណងទាក់ទងទៅនឹងការផ្តល់សេវាថែទាំវេជ្ជសាស្ត្រ និងសេវាថែទាំផ្លូវចិត្ត ថាស្ថិតនៅក្រៅវិសាលភាពនៃសំណង។

ង) អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងផ្នែកច្បាប់ ដោយតម្រូវឲ្យមានទំនាក់ទំនងរវាងការទាមទារសម្រាប់ថែទាំផ្នែកវេជ្ជសាស្ត្រ និងសេវាអប់រំនានា និងឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានរកឃើញថាជាអ្នកទទួលខុសត្រូវ។

ច) អង្គជម្រះសាលាដំបូងមានកំហុសឆ្គងលើអង្គហេតុ ដោយបានបដិសេធចោលនូវការទាមទារមួយចំនួនទោះបីជាការទាមទារនេះមានលក្ខណៈលម្អិតយ៉ាងណាក៏ដោយ។ ដូចជាការទាមទារទាក់ទងទៅនឹងការបញ្ចូលយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការសុំអភ័យទោស ឬការទាមទារការផលិត និងផ្សព្វផ្សាយឯកសារសោតទស្សន៍ស្តីពីសវនាការ។

[០៩:១១:៣៩]

ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានបញ្ចូលឈ្មោះលោកស្រី គឹម សុវណ្ណារី និងកូន ដែលជាជនរងគ្រោះផ្ទាល់នៃមន្ទីរស-២១ ទៅក្នុងសាលក្រម។

ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ បានប្តឹងសាទុក្ខលើការច្រានចោលរបស់អង្គជំនុំជម្រះសាលាដំបូងលើការទាមទារសំណងដោយមូលហេតុដូចខាងក្រោម៖

ក) អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងផ្នែកច្បាប់ដោយបកស្រាយវិធានមិនបានត្រឹមត្រូវចំពោះវិធាន២៣(១២) នៃវិធានផ្ទៃក្នុង ដែលចែងថា “សំណងអាចមានទម្រង់ជាការបង្គាប់ឲ្យផ្តល់មូលនិធិដល់សកម្មភាព ឬសេវាមិនរកប្រាក់ចំណេញណាមួយដែលមានបំណងផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះ”។

ខ) អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងលើអង្គច្បាប់ ដោយខកខានមិនបានអនុវត្តនូវមាត្រា៣៩ នៃច្បាប់អ.វ.ត.ក ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ ឬលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬតាមរយៈ

អំពីឧក្រិដ្ឋកម្ម។

គ) អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងផ្នែកច្បាប់ ដោយបង្ហាញថាការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីខ្វះនូវភាពជាក់លាក់ ទាក់ទងនឹងសោហ៊ុយប៉ាន់ស្មានទុកលើការសាងសង់បូជនីយដ្ឋាន និងទីកន្លែងដែលគិតទុក។

[០៩:១៣:០៣]

ឃ) អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងលើអង្គច្បាប់ ដោយខកខានមិនបានដោះស្រាយលើបញ្ហាក្នុងការបង្កើតមូលនិធីដើម្បីសំណង អនុវត្តសំណង ហើយអង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងលើអង្គច្បាប់ ដោយបដិសេធមិនទទួលនូវទំនាក់ទំនងរវាងការទាមទារសម្រាប់ថែទាំវេជ្ជសាស្ត្រ និងវិធានការអប់រំ និងឧក្រិដ្ឋកម្មដែលជនជាប់ចោទទទួលខុសត្រូវ។ មេធាវីការពារជនជាប់ចោទមិនបានធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម២ ក្រុម៣ នោះទេ។

នៅក្នុងពេលសវនាការលើបណ្ដឹងសាទុក្ខនេះ អញ្ជើញមេធាវីតំណាងភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម២និងក្រុម៣ ធ្វើបទបង្ហាញលើសំណើជាក់លាក់ផ្នែកសេចក្ដីសម្រេចនៃសាលដីកាដែលបានស្នើសុំ។

សូមអរគុណ។

[០៩:១៤:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហមេធាវីក្រុម១ ដើម្បីធ្វើសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ហើយខ្ញុំសូមជម្រាបផងដែរថា ពីម្សិលមិញនេះ គឺខាងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ បានសុំបន្ថែមភស្ដុតាងបន្ថែម ហើយអង្គជំនុំជម្រះក៏បានទទួលហើយ។ ដូច្នេះ នៅពេលដែលលោក លោកស្រីធ្វើសេចក្ដីថ្លែងការណ៍ គឺសូមអញ្ជើញលើកឡើងអំពីភស្ដុតាងបន្ថែមដែលលោក លោកស្រីបានដាក់ពីម្សិលមិញនេះ។

សូមអញ្ជើញ!

**លោក ខារីម ខាន៖**

សូមគោរព លោកប្រធាន លោក លោកស្រីចៅក្រម, ខ្ញុំឈ្មោះ ខារីម ខាន ជាមួយសហភាតាខ្ញុំ ទ្រី ស្រ៊ីនណា គឺជាសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១។ ក្នុងរយៈពេល៤០នាទី ដែលបាន

កំណត់ឲ្យយើងខ្ញុំលើកឡើងអំពីសារណារបស់យើងខ្ញុំនោះ គឺយើងខ្ញុំនឹងបែងចែកពេលវេលាជាពីរស្មើៗគ្នា។

បន្ទាប់ពីមានការធ្វើបទបង្ហាញជាបឋមខ្លះ និងប្រវត្តិសាវតារដែលនិយាយអំពីបណ្តឹងដ៏ទូលំទូលាយដែលបានដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ហើយដែលយើងបានលើករកឃើញនូវកំហុសដែលប្រព្រឹត្ត ដោយរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ សហភាតារបស់ខ្ញុំ បន្ទាប់មកនឹងបង្ហាញនូវអង្គហេតុមួយចំនួន និងភស្តុតាងដែលបានយកមកបង្ហាញជូននៅក្នុងអំឡុងសវនាការដែលយើងបានគិតថា ជាការគ្រប់គ្រាន់ហើយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដើម្បីទទួលបាននូវការទទួលស្គាល់ឋានៈនេះនៅទូទាំងអំឡុងនៃដំណើរការនីតិវិធី។ សហមេធាវីការពារក្តីក៏នឹងលើកឡើងអំពីភស្តុតាងថ្មីចាប់តាំងពីក្រោយពេលបញ្ចប់សវនាការសាលាដំបូងមក។

[០៩:១៦:១៧]

លោក លោកស្រីចៅក្រមជាទីគោរព, យើងខ្ញុំនឹងផ្តល់នូវការអានរបាយការណ៍របស់ចៅក្រមរបាយការណ៍ គឺដែលបានលើកឡើងនោះ គឺជាការត្រឹមត្រូវហើយ ដែលថាបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ គឺមិនបានគ្របដណ្តប់ទៅលើបញ្ហាសំណងនោះទេ។ ក៏ប៉ុន្តែៗ បើសំអាងហេតុ-- បើយើងខ្ញុំដាក់សំអាងហេតុនេះជូនដោយផ្ទាល់ ដោយដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតជាការជោគជ័យនេះ គឺថាវាជាការត្រឹមត្រូវ និងយុត្តិធម៌ដែលដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្ញុំជាតំណាងឲ្យគឺថានឹងគួរណាស់តែទទួលបានផលប្រយោជន៍ពីសំណង ពីការផ្តល់សំណងនេះ បើទុកណាជាសំណងសមូហភាព និងផ្លូវចិត្តក្តី ខ្ញុំគិតថាមិនមានជាបញ្ហាអីធំដុំនោះទេ បើតែខ្ញុំនឹងបញ្ជាឲ្យច្បាស់ចាប់ពីដើមដំបូងនេះទៅ។

[០៩:១៧:៣៣]

លោក លោកស្រីចៅក្រមជាទីគោរព, នៅពេលដែលយើងពិនិត្យមើលទៅលើមូលដ្ឋាននៃបណ្តឹងសាទុក្ខដែលបានដាក់ជូននេះ សារណាដែលខ្ញុំបានដាក់ជូនតុលាការកំពូលនេះ គឺដើម្បីធ្វើការពិនិត្យឡើងវិញ ហើយនិងពិនិត្យមើលថាតើមានអ្វីខ្លះដែលបានសម្រេច និងបានកើតឡើងនោះ?

ក្រោយពីការទទួលពីការចូលរួមនៅក្នុងដំណើរការនីតិវិធីរាប់ខែនៅក្នុងដំណើរការសវនាការ។ អ្វីទាំងអស់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំបំពេញទម្រង់បានគ្រប់គ្រាន់ហើយនោះ ហើយមានការទាក់ទងជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាជាអង្គការអន្តរការីមួយ ហើយដើមបណ្តឹងរដ្ឋប្បវេណី

ក៏ផ្តល់ការណែនាំមកដល់មេធាវីការពារក្តី-- មកដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ដើមបណ្តឹងរដ្ឋប្បវេណីបីនាក់ គឺបានដាក់ជូននូវភស្តុតាង គឺបានដាក់ជូននូវអ្វីៗទាំងអស់ដែលសាលាដំបូងបានទាមទារ។

[០៩:១៨:៤២]

ជាមួយនឹងសេចក្តីរំពឹងយ៉ាងខ្លាំង ចង់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃប្រកាសសាលក្រមនោះ ដែលជាលើកដំបូង ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលដំណឹងថា ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ដែលបានផ្តល់ឲ្យពួកគាត់នោះ ប៉ុន្មានខែមុននោះ គឺត្រូវបានដកហូតទៅវិញហើយ ដោយសារតុលាការបានរកឃើញនូវគោលការណ៍មួយដែលមានកម្រិតខ្ពស់ទាក់ទងទៅនឹងបញ្ហាយុត្តិធម៌នេះ។ គឺដោយការអនុវត្តនូវវិធាន២១ ដើម្បីធានាអំពីភាពប្រាកដប្រជានៃនីត្យានុកូលភាព និងតម្លាភាពនៃដំណើរការនីតិវិធីដែលបានតម្រូវ ដោយវិធាន២១(គ) ដើម្បីជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិដែលត្រូវការពារទៅដល់ពួកគាត់។

នេះគឺជាការណ៍មួយដ៏គួរឲ្យរន្ធត់សម្រាប់ពួកគាត់ ហើយពួកគាត់មានការច្របូកច្របល់ គាត់មានការអាក់អន់ទឹកចិត្តដែរ គឺថាគាត់ធ្លាប់បានទទួលនូវជំងឺបាក់ស្បាតដោយសារតែជនជាប់ចោទ ឬទណ្ឌិត បើរកឃើញថាមានពិរុទ្ធភាពឈ្មោះ ឌុច នេះ។

[០៩:២០:១៦]

លោក លោកស្រីចៅក្រម មិនគួរណាភ័ន្តច្រឡំទៅលើ មើលរំលងទៅលើអង្គហេតុនៅក្នុងមូលដ្ឋាននៃបណ្តឹងសាទុក្ខដែលបានដាក់ជូននោះទេ។ នៅក្នុងសំណើសុំរបស់យើង ហើយក៏នៅក្នុងសេចក្តីណែនាំស្តីអំពីការដាក់ឯកសារ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនមានអ្វីដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចអំពីការចូលរួម ហើយវិធានផ្ទៃក្នុងក៏មិនមានចែងដែលថានឹងផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីជឿជាក់ថានឹងមានលក្ខខណ្ឌពីរដំណាក់កាល ដែលនឹងត្រូវយកមកអនុវត្តបែបនោះទេ។

គឺទីមួយ ត្រូវបានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ហើយមួយក្រុមទៀតនៅចុងបញ្ចប់ នឹងត្រូវទទួលនូវចុងបញ្ចប់ និងផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

ដូច្នេះ ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនគួរត្រូវដកយកទៅវិញទេ។ នេះគឺជាសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំ ដែលសាលាដំបូងបានបង្កើតបំបែកនូវវិធីសាស្ត្រទាំងនេះ ដើម្បីដោះស្រាយបញ្ហា ការទទួលស្គាល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនេះ។ ហើយសាលាដំបូងធ្វើដូចនេះ គឺជាការផ្ទុយ

ទៅនឹងភាសា ក៏ដូចជាគោលបំណងនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ជាពិសេស វិធាន១០០ នៃវិធានផ្ទៃក្នុងនេះតែម្ដង។

[០៩:២១:៥៨]

បទដ្ឋានផ្សេងៗទៀតដែលបានរៀបចំឡើងដោយសាលាដំបូង គឺមិនមានមូលដ្ឋានណាមួយនោះទេនៅក្នុងច្បាប់អន្តរជាតិ។ ច្បាប់ដែលយកមកសំអាងពីតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាការផ្ទុយ គឺស្ថិតនៅក្រោមបរិបទនៃសំណើសុំនេះ។ ឧទាហរណ៍នៅក្នុងរឿងក្ដី *ឌូទី* ដែលបានលើកឡើងថា ដែលបានដោះស្រាយទៅលើបញ្ហាទាំងអស់នេះ។ នៅពេលដែលមានការអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេតនៅចំពោះមុខតុលាការទាក់ទងទៅនឹងបុគ្គលទាំងអស់នោះ គឺគេបានដោះស្រាយបញ្ហានេះនៅដំណាក់កាលអង្គបុរេជំនុំជម្រះ ដែលតុលាការកំពូលគួរណាស់តែពិចារណា គឺយើងគឺបានដាក់ជូននៅចំពោះមុខសាលាដំបូងនៅក្នុង អ.វ.ត.ក នេះ។

ការដែលបានរកឃើញនៅក្នុងសាលក្រមដែលតម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញនូវឯកសារដើម្បីជាសំអាងនោះ គឺឯកសារដែលទាក់ទងទៅនឹងជនរងគ្រោះដោយផ្ទាល់គឺមិនមានមូលដ្ឋានមួយនោះទេ បើសំអាងទៅនឹងយុត្តិសាស្ត្រនេះ។ ហើយទាក់ទៅនឹងឧត្តមសេនីយ៍ ថាណើ ដែលទាក់ទងទៅនឹងច្បាប់អន្តរជាតិ គឺថាមិនមានការស៊ីសង្វាក់គ្នាទេ។ ហើយចុងក្រោយ គឺជនជាប់ចោទត្រូវបានផ្ដន្ទាទោសបើសិនណាតុលាការរកឃើញថា សាក្សីទាំងនោះគឺនិយាយជាការពិត។

[០៩:២៣:៤៣]

បើនិយាយអំពីដើមបណ្ដឹងរដ្ឋប្បវេណីវិញ គឺលក្ខខណ្ឌតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការនេះគឺជារឿងមួយដែលសំខាន់ណាស់។ ទាក់ទងទៅនឹងបរិយាកាស និងនៅក្នុងស្ថានភាពប្រទេសជាតិ ក៏ដូចជាប្រវត្តិសាវតាររបស់ប្រទេសជាតិ នៅពេលភស្តុតាងបង្ហាញថា កំណត់ត្រាផ្សេងៗនោះ គឺមានលក្ខណៈពេញលេញគ្រប់គ្រាន់ដែលអាចយកមកធ្វើជាសំអាង។ ជាពិសេស គឺដែលមានសំអាងនៅក្នុងសៀវភៅរបស់ នីក ដងឡុប ដែលយើងបានយកមកប្រើប្រាស់នៅក្នុងសវនាការ គឺគេបានយកចំណុចនេះមកសំអាងនៅក្នុងសវនាការ។

ដូច្នេះ ការទាមទារឲ្យមានកិច្ចសហប្រតិបត្តិការ ដូចដែលយើងខ្ញុំបានបញ្ជាក់ថា បទដ្ឋានដែលទាក់ទងទៅនឹងជនរងគ្រោះដោយផ្ទាល់ ដែលដើមបណ្ដឹងរដ្ឋប្បវេណី គឺត្រូវតែមានសេចក្ដីស្រឡាញ់ ត្រូវស្ថិតនៅក្នុងបន្ទុក ឬជាប់សំណងសាច់ញាតិ យ៉ាងហោចណាស់ក៏នៅក្នុងក្រុមខ្ញុំ គឺមានដើមបណ្ដឹង

រដ្ឋប្បវេណីចំនួនពីរគឺ រ៉ូស្ស៊ូ និង ជេហ្វហ្វ្រី ចេមស៍ ដែល ឌុច ខ្លួនគាត់ផ្ទាល់មិនបានបដិសេធទេ មិនបានបដិសេធ មិនបានមិនទទួលស្គាល់នោះទេក្នុងការទទួលស្គាល់ពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីរបស់យើងខ្ញុំ។

[០៩:២៥:២១]

លោក លោកស្រីចៅក្រមជាទីគោរព, វិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ហើយ គឺវិធានផ្ទៃក្នុងដែលអនុវត្ត ត្រូវយកមកអនុវត្តនៅពេលសម្រេចថា តើសាលាដំបូងបានប្រព្រឹត្តឲ្យមានកំហុស ឬក៏បានប្រើប្រាស់ទាំងមិនត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការទទួលយកភស្តុតាងដើម្បីឈានទៅដល់ការធ្វើសេចក្តីសម្រេចនេះ?

នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ គឺនៅដើមដំបូងនៃដំណើរការនីតិវិធី សាលាដំបូងបានយល់ច្បាស់ហើយថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលយកហើយ ហើយដើមបណ្តឹងរដ្ឋប្បវេណីពីរ គឺឈ្មោះ លី ហ៊ ហើយនិង ហ៊ឹម មុំ ត្រូវបានបញ្ជាក់អះអាងថាជាដើមបណ្តឹងរដ្ឋប្បវេណីហើយនៅក្នុងសវនាការនាពេលនោះ។ ហើយនៅក្នុងសារណារបស់យើងខ្ញុំ វាកាន់តែច្បាស់ជាងនេះទៅទៀតហើយនៅពេលដែលសាលាដំបូងបានលើកឡើង ហើយខ្ញុំសូមដកស្រង់។ ដោយការពិនិត្យពិច័យយ៉ាងត្រឹមត្រូវនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយ។ ហើយនៅពេលដែលអនុវត្តភស្តុតាងមួយក្រឡេកភ្នែក ដើម្បីសម្រេចទៅលើលក្ខណៈវិនិច្ឆ័យ ដើម្បីធ្វើការវាយតម្លៃទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ និងក្រោយពីស្តាប់មតិយោបល់របស់ភាគីដទៃៗទៀត សាលាដំបូងបានសម្រេចប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្ននោះ គឺថានឹងបានទទួលឋានៈនេះហើយ។

[០៩:២៧:០៧]

លោក លោកស្រីចៅក្រមជាទីគោរព, មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សាធារណជន ក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីគួរទទួលបាននូវសិទ្ធិ ហើយសាលាដំបូង ដែលត្រូវទទួលស្គាល់ពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនមែនដោយសារតែគ្រាន់តែការសួរដេញដោលគ្នា ហើយវាមិនមានផលប៉ះពាល់នេះទេ។

ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ គឺថាវាមានជាប់ពាក់ព័ន្ធទៅនឹងសិទ្ធិមួយចំនួន ហើយសិទ្ធិទាំងអស់នេះ គឺបានផ្តល់មកដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំបួន ដែលពួកគាត់មានសេចក្តីរំពឹង

ថានឹងទទួលបាននូវឋានៈនេះ។ ហើយដូចខ្ញុំបានជម្រាបជូនខាងដើមហើយ ពួកគាត់បានមកចូលរួមនៅជាមួយនឹងដំណើរការនីតិវិធីតុលាការក្នុងរយៈពេលយ៉ាងយូរ។ ហើយបញ្ហានេះគឺបានឈានទៅដល់សេចក្តីសន្និដ្ឋានមួយ ហើយពួកគាត់នេះ គឺជាអ្នកបង្ហាញនូវការទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនេះនៅក្នុងប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនេះហើយ។ ក៏មានបំណងដើម្បីផ្តល់សិទ្ធិឲ្យបានត្រឹមត្រូវជូនទៅដល់ជនរងគ្រោះទាំងអស់។

[០៩:២៨:២៦]

នេះគឺជាកាតព្វកិច្ចមួយរបស់រដ្ឋដែលខានមិនអាចខានបាន។ ហើយនៅក្នុងដំណើរការនីតិវិធីនោះ គឺថាគាត់បានចូលនៅក្នុងដំណើរការនីតិវិធីដោយផ្តល់សេចក្តីណែនាំ ដោយរៀបរាប់នៅដំណើររឿងដោយរៀបរាប់អំពីជំងឺបាក់ស្បាតដែលគាត់បានទទួលរងជូនដល់មេធាវីការពារក្តី ដែលចូលរួមនៅក្នុងដំណើរការនីតិវិធីនេះ។ ពួកគាត់បានរស់នៅ ដែលអ្វីយើងហៅថា រស់នៅប្រកបទៅដោយភាពតានតឹងធុញថប់នៅក្នុងអារម្មណ៍។

ដូច្នេះ វិធានផ្ទៃក្នុងគួរណាស់តែយកមកបកស្រាយទាក់ទងទៅនឹងសំណើសុំរបស់យើងខ្ញុំទាក់ទងទៅនឹងការផ្តល់សិទ្ធិទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេស នៅក្នុងរឿងក្តីចំពោះមុខយើងទាំងអស់គ្នានេះ ដែលមិនគួរណានឹងត្រូវបានច្រានចោលសំណើសុំនោះទេ ដែលគឺថាវាជាភស្តុតាងមួយសម្រាប់ប្រឆាំងទៅនឹង ឌុច នេះផ្ទាល់ ដែលពួកគាត់បានរៀបរាប់ទៅលើជំងឺបាក់ស្បាត ការទទួលរងការឈឺចាប់ ហើយខ្ញុំនឹងលើកឡើងនូវអង្គហេតុដែលមាននៅក្នុងសារណារបស់យើងខ្ញុំ ដែលអាចមានទម្ងន់មកដល់សំណើសុំទាំងនេះ។

[០៩:២៩:៤៨]

លោក លោកស្រីចៅក្រមជាទីគោរព, អ្វីដែលប្រសើរបំផុតនោះ គឺនៅខែសីហា ឆ្នាំ២០០៩ ដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមនៅក្នុងដំណើរ-- បានចងចាំនូវអ្វីដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសុំទុកចំណុចនេះមួយអន្លើ។

បញ្ហាដែលថា ដើមបណ្តឹងរដ្ឋប្បវេណីមិនបានជំទាស់ទៅនឹង រ៉ូហ្សា និង រ៉ូឆាល ឬក៏ ហ៊ឹម មុំ នេះ ដែលអ្នកបីនេះ គឺថាមិនត្រូវបានជនជាប់ចោទប្រឆាំងនោះទេ។ ក៏ប៉ុន្តែ ត្រូវបានសាលាដំបូងច្រានចោលទាំងបីនាក់។

ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ពាក្យសុំនេះ នៅថ្ងៃទី៧ ខែសីហា ជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង។ ពាក្យសុំរបស់ លី ហ៊ ដែលជាអ្នករស់រានមានជីវិតពីមន្ទីរសន្តិសុខស-២១ គឺថា គឺបានដាក់ជូនដល់អង្គជំនុំជម្រះសាលាដំបូង។ ប៉ុន្តែ មិនបានសម្រេចទៅលើពាក្យសុំនេះទេ សូម្បីតែនៅក្នុងសាលក្រមក៏មិនបានសម្រេចរហូតមកថ្ងៃនេះ គឺមិនទាន់បានយកមក យកពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនេះមកពិចារណានោះទេ។

[០៩:៣១:២៨]

អ្វីដែលសាលាដំបូងបានធ្វើ គឺបានយោងទៅលើលេខយោងជើងទំព័រ ដោយមិនបានអង្គសេចក្តីនៅក្នុងសំណើសុំ យកពិចារណានោះទេ។ ពីព្រោះនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ យើងបានដាក់សារណាមួយដើម្បីបង្កើតនូវទំនាក់ទំនងរវាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននៅក្នុងក្រុមមួយ ដែលជាជនរងគ្រោះដោយផ្ទាល់នៅមន្ទីរសន្តិសុខស-២១។ ហើយបន្ទាប់មកក៏បានដាក់ភស្តុតាង ដើម្បីគាំទ្រទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីប្រាំនាក់នៅក្នុងក្រុមមួយ។ ហើយនៅក្នុងខែវិច្ឆិកា គឺយើងបានដាក់ជូនសារណាជាលាយលក្ខណ៍អក្សររបស់យើងជូនទៅអង្គជំនុំជម្រះសាលាដំបូងទៅលើបញ្ហានេះ។

[០៩:៣២:១៦]

លោក លោកស្រីចៅក្រមជាទីគោរព, មធ្យោបាយជាក់ស្តែងដំបូងបំផុតដែលថា សាលាដំបូងបានប្រព្រឹត្តកំហុស គឺយោងទៅលើវិធាន១០១ នៃវិធានផ្ទៃក្នុង ដែលសាលាដំបូងយល់ឃើញវិធានផ្ទៃក្នុងនេះ គឺផ្តល់អំណាចទៅឲ្យសាលាដំបូងធ្វើការសម្រេចដកសិទ្ធិ ឬក៏ដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីពីអ្នកសុំនៅចុងបញ្ចប់នៃរឿងក្តី។ គឺនៅក្នុងបណ្តឹងសាទុក្ខរបស់យើង គឺយើងខ្ញុំបានបង្ហាញថា វិធាន ១០០-- អនុកថាខណ្ឌ១ នេះ គឺវាពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្តល់សំណងនេះហើយ។ វិធាននេះទាំងមូលគឺទាំងទងទៅនឹងសំណងតែម្តង គឺនៅក្នុងវិធាននេះមិនមានអ្វីចែង ខុសពីនេះដែលថាផ្តល់អំណាចទៅឲ្យសាលាដំបូងពិចារណាឡើងវិញការយល់ឃើញរបស់ខ្លួនពីមុនមកហើយនោះទេ។

[០៩:៣៣:២៥]

នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំ យើងបានយោងទៅលើអង្គហេតុដែលសាលាដំបូងខ្លួនឯងផ្ទាល់ ហើយដែលបានឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ គឺមិនមានអ្វីចែងច្បាស់លាស់នៅក្នុងវិធាននេះ ដើម្បីឲ្យគាត់ពិចារណាឡើងវិញនោះទេ។ ដូច្នេះ ប្រសិនណាជាសាលាដំបូង គឺមានសិទ្ធិបែបនេះ គឺយើងគិតថា វាមិនមែនជាករណីដែលសាលាដំបូងអាចធ្វើដូច្នេះទៅលើដើមបណ្តឹង

រដ្ឋប្បវេណីក្រុម១ បាននោះទេ។ ការធ្វើដូចនេះហាក់បីដូចជាការដាក់ខ្នោះដៃ ឬក៏ការដែលយកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនេះយកមកពិចារណាឡើងវិញដែលទាក់-- ប៉ុន្តែដើម្បីសម្រេចដូច្នេះបានត្រូវតែមានការកែប្រែទៅលើកាលៈទេសៈមួយចំនួន។

ឧទាហរណ៍ថា ដើមបណ្តឹងរដ្ឋប្បវេណីគាត់មានការកុហក គាត់និយាយមិនពិត។ ជាការពិតណាស់ដែលថា ដើម្បីស្វែងរកយុត្តិធម៌សាលាដំបូងអាចពិចារណាឡើងវិញនូវការផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីបាន។ ប៉ុន្តែ នៅក្នុងករណីរបស់យើងនេះ កាលៈទេសៈជុំវិញពាក្យសុំរបស់អ្នកទាំងប្រាំបួននាក់នេះ គឺមិនមានការកែប្រែអ្វីនោះទេ ដែលគាត់រំពឹងថាគាត់ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលដែលចេញសាលក្រមនេះ។ នេះគឺជាមូលដ្ឋានដែលយើងខ្ញុំបានដាក់ជូននៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំហើយ។

[០៩:៣៤:៥៩]

លោក លោកស្រីចៅក្រម យើងក៏នឹងបញ្ចូលទៅពិចារណាទៅលើលទ្ធភាពនៃវិធាន២៣(៤) ដែលយើងបានលើកឡើងហើយ គឺត្រូវតែប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែទទួលស្គាល់ ដែលថាសាលាដំបូងត្រូវតែសម្រេចទៅលើចំណុចនេះ។ ប៉ុន្តែ សាលាដំបូងមិនអាចធ្វើដូច្នេះបាន ដោយសារតែបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុងមួយនេះ ដែលច្បាស់ហើយថា សេចក្តីសម្រេចនេះត្រូវបានធ្វើឡើងនៅមុនដំណាក់កាលនៃដំណើរការនីតិវិធី ហើយខ្ញុំបាន-- គឺចំណុចនេះ គឺមានលើកឡើងនៅក្នុង-- នៅលើទំព័រ៩នៃសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំ។ ជាការពិតណាស់នៅពេលនោះ គឺថាវិធានផ្ទៃក្នុងចាស់គឺត្រូវតែយកមកអនុវត្ត ហើយដែលត្រូវសម្រេចទៅលើស្ថានភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី នេះជារឿងមួយធម្មតា។ ជារឿងមួយប្រកបទៅដោយវិចារណញ្ញាណហើយ នៅពេលដែលយើងយកវិធាន២៣ស្ទួនយកមកអនុវត្ត។ ដែលថា សហចៅក្រមស៊ើបអង្កេតខ្លួនឯងត្រូវសម្រេចថា តើត្រូវទទួលស្គាល់ដើម-- អ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏អត់នេះ? គឺត្រូវសម្រេចទៅលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីតាំងពីដើមដំបូងមកម្ល៉េះ ហើយដែលតុលាការដែលចៅក្រមសាលាដំបូងបានសម្រេចដកហូតជាឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីវិញនេះ ទាំងមិនត្រឹមត្រូវ។

[០៩:៣៦:៤៤]

សេចក្តីសង្ឃឹមមួយ គឺនៅក្នុងសាលាក្រមនោះគឺ នៅក្នុងវិធានផ្ទៃក្នុងគឺត្រូវតែបកស្រាយវិធាននេះឲ្យបានច្បាស់លាស់ ហើយចំណុចនេះយើងបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើង

ច្បាស់លាស់ហើយ។ អ្វីដែលបានបង្ហាញច្បាស់ចំពោះការសម្រេចទៅលើវិធាន២៣(៥) ចៅក្រមបានជឿជាក់ថា ពាក្យសុំទាំងឡាយដែលខ្លួនបានទទួលស្គាល់នោះបានរួមមានព័ត៌មានគ្រប់គ្រាន់រួចទៅហើយ ដែលអនុញ្ញាតឲ្យមានការផ្ទៀងផ្ទាត់គ្នាយ៉ាងត្រឹមត្រូវ ហើយវាបានគោរពទៅតាមវិធានផ្ទៃក្នុង។

លោក លោកស្រីចៅក្រម មានចំណុចជាច្រើនដែលត្រូវលើកឡើង ហើយយើងខ្ញុំផ្អែកទៅលើសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំដែលបានដាក់ជូននៅក្នុងការសម្រេច ថាតើយើងគួរចាត់វិធានការបែបណានោះ? ជាពិសេសនៅក្នុងដំណាក់កាលនេះ។ នៅក្នុងករណីដែលចៅក្រមមានការភ័ន្តច្រឡំ យើងខ្ញុំសូមលើកឡើងថា ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គួរតែផ្តល់ជូនឡើងជូនវិញអ្នកទាំងអស់ហ្នឹង។

លោកលោកស្រីចៅក្រម ប្រសិនបើលោក លោកស្រីមិនសម្រេចដូច្នោះទេ សហភាតារបស់ខ្ញុំគឺនឹងលើកឡើងជូនលោកចៅក្រមថា អ្វីទាំងឡាយដែលយើងបានដាក់ជូននៅចំពោះមុខសាលាដំបូងគឺជាភស្តុតាងគ្រប់គ្រាន់សម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ និងជឿថាឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីគួរតែត្រូវបានផ្តល់ជូនរួចទៅហើយនៅក្នុងដំណាក់កាលមុនដំបូងមុនពេលសវនាការ។ ហើយមិនមានមូលដ្ឋានណាមួយដែលយើងអាចដកចេញនូវឋានៈរបស់គាត់ទៀតនោះឡើយ។

[០៩:៣៩:០២]

លោក លោកស្រីចៅក្រម ខ្ញុំគិតថាវាដល់ពេលហើយសម្រាប់ខ្ញុំក្នុងការលើកសេចក្តីសន្និដ្ឋាន ហើយខ្ញុំនឹងឆ្លើយតបទៅនឹងសំណួរដែលចោទសួរពីអង្គជំនុំជម្រះនៅពេលក្រោយ។ ហើយដោយសារនៅពេលនេះ ខ្ញុំសុំអនុញ្ញាតផ្តល់ជូនវេទិកានេះទៅដល់សហមេធាវីជាតិវិញ។ សូមឲ្យលើកនូវសេចក្តីសន្និដ្ឋាន។

[០៩:៣៩:២៥]

**លោកស្រី ទី ស្រ៊ីនណា៖**

ជាបឋម នាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល និងលោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងអង្គជំនុំជម្រះនេះ។ នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិនៅក្នុងក្រុម១។

សូមធ្វើសេចក្តីសន្និដ្ឋាន ដូចតទៅ៖

ពាក់ព័ន្ធជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់ក្រុមនាងខ្ញុំ គឺលោក ខារីម ខាន ដែលជាសហមេធាវីអន្តរជាតិរបស់នាងខ្ញុំបានលើកឡើងយ៉ាងច្រើនក្បោះក្បាយពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គច្បាប់ ដែលអង្គ

ជំនុំជម្រះសាលាដំបូងបានខកខាន-- បានអនុវត្តដោយហួសពីវិសាលភាពដែលគាត់បាន-- ហួសពីវិសាលភាពដែលច្បាប់បានកំណត់។

ទាក់ទងទៅនឹងការបដិសេធកូនក្តីរបស់នាងខ្ញុំចំនួនប្រាំបួននាក់ នាងខ្ញុំយល់ឃើញថាការសម្រេចសេចក្តីនៅក្នុងការដកហូតសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ គឺមិនបានផ្តល់នូវយុត្តិធម៌ដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានទាមទារឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ធ្វើការបង្ហាញភស្តុតាងទៅតាមបទដ្ឋានដែលគាត់បានកំណត់។ កាលដែលទាមទារនោះ-- បទដ្ឋានដែលគាត់បានកំណត់នោះ គឺមានលក្ខណៈខ្ពស់ ហួសពីសមត្ថភាពដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលគាត់អាចធ្វើទៅបាន។

[០៩:៤១:០៧]

ដូច្នេះ នាងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញ នូវរាល់ឯកសារទាំងឡាយដែលដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ជូន និងនូវរាល់ការបំភ្លឺទាំងឡាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីគាត់បានបំភ្លឺនៅក្នុងពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់។ ទន្ទឹមហ្នឹងនេះដែរ នាងខ្ញុំនឹងធ្វើការបង្ហាញនូវចំណុចដែលភាព-- លើកបង្ហាញនូវចំណុចដែលជាភស្តុតាងដែលអាចទទួលយកបានរបស់កូនក្តីរបស់នាងខ្ញុំមួយ ដើម្បីជូនឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណាឡើយវិញ។

[០៩:៤១:៤៥]

ទីមួយ ពាក់ព័ន្ធនឹងកូនក្តីដែលមានឈ្មោះ លី ហ៊ា។ លី ហ៊ា ត្រូវបានអង្គជំនុំជម្រះសាលាដំបូងធ្វើការបដិសេធដោយសំអាងទៅលើភាពមិនអាចកំណត់បាននៃដើមបណ្តឹងរដ្ឋប្បវេណី។ មានន័យថាដើមបណ្តឹងរដ្ឋប្បវេណីមានឈ្មោះ អ៊ា ហ៊ារ ដែលមានកំណត់ត្រាជាចម្លើយសារភាពនៅមន្ទីរស-២១ ក៏ប៉ុន្តែ ពេលដែលគាត់ដាក់ពាក្យបណ្តឹងៗចូលមកអង្គជំនុំជម្រះសាលដំបូង គាត់បានប្រើប្រាស់ពាក្យថា លី ហ៊ា។ នេះគឺជាចំណុចមួយដែលអង្គជំនុំជម្រះពិបាកក្នុងការសន្និដ្ឋានអំពីអត្តសញ្ញាណរបស់ពួកគាត់។

ដូច្នេះ នាងខ្ញុំធ្វើការបង្ហាញនិងជម្រះនូវមន្ទិលសង្ស័យរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុចនេះ។

កូនក្តីរបស់នាងខ្ញុំបានឆ្លើយបំភ្លឺកាលពីដំណាក់កាលដេញដោល ក៏ដូចជាបានដាក់ឯកសារមួយចំនួនពាក់ព័ន្ធជាមួយនឹងការបំភ្លឺពីអត្តសញ្ញាណរបស់គាត់ថា អ៊ា ហ៊ារ និង លី ហ៊ា ជាបុគ្គលតែម្នាក់។

[០៩:៤២:៥២]

ក្រោយមកទៀត នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ចោក់ បានចេញសេចក្តីសម្រេចមក គឺធ្វើឲ្យមានលក្ខណៈមិនទទួលស្គាល់គាត់ដដែល គឺធ្វើឲ្យគាត់មានការខកបំណងជាខ្លាំង។ ក្រោយមកគាត់ក៏បានដាក់ឯកសារ កាលពីថ្ងៃទី១១ ខែមីនា ២០១១ នេះថ្មីៗហ្នឹង គាត់បានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណា និងពិនិត្យទៅលើស្នាមមេដៃរបស់គាត់ ដែលមាននៅក្នុងៗចម្លើយសារភាពរបស់គាត់ ដែលមានលេខ ERN00279930 ជាភាសាខ្មែរ ជាមួយនឹងសំណើសុំ ស្នាមមេដៃរបស់គាត់ដែលគាត់ស្នើសុំថ្មីៗនេះដែលបានដាក់ជូនអង្គជំនុំជម្រះរួចហើយ។

[០៩:៤៣:៣៧]

ហើយនិងចំណុចមួយទៀត គាត់ក៏បានធ្វើការស្នើសុំផងដែរដល់អង្គជំនុំជម្រះ ដើម្បីដាក់នូវឯកសារថ្មីមួយទៀតដែលពាក់ព័ន្ធទៅនឹងអត្តសញ្ញាណរបស់គាត់ ទាក់ទងនឹងសាវតាររបស់គាត់ ដែលអាចបង្ហាញ ដើម្បីឲ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់ឲ្យកាន់តែច្បាស់ ដើម្បីធ្វើការបញ្ជាក់ឲ្យកាន់តែច្បាស់ថា តើ លី ហ៊ា និង អ៊ា ហ៊ីវ ជាមនុស្សតែម្នាក់ ឬក៏យ៉ាងណា?

[០៩:៤៣:៥៦]

ដូច្នេះ លិខិតនាងខ្ញុំសូមប្រគល់ជូនអង្គជំនុំជម្រះឥឡូវនេះ ព្រោះដោយសារតែយើងមិនអាចដាក់ទាន់នៅពេលដែលយើងធ្វើការបកប្រែជាពីរភាសា។ ឥឡូវនេះ ឯកសារនេះបានបំពេញចប់សព្វគ្រប់ហើយ អ៊ីចឹងស្នើសុំឲ្យខាងតុលាការទទួលយកនូវឯកសារនេះនៅពេលនេះតែម្តង។

ទីពីរ ទាក់ទងនឹងកូនក្តីឈ្មោះ ហ៊ឹម មុំ។ ហ៊ឹម មុំ ត្រូវបានតុលាការសាលាដំបូងធ្វើការបដិសេធដោយមិនអាចកំណត់អត្តសញ្ញាណរបស់បងប្រុសរបស់គាត់ដែលឈ្មោះ សាំង គឹមលាង។ ដែលកូនក្តីរបស់នាងខ្ញុំបានធ្វើការបង្ហាញនូវរូបថត និងរូបថតរបស់គាត់ដែលគាត់បានចង្អុលបង្ហាញពីអត្តសញ្ញាណថា រូបថតបុគ្គលម្នាក់នេះ គឺជាបងប្រុសរបស់គាត់។ ដែលគាត់ចង្អុលបង្ហាញនេះ គឺឆ្លងទៅតាមការចងចាំនូវអត្តសញ្ញាណ ដោយភិនភាគទៅលើរូបភាព រូបរាងបងប្រុសរបស់គាត់។ ក៏ប៉ុន្តែ បែរជាខាងអង្គជំនុំជម្រះសាលា ដំបូងគាត់មិនបានពិចារណាទៅលើចំណុចនេះទេ។

[០៩:៤៥:២១]

ដូច្នេះហើយ បានជាដើមបណ្តឹងរដ្ឋប្បវេណីក្រុមខ្ញុំ គាត់ក៏បានធ្វើការបញ្ជាក់បន្ថែម និងបានដាក់លិខិតស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់បន្ថែមទៅលើចំណុចនេះ ទាក់ទងទៅនឹងការចង្អុលបង្ហាញពីអត្តសញ្ញាណរបស់បុគ្គលម្នាក់នេះ ដែលដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម មុំ អះអាងថាត្រូវជាបងប្រុស

របស់គាត់ គឺគាត់បានធ្វើការចង្អុលបង្ហាញ មានលិខិតពីរច្បាប់នេះដែលធ្វើឡើងដោយបងស្រីរបស់គាត់ គឺ សាំង ណេង ដែលបានចង្អុលបង្ហាញ និងបានឃើញរូបថតនេះហើយ ក៏បានចង្អុលបង្ហាញថា រូបថតនេះគឺពិតជា សាំង គឹមលាង ដែលត្រូវជាបងប្រុសរបស់ ហ៊ឹម មុំ ពិតប្រាកដមែន។

ហើយចំណុចដែលគួរឲ្យ-- ចំណុចដែលសំខាន់ ដែលអាចបញ្ជាក់កាន់តែច្បាស់ថែមទៀតនោះគឺមិត្តភក្តិរបស់បងប្រុសរបស់គាត់ដែលបានជាប់នៅក្នុងមន្ទីរស-២១ គឺរូបថតមួយនេះ គឺបញ្ជាក់ថា រូបថតនេះ គាត់ពិតជា សាំង គឹមលាង ដែលត្រូវជាមិត្តភក្តិរបស់គាត់ ហើយគាត់ក៏បានចងចាំនូវរូបភាពនេះជាអត្តសញ្ញាណដែលពិតជាមិត្តភក្តិរបស់គាត់ប្រាកដមែន។

ដូច្នេះ នាងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាទៅលើភស្តុតាងដែលជាសាក្សីបន្ថែម ដែលខាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដាក់នេះដើម្បីធ្វើការសម្រេចពិចារណាសារឡើងវិញចំពោះការទទួលយកសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីកូនក្តីរបស់នាងខ្ញុំ។

[០៩:៤៦:៤៦]

ពាក់ព័ន្ធជាមួយនឹងកូនក្តីម្នាក់ទៀតឈ្មោះ នង សាវ៉ាត។ នង សាវ៉ាត់ គាត់បានធ្វើការអះអាងថាឪពុកមា និងបងជីដូនមួយរបស់គាត់ត្រូវបានទៅកាន់នៅមន្ទីរស-២១។ ហេតុផលដែលគាត់ប៉ានធ្វើអំណះអំណាងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថា បងប្រុសរបស់គាត់ បងជីដូនមួយ និងក៏ដូចជាឪពុកដែលត្រូវជាប់នៅក្នុងមន្ទីរស-២១ នោះគឺពិតជាជាប់នៅក្នុងមន្ទីរស-២១ មែន ដោយសារតែគាត់មានតឹកតាងបង្ហាញថា ពូ ឪពុកមារបស់គាត់ គឺជាមន្ត្រីថ្នាក់ធំមួយរូបនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ដែលគាត់--

[០៩:៤៧:៣២]

**ប្រធានអង្គជំនុំ៖**

អ៊ីចេះៗ សូមលោកស្រីមេធាវីបង្ហាញឯកសារហ្នឹងដោយបញ្ជាក់លេខ អ៊ី.អ័រ.អិន ផងដើម្បីឲ្យកត់ចូលនៅក្នុងកំណត់ត្រា។

**លោកស្រី ទី ស្រ៊ីនណា៖**

លោកប្រធាននាងខ្ញុំសូមស្នើថា ប្រាប់ពីថ្ងៃខែ ពីព្រោះអីឯកសារខ្លះ គឺខ្ញុំអត់បានកុកូបពីចេញមកពីហ្សាយឡេប ទេគឺខ្ញុំយកចេញមកពីឯកសារដែលខ្ញុំមាន ហើយបានដាក់ជូន ហើយនិងបានកត់កំណត់នូវថ្ងៃដែលខ្ញុំបានដាក់។ ដូច្នេះ នាងខ្ញុំសូមបញ្ជាក់នូវថ្ងៃដែលខ្ញុំបានដាក់ និងលេខលិខិតដែលធ្វើនៅថ្ងៃទី

ប៉ុន្មាន? បើសិនជាលោកប្រធានអនុញ្ញាតខ្ញុំនឹងលើកនឹងចំណុចនុំងដដែល។

ឈ្មោះ នង សាវ៉ាត នេះដែរ ដែលគាត់បានដឹងពីតួនាទីរបស់ឪពុកមារបស់គាត់ដែលមានឈ្មោះ--

[០៩:៤៨:៤៩]

**ប្រធានអង្គជំនុំ៖**

សូមជម្រាបអ៊ីចេះថា តើឯកសារហ្នឹងថាជាឯកសាររបស់លោកស្រីដែលបានដាក់ពីលើកមុនហ្នឹង ឬក៏ឯកសារថ្មីទើបនឹងដាក់ឥឡូវហ្នឹងទៀត?

**លោកស្រី ទី ស្រ៊ុនណា៖**

ឯកសារថ្មីដែលបានដាក់ពីថ្ងៃទី ២៥ ខែមីនា ក្នុងឆ្នាំហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ, អ៊ីចឹង ដាក់ពីលើកមុន?

**លោកស្រី ទី ស្រ៊ុនណា៖**

ចាំស។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង អាចបញ្ជាក់ពីអត្តសញ្ញាណរបស់ឯកសារហ្នឹងមក ហើយមានលេខដូចជាលេខរបស់តុលាការកំពូលយើងដែលបានទទួលហើយទេ? បើមានអានលេខហ្នឹងផង។

**លោកស្រី ទី ស្រ៊ុនណា៖**

ចំពោះឯកសារហ្នឹង ឯកសារមួយបាន ខ្ញុំបានកូកុបពីចេញពីហ្សាយឡែបឡិប ឯចំណែកឯកសារមួយទៀតខ្ញុំយកចេញមកពីឯកសារដែលខ្ញុំមាន។ ដូច្នេះហើយ ឯកសារខ្លះ គឺខ្ញុំអត់បានកត់សម្គាល់ទេ ប៉ុន្តែ ឯកសារដែលខ្ញុំមាន ខ្ញុំនឹងបញ្ជាក់ជូនទៅអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ុនណា៖**

ចាំស, ចំពោះឯកសារដែលមាន ឯកសារដែលជាភស្តុតាង ដែលថ្មីៗនេះកូនក្តីរបស់ខ្ញុំទើបនឹងដាក់កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ គឺមានឯកសារដែលជាសាក្សីរបស់ ដែលត្រូវជាបងស្រី បង្កើត

នង សង ដែលត្រូវជាបងជីដូនមួយរបស់ នង សារ៉ាត់ ដែលឯកសារហ្នឹងអាចបញ្ជាក់ពីទំនាក់ ទំនងរវាង នង សារ៉ាត ជាមួយនឹង នង សង ដែលជាបងជីដូនមួយរបស់គាត់ ក៏ដូចជា នង សារួត ដែលត្រូវជាឪពុកមារបស់គាត់។

ឯកសារហ្នឹងមានលេខ ERN00657012 ហើយនិងលេខសម្គាល់របស់ខាង-- រហូតដល់ 00657013 ដែលមានលេខសម្គាល់របស់ខាងអង្គជំនុំ ជម្រះតុលាការកំពូល F2/5.9.1 និងឯកសារភស្តុតាងដែលយើងទើបនឹងដាក់ថ្ងៃជាមួយគ្នាហ្នឹងដែរដែលខ្ញុំបានបញ្ជាក់ជូនខាងដើមហើយថា ខ្ញុំបានដកចេញមកពីឯកសារដែលខ្ញុំមាន ខ្ញុំអត់បានព្រីនចេញពីឯកសារហ្សាយឡេប ទេគឺឯកសាររបស់ នង សារ៉េត។ នង សារ៉េត ហ្នឹង គឺត្រូវជាពូបង្កើតរបស់-- ត្រូវជាពូបង្កើតរបស់ នង សារ៉ាត ជាមួយនិង ស សារ៉េត ដូចដែលត្រូវជាបងប្អូនជីដូនមួយជាមួយគ្នាដែរ។ ហើយឯកសារនេះអាចសរបញ្ជាក់ ឆ្លុះបង្ហាញអំពី ឯកសារនេះឆ្លុះបង្ហាញអំពីទំនាក់ទំនងរវាង នង សារ៉ាត ជាមួយនិង នង សារួត ក៏ដូចជាមួយនិង នង សង ដែលត្រូវជាសាច់ញាតិ។ ហើយនិងឯកសារនេះក៏បានបញ្ជាក់ពីតួនាទីរបស់ នង សារួត នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលបញ្ជាក់ថា នង សារួត គាត់ជាអនុប្រធានសាលាហ្វឹកហ្វឺនហ្វឹកហ្វឺនទ័ពខ្មែរក្រហមប្រចាំតំបន់២៣ ក្នុងខេត្តព្រៃវែង។

[០៩:៥១:៥៥]

ដូច្នេះ នាងខ្ញុំស្នើសុំឲ្យលោកប្រធានពិចារណាត្រង់ចំណុច ឯកសារដែលខាងក្រុមខ្ញុំទើបតែបានដាក់ ក៏ដូចជាឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បំភ្លឺកន្លង។

ពាក់ព័ន្ធជាមួយនឹងកូនក្តីម្នាក់ទៀតដែលមានឈ្មោះថា ធៀវ នាប។ ធៀវ នាប ត្រូវបានអង្គជំនុំជម្រះធ្វើការបដិសេធដោយលើកសំអាងថា មិនមានភស្តុតាង ឬក៏ឯកសារបញ្ជាក់ពីទំនាក់ទំនងសាច់ញាតិ និងឯកសារបញ្ជាក់អំពីទំនាក់ទំនងរបស់ជនរងគ្រោះនៅមន្ទីរស-២១។

[០៩:៥២:១៨]

ពាក់ព័ន្ធជាមួយនិងនឹងចំណុចនេះដែរ នាងខ្ញុំសុំឲ្យអង្គជំនុំជម្រះមេត្តាពិចារណាចំពោះគាត់ ព្រោះ ធៀវ នាប ថ្វីត្បិតតែគាត់គ្មានសាក្សី និងភស្តុតាងបញ្ជាក់ ក៏ប៉ុន្តែសម្តីរបស់គាត់ គឺជាសាក្សីតែមួយគត់បញ្ជាក់ពីទំនាក់ទំនងសាច់ញាតិរបស់គាត់ជាមួយៗនឹងជនរងគ្រោះនៅមន្ទីរស-២១។

គាត់បានលើកឡើងថា ប្តីរបស់គាត់ ធ្លាប់ជាអតីតកងទ័ពខ្មែរក្រហមដែលធ្លាប់បានចូលរួមនៅក្នុងការវាយដណ្តើមយកភ្នំពេញនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥។ និងក្រោយមកទៀត ត្រូវបានប្តូរ

តំណែងជាកម្មាភិបាលនៅផ្សារថ្មីទទួលបន្ទុកសេដ្ឋកិច្ច។

លុះដល់ឆ្នាំ១៩៧៨ នៅពេលដែលកម្មាភិបាលជាច្រើននាក់ត្រូវបានអង្គការធ្វើការចាប់ខ្លួនបន្តបន្ទាប់ គាត់ក៏ត្រូវបានឡើងតំណែងជាកម្មាភិបាលនៅមន្ទីរ៨៧០។

[០៩:៥៣:២២]

ចំណុចមួយទៀត ដែលកូនក្តីរបស់នាងខ្ញុំ ធៀវ នាប គាត់អាចបំភ្លឺបានមួយទៀតគឺ ការចាប់ខ្លួនរបស់ប្តីរបស់គាត់។ ការចាប់ខ្លួនប្តីរបស់គាត់ គឺធ្វើឡើងនៅខាងជើងផ្សារថ្មី នៅក្នុង នៅខាងជើងផ្សារថ្មី នៅក្នុងឆ្នាំ១៩៧៨។ ដែលធ្វើឡើងដោយកម្មាភិបាលបីរូបដែលជិះឡានហ្ស៊ីប មកយក មកចាប់ប្តីរបស់គាត់យកទៅ។

ដូចលោក លោកស្រីចៅក្រម ក៏ដូចជាអង្គជំនុំជម្រះ ក៏ដូចជាភាគីទាំងអស់បានជ្រាបហើយថា ទាក់ទងទៅនឹងអង្គហេតុនេះ គឺវាមានភាពស៊ីសង្វាក់គ្នាជាមួយនឹងស្ថានភាពនៅមន្ទីរស-២១ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មានន័យថា ការចាប់ខ្លួនធ្វើនៅទីក្រុងភ្នំពេញ។ ដូច្នេះ បើសិនជា ទីមួយគាត់មានតួនាទីធំនៅក្នុងបក្សកុម្មុយនីស្តប្រជាធិបតេយ្យ។ ទីពីរ គាត់ត្រូវបានចាប់ខ្លួននៅទីក្រុងភ្នំពេញ។ ដូច្នេះ ការនាំគាត់ទៅ ចេញទៅគឺមិន គឺខ្ញុំអាចសន្មតថា គឺខ្ញុំអាចសន្មតថា វាជាការសន្និដ្ឋានមួយយ៉ាងច្បាស់ថា អ្នកដែលយកទៅនោះ មិនអាចយកទៅឆ្ងាយពីរង្វង់នៃទីក្រុងភ្នំពេញឡើយ។

សូមលោកប្រធាន លោក លោកស្រីចៅក្រមមេត្តាពិចារណាត្រង់ចំណុចនេះ។

[០៩:៥៤:៤៦]

ចំណុចមួយទៀត ទាក់ទងទៅនឹងកូនក្តីរបស់ខ្ញុំឈ្មោះ ង៉ែត អ៊ុយ។ ង៉ែត អ៊ុយ ដែលមានប្តីឈ្មោះ ប្រាក់ ប៉ាន។ គាត់ក៏ត្រូវអង្គជំនុំជម្រះធ្វើការបដិសេធដោយលើកហេតុផលប្រហាក់ប្រហែល និងស្រដៀងគ្នានឹងដើមបណ្តឹងរដ្ឋប្បវេណីមុនៗដែលខ្ញុំបានលើកឡើងរួចមកហើយ។

ប៉ុន្តែ កូនក្តីមួយនេះ ដែលក៏ខ្ញុំ សូមឲ្យអង្គជំនុំជម្រះពិចារណាទៅលើអង្គហេតុ និងភាពស៊ីសង្វាក់គ្នានៃសាច់រឿងរបស់ពួកគាត់។ គាត់បានលើកឡើងថា ប្តីគាត់ជាអតីតកម្មាភិបាលវរសេនាធំ កងពលលេខ១ ប្រចាំនៅភ្នំពេញ។ ដូច្នេះហើយ ចំពោះការចាប់ខ្លួន និងការបាត់ខ្លួនប្តីរបស់គាត់ គឺមិនអាចធ្វើឡើងហួសពីវិសាលភាពនៃដែនកំណត់របស់ទីក្រុងភ្នំពេញឡើយ។ សូមលោកប្រធានពិចារណាត្រង់ចំណុចនេះផងដែរ។

[០៩:៥៥:៥៣]

ពាក់ព័ន្ធជាមួយកូនក្តីដែលមានឈ្មោះ ជេហ្វហ្វ្រី ចេមស៍ និង រ៉ូហ្សា រ៉ូឆាល គឺលោក ខារីម ខាន បានលើកយ៉ាងច្បាស់ទៅលើភាពពាក់ព័ន្ធរបស់ពួកគាត់រួចហើយ។ ដូច្នេះ នាងខ្ញុំមិនលើកតទៅទៀតទេ។

នាងខ្ញុំសូមលើកកូនក្តីដែលមានឈ្មោះ លឹម យ៉ុន។ លឹម យ៉ុន គឺជា គាត់ខាងអង្គជំនុំជម្រះសាលាដំបូងធ្វើការបដិសេធគាត់ដោយសំអាងថា គាត់មិនមានភស្តុតាងបញ្ជាក់បន្ថែម ឬក៏បង្ហាញពីទំនាក់ទំនងសាច់ញាតិ ក៏ដូចជា ជនរងគ្រោះនៅក្នុងមន្ទីរស-២១។ ក៏ប៉ុន្តែ នាងខ្ញុំសូមឲ្យលោកចៅក្រមពិចារណាទៅលើព័ត៏មានរបស់គាត់ដែលមាននៅក្នុងលេខ ERN002807001 ដែលជាព័ត៏មាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់។ គាត់បានផ្តល់ព័ត៏មានយ៉ាងច្បាស់ហើយថា ព័ត៏មានដែលគាត់ទទួលបានថា បងប្រុសរបស់គាត់ជាប់នៅមន្ទីរស-២១ គឺដោយសារតែមានប្រធានមន្ទីរសន្តិសុខមួយរូបបានប្រាប់មកគាត់។ កាលដែលប្រាប់នោះ ប្រធានមន្ទីរសន្តិសុខ ដែលប្រាប់គាត់នោះ គឺប្រាប់នៅក្នុងអំឡុងពេលដែលគាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដូចគ្នា។

ដូច្នេះហើយ ការសរបញ្ជាក់ពីចេតនារបស់សាក្សីដែលបានប្រាប់មកគាត់ថា បងប្រុសរបស់គាត់នៅក្នុងមន្ទីរស-២១ នោះ គឺជាចេតនាមួយប្រាប់ដោយចង្អុលបង្ហាញការពិត មិនមានលក្ខណៈមួយដែលចង្អុលបង្ហាញពីកង្វះខាតនោះទេ។ មានន័យថា គាត់បានដឹងហើយ ថ្វីត្បិតតែឯកសារ ដែលគាត់នៅពេលចប់ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យចប់ គាត់បានស្វែងក៏ពិតមែន។ ស្វែងរកឯកសាររបស់បងប្អូន បងប្រុសរបស់គាត់ពុំឃើញ។ ក៏ប៉ុន្តែ ខ្ញុំនឹងធ្វើការសន្និដ្ឋានដោយលើកយកនូវអង្គហេតុមួយចំនួនជូនអង្គជំនុំជម្រះពិចារណាពីភាពកង្វះនៃឯកសារទាំងនេះ។

[០៩:៥៧:៤៨]

**ប្រធានអង្គជំនុំ៖**

លោកស្រីគឺលោកអស់ពេលហើយ ហើយលោកនៅមានបន្តទៅទៀត។ ដូច្នេះធ្វើឲ្យខ្លីបន្តិចមក។

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំសុំពេលថែមតែ៥នាទីទៀត។ សូមអរគុណ។

ទាក់ទងទៅនឹងឯកសារដែលបង្ហាញពីពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងសាច់ញាតិ។ ទាក់ទងនឹងទំនាក់ទំនងសាច់ញាតិ នាងខ្ញុំសូមបង្ហាញថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាភាគីទាំងអស់នៅក្នុងសំណុំរឿង០០១ សុទ្ធតែបានទទួលស្គាល់ថា បានកើតឡើងកាលពី៣០ឆ្នាំ។ ហើយឯកសារដែលពាក់ព័ន្ធក្តី ក៏ដូចជាឯកសាររបស់ប្រជាជនស្លូតត្រង់ភាគច្រើន គឺត្រូវបាន

បំផ្លិចបំផ្លាញបាត់បង់អស់។ ចំណុចទាំងនេះហើយដែលជាកត្តាមួយ ដែលជាលក្ខណៈពិបាកក្នុងការដែលកូនក្ដីរបស់នាងខ្ញុំក្នុងការស្វែងរកភស្តុតាងដើម្បីមកបញ្ជាក់បន្ថែម។ ទាក់ទងទៅនឹងចំណុចនេះផងដែរ ការបំផ្លិចបំផ្លាញចំពោះកូនក្ដីរបស់នាង-- ឯកសាររបស់កូនក្ដីនាងខ្ញុំ។

[០៩:៥៩:០៧]

កាលពីសម័យកម្ពុជាប្រជាធិបតេយ្យ គឺប្រជាជនខ្មែរទាំងអស់ ក៏ដូចជាជនរងគ្រោះទាំងអស់គឺបានដឹងហើយថា ឯកសារដែល-- ឯកសារក៏ដូច ជាទ្រព្យសម្បត្តិទាំងអស់ គឺត្រូវបានបក្សកុម្មុយនីស្ដកម្ពុជាប្រជាធិបតេយ្យ បានរឹបអូសយកទៅអស់ បានរឹបអូសយកទៅអស់ ហើយឯកសារមួយចំនួនទៀត គឺគាត់ត្រូវដុតបំផ្លាញចោលដើម្បីៗគេចផុតពីការតាមចាប់ និងការសម្លាប់របស់ពួកខ្មែរក្រហម។

ម្យ៉ាងវិញទៀត អ្នកដែលអាចមានសិទ្ធិនៅក្នុងការកាន់កាប់ និងគ្រប់គ្រងឯកសារ គឺមានតែបក្សកុម្មុយនីស្ដកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ជាអ្នកមានសិទ្ធិក្នុងការគ្រប់គ្រង និងរក្សាទុកឯកសារដើម្បីគ្រប់គ្រងបក្សកុម្មុយនីស្ដកម្ពុជាប្រជាធិបតេយ្យ។

[០៩:៥៩:៥១]

នេះគឺជាចំណុចមួយដែលបង្ហាញពីអង្គហេតុដែលបញ្ជាក់ថា កូនក្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ក៏ដូចជាកូនក្ដីរបស់យើងខ្ញុំមានការពិបាកក្នុងការរកឯកសារមកបង្ហាញបញ្ជាក់ពីទំនាក់ទំនងសាច់ញាតិរបស់ពួកគាត់។ សូមលោកប្រធានមេត្តាពិចារណាត្រង់ចំណុចនេះ។

ចំណុចដែលសំខាន់មួយទៀត ដែលពាក់ព័ន្ធទៅនឹងឯកសារបញ្ជាក់នៅក្នុងមន្ទីរស-២១។ នៅក្នុងមន្ទីរស-២១ នាងខ្ញុំសូមបញ្ជាក់។ នៅក្នុងមន្ទីរស-២១ កាលពីឆ្នាំ១៩៧៨ មន្ទីរស-២១ បានជួបនូវភាពវឹកវរ ដែលពេលនោះមន្ទីរស-២១ មិនអាចធ្វើការចុះបញ្ជីចំពោះអ្នកទោសដែលចូលមកថ្មីៗជាច្រើនសន្ធឹកសន្ធាប់ទេ ពីព្រោះអ្នកទោសចូលមកច្រាល់ជាច្រើនពេក។ ដូច្នេះហើយ គាត់មិនអាចចុះបញ្ជីនោះបន្ថែមទៀតបានឡើយ នេះគឺភាពនៃការបាត់ឯកសារ។

[១០:០០:៥៩]

ចំណែកឯកសារមួយទៀត ក៏ត្រូវបានរកឃើញថា ឯកសាររបស់មន្ទីរស-២១ ត្រូវបានបាត់បង់ផងដែរ ដូចជាការបញ្ជាក់របស់លោក ខារីម ខាន ពីខាងដើមទាក់ទងទៅនឹងការលើកឡើងរបស់លោកអ្នកស្រាវជ្រាវម្នាក់ឈ្មោះ នីក ដងឡុប ដែលគាត់បានស្រាវជ្រាវរកឃើញថា ឯកសារមួយចំនួនត្រូវបានប្រជាជនយកទៅធ្វើខ្ចប់ចេក ហើយនិងឯកសារមួយចំនួនទៀត ក៏ត្រូវបានបញ្ជាក់ថាបាត់ផងដែរ។

វាមានភាពស៊ីសង្វាក់គ្នាជាមួយនឹងរឿងរ៉ាវរបស់ឪពុកដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលមានឈ្មោះ ភឹង ហ្គុតស៊ុនថារី ដែលគាត់បានលើកឡើងអះអាងថា គាត់បានរកឃើញអត្តសញ្ញាណរបស់ឪពុករបស់គាត់ នៅពេលដែលគាត់ទិញស្ករត្នោតពីអ្នកជិះកង់ម្នាក់។ គាត់ទិញស្ករត្នោតពីអ្នកជិះកង់ដែលរកឃើញអត្ត-សញ្ញាណឯកសាររបស់មន្ទីរស-២១ ដែលរាយប៉ាយនៅក្រោយពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ ហ្នឹងត្រូវបានផ្តួលរលំ។

[១០:០២:០១]

ខ្ញុំសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាទៅលើអង្គហេតុទាំងនេះ ដែលវាមានភាពស៊ីសង្វាក់គ្នាជាមួយនឹងអង្គហេតុរបស់កូនក្ដីរបស់ខ្ញុំនិមួយៗ ក៏ដូចជាអង្គហេតុរបស់ ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត។ ដូច្នេះ នាងខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការពិចារណាពីភាពស៊ីសង្វាក់ គ្នានៃអង្គហេតុទាំងនេះ ដើម្បីសម្រេចទទួលយកពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីឡើងវិញ។

ចំណុចមួយទៀតដែលខ្ញុំបានសង្កេតឃើញផងដែរ គឺអង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេច របស់អង្គជំនុំជម្រះមួយផ្នែក គឺផ្អែកទៅលើចម្លើយរបស់ជនជាប់ចោទជាអ្នកចង្អុលបង្ហាញ។ នាងខ្ញុំយល់ ឃើញថា--

**ប្រធានអង្គជំនុំ៖**

លោកស្រីសូមបញ្ចប់ទៅ! ហើយបើមិនបញ្ចប់ទេ តុលាការនឹងបញ្ចប់ហើយ ព្រោះហួសម៉ោង ច្រើនទៅហើយ។

**លោកស្រី ទី ស្រ៊ីនណា៖**

អ៊ីចឹងខ្ញុំសូមបញ្ចប់ត្រឹមហ្នឹង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញចៅក្រម បើមានសំណួរ សូមអញ្ជើញសួរ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណលោកប្រធាន។ កំណត់សម្គាល់មួយទាក់ទងទៅនឹងភស្តុតាងដែលមេធាវីតំណាង ដើមរដ្ឋប្បវេណីបានលើកឡើង គឺអង្គជំនុំជម្រះតុលាការកំពូលបានទទួលយកភស្តុតាងនេះហើយ យើង គ្រាន់តែសួរឲ្យភាគីនៅក្នុងចម្លើយតបរបស់ខ្លួន របស់ដើមបណ្តឹមរដ្ឋប្បវេណីក្រុម១ ដើម្បីផ្តល់មតិយោបល់ ទៅលើភស្តុតាងនេះ។ ប៉ុន្តែឥឡូវនេះ ដោយសារថាវាដល់ពេលវេលាដែលយើងត្រូវចោទជាសំណួរ

ហើយនោះ ខ្ញុំចង់លើកឡើងអំពីភាពទទួលយកបាននៃដើមបណ្តឹង នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបទដ្ឋាននៃការបង្ហាញភស្តុតាង។

[១០:០៤:៣៣]

បញ្ហាដែលមេធាវីបានលើកឡើងនេះ គឺខ្ញុំសូមចាប់ផ្តើមដោយនិយាយថា យើងនៅទីនេះ យើងមកទីនេះ យើងយល់យើងមានសេចក្តីអាណិតអាសូរទាក់ទងទៅនឹងការអាក់អន់ស្រពន់ចិត្តរបស់អ្នកដែលបានរកឃើញថាឈ្មោះរបស់ខ្លួនត្រូវបានច្រានចោលនៅក្នុងសាលក្រមនោះ។ ប៉ុន្តែ ថាតើសេចក្តីរំពឹងរបស់ពួកគាត់ ហើយអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការចាត់ចែងទៅលើសេចក្តីរំពឹងនេះ គឺវាចាប់ផ្តើមឡើងជាមួយនឹងព័ត៌មានជាក់លាក់នៅក្នុងច្បាប់ ហើយក៏វាស្ថិតនៅក្នុងវិសាលរបស់តុលាការ ក៏ដូចជាភាគីដែលមានមេធាវីរបស់ខ្លួនជាធ្វើជាតំណាងក្នុងការគិតឃើញប្រមើលជាមុនឲ្យដឹងថា អាចនឹងមានផលវិបាកតាមផ្លូវច្បាប់។

[១០:០៥:២១]

សំណួរនេះ គឺថាខ្ញុំសូមសំអាងទៅលើមាត្រា១២ នៃកិច្ចព្រមព្រៀងដែលចង្អុលបង្ហាញទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ ដែលគ្រប់គ្រងគ្របដណ្តប់ទៅលើបញ្ហាទាំងអស់ ប្រសិនណាជាមិនមានភាពច្បាស់លាស់នៅលើចំណុចណាមួយ ឬក៏ថាមិនមានភាពស៊ីសង្វាក់ជាមួយនឹងបទដ្ឋានអន្តរជាតិនោះទេ។

សំណួរនេះ គឺទាក់ទងទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលបានចូលជាធរមានតាំងពីឆ្នាំ២០០៧។ ក្រមព្រហ្មទណ្ឌនេះ គឺហាក់បីដូចជាអនុញ្ញាតឲ្យមានការសម្រេចទៅលើពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាពីរដំណាក់កាល ហើយអ្វីដែលយើងបានរកឃើញនៅក្នុងពាក្យបណ្តឹងក៏មានសម្រេចនៅក្នុងពីរដំណាក់កាលដែរ គឺសម្រេចទៅលើភស្តុតាងបឋម ហើយនិងសម្រេចភស្តុតាងជាបន្តបន្ទាប់ទៅទៀត នៅពេលធ្វើសេចក្តីសម្រេចជាចុងក្រោយ។

[១០:០៦:៣០]

អ៊ីចឹង ទាក់ទងទៅនឹងក្របខ័ណ្ឌនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺថាវាតែងតែមានហានិភ័យថាដើមបណ្តឹងរដ្ឋប្បវេណីអាចមានការខ្វះ-- អឺ!មិនមានខ្វះខាតភាពនីត្យានុកូលភាពដោយប្រការណាមួយ។ ហើយខ្ញុំសូមយោងទៅមាត្រា៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺយើងបានដកស្រង់ពីកថាខណ្ឌនេះ តុលាការសម្រេចអំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏ត្រូវសម្រេចទៅលើពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ នេះគឺពាក់ព័ន្ធទៅនឹងការសម្រេចនៅក្នុងសាល--

នៅក្នុងសេចក្ដីសម្រេចសាលក្រម ឬក៏សាលដីកា។

[១០:០៧:២០]

ខ្ញុំសូមចូលទៅនឹងបញ្ហាបទដ្ឋាននៃការបង្ហាញភស្តុតាង។ ខ្ញុំសូមឲ្យមេធាវីយោងទៅមាត្រា១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុង ដែលនិយាយថាបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានដាក់ដោយជនរងគ្រោះនៃបទល្មើសដែលជាផលវិបាកផ្ទាល់នៃបទល្មើស ជាព្យាសនកម្មផ្ទាល់បានកើតឡើងនៅក្នុងពេលបច្ចុប្បន្ន ដែលហើយព្យាសនកម្មអាចជាព្យាសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬខាងផ្លូវចិត្ត។

នៅពេលដែលយើងបានពិនិត្យលើកំណត់ត្រាផ្សេងៗ គឺយើងបានឃើញថាព្យាសនកម្ម ឬការរងរបួស ដែលជាផលវិបាកដោយផ្ទាល់នៃបទល្មើសនេះ។ ជាពិសេសចៅក្រម ឡាវែន៍ គាត់បានលើកឡើងនៅចំពោះមុខមេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះ ទាក់ទងទៅនឹងបទប្បញ្ញត្តិនេះ ដែលយើងបានរកឃើញនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបើមេធាវី ឬក៏អ្នកដាក់ពាក្យសុំអាចផ្ដល់ជាយោបល់ថាយើងគឺថាព្រោះយើងមិនបានជូនដំណឹងបានគ្រប់គ្រាន់ទេ។ ដូច្នេះដើម្បីឲ្យពិនិត្យទៅវិញឡើងបាន ទាក់ទងទៅនឹងបទដ្ឋាននៃការបង្ហាញភស្តុតាងនេះ នេះគឺអ្វីដែលមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថាជាការមួយគួរតក់ស្លុតរន្ធត់ អាក់អន់ចិត្តនោះ។

[១០:០៩:១៨]

**លោក ខារីម ខាន៖**

លោកស្រីចៅក្រម ខ្ញុំសូមអរគុណច្រើនណាស់។ ទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗ តើតុលាការកំពូលនឹងប្រកាសនៅពេលឥឡូវនេះ ឬក៏នឹងនៅពេលក្រោយមួយណាដែលមានលក្ខណៈនេះ?

**ចៅក្រម អាកនីស្តា ក្លូណ្សូវីកកា មីឡាត៖**

កាលណាមានផ្ដល់ចម្លើយ គឺឲ្យតែនៅពេលណាដែលផ្ដល់ចម្លើយ គឺយើងអាចនឹងសម្រេចបាន។

**លោក ខារីម ខាន៖**

អ្វីដែលសាលាដំបូងបានយោង គឺគាត់មិនយោងមកលើបទប្បញ្ញត្តិទាំងអស់នេះទេ។ គឺសាលាដំបូងបានសំអាងទៅលើឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគឺទៅលើវិធាន១០០ ហើយនិងពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១។ ថាតើថ្ងៃ-- គឺដែលសាលាដំបូងមិនមានសិទ្ធិដកហូតឋានៈដើមបណ្ដឹងរដ្ឋប្បវេណីឡើងវិញនោះទេ។ នេះគឺជាចំណុចដែលយើងត្រូវចាប់ផ្ដើមនៅពេលដែលត្រូវពិនិត្យមើល ថាតើសាលាដំបូងបានប្រព្រឹត្តកំហុសមែន ឬក៏អត់នោះ? គឺសាលាដំបូងមិនបានចង្អុលបង្ហាញនូវច្បាប់ដូច

ដែលលោកស្រីចៅក្រមបានចង្អុលបង្ហាញនោះទេ ក្រៅតែវិធាន១០០ នៃវិធានផ្ទៃក្នុងតែប៉ុណ្ណោះ ដែលវិធាននេះទាក់ទងទៅនឹងសំណងរដ្ឋប្បវេណី។

[១០:១០:៥២]

វិធាននេះ គឺមិនទាក់ទងទៅនឹងការដកហូតឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីឡើងវិញនោះទេ។ ហើយបើសិនណាជាលោក លោកស្រីចៅក្រម អនុញ្ញាតគឺថាបើសិនណាមានជាសំណួរម្តងទៀត គឺថាខ្ញុំនឹងស្នើសុំតុលាការអនុញ្ញាតឲ្យខ្ញុំឆ្លើយជាលម្អិតបន្តទៅទៀត។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

គឺសូមអរគុណច្រើនលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ គឺថាបើសិនណាពេលក្រោយអនុញ្ញាតឲ្យមេធាវីលម្អិតជាការល្អណាស់។ ប៉ុន្តែ ជាបទប្បញ្ញត្តិមួយចំនួនគឺមានយោងនៅក្នុងសាលក្រម ប៉ុន្តែមាត្រាខ្លះមិនត្រូវបានយោងទេ។ ប៉ុន្តែ នៅក្នុងពេល យើងខ្ញុំមិននិយាយថា យើងមិនពិភាក្សាថាតើសាលក្រមនោះ វាសមហេតុផល ឬក៏អត់ នៅក្នុងពេលនេះទេ តែគ្រាន់តែយើងប្រមើលមើលទៅលើក្របខ័ណ្ឌច្បាប់ និងភាពត្រឹមត្រូវនៃបញ្ហាទាំងនេះ ដែលខ្ញុំរំពឹងថា ថាតើយើងត្រូវកំណត់-- ថាតើសាលាដំបូងបានពិនិត្យពិច័យទៅលើអង្គច្បាប់បានល្អិតល្អន់ដោយរបៀបណា? ហើយយើងនឹងពិភាក្សាទៅលើបទដ្ឋាននៃការបង្ហាញនោះ។

[១០:១២:២៤]

**លោក ខារីម ខាន៖**

លោកស្រីចៅក្រម តាមការពិតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយនិងវិធានផ្ទៃក្នុង ហើយនិងឧទាហរណ៍ជាច្រើនៗទៀត គឺវិធាន២៣ នៃវិធានផ្ទៃក្នុង។ ដូច្នេះ ការសេចក្តីសន្និដ្ឋានគឺជាការត្រឹមត្រូវប្រហែលជាចំណុចពិសេសៗជាក់លាក់មួយចំនួនទៀត នៃដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ។

អ្វីដែលច្បាស់នោះគឺថា ចៅក្រមនៅពេលដែលលើកឡើងថាៗ ផ្តល់ឋានៈមកឲ្យដើមបណ្តឹងរដ្ឋប្បវេណីគឺមិនអ្វីយកមកជាសំអាងភ្ជាប់នោះទេ។ នេះគឺជាការផ្តល់នូវឋានៈដ៏ងាយៗ ដែលវាច្បាស់ហើយដែលថា នៅដែលបានផ្តល់ឲ្យនៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនៅក្នុងសវនាការបឋម។ ប៉ុន្តែប៉ុន្មានខែក្រោយមក ប្រសិនណា វានេះជាសេចក្តីរំពឹងមួយគឺអ្នកដែលយើងគិតស្មានថាបានទទួលឋានៈនេះ ប៉ុន្តែសម្រាប់មេធាវីជាតិ មេធាវីកម្ពុជា ជាពិសេសនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើងគឺមានការភ្ញាក់ផ្អើល។ ជាពិសេស រួមទាំងអ្នកសារព័ត៌មានដែលបានរាយការណ៍ទៅលើដំណើរការនីតិវិធី

ទាំងនេះផង។ ដូច្នេះ វាពាក់ព័ន្ធទៅនឹងការប្រមើលមើលជាមុនទៅបាន។

[១០:១៣:៥៥]

ជម្រើសមួយដែលអាចធ្វើទៅបាន គឺត្រូវមានការផ្តល់នូវគំនិតយោបល់ ការប្រឹក្សានូវគំនិតយោបល់ផ្លូវច្បាប់ ដែលតាមការពិតគឺថាម្នាក់ៗ នៅក្នុងសាលសវនាការនេះ ក៏ដូចជាសាធារណជន គឺថាវិធានផ្ទៃក្នុងមិនបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការនៅក្នុងលក្ខណៈបែបនេះទេ។

គឺខ្ញុំសូមសំអាងទៅលើវិធាន២៣ និងវិធាន១០០ នៃវិធានផ្ទៃក្នុង ដែលនៅក្នុងសារណារបស់ខ្ញុំគឺត្រូវតែមានការបង្ហាញឲ្យបានច្បាស់លាស់ ហើយនេះវាជាកំហុសរបស់សាលាដំបូ ដែលសម្រេចនៅក្នុងសាលក្រមរបស់ខ្លួន។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមគោរពលោកប្រធាន, នាងខ្ញុំសូមបន្ថែមទៅលើអ្វីដែលខាងសហភាគីរបស់ខ្ញុំបានលើកឡើងពាក់ព័ន្ធជាមួយនឹង-- ហើយនិងសូមធ្វើការឆ្លើយតបជាមួយនឹងសំណួររបស់លោកស្រីចៅក្រម ពាក់ព័ន្ធជាមួយនឹងមាត្រា៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នាងខ្ញុំសូមលើកអង្គជំនុំជម្រះពិចារណាទៅលើមាត្រា៣៣៥ហ្នឹង គឺមាត្រា៣៣៥ នេះ នាងខ្ញុំគ្រាន់-- ៣៥៥ នេះ គឺខ្ញុំចង់បញ្ជាក់ពីភាពខុសគ្នានៃសាលាក្តី។ ទាក់ទងនឹងសាលាក្តីខ្មែរក្រហមនេះ គឺវាមានភាពខុសគ្នាជាមួយនឹងសាលាក្តីនៅក្នុងស្រុក។ នៅក្នុងសាលាក្តីនៅក្នុងស្រុក គឺយើងមិនមានសវនាការបឋមដូចនៅក្នុងសាលាក្តីខ្មែរក្រហមនេះទេ។ ដូច្នេះ ហើយបានជាមាត្រា៣៥៥ នេះ គឺចង្អុលបង្ហាញឲ្យខាងអង្គជំនុំជម្រះនៅក្នុងសាលាក្តីក្នុងស្រុកធ្វើការសម្រេចទៅលើភាពជាដើមបណ្តឹងរដ្ឋប្បវេណីនេះ។

ដោយឡែក ចំពោះសាលាក្តីខ្មែរក្រហមយើងនេះ គឺ អ៊ី.ស៊ី.ស៊ី.ស៊ី នេះ គឺយើងមានសវនាការបឋម។ ទាក់ទងទៅនឹងនីតិវិធីរបស់សវនាការបឋមនោះ គឺវាមានចែងនៅក្នុងវិធាន៨០ នៃវិសោធនកម្មលើទី៣របស់ អ.វ.ត.ក យើងនេះ។

[១០:១៦:១០]

ហើយនៅក្នុងសវនាការបឋមហ្នឹង គឺតម្រូវឲ្យអង្គជំនុំជម្រះធ្វើការពិចារណាទៅលើភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ អ៊ីចឹង រាល់ឯកសារទាំងឡាយ គឺគាត់ត្រូវតែធ្វើការពិនិត្យ និងពិចារណា និងសម្រេចឲ្យហើយ។

នេះគឺជាអ្វីដែលខ្ញុំសូមធ្វើការឆ្លើយតបជាមួយនឹងលោកស្រីចៅក្រម ទាក់ទងទៅនឹងមាត្រា៣៥៥។

**ប្រធានអង្គជំនុំ៖**

បាទ, សូមដល់ពេលសម្រាក តុលាការប្រកាសសម្រាកម្ភៃនាទី ហើយម៉ោងដប់សែសិននាទី យើងចូលបន្តកិច្ចសវនាការរបស់យើងទៀត។ ហើយសូមខាងមន្ត្រីពន្ធនាគារ គឺសូមនាំជនជាប់ចោទទៅសម្រាក។

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:៤០ នាទី ដល់ម៉ោង ១០:៤៧នាទី)*

[១០:៤៧:២០]

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

ប្រកាសបន្តសវនាការ។ ទាក់ទងនឹងបញ្ហាការដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយបានដាក់ភស្តុតាងបន្ថែម មានលិខិតបញ្ជាក់របស់នាយប៉ុស្តិ៍នគរបាលរដ្ឋបាលភ្នំតូច ឈ្មោះ ឱម សុផៃ បញ្ជាក់អំពីសាវតារជាតិរបស់ លី ហ៊ា ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១១ នេះ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចទទួលយកធ្វើការពិនិត្យ និងពិចារណា ហើយបើសហមេធាវី ហើយនិងខាងភាគីផ្សេងទៀតដែលពាក់ព័ន្ធមានបំណងនឹងឆ្លើយតប និងនៅពេលដែលធ្វើសេចក្តីថ្លែង គឺសូមលើកឡើងអំពីបញ្ហានេះ។

ហើយជាបន្តទៅទៀត ដើមបណ្តឹង-- សូមសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរធ្វើសេចក្តីថ្លែងអំពីសារណាបណ្តឹងសាទុក្ខ។

បាទ, សូមអញ្ជើញ!

**លោក ហុង គីមសួន៖**

សូមអរគុណឯកឧត្តមប្រធាន។ ជាដំបូងខ្ញុំបាទសូមគោរពឯកឧត្តមប្រធាន តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា និងលោក លោកស្រីចៅក្រម ព្រមទាំងសហភាគា លោក លោកស្រី បងប្អូន ជនរួមជាតិទាំងឡាយដែលបានចូលរួមក្នុងអង្គសវនាការថ្ងៃនេះ ព្រមទាំងអ្នកស្តាប់នៅឯ

ក្រោមន្ទីរ ឬក៏តុលាការនេះដែលកំពុងតាមដានស្តាប់ជាទីគោរព។

[១០:៤៩:៣៨]

ខ្ញុំបាទឈ្មោះ ហុង គឹមសួន ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ និងសហភាតាជាសហមេធាវីអន្តរជាតិជាមួយខ្ញុំបាទដែរ គឺលោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី ជាតំណាងឲ្យដើមបណ្តឹងក្រុមរដ្ឋប្បវេណីនៃក្រុមពីរផងដែរ។

ដោយសារពេលវេលារបស់យើងខ្ញុំមានរយៈពេលកំណត់បំផុតនោះ យើងខ្ញុំសូមផ្តោតយកចិត្តទុកដាក់តែទៅលើទឡ្ហីករណ៍តែពីរប៉ុណ្ណោះ នៅក្នុងបណ្តឹងសាទុក្ខពីរ ក្នុងចំណោមបណ្តឹងសាទុក្ខទាំងបីរបស់យើងខ្ញុំ។

[១០:៥០:០៧]

យើងខ្ញុំនឹងចាប់ផ្តើមពិភាក្សាទៅលើបណ្តឹងសាទុក្ខ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបដិសេធមិនទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់កូនក្តីយើងខ្ញុំចំនួនប្រាំនាក់។ សហភាតាអន្តរជាតិរបស់ខ្ញុំបាទនឹងបកស្រាយទៅលើមូលដ្ឋាននៃបណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះសំណើទាមទារឲ្យផ្តល់សំណង។

ក្រោយពីដើមបណ្តឹងរដ្ឋប្បវេណី និងដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីស្ទើតែទាំងអស់បានអនុវត្តសិទ្ធិក្នុងការចូលរួមពេញលេញនៅទូទាំងដំណើរការនីតិវិធីនៃសំណុំរឿង០០១ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១០ ដែលជាថ្ងៃប្រកាសសាលក្រម ឈ្មោះរបស់អ្នកដាក់ពាក្យសុំដែលអាចទទួលយកបានត្រូវបានអាននៅក្នុងវគ្គប្រកាសផ្សាយជាសាធារណៈមួយ។

[១០:៥១:០០]

នៅថ្ងៃនោះ ក្រោយពីមិនបានឮឈ្មោះរបស់ពួកគាត់ កូនក្តីរបស់យើងខ្ញុំចំនួនប្រាំនាក់ដឹងថា អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់។ វាជាការខូចខាតដ៏ធំធេងមួយចំពោះអ្នកចូលរួមទាំងនេះ ដែលបណ្តាលឲ្យជនរងគ្រោះទាំងអស់នេះកាន់តែមានជំងឺបាក់ស្បាត និងឈឺចាប់ខ្លាំងឡើងជាទីបំផុតថែមទៅទៀត។ នៅក្នុងពេលនេះ មិនមែនតែអ្នកចូលដែលត្រូវបានបដិសេធប៉ុណ្ណោះទេដែលបានទទួលរងការឈឺចាប់ ប៉ុន្តែ អ្នកដែលបានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីហើយ ក៏បានទទួលរងការឈឺចាប់ក្នុងលក្ខណៈសាមគ្គីភាពផងដែរ។

[១០:៥១:៤៣]

គេអាចទាញសេចក្តីសន្និដ្ឋានបានថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីចេញសេចក្តីសម្រេចអំពីភាពអាចទទួលយកបាន នៅដើមដំបូងនៃដំណើរការនីតិវិធីក្នុងសំណុំរឿង០០១ គឺដោយតែមានការដាក់សំពាធពីសាធារណជន សូមឲ្យចាប់ផ្តើមបើកសវនាការឲ្យបានឆាប់តាមដែលអាចទៅបាន។ ដោយការខកខានមិនបានធ្វើការពិចារណាជាចុងក្រោយទៅលើភាពអាចទទួលយកបាននេះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ជូនអ្នកទាំងនេះ នូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្ន ឬបានចាប់ផ្តើមនិយាយសំដៅទៅលើពួកគាត់ថា ជាដើមបណ្តឹងរដ្ឋប្បវេណី។

[១០:៥២:២០]

តាមមធ្យោបាយនេះ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំទាំង៩០នាក់ ចូលរួមយ៉ាងពេញលេញ។ ការមិនបានពន្យល់ឲ្យបានត្រឹមត្រូវចំពោះអត្ថន័យនៃពាក្យថា "ឋានៈបណ្តោះអាសន្ន ឬដើមបណ្តឹងរដ្ឋប្បវេណី" បែបនេះ បានបណ្តាលឲ្យអ្នកទាំងនេះយល់ច្រឡំទាំងស្រុងថា ពួកគាត់បានទទួលឋានៈពេញលេញហើយ។ រួមទាំងសិទ្ធិចូលរួមពេញលេញនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល។

នៅក្នុងអំឡុងសវនាការ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ត្រូវបានចាត់ទុកដូចគ្នាទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ពួកគាត់បានដាក់សារណា និងសំណើសុំតាមរយៈមេធាវីរបស់ពួកគាត់ និងបានចោទសួរសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។

[១០:៥៣:០៨]

តាមពិតទៅ កូនក្តីរបស់យើងខ្ញុំឈ្មោះ ណាំ ម៉ុន បានផ្តល់សក្ខីកម្មក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនចាំបាច់ផ្តល់សម្បថ និងបានសួរជនជាប់ចោទដោយផ្ទាល់តែម្តង។ អ្នកដាក់ពាក្យសុំទាំងអស់មានវត្តមាននៅក្នុងសាលសវនាការ និងបានចូលរួមក្នុងកិច្ចប្រជុំប្រចាំខែជាទៀតទាត់ជាមួយនឹងមេធាវីរបស់ខ្លួន ដើម្បីទទួលបានព័ត៌មានថ្មីៗទាក់ទងទៅនឹងសវនាការ។ ដោយសារតែកម្រិតនៃការចូលរបស់ពួកគាត់មានសិទ្ធិទទួលបាន អ្នកទាំងនេះបានគិតថា ខ្លួនបានទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងពេញលេញទៅហើយ។ សំខាន់បំផុតនោះ គឺពួកគាត់ត្រូវបានសំអាងថា ជាដើមបណ្តឹងរដ្ឋប្បវេណីនៅទូទាំងសវនាការ ជាជាងគ្រាន់តែជាអ្នកចូលរួមទៅវិញនោះ។ កូនក្តីរបស់យើងខ្ញុំទទួលបានតួនាទីមួយលេចធ្លោនៅក្នុងសហគមន៍របស់ពួកគាត់ និងបានធ្វើដំណើរមកទីក្រុងភ្នំពេញជាញឹកញាប់ និងត្រូវបានគេគោរពនៅក្នុងសហគមន៍របស់ខ្លួន ដោយសារតែឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីពិតប្រាកដនេះឯង។

[១០:៥៤:១២]

ពួកគាត់ជឿជាក់ថា នៅចុងបញ្ចប់នៃសវនាការនេះ ពួកគាត់នឹងមិនត្រូវដកហូតសិទ្ធិចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនេះទេ រួមទាំងសិទ្ធិទទួលបានសំណងផ្សេងៗទៀតផង។ នៅក្នុងសាលាក្រមនៃសំណុំរឿង០០១ កូនក្តីរបស់យើងខ្ញុំត្រូវបានបដិសេធដោយសារតែមូលហេតុបីៈ ទី១ មិនស្របទៅនឹងបទដ្ឋាននៃការបង្ហាញភស្តុតាង ទី២ ខ្វះការបង្ហាញនូវចំណងនៃសេចក្តីស្រឡាញ់ពិសេស និងទី៣ ជំនឿទុកចិត្ត។

[១០:៥៤:៤៥]

១) លោកស្រី ណាំ ម៉ុន ត្រូវបានបដិសេធដោយសារមិនបានបង្ហាញថា រូបថតដែលបានដាក់ជូនពិតជាបញ្ជាក់ពីសាច់ញាតិរបស់អ្នកដាក់ពាក្យសុំ ដោយមិនមានភស្តុតាងដទៃទៀត និងភាពមិនស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្មរបស់គាត់។

២) លោកស្រី ឆាយ កន ហៅ លៀង កន មិនមានការបង្ហាញថា រូបថតរបស់អ្នកជាប់ឃុំឃាំងគឺជាក្មួយប្រុសរបស់លោកស្រីឈ្មោះ ញែម ឆឹយ នោះឡើយ។

[១០:៥៥:១១]

៣) លោកស្រី ហុង សាវ៉ាត ខកខានមិនបានដាក់ជូនរូបថតពូរបស់លោកស្រី ដែលលោកស្រីអះអាងថា បានរកឃើញនៅក្នុងមន្ទីរសន្តិសុខស-២១ និង មិនមានភស្តុតាងផ្សេងទៀតដើម្បីបញ្ជាក់ពីការជាប់ឃុំឃាំងរបស់ពូគាត់នោះទេ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលពាក្យសុំរបស់លោកស្រី ដោយសារតែមិនមានភស្តុតាងបញ្ជាក់ពីចំណងនៃសេចក្តីស្រឡាញ់។

៤) លោក ឈឹម ស៊ីថា ត្រូវបានបដិសេធដោយសារតែគាត់មិនបានបង្ហាញពីចំណងនៃសេចក្តីស្រឡាញ់ពិសេស។

៥) លោកស្រី ញ៉ឹប គឹមស្រ៊ា ត្រូវបានបដិសេធចោល ដោយសារតែលោកស្រីត្រូវបានកើតក្រោយពីពូមីង និងបងប្អូនជីដូនមួយរបស់លោកស្រី ចំនួនប្រាំនាក់ បានស្លាប់ទៅ និងមិនបានបង្ហាញពីចំណងនៃសេចក្តីស្រឡាញ់ពិសេស។

[១០:៥៥:៥៥]

យើងខ្ញុំបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូងបានយល់ច្រឡំទៅលើអង្គហេតុ និងអង្គច្បាប់ នៅពេលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធកូនក្តីរបស់យើងខ្ញុំ។

ឥឡូវនេះ ខ្ញុំបាទសូមបញ្ជាក់ជូននូវមូលដ្ឋានសំខាន់នៃបណ្ដឹងសាទុក្ខនេះ។ មូលដ្ឋានទីមួយនៃបណ្ដឹងសាទុក្ខ អនុវត្តចំពោះកូនក្ដីទាំងប្រាំនាក់របស់យើងខ្ញុំ និងសូមយកមកធ្វើការជំទាស់តវ៉ាចំពោះការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានរំលោភទៅលើវិធាន២១(១), ២១(១)(ក), ២១(១)(គ), ២៣(៣), ២៣(៤), ៨៣(១) និងវិធាន១០០ នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះនៃតុលាការកម្ពុជា។

[១០:៥៦:៥៣]

អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តដំណើរការពីរដំណាក់កាលៈ

ទីមួយ អ្នកដាក់ពាក្យសុំត្រូវបានផ្ដលឋានៈបណ្ដោះអាសន្ន ដែលត្រូវបានសំអាងកន្លងមកថា ជាដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់ហើយ។

ទីពីរ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទៅលើ ការទទួលយកអ្នកដាក់ពាក្យសុំទាំងអស់នៅក្នុងសាលក្រមរបស់ខ្លួន។ ដំបូងអង្គជំនុំជម្រះសាលាដំបូងបានបញ្ចេញយោបល់របស់ខ្លួនថា ខ្លួនមានសិទ្ធិចេញសេចក្ដីសម្រេចអំពីភាពអាចទទួលយកនេះ តែទៅលើមូលដ្ឋាននៃភស្ដុតាងបឋមតែប៉ុណ្ណោះ ដើម្បីពិនិត្យ និងសម្រេចទៅលើសេចក្ដីនៃពាក្យសុំទាំងអស់។

[១០:៥៧:៣៦]

នៅចុងបញ្ចប់នៃសវនាការ អង្គជំនុំជម្រះសាលាដំបូងបានយកគំនិតនេះមកពីវិធាន១០០ នៃវិធានផ្ទៃក្នុង ដែលអាចជំទាស់តវ៉ាបាន ដែលវិធាននេះចែងថា “សេចក្ដីសម្រេចអំពីការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវចេញនៅក្នុងសាលក្រម”។

វិធាន១០០ វិសោធនកម្មលើកទីបី ចែងថា “អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចនៅក្នុងសាលក្រម អំពីការទទួលយក និងខ្លឹមសារនៃការទាមទារបែបនេះប្រឆាំងនឹងជនជាប់ចោទ”។ ប៉ុន្ដែ យើងខ្ញុំសូមបញ្ជាក់ថា វិធានផ្ទៃក្នុងមានលក្ខណៈច្បាស់លាស់ហើយ ចំពោះដំណើរការនៃអាចភាពទទួលយកបាននេះ និងមិនបានចែងពីដំណើរការពីរដំណាក់បែបនេះទេ។ ទោះបីជាវិធានផ្ទៃក្នុងពាក់ព័ន្ធមិនបានកំណត់ច្បាស់លាស់ ថាតើនៅពេលណាទើបអាចចេញសេចក្ដីសម្រេចអំពីការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីក៏ដោយ ក៏ចំណុចនេះកើតចេញពីការដែលថា មានតែដើមបណ្ដឹងរដ្ឋប្បវេណីទេ ទើបអាចទទួលបានសិទ្ធិចូលរួមពេញលេញ។

យោងតាមមូលដ្ឋាននេះ យើងខ្ញុំយល់ឃើញថា ស្ថាប័ននីមួយៗអាចជាសហចៅក្រមស៊ើបអង្កេតក៏បាន ឬអង្គជំនុំជម្រះសាលាដំបូងក៏បាន ត្រូវតែសម្រេចទៅលើការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណី

ឲ្យបានឆាប់តាមដែលអាចទៅបាន ដើម្បីអាចឲ្យជនរងគ្រោះអនុវត្តសិទ្ធិក្នុងការចូលរួមរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងប្រកបដោយអត្ថន័យក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។

[១០:៥៩:១០]

ប្រសិនបើអ្វីដែលបានចែងដោយអ្នកធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុង គឺជាដំណើរការពីរដំណាក់កាលដូចអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេច នោះវិធានផ្ទៃក្នុងគួរតែចែងឲ្យបានច្បាស់អំពីដំណើរការបែបនេះ។ ប៉ុន្តែ វិធានផ្ទៃក្នុងមិនបានចែងអំពីចំណុចនេះទេ គ្រាន់តែចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាទៅលើសំណើសុំណាមួយនៅក្នុងសវនាការបឋម ដែលតាមការស្នើសុំរបស់យើងខ្ញុំគួរតែយល់ថា ជាការសម្រេចអំពីភាពអាចទទួលយកបាននេះ។

[១០:៥៩:៤៤]

បន្ថែមលើនេះទៅទៀត ដំណើរការពីរដំណាក់កាលមិនអាចកំណត់ដោយវិធានផ្ទៃក្នុងថា អាចបដិសេធមិនឲ្យអ្នកដាក់ពាក្យសុំប្តឹងសាទុក្ខប្រឆាំងសេចក្តីសម្រេចអំពីសំណងនោះទេ។ ដោយសារថាមានតែដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យប្តឹងសាទុក្ខ ជំទាស់នឹងសេចក្តីសម្រេចអំពីសំណងនេះបាន គឺមិនមែនអ្នកដាក់ពាក្យសុំនោះទេ។

មានមូលដ្ឋានបន្ថែមមួយទៀត ដោយថា ហេតុអ្វីបានជាដំណើរការពីរដំណាក់កាលមិនត្រូវបានចែងនៅក្នុងវិធានផ្ទៃក្នុងទាល់តែសោះនោះ? និយាយរួមវាជាបញ្ហានៃភាពត្រឹមត្រូវផ្នែកនីតិវិធី ដែលអ្នកដាក់ពាក្យសុំដែលប្តឹងជំទាស់ប្រកបដោយជោគជ័យ ប្រឆាំងនឹងសេចក្តីបដិសេធអំពីភាពអាចទទួលយកបាន។ ក៏ត្រូវតែមានសិទ្ធិប្តឹងសាទុក្ខជំទាស់នឹងការបដិសេធអំពីការទាមទារសំណងរបស់ខ្លួនបានដែរ។

[១១:០០:៣៧]

ក្នុងករណីនេះកាលបរិច្ឆេទផុតកំណត់ ប្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចអំពីសំណងនេះបានផុតកំណត់។ ក្រោយពីអង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីកាស្តាពរ សេចក្តីសម្រេចទៅលើសាលក្រមដែលបានត្រូវបានបដិសេធនេះ។ អាចនិយាយបានម្យ៉ាងទៀតថា អ្នកដាក់ពាក្យសុំដែលត្រូវបានច្រានចោលក្នុងសាលក្រម និងដែលត្រូវបានសម្រេចថា អាចទទួលបានក្រោយពីប្តឹងសាទុក្ខអាចត្រូវបានដកហូតឱកាសដើម្បីប្តឹងសាទុក្ខតវ៉ានឹងសេចក្តីសម្រេចអំពីសំណងនេះ។

នេះបង្ហាញយ៉ាងច្បាស់ថា សេចក្តីសម្រេចលើកទីពីរទៅភាពអាចទទួលយកបាននៅក្នុងសាលក្រម អាចជំទាស់ទៅនឹងផលប្រយោជន៍នៃយុត្តិធម៌ ដោយមិនបានផ្តល់ដំណោះស្រាយផ្នែកច្បាប់ដល់

អ្នកដាក់ពាក្យសុំ និងរំលោភសិទ្ធិរបស់ពួកគាត់នៅក្នុងការទទួលបានភាពត្រឹមត្រូវនៃដំណើរការនីតិវិធី។

[១១:០១:២៤]

សំខាន់បំផុត គឺការអនុវត្តសិទ្ធិផ្នែកច្បាប់ និងនីតិវិធីរបស់បណ្តឹងរដ្ឋប្បវេណី រួមទាំងការផ្តល់សក្ខីកម្មដោយមិនធ្វើសម្បថ ដោយមិនអាចមានសុពលភាពប្រតិសកម្មបានទេ។

មូលដ្ឋានទីពីរនៃបណ្តឹងសាទុក្ខរបស់យើងខ្ញុំ គឺពាក់ព័ន្ធនឹងលោកស្រី លៀង កន, លោកស្រី ហុង សារ៉ាត និងលោកស្រី ណាំ ម៉ុន ដែលពាក្យសុំរបស់ពួកគាត់ត្រូវបានបដិសេធការអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលមិនត្រឹមត្រូវផ្ទុយទៅនឹងវិធាន២៣(៥) នៃវិធានផ្ទៃក្នុង។

[១១:០១:៥៥]

នៅក្នុងបណ្តឹងសាទុក្ខ យើងខ្ញុំបានលើកឡើងជាលម្អិតថា វិធានផ្ទៃក្នុងគ្រាន់តែតម្រូវឲ្យមានការផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ដើម្បីអនុញ្ញាតឲ្យមានការបញ្ជាក់ថាស្របនឹងវិធានផ្ទៃក្នុងប៉ុណ្ណោះ។

ដោយសារវិធានផ្ទៃក្នុងមិនបានចែងអំពីលក្ខខណ្ឌបន្ថែម នោះគេអាចស្វែងរកការណែនាំពីសាលាជម្រះក្តី និងតុលាការអន្តរជាតិ និងសាលាជម្រះក្តីថ្នាក់តំបន់។ សេចក្តីបញ្ជាក់របស់អ្នកដាក់សុំគឺគ្រប់គ្រាន់ហើយ ប្រសិនបើព័ត៌មាននេះជាប់ទាក់ទងគ្នាពិតប្រាកដ និងស៊ីសង្វាក់គ្នាជាមួយព័ត៌មានទូទៅដែលអាចរកបាន។ ប្រសិនបើមាន។

[១១:០២:៣៥]

យើងខ្ញុំសូមស្នើថា សេចក្តីបញ្ជាក់របស់លោកស្រី លៀង កន ដែលគាត់រៀបរាប់ថា តើគាត់បានរកឃើញរូបថតក្តួយប្រុសរបស់គាត់ដោយរបៀបណា? នៅឯមន្ទីរគុកទួលស្លែង ឬមន្ទីរស-២១ ដែលរួមមានទាំងវិវេកភាពយ៉ាងខ្លាំង គឺគាត់យំទួញសោកយ៉ាងខ្លាំង និងលើសលប់ផងនោះ គឺជាការបង្ហាញយ៉ាងគ្រប់គ្រាន់ថា បុគ្គលនៅលើរូបថតនេះ គឺក្តួយប្រុសរបស់លោកស្រីហើយ។ ហើយបន្ថែមលើនេះទៅទៀត មានចំណងនៃសេចក្តីស្រឡាញ់យ៉ាងខ្លាំងរវាងលោកស្រី និងក្តួយប្រុសរបស់លោកស្រី។ សេចក្តីបញ្ជាក់របស់លោកស្រី គឺជាប់ពាក់ព័ន្ធគ្នាយ៉ាងខ្លាំង និងពិតប្រាកដ។

លើសពីនេះទៅទៀត រូបថតដែលបានដាក់ជូនបញ្ជាក់ពីរបៀបនៃរកឃើញរូបថតនៅឯសារមន្ទីរគុកទួលស្លែង។ បន្ថែមទៅលើនេះ សេចក្តីបញ្ជាក់ដែលស៊ីសង្វាក់គ្នារបស់បងស្រីលោកស្រីឈ្មោះ ឆាយ ញ៉ែម បង្ហាញឲ្យឃើញថា រូបថតនេះបញ្ជាក់ថា ក្តួយប្រុសរបស់លោកស្រីដែលលោកស្រី លៀង កន បានចិញ្ចឹមបីបាច់ដូចកូនប្រុសបង្កើតរបស់គាត់តាំងពីដើមមក។

[១១:០៣:៣៦]

លោកស្រីមិនបានដឹងជាមុនទេថា អង្គជំនុំជម្រះសាលាដំបូងនឹងចោទជាបញ្ហាទៅលើសេចក្តីបញ្ជាក់របស់គាត់ ដែលថាបុគ្គលនៅលើរូបថតនេះគឺជាក្មួយប្រុសរបស់គាត់នោះទេ។ ហេតុដូច្នេះ ទើបលោកសេចក្តីស្នើសុំដាក់ជូនសេចក្តីថ្លែងបញ្ជាក់នៅពេលប្តឹងសាទុក្ខនេះ។

កូនក្តីរបស់យើងខ្ញុំម្នាក់ទៀតលោកស្រី ហុង សាវ៉ាត បានដាក់ជូនសេចក្តីបញ្ជាក់ច្បាស់លាស់និងស៊ីសង្វាក់គ្នាដែលថា រូបថតដែលបានរកឃើញនៅសារមន្ទីរទួលស្លែងបានបង្ហាញថា ជាពូរបស់លោកស្រី។ បន្ថែមទៅលើអ្វីដែលបានបញ្ជាក់អះអាងដោយបងប្រុសរបស់ជនរងគ្រោះផ្ទាល់។

[១១:០៤:១៧]

មិនមានអ្វីឲ្យមន្ទិលសង្ស័យទេថា រូបថតដែលបានយកមកពីមន្ទីរស-២១ ត្រូវបានរកឃើញនៅសារមន្ទីរទួលស្លែង។ ហើយបុគ្គលដែលរៀបរាប់បញ្ជាក់នេះ គឺជាពូរបស់កូនក្តីយើងខ្ញុំ ដោយសារថាអត្តសញ្ញាណរបស់បុគ្គលដែលរៀបរាប់នៅក្នុងរូបថតនេះ ត្រូវបានបញ្ជាក់ថា ជាពូរបស់លោកស្រីនោះបទដ្ឋាននៃការបង្ហាញភស្តុតាងត្រូវតម្រូវសម្រាប់ការពិចារណា ថាតើកូនក្តីរបស់យើងខ្ញុំត្រូវអនុវត្តស្របតាមវិធានផ្ទៃក្នុងដែរឬយ៉ាងណានោះ? បង្ហាញថា កូនក្តីរបស់យើងខ្ញុំបានបំពេញលក្ខខណ្ឌនេះហើយទំនាក់ទំនងសាច់ញាតិនៅក្នុងគ្រួសារ ដែលជាមូលដ្ឋាននៃព្យសនកម្មផ្លូវចិត្តរបស់លោកស្រី ដែលលោកស្រីបានទទួលរងដោយសារផលវិបាកផ្ទាល់ពីឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ។

[១១:០៥:០០]

នៅក្នុងអំឡុងពេលសវនាការលោកស្រី ហុង សាវ៉ាត បានដាក់ជូនសេចក្តីបញ្ជាក់របស់លោក យូ ហុង ដែលបានអះអាងថា លោក ឡឹក ស្រ៊ាង គឺជាពូរបស់លោកស្រី។ រូបថតដែលបានដាក់ជូននេះបានបញ្ជាក់អះអាងដោយសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរដោយលោក យូ ហុង ថាជារូបថតរបស់ពូលោកស្រីពិតប្រាកដហើយ។

កូនក្តីរបស់យើងខ្ញុំក៏បានបញ្ជាក់ផងដែរថា លោកស្រីមានចំណងនៃសេចក្តីស្រលាញ់ជាមួយគាត់ជាមួយនឹងជនរងគ្រោះ។ ជាពិសេស ដោយសារមិនមានការណែនាំណា មួយនោះលោកស្រីមិនអាចដឹងជាមុនទេថា អង្គជំនុំជម្រះសាលាដំបូងអាចជំទាស់ទៅនឹងអង្គហេតុដែលថា ពូរបស់លោកស្រីត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខស-២១ នោះទេ។

[១១:០៥:៤២]

អាស្រ័យហេតុនេះ ក្រោយពីបានដឹងអំពីបញ្ហានេះនៅក្នុងសាលក្រមទើបលោកស្រីអាចដាក់ជូននៅសេចក្តីបញ្ជាក់ពីលោក យូ ហុង ដែលបានបញ្ជាក់លម្អិតអំពីអត្តសញ្ញាណរបស់បុគ្គលនៅក្នុងរូបថត និងចំណងនៃសេចក្តីស្រលាញ់រវាងកូនក្តីរបស់យើងខ្ញុំ និងបុគ្គលនៅក្នុងរូបថតនេះ។ លោកស្រី ណាំ ម៉ុន គាត់បានប្រកាសថា ពីដំបូងលោកស្រីធ្វើការងារជាបុគ្គលិកពេទ្យនៅក្នុងមន្ទីរស-២១ ក្នុងនេះខ្ញុំបាទសូមជម្រាបអង្គជំនុំជម្រះតុលាការកំពូលថា ពាក្យថាបុគ្គលិកពេទ្យនេះមិនមែនមានន័យថា ជាគិលានុបដ្ឋាក ឬគិលានុបដ្ឋាយិកា ដូចពេទ្យយើងទេធម្មតានោះទេ។ គឺសម័យនោះជាអ្នកដើរចែកថ្នាំបុរាណនោះ គឺគេហៅបុគ្គលិកពេទ្យ។ លោកស្រីធ្វើការងារជាបុគ្គលិកពេទ្យនៅមន្ទីរស-២១ ហើយក្រោយមកបានជាប់ឃុំនៅ ទីនោះជាមួយនឹងសមាជិកគ្រួសាររបស់គាត់។

[១១:០៦:៣៥]

សេចក្តីប្រកាសនេះស្របគ្នានិងស៊ីសង្វាក់ជាមួយនឹងភស្តុតាងដទៃៗទៀត ទោះបីសេចក្តីប្រកាសនេះបានលាតត្រដាងជាលើកដំបូងនៅក្នុងពេលសវនាការជំនុំជម្រះក៏ដោយ វាមិនបានបង្កើតជាចំណុចសង្ស័យណាមួយលើភាពត្រឹមត្រូវនៃខ្លឹមសាររបស់វាឡើយ ព្រោះលោកស្រីអាចធ្វើការពន្យល់ដោយផ្ទាល់ថា ហេតុអ្វីបានជាលោកស្រីមិនអាចលាតត្រដាងរឿងរ៉ាវរបស់លោកស្រីតាំងពីដំបូងមក។ ដោយសារលោកស្រីបានបញ្ជាក់ថា លោកស្រីគិតទុកជាមុនថា នឹងមានការសងសឹកពីអ្នកដទៃ។ ហេតុដូច្នេះសេចក្តីប្រកាសរបស់លោកស្រីមានលក្ខណៈស៊ីសង្វាក់គ្នា។

លើសពីនេះទៅទៀត វាបានបំពេញបទដ្ឋាននៃការបង្ហាញភស្តុតាងដែលជាលក្ខខណ្ឌតម្រូវ ដោយហេតុថា សេចក្តីប្រកាសនេះរួមជាមួយនឹងរូបថតសមាជិកគ្រួសាររបស់លោកស្រី ដែលបានដាក់ជូនក្រោយពីរកបាននៅមន្ទីរទួលស្លែង មានភាពស៊ីសង្វាក់ជាមួយនឹងសេចក្តីបញ្ជាក់របស់ប្រធានឃុំដែលបានកំណត់ថា បុគ្គលនៅក្នុងរូបថតមួយសន្លឹកក្នុងចំណោមរូបថតដែលគាត់បានដាក់ជូននោះ គឺជាឪពុករបស់លោកស្រី ណាំ ម៉ុន ។

[១១:០៧:៣៣]

សេចក្តីប្រកាសបន្ថែមបញ្ជាក់លើព័ត៌មាននេះមិនបានដាក់ជូននៅពេលជំនុំជម្រះនោះឡើយ ដោយហេតុថា កូនក្តីរបស់ខ្ញុំបាទមិនអាចប្រមើលមើលឃើញថា អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចថាសេចក្តីប្រកាសរបស់លោកស្រីថារូបថតឪពុករបស់លោកស្រី ដែលបានរកឃើញនៅទួលស្លែងមិនមានលក្ខណៈគ្រប់គ្រាន់នោះឡើយ។ លោកស្រីសង្ឃឹមថា សេចក្តីប្រកាសទីពីរនឹងបញ្ជាក់យ៉ាងសមស្រប

ទៅលើបញ្ហាទាំងនេះ។

ម្យ៉ាងវិញទៀត យើងខ្ញុំធ្វើការតវ៉ាលើការបដិសេធកូនក្តីរបស់យើងខ្ញុំចំនួនបីនាក់ ដែលថាកូនក្តីរបស់យើងខ្ញុំមិនបានបង្ហាញថាជាសាច់ញាតិ និងចំណងនៃសេចក្តីស្រលាញ់ ដែលនេះជាការរំលោភលើវិធានផ្ទៃក្នុង២៣(២) លក្ខខណ្ឌនេះមិនបានផ្អែកលើវិធានផ្ទៃក្នុងនិងច្បាប់កម្ពុជាឡើយ។

យោងតាមវិធានផ្ទៃក្នុង ទោះបីជាសាច់ញាតិ និងចំណងនៃសេចក្តីស្រលាញ់អាចត្រូវបានចាត់ទុកថាជាសញ្ញាណបញ្ជាក់យ៉ាងរឹងមាំមួយ ថាជាលក្ខខណ្ឌតម្រូវនៃការខូចខាតផ្ទាល់ខ្លួន ដែលជាផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មនេះក៏ដោយ ក៏វាមិនមែនជាលក្ខខណ្ឌនោះឡើយ។

[១១:០៨:៣៨]

លោកស្រី ញិប គឹមស្រ៊ា កើតនៅឆ្នាំ១៩៧៨។ ក្រោយពេលមរណភាពនៃឪពុកមារបស់លោកស្រី និងគ្រួសាររបស់ឪពុកមាលោកស្រី លោកស្រីបានបង្ហាញថា លោកស្រីរងនូវការខាតបង់ដោយផ្ទាល់ខ្លួន និងដោយផ្ទាល់ដោយសារតែមរណភាពនៃឪពុកមារបស់លោកស្រីនេះឯង។ ទោះបីលោកស្រីមិនបានដឹងអំពីជនរងគ្រោះដោយផ្ទាល់ក៏ដោយ ជារៀងរាល់ថ្ងៃលោកស្រីប្រឈមនឹងការឈឺចាប់របស់ឪពុកបង្កើតដែលចាស់ជរារបស់លោកស្រីដែលដឹងរឿងពិត និងនិទានរឿងប្រាប់គាត់ដែលទទួលរងនូវការឈឺចាប់ដោយសារតែមរណភាពនៃបងប្អូនរបស់គាត់។ ប្អូនប្រុសរបស់គាត់។ ដោយសារលោកស្រីជាញាតិសន្តានខ្សែទីពីរ លោកស្រីជាសមាជិកគ្រួសារតែម្នាក់គាត់ដែលអាចតំណាងគ្រួសាររបស់លោកស្រីនៅចំពោះមុខ អ.វ.ត.ក នេះ។

[១១:០៩:២៨]

លោកស្រីមិនអាចប្រមើលមើលឃើញថា អង្គជំនុំជម្រះសាលាដំបូង នឹងមិនទទួលយកសេចក្តីប្រកាសរបស់លោកស្រីនោះទេ ដែលបង្ហាញអំពីចំណងនៃសេចក្តីស្រលាញ់ពិសេសលើឪពុកមាររបស់លោកស្រី។ ករណីនេះហើយដែលនាំឲ្យលោកស្រីដាក់សេចក្តីប្រកាសបន្ថែមមួយអមជាមួយនឹងបណ្តឹងសាទុក្ខនេះដើម្បីបញ្ជាក់អំពីចំណងជិតស្និតរវាងលោកស្រី និងគ្រួសាររបស់ឪពុកមារបស់លោកស្រី។

លោកស្រី ហុង សាវ៉ាត អាចបង្ហាញតាមរយៈសេចក្តីប្រកាសរបស់លោកស្រីថា ឪពុកមារបស់លោកស្រីបានស្លាប់នៅក្នុងមន្ទីរស-២១។ យោងតាមលិខិតបញ្ជាក់មួយច្បាប់ពីបងប្អូនជនរងគ្រោះផ្ទាល់ចំណងជិតស្និទ្ធរបស់លោកស្រីជាមួយនឹងឪពុកមានេះត្រូវបានបញ្ជាក់ថាពិតប្រាកដហើយ។

[១១:១០:០៩]

លោក ឈឹម ស៊ីថា បានបង្ហាញនៅក្នុងពាក្យសុំរបស់ខ្លួនថា លោកបានទទួលរងនូវការខូចខាតដោយសារមរណភាពនៃក្មួយរបស់លោក ដែលបាននៅជាមួយគ្នានៅក្នុងកងពលលេខ៣១០ នាសម័យខ្មែរក្រហម។ ក្រោយមក ក្មួយប្រុសរូបនេះ ជាមួយនឹងអ្នកមកពីកងពលនេះត្រូវបានគេសម្លាប់ចោលនៅមន្ទីរស-២១។ លោក ឈឹម ស៊ីថា បានលើកឡើងថា យោងតាមលក្ខខណ្ឌនៅក្នុងវិធានផ្ទៃក្នុងលោកបានទទួលរងដោយផ្ទាល់ខ្លួននូវការខូចខាតដោយសារផលវិបាកនៃមរណភាពលើក្មួយប្រុសរបស់លោក ដែលទើបតែក្រោយពេលចេញសាលក្រមតែប៉ុណ្ណោះ ដែលលោកបានដឹងថាអង្គជំនុំជម្រះសាលាដំបូងបានទាមទារលើសពីសេចក្តីប្រកាសរបស់ខ្លួនឲ្យបង្ហាញនូវចំណងនៃសេចក្តីស្រលាញ់ ពិសេសរវាងរូបលោកនិងក្មួយរបស់លោក។

[១១:១០:៥៨]

ហេតុដូច្នេះលោកបានដាក់ជូននៅក្នុងបណ្តឹងសាទុក្ខនេះ នូវសេចក្តីប្រកាសមួយច្បាប់របស់បងស្រីរបស់លោកដែលបានបញ្ជាក់ថា លោកបានរស់នៅជិតធាត់ជាមួយនឹងក្មួយប្រុសរបស់លោក ហើយអ្នកទាំងពីរនោះបានចូលធ្វើខ្មែរក្រហមជាមួយគ្នា។ ហេតុដូច្នេះ បានបង្កើតចំណងនៃសេចក្តីស្រលាញ់ពិសេសជាមួយនឹងជូនរងគ្រោះផ្ទាល់តាមរបៀបនេះឯង។

ដូចយើងខ្ញុំបានបង្ហាញទឡ្ហីករណ៍យ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើវិធានផ្ទៃក្នុង ទាំងលើវិធី នីតិវិធី ទាំងច្បាប់សារធាតុ នៅពេលខ្លួនបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកទាំងអស់នេះ។ ហេតុដូច្នេះហើយ យើងខ្ញុំជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលច្រានចោល ការបដិសេធចោលកូនក្តីរបស់យើងខ្ញុំ ហើយសូមឲ្យទទួលស្គាល់ឡើងវិញ ថាពួកគាត់គឺជាដើមបណ្តឹងរដ្ឋប្បវេណីឡើងវិញ។

តទៅនេះខ្ញុំបាទ សូមឲ្យផ្តល់ឱកាសដល់សហភាតាខ្ញុំគឺអ្នកស្រី ស៊ីលឃី ស្ទូតហ្សីនស្តី ធ្វើការថ្លែងការណ៍បន្តទៀត។ សូមអរគុណ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្តីៈ**

ជម្រាបសួរលោក លោកស្រីចៅក្រម សហភាតា លោក លោកស្រីព្រមទាំងបងប្អូនសាធារណជនទាំងអស់ដែលបានចូលរួមក្នុងសវនាការនាថ្ងៃនេះ។ ថ្ងៃនេះជាថ្ងៃមួយដែលគួរឲ្យចងចាំ ដែលវត្តមានរបស់យើងនៅចំពោះមុខតុលាការកំពូលនឹងបង្ហាញឲ្យឃើញនៅវត្តមានរបស់យើងខ្ញុំជាចុងក្រោយក្នុងនាមជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលជាមេធាវីមានឯករាជ្យពេញលេញក្នុងការបំពេញកិច្ចការ

ដោយផ្ទាល់គឺជាឧត្តមប្រយោជន៍របស់កូនក្ដីយើងខ្ញុំ។

នៅថ្ងៃមុខ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនឹងមិនមានសិទ្ធិនិងលទ្ធភាពចូលរួមនៅចំពោះមុខតុលាការកំពូល នៅចំពោះមុខតុលាការ ហើយត្រូវពឹងពាក់ទៅលើសមត្ថភាព និងសុឆន្ទៈរបស់សហមេធាវីដើមបណ្ដឹង-- សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំនឹងបន្តជាមួយការសង្ខេបនូវសំណុំរឿងទាំងឡាយដែលនិយាយអំពីសំណង។ ដើម្បីជាការកត់សម្គាល់ដំបូងវាជាការសំខាន់ណាស់ ដែលត្រូវឲ្យដឹងថាវិធានផ្ទៃក្នុងវាក្របដណ្ដប់ទៅលើដំណើរការនីតិវិធីមានចែងពីសំណងសមូហភាពនិងសំណងផ្លូវចិត្ត។

[១១:១៣:២៧]

ចំណុចនេះ ងាកចេញពីក្រមនីតិវិធីព្រហ្មទណ្ឌជាតិជាធរមានដែលក្នុងនោះ សំណងជាហិរញ្ញវត្ថុជាសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីគឺជាបន្ទុករបស់ទណ្ឌិតដែលនេះគឺជាបទដ្ឋានមួយ មិនមានយុត្តិសាស្ត្រនៅក្នុងតុលាការព្រហ្មទណ្ឌ ឬសាលាជម្រះក្ដីដទៃដែលបានកំណត់អំពីសំណងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី សូម្បីតែសំណងសមូហភាព ឬផ្លូវចិត្តក៏មិនមានដែរ។ ចំណុចនេះ គឺជាចរិតលក្ខណៈពិសេសនៅអ.វ.ត.ក។

ពាក្យថា "សំណងសមូហភាព ឬសំណងផ្លូវចិត្ត" ដែលជាបន្ទុករបស់ទណ្ឌិតមិនត្រូវបានកំណត់និយមន័យនៅក្នុងវិធានផ្ទៃក្នុង ឬច្បាប់ដទៃទៀតនោះទេ។ កង្វះនិយមន័យបែបនេះ បានបណ្ដាលឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អង្គការអន្តរការីមិនមែនរដ្ឋាភិបាលដែលជួយដល់អ្នកដាក់ពាក្យសុំ និងជួយដល់មេធាវីនូវការខ្វះខាត ណែនាំថា ហេតុអ្វីបានជាសំណងសមូហភាព-- មានសំណងសមូហភាព និងផ្លូវចិត្តនោះ?

[១១:១៤:២១]

ភាពមិនច្បាស់លាស់នេះ បានបណ្ដាលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅតែមានភាពមិនច្បាស់លាស់រហូតមកដល់សព្វថ្ងៃនេះ ថាតើប្រភេទសំណងណាដែលពួកគាត់អាចទាមទារបាននោះ? ជាការគួរឲ្យកត់សម្គាល់ផងដែរ ថាចាប់តាំងពីដើមដំបូងមកជនជាប់ចោទទាំងអស់ត្រូវបានចាត់ទុកថាជាជនក្រីក្រ ដោយសេចក្ដីថ្លែងដ៏សាមញ្ញរបស់អង្គភាពគាំពារការការពារក្ដី មិនមានភស្តុតាងណាមួយស៊ីសង្វាក់គ្នាណាមួយនោះទេ។ ហើយតុលាការនេះ ក៏មិនមានការស៊ើបអង្កេតទៅលើបញ្ហាហិរញ្ញវត្ថុរបស់ជនជាប់ចោទទាំងនេះនោះដែរ។

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមានការស៊ើបអង្កេតទៅលើហិរញ្ញវត្ថុ ទៅលើទ្រព្យ

សម្បត្តិរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង០០១ ប៉ុន្តែសំណើសុំនេះត្រូវបានសហចៅក្រមស៊ើបអង្កេតច្រានចោល ដោយអះអាងថា ការស៊ើបអង្កេតទៅលើទ្រព្យសម្បត្តិរបស់ជនជាប់ចោទគឺហួសពីអាណត្តិរបស់ខ្លួន។

[១១:១៥:១៤]

អង្គជំនុំជម្រះបានច្រានចោលបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីថា មិនអាចទទួលយកបាននិងសម្រេចថា អ.វ.ត.ក មានអំណាចស៊ើបអង្កេតទៅលើហិរញ្ញវត្ថុ ឬក៏សាទុក្ខ បង្កក ឬរឹបអូសទ្រព្យសម្បត្តិណាមួយរបស់ជនជាប់ចោទបានទេ។

សំណើសុំទាមទារសំណងស្ទើរតែទាំងអស់ដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង មានតែសំណងមួយគត់ដែលបានផ្តល់ជូន គឺការដាក់បញ្ចូលឈ្មោះរបស់ដើមរដ្ឋប្បវេណី និងទំនាក់ទំនងរបស់គាត់ជាមួយជនរងគ្រោះដោយផ្ទាល់នៅក្នុងសាលក្រម ការផ្សព្វផ្សាយសាលក្រមស្តាពរនៅលើគេហទំព័ររបស់សាលាក្តី និងការចងក្រងការសុំអភ័យទោសទាំងអស់របស់ជនជាប់ចោទ។

ការបោះពុម្ពផ្សាយសាលក្រមវាជាកាតព្វកិច្ចរបស់តុលាការនេះដែលត្រូវផ្តល់ជូនសាធារណជនហើយការចងក្រងការសុំអភ័យទោស គឺមិនមានអ្វីនោះទេ ដោយសារនៅចុងបញ្ចប់នៃការពិភាក្សាដេញដោលជនជាប់ចោទបានស្នើសុំឲ្យមានការដោះលែងរូបគាត់ ហើយសំណើសុំរបស់សេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការសុំអភ័យទោសទាំងអស់នៅក្នុងកម្រងឯកសារសូមអភ័យទោស ត្រូវបានបដិសេធ។

[១១:១៦:២០]

លទ្ធផលនេះត្រូវបានដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំគឺថាមានការអាក់អន់ចិត្តដូចគ្នាដោយសារអង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា គោលបំណងចម្បងក្នុងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺស្នើសុំឲ្យផ្តល់សំណង។ នោះលទ្ធផលនៅក្នុងសាលក្រមនៃសំណុំរឿង០០១ ដែលបានសម្រេចទៅលើសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនមានន័យអ្វីនោះទេ ហើយជាចុងក្រោយមិនអាចទទួលយកបានឡើយ។ ក្នុងន័យនេះ បើនិយាយពីលទ្ធផលនៃសេចក្តីសម្រេចឃើញថា ការពិភាក្សាដែលបានសម្របសម្រួលដោយអង្គការអន្តរការីមិនមែនរដ្ឋាភិបាលដើម្បីកំណត់អំពីសេចក្តីត្រូវការរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ អំពីសំណងផ្លូវចិត្តនិងសំណងសមូហភាព មិនបានផ្តល់ផ្លែផ្កាអ្វីនោះទេ។ ហើយហេតុដូច្នេះហើយ ការអនុវត្តសិទ្ធិ គឺមិនមានប្រសិទ្ធភាពអ្វីនោះឡើយ។

[១១:១៧:០៣]

ក្រៅពីសំណើសុំរួមបញ្ចូលគ្នា និងទូទៅបំផុត ដែលដាក់ជូនដោយក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ បានដាក់សំណើសុំយ៉ាងជាក់លាក់ចំនួនប្រាំបួន។ សារណារបស់ខ្ញុំ គឺមានការលើកឡើងច្បាស់លាស់ និងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការដាក់បញ្ចូលមតិយោបល់នៃការថ្លែងសូមអភ័យទោសដែលមាននៅក្នុងសំណើសុំទាមទាររួមបញ្ចូលគ្នានេះ។

ដូចដែលបានសហភាតារបស់ខ្ញុំលើកឡើង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានចាត់ទុកថាមិនអាចទទួលយកបាននៅក្នុងសាលក្រមនៃសំណុំរឿង០០១ គួរមានសិទ្ធិប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើសំណងនេះក្នុងករណីដែលបណ្តឹងសាទុក្ខទទួលយកពាក្យសុំរបស់ពួកគាត់ទទួលបានជោគជ័យចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនេះ។ នេះជាចន្លោះប្រហោងផ្នែកនីតិវិធី និងប្រសិនបើកូនក្តីទាំងអស់ត្រូវបានច្រានចោលពីការប្តឹងសាទុក្ខប្រឆាំងសេចក្តីសម្រេចអំពីសំណងដែលកំពុងរង់ចាំការពិចារណាទៅលើភាពទទួលយកបានជាចុងក្រោយដោយតុលាការកំពូល នោះពួកគាត់ត្រូវបានដកហូតទាំងស្រុកនូវសិទ្ធិបានដំណោះស្រាយតាមផ្លូវច្បាប់អំពីបញ្ហានេះ។

ហើយហេតុដូច្នេះ បណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងសំណងនេះត្រូវបានធ្វើក្នុងនាមឲ្យកូនក្តីរបស់យើងខ្ញុំដែលជាពាក្យសុំរបស់ពួកគាត់ត្រូវបានចាត់ទុកថា មិនអាចទទួលយកបាននោះទេ។

[១១:១៨:២១]

ជាការកត់សម្គាល់បឋមយើងខ្ញុំសូមលើកឡើងថា កាតព្វកិច្ចរបស់រដ្ឋដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ គឺមានអាទិភាពសម្រាប់ដោះស្រាយកំហុសជាអន្តរជាតិនេះឲ្យបានពេញលេញតាមដែលអាចធ្វើទៅបាន។ ទោះបីជា អ.វ.ត.ក មិនមានយុត្តាធិការបង្គាប់ឲ្យផ្តល់សំណង ថាការផ្តល់សំណងគឺជាបន្ទុករបស់រដ្ឋាភិបាលក៏ដោយ ក៏តុលាការនេះមិនត្រូវបានហាមឃាត់មិនឲ្យចេញសេចក្តីសម្រេចអំពីសំណងប្រឆាំងនឹងជនជាប់ចោទ ដែលតម្រូវឲ្យមានជំនួយពីរដ្ឋាភិបាលដើម្បីអនុវត្តនោះទេ។

វិធានការទាំងនេះ រួមមានការគាំទ្រមិនមែនហិរញ្ញវត្ថុ និងរដ្ឋបាលក្រៅពីការបរិច្ចាគជាហិរញ្ញវត្ថុ និងមិនត្រូវយល់ថា ជាការដាក់ទណ្ឌកម្មចំពោះរដ្ឋាភិបាលនោះទេ។ ចំណុចនេះកើតចេញពីកាតព្វកិច្ចទូទៅរបស់រដ្ឋចំពោះប្រជាពលរដ្ឋដែលរដ្ឋត្រូវបម្រើឲ្យប្រជាពលរដ្ឋរបស់ខ្លួននោះ។

[១១:១៩:១៥]

កំណត់សម្គាល់ទីបី គឺសំដៅទៅលើការកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងហ្មត់ចត់អំពីភាពក្រីក្ររបស់ជនជាប់ចោទ ដែលជាឧបសគ្គមួយដល់សំណើសុំឱ្យផ្តល់-- សំណើសុំទាំងឡាយដែលមានប៉ះពាល់ដល់ផ្នែកហិរញ្ញវត្ថុ។ យើងកត់សម្គាល់ថា ភាពក្រីក្ររបស់ជនជាប់ចោទមិនមានផលប៉ះពាល់ដែលសេចក្តីសម្រេចអំពីសំណងនោះទេ អាចមានលទ្ធភាពដែលថា ជនជាប់កំពុងតែគ្រប់គ្រងទ្រព្យសម្បត្តិដែលមិនទាន់បានរកឃើញនៅឡើយ ព្រោះថាមិនមានការស៊ើបអង្កេតទៅលើហរិញ្ញវត្ថុនោះទេ។

ហើយលើសពីនេះទៅទៀត អាចនិយាយបានថា ជនជាប់ចោទអាចមិនស្ថិតនៅក្នុងភាពក្រីក្រនៅក្នុងពេលអនាគតនោះ។ ឧទាហរណ៍ ទណ្ឌិតអាចសរសេរ និងលក់ប្រវត្តិសាវតារផ្ទាល់ខ្លួន ឬក៏បរិច្ចាគទៅឱ្យក្រុមហ៊ុនភាពយន្តណាមួយដែលមានចំណងជើងថា “ពេជ្ឈឃាដចុងក្រោយ”។

[១១:២០:00]

ខ្ញុំសូមលើកឡើងនូវមូលដ្ឋានទីមួយ និងទូទៅនៅក្នុងបណ្តឹងសាទុក្ខ ដែលជាការរំលោភលើគោលការណ៍ជាសារវន្តនៃភាពត្រឹមត្រូវផ្នែកនីតិវិធី និងសិទ្ធិទទួលបានសេចក្តីសម្រេចប្រកបដោយហេតុផល។ ហេតុដូច្នេះ មូលដ្ឋាននេះអនុវត្តចំពោះសំណើសុំឱ្យផ្តល់សំណងទាំងអស់ ដែលយើងខ្ញុំបានដាក់ជូន។

អង្គជំនុំជម្រះសាលាដំបូងបានសង្ខេបសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងដាក់ពាក្យសុំចំនួន៣៦ តែចំនួនបីទំព័រនៅក្នុងសាលក្រម និងបានវិភាគថា សំណើសុំនេះមានតែចំនួនបីទំព័រប៉ុណ្ណោះ។ វិសាលភាពនៃសំអាងហេតុសម្រាប់ការច្រានចោលលើសំណើសុំទាមទារនេះ បង្ហាញឱ្យឃើញថាសាលាដំបូងបានពិចារណាតិចតួចបំផុតលើចំណុចនេះ។

លើសពីនេះទៅទៀត យើងកត់សម្គាល់ឃើញថា សាលាដំបូងបានបង្កជាឧបសគ្គចំពោះសំណើសុំទាំងនេះ និងបានដាក់បញ្ចូលសំណើសុំមួយចំនួនទៅក្នុងផ្នែកផ្សេងៗពីគ្នា ប៉ុន្តែមិនបានចង្អុលបង្ហាញថាតើសំណើសុំណាមួយដែលអង្គជំនុំជម្រះសាលាដំបូងចង់លើកឡើងនៅក្នុងកថាខណ្ឌណាមួយនោះទេ។ ចំពោះមូលហេតុនេះ អ្នកដាក់ពាក្យសុំមិនអាចកំណត់បានថា សំអាងហេតុមួយណាដែលយោងទៅលើសំណុំជាក់លាក់នោះទេ ក្រៅតែកាត់យល់តែប៉ុណ្ណោះ។ ចំពោះសំអាងហេតុដែលពាក់ព័ន្ធទៅនឹងដំណើរការនៅទីនេះ យើងយល់ឃើញថា វាមានការលំបាកដើម្បីអាចឱ្យដឹងថា តើអង្គជំនុំជម្រះតុលាការកំពូលអាចធ្វើការពិនិត្យឡើងវិញ ឱ្យបានត្រឹមត្រូវដោយរបៀបណានោះ?

[១១:២១:០៩]

សំអាងហេតុរបស់សាលាដំបូង គឺមិនមានលក្ខណៈគ្រប់គ្រាន់ទាល់តែសោះ។ វិសាលភាពនៃសំអាងហេតុយ៉ាងហោចណាស់ត្រូវបញ្ជាក់ឲ្យគ្រប់គ្រាន់ ថាតើអង្គហេតុណាមួយដែលសាលាដំបូងយល់ឃើញថា មានការពាក់ព័ន្ធទៅនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលនឹងត្រូវធ្វើនោះ។ ការខកខានបែបនេះ អង្គជំនុំជម្រះសាលាដំបូង បានរំលោភទៅលើសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងដែលជាការរំលោភទៅលើវិធាន២១ នៃវិធានផ្ទៃក្នុង។

[១១:២១:៥០]

បន្ថែមទៅលើបណ្តឹងឧទ្ធរណ៍នេះ យើងខ្ញុំសុំចូលទៅពិភាក្សាចំណុចចម្បងៗ ការយល់ឃើញរបស់សាលាដំបូង ប្រសិនបើមាន និងកំហុសផ្នែកអង្គច្បាប់និងអង្គហេតុ។ សំណើសុំទីមួយ គឺត្រូវបានច្រានចោលអំពីសំណាងទាក់ទងទៅនឹងការចងក្រង និងផ្សព្វផ្សាយការអភ័យទោស ដែលបានផ្តល់តែសេចក្តីថ្លែងអភ័យទោសរបស់ជនជាប់ចោទតែប៉ុណ្ណោះ។ មូលហេតុដែលសាលាដំបូងបានលើកឡើងច្រានចោលការទាមទារនេះ គឺទីមួយ សេចក្តីថ្លែងនេះខុសពីសេចក្តីថ្លែងរបស់ជនជាប់ចោទ និងទីពីរខ្លឹមសារនៃសេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនមានលក្ខណៈច្បាស់លាស់។

[១១:២២:៣៨]

មូលដ្ឋានទីមួយ គឺមានលក្ខណៈសមហេតុផល។ ប៉ុន្តែមូលដ្ឋានទីពីរ ប្រសិនបើអនុវត្តដូចគ្នាទៅនឹងសេចក្តីថ្លែងរបស់ជនជាប់ចោទ គឺផ្ទុយគ្នានឹងសេចក្តីសម្រេចរបស់សាលាដំបូងចំពោះការអនុញ្ញាតឲ្យមានការបោះពុម្ពផ្សាយសេចក្តីថ្លែងសូមអភ័យទោសរបស់ជនជាប់ចោទ ដោយសារមូលហេតុថាចំពោះការផ្តល់សំអាងដូចគ្នានេះ គឺជាសេចក្តីថ្លែងរបស់ជនជាប់ចោទ មិនមានលក្ខណៈលម្អិតជាក់លាក់ដូចសេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ។

សំអាងហេតុដែលបានលើកឡើងនេះ មិនគ្រប់គ្រាន់នោះទេ ព្រោះមូលហេតុដែលបានលើកឡើងនោះមិនអាចយល់បានថា ឬសំអាងហេតុនោះផ្ទុយទៅនឹងផ្នែកខ្លះនៃសំណើសុំ។ យើងខ្ញុំយល់ឃើញថា នេះគឺជារំលោភបំពានទៅលើវិធាន២១ កថាខណ្ឌ១(ក) និង២១ កថាខណ្ឌ១(គ) នៃវិធានផ្ទៃក្នុង។

[១១:២៣:២៥]

សំណើសុំទីពីរ យើងខ្ញុំសំណូមពរឲ្យសាលាដំបូង បង្គាប់ឲ្យជនជាប់ចោទសរសេរលិខិតមួយ

ច្បាប់ជាចំហទៅរាជរដ្ឋាភិបាលកម្ពុជា ដើម្បីស្នើសុំឲ្យមានការអភ័យទោសហ្មត់ចត់ ស្មោះត្រង់ និងសុទ្ធចិត្ត។

សាលាដំបូងមិនបានពិនិត្យមើលទៅលើសំណើសុំនេះទាល់តែសោះ ការខកខានបែបនេះគឺជាការរំលោភវិធានផ្ទៃក្នុង១០០ នៃវិធានផ្ទៃក្នុងដែលមានចែងថា អង្គជំនុំជម្រះត្រូវសម្រេចលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុងសាលក្រម។ នៅពេលជាមួយគ្នានេះដែរ ការខកខាននេះបង្កើតបានជាកំហុសអង្គហេតុ។

នៅក្នុងចំណោមការវិភាគនៅក្នុងសាលក្រមមានផ្នែកមួយដែលមានចំណងជើងថា "សំណើសុំឲ្យមានការចាត់វិធានការដោយរាជរដ្ឋាភិបាលកម្ពុជា គឺស្ថិតនៅក្រៅយុត្តាធិការរបស់សាលាដំបូង"។ ការវិភាគនេះបានលើកឡើងបន្ថែមទៀតថា ការចេញសេចក្តីថ្លែងសុំអភ័យទោសជាផ្លូវការ គឺជាបុព្វសិទ្ធិរបស់រដ្ឋាភិបាល ដែល អ.វ.ត.ក មិនមានសមត្ថកិច្ចចាប់បង្ខំបាននោះឡើយ។

យើងខ្ញុំសូមលើកឡើងថា សាលាដំបូងបានមើលរំលង និងបានធ្វើមិនដឹងមិនឮថា សំណើសុំនេះគឺមិនបានស្នើសុំឲ្យមានដីកាបង្គាប់ដល់រដ្ឋាភិបាលនោះទេ។ ប៉ុន្តែសំណើសុំនេះ គឺគ្រាន់តែស្នើសុំឲ្យបង្គាប់ឲ្យជនជាប់ចោទ សរសេរលិខិតចំហមួយច្បាប់ជូនរដ្ឋាភិបាល វាពិបាកយល់ថាតើហេតុអ្វីបានជាសាលាដំបូងមិនអាចយល់ចំពោះពាក្យពេចន៍ដ៏សាមញ្ញក្នុងសំណើសុំ?

[១១:២៤:៥០]

សំណើសុំទីបី និងទីបួន ដើមបណ្តឹងរដ្ឋប្បវេណី សុំដំឡើងបូជនីយដ្ឋាននៅក្នុងសារមន្ទីរទួលស្លែង និងជើងឯក និងសុំឲ្យផ្លាស់ប្តូរទីតាំងព្រៃសទៅជាទីកន្លែងបូជនីយកិច្ច។ អគារដែលបានស្នើសុំសាងសង់នោះតម្រូវឲ្យមានរៀបរាប់លម្អិតទាក់ទងទៅនឹងទំហំ សម្ភារៈ និងទីតាំងពិតប្រាកដ និងខ្លឹមសារក្នុងកម្រិតអប្បបរមានៃអត្ថបទដែលត្រូវចារឹកនេះ។ ទាក់ទងនឹងព្រៃស ដើមបណ្តឹងរដ្ឋប្បវេណីបានសម្រេចស្នើសុំឲ្យគូសបង្គង់ទីតាំង តាមរយៈការដេញថ្លៃប្រកួតប្រជែងក្នុងលក្ខណៈស្ថាបត្យកម្មអន្តរជាតិ។

សាលាដំបូងបានបដិសេធសំណើសុំទាំងនេះ នៅក្នុងសាលក្រមក្រោមចំណងជើងថា "សំណើសុំឲ្យសាងសង់ វត្តអារាម និងបូជនីយដ្ឋានដទៃទៀត"។

**ប្រធានអង្គជំនុំ៖**

ស្នើសុំឲ្យលោកស្រីមេធាវីថយបន្តិច។ ស្នើសុំឲ្យបន្ថយបន្តិចបាទ។

**លោកស្រី ស៊ីលឃីស្នូត ហ្សីនស្គី៖**

សាលាដំបូងបានច្រានចោលសំណើសុំរបស់យើងខ្ញុំ ដោយសំអាងថា ខ្វះភាពជាក់លាក់ទាក់ទងនឹងចំនួនពិតប្រាកដនៃចំនួនបូជនីយដ្ឋាន ដែលបានស្នើសុំ និងសារប្រយោជន៍ទីតាំង ឬតម្លៃ ដែលត្រូវបានប៉ាន់ប្រមាណ។

សាលាដំបូងបានរៀបរាប់បន្ថែមទៀត និងបានលើកឡើងនូវឧទាហរណ៍មួយចំនួនដែលសាលាដំបូងគិតថា គួរយកដាក់ជូននៅចំពោះមុខខ្លួន ដូចជាការអនុញ្ញាតឲ្យមានការសាងសង់តាមលក្ខណៈរដ្ឋបាលជាចាំបាច់ ឬការយល់ព្រមពីម្ចាស់ដីធ្លី។ យើងខ្ញុំយល់ឃើញថា សាលាដំបូងបានរំលោភអនុវិធាន ២១ កថាខណ្ឌ១(ក) និងវិធាន២១ កថាខណ្ឌ១(គ) និងវិធាន២៣ នៃវិធានផ្ទៃក្នុង បានសំអាងទៅលើអង្គហេតុដែលមិនត្រឹមត្រូវនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន។

[១១:២៦:៤២]

ភាពត្រឹមត្រូវនៃដំណើរការនីតិវិធី តម្រូវឲ្យមានលក្ខណៈវិនិច្ឆ័យប្រកបដោយហេតុផលចំពោះសំណើសុំណាមួយ ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានជំនួយ ឬធនធានអាចបំពេញលក្ខខណ្ឌទាំងនេះបាន។ ដោយសារកំណត់លក្ខណៈវិនិច្ឆ័យក្នុងកម្រិតខ្ពស់នេះ សាលាដំបូងពិតជាបានបង្កឧបសគ្គដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណង។ លើសពីនេះទៅទៀត សាលាដំបូងមិនបានផ្តល់គោលការណ៍ណែនាំណាមួយជាមុននោះទេ ការដាក់បន្ទុកទៅលើដើមបណ្តឹងរដ្ឋប្បវេណី ដោយតម្រូវឲ្យពួកគាត់ដាក់ជូននូវការប៉ាន់ប្រមាណលើតម្លៃ គឺហួសពីមធ្យោបាយរបស់ពួកគាត់ ដែលអាចធ្វើទៅបានហើយ។

[១១:២៧:២២]

ហើយសាលាដំបូង ខកខានមិនបានញែកឲ្យដាច់ពីគ្នារវាងស្តង់ដារក្នុងស្រុក ចំពោះដែលបានអនុវត្តចំពោះការទាមទារការខូចខាតផ្នែកហិរញ្ញវត្ថុ។ ស្តង់ដារចុងក្រោយនេះ គឺមានការលំបាកយ៉ាងខ្លាំងចំពោះការគណនា ដោយមិនមានវត្តមានរបស់អ្នកជំនាញ ឬជំនួយតាមផ្លូវការរបស់តុលាការនោះ។

សាលាដំបូងមិនបានយកចិត្តទុកដាក់នៅក្នុងទៅលើចំណុចពិសេសៗ ដែលបានរៀបរាប់លម្អិតទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធបូជនីយដ្ឋាន ដែលដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំនោះទេ។

ដោយសារស្តង់ដារនៃភាពជាក់លាក់មិនត្រូវបានកំណត់និយមន័យនៅក្នុងវិធានផ្ទៃក្នុង នោះត្រូវស្វែងរកការណែនាំនៅក្នុងកម្រិតអន្តរជាតិ។ នៅក្នុងបណ្តឹងសាទុក្ខរបស់យើងខ្ញុំ យើងខ្ញុំបានពិភាក្សាយ៉ាងទូលំទូលាយអំពីការអនុវត្តរបស់តុលាការអន្តរជាតិនិងតុលាការថ្នាក់តំបន់ ដោយការរកឃើញថា

វិធានការដែលបានស្នើសុំដោយជនរងគ្រោះត្រូវបានទទួលយក។ ឧទាហរណ៍ តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង បានរកឃើញមធ្យោបាយប្រកបដោយស្ថាបនា ដើម្បីដោះស្រាយតម្រូវការ និងព្យសនកម្មរបស់ជនរងគ្រោះ ដោយបង្គាប់ឲ្យមានការផ្តល់សំណងប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលបានស្នើសុំនៅចំពោះមុខ អ.វ.ត.ក និងកំពុងតែអនុវត្តស្តង់ដារ ស្តីអំពីភាពជាក់លាក់ក្នុងកម្រិតទាបបំផុត។

[១១:២៨:៤០]

ដីកាបង្គាប់របស់ខ្លួនចំពោះរដ្ឋនានា ត្រូវបានសេចក្តីព្រាងទូទៅ ឧទាហរណ៍ ខ្ញុំសូមដកស្រង់ការសាងសង់បូជនីយកិច្ចនៅក្នុងតំបន់ជាក់លាក់ ភាពទាក់ទងនឹងជនរងគ្រោះ គឺដាក់ឈ្មោះផ្លូវ ឬទីលានដែលគេបានស្គាល់យ៉ាងច្រើន។

តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនទាន់ឈានដល់ដំណាក់កាលការផ្តល់សំណងទេនៅក្នុងករណីទីមួយរបស់ខ្លួន។ ប៉ុន្តែ បានដាក់ការទទួលខុសត្រូវទៅលើជនរងគ្រោះ ទាក់ទងនឹងភាពជាក់លាក់និងមិនហួសហេតុនោះទេ ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិអនុញ្ញាតឲ្យមានភាពបត់បែននៅក្នុងការពិចារណាអំពីវិសាលភាព និងទម្រង់នៃសំណង។

ហេតុដូច្នេះ ភាពជាក់លាក់ក្នុងកម្រិតខ្ពស់គួរឲ្យមានការភ្ញាក់ផ្អើល ដែលតម្រូវដោយសាលាដំបូងនេះ ដោយមិនបានផ្តល់ការណែនាំជាមុន គឺជាការរំលោភទៅលើភាពត្រឹមត្រូវផ្នែកនីតិវិធីហើយ។

ក្នុងពេលជាមួយនេះ សាលាដំបូងបានបង្កឲ្យមានកំហុសអង្គហេតុ ដោយសារតែសាលាដំបូងមិនបានយកចិត្តទុកដាក់ ឬធ្វើមិនដឹងមិនឮ ចំពោះការពន្យល់រៀបរាប់លម្អិត អំពីទីតាំង ប្រភេទ ការគូសប្លង់ និងចំនួនអគារដែលបានស្នើសុំ។

[១១:២៩:៤៩]

សំណើសុំទីប្រាំ នៅក្នុងសំណើសុំនេះ យើងបានស្នើសុំឲ្យមានការផ្តល់ថវិកាដល់ជនរងគ្រោះ ដើម្បីផ្តល់ឱកាសឲ្យជនរងគ្រោះអាចមកទស្សនាបូជនីយដ្ឋានទាំងនេះបីដងក្នុងមួយឆ្នាំ។ សាលាដំបូងមិនបានពិចារណាទៅលើសំណើសុំនេះទាល់តែសោះ។ ហេតុដូច្នេះ បានរំលោភទៅលើវិធាន១០០ នៃវិធានផ្ទៃក្នុង។ បន្ថែមលើនេះទៅទៀត សេចក្តីសម្រេចនេះបានសំអាងលើអង្គហេតុ ដែលមិនត្រឹមត្រូវ ដោយសំអាងដោយមិនបានពិចារណាទៅលើសំណើសុំជាជាក់ស្តែងនោះទេ។

សំណើសុំទីប្រាំមួយ កូនក្តីរបស់យើងខ្ញុំ បានស្នើសុំឲ្យមានការព្យាបាលសុខភាព និងការគាំទ្រផ្នែកផ្លូវចិត្ត រួមទាំងការដឹកជញ្ជូនប្រសិនបើចាំបាច់។ សាលាដំបូងបានបដិសេធ ការធានានេះទៅលើ

មូលដ្ឋានចំនួនបី។ ១) ខ្លឹមសាររបស់សំណើសុំ មិនមែនជាសំណើសុំនិមិត្តរូបនោះទេ។ ២) សំណើសុំនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ជាប្រយោជន៍ដល់ជនរងគ្រោះមួយចំនួនធំ។ និង៣) សំណើសុំនេះមិនស្ថិតនៅក្នុងវិសាលភាពនៃការផ្តល់សំណងដែលអាចធ្វើទៅបាន ព្រោះតុលាការនេះមិនអាចដាក់កាតព្វកិច្ចទៅលើអាជ្ញាធរសុខាភិបាលបានទេ។

ជាក់ស្តែង សាលាដំបូង-- ហេតុដូច្នេះយើងអ្នកដាក់ពាក្យសុំចំនួន១៧ យើងបានដាក់ពាក្យសុំទៅលើអ្នកដែលសុំចំនួន១៧ តែប៉ុណ្ណោះ។ សាលាដំបូងបានយោងសេចក្តីសម្រេចរបស់ខ្លួនទាំងភ័ន្តច្រឡំចំពោះពាក្យថា "សមូហភាពនិងផ្លូវចិត្ត" ដូចដែលមានចែងក្នុងវិធាន២៣(១)(ខ) និងបានចាត់ទុកសំណើសុំនេះ មិនមានលក្ខណៈជានិមិត្តរូបនោះទេ តាមខ្លឹមសាររបស់វា។

សាលាដំបូងខកខានមិនបានកំណត់និយមន័យ ថាតើពាក្យសុំនេះគួរចាត់ទុកថាខុសគ្នាពីសំណើសុំផ្តល់ហិរញ្ញវត្ថុជាបុគ្គល ដែលសំណើសុំទាំងអស់នេះ គឺថាត្រូវបានច្រានចោល។ សំណើសុំទាំងអស់រួមទាំង សំណើសុំជាសមូហភាពគួរតែចាត់ទុកថា នឹងផ្តល់ប្រយោជន៍ទៅដល់អ្នកដាក់ពាក្យសុំក្នុងលក្ខណៈជាសមូហភាព។

[១១:៣១:៥៨]

យើងបានស្វែងរកការណែនាំនៅក្នុងកម្រិតអន្តរជាតិ ហើយលទ្ធផលដែលបានរកឃើញ គឺថាសំណើសុំសមូហភាពនិងផ្លូវចិត្ត។ តាមការពិតគឺ ត្រូវតែពាក់ព័ន្ធនឹងថវិកា ដើម្បីអនុវត្តនោះដែរ ហើយទីពីរ សំណើសុំនេះត្រូវខុសគ្នាពីសំណើសុំផ្តល់ហិរញ្ញវត្ថុជាបុគ្គល មានន័យថាអ្វីក៏ដោយដែលលើសពីសំណើហិរញ្ញវត្ថុជាបុគ្គលដែលថិតនៅក្រោមចំណងជើងថា "សំណងជាសមូហភាពនិងផ្លូវចិត្ត"។

ការមិនយកចិត្តទុកដាក់ចំពោះវិសាលភាព ដែលបានផ្តល់ជូនចំពោះការបកស្រាយនេះដោយតុលាការអន្តរជាតិ ឬតុលាការតំបន់ សាលាដំបូងបានច្រាននូវលទ្ធភាព ទទួលបានការថែទាំសុខភាពការព្យាបាលសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំ។ តាមការយល់ឃើញរបស់យើងខ្ញុំការបដិសេធនេះ បង្កបានជាកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ។

[១១:៣២:៥៥]

សំណើសុំទីប្រាំពីរ យើងខ្ញុំ នៅក្នុងនេះយើងបានស្នើសុំឲ្យមានការផលិត និងការផ្សព្វផ្សាយសម្ភារៈសោតទស្សន៍ និងរូបភាពវីដេអូ និងដាក់បញ្ចូលនូវការរៀបរាប់លម្អិតអំពីខ្លឹមសារនៃសម្ភារៈទាំងនេះ ក៏ដូចជាកម្រិតនៃការផ្សព្វផ្សាយដែលបានស្នើសុំនេះ។ មិនមានភាពច្បាស់លាស់ទេ ថាតើសាលា

ដំបូងបានសម្រេចពេញលេញទៅលើសំណើសុំនេះទេ ដោយសារយើងគ្រាន់តែអាចសន្មត គ្រាន់តែស្មាន បានថាសំណើសុំនេះត្រូវបានចាត់ទុកថា ឋិតនៅក្រោមផ្នែកសាលក្រមដែលមានចំណងជើងថា “សំណើសុំទាក់ទងនឹងការបោះពុម្ពផ្សាយសាលក្រម និងការផ្សព្វផ្សាយ”។ ទោះបីជាសំណើសុំនេះ បញ្ជាក់លម្អិតអំពីខ្លឹមសារនៃសម្ភារៈឯកសារដែលបានស្នើសុំឲ្យផ្សព្វផ្សាយ ក៏ដូចជាការរៀបរាប់អំពីដំណាក់កាលផ្សព្វផ្សាយក៏ដោយ ក៏សាលាដំបូងបានច្រានចោលសំណើសុំនេះ ដោយសំអាងថា ខ្វះភាពជាក់លាក់ដដែល។

[១១:៣៣:៤៧]

បានបន្ថែម ខ្លឹមសារច្បាស់លាស់នៃវិធានការដែលបានស្នើសុំ និងសោហ៊ុយ នៃវិធានការ គឺមិនច្បាស់លាស់នោះទេ។ អាស្រ័យហេតុនេះ មិនអាចឲ្យ កាំង ហ្កេកអ៊ាវ ហៅ ឌុច ទទួលរ៉ាប់រងចំពោះសំណងនេះបានទេ។ ហេតុដូច្នេះ ដោយការបដិសេធសំណើសុំនេះ សាលាដំបូងបានរំលោភវិធាន២១ កថាខណ្ឌ១(ក) វិធាន២១ កថាខណ្ឌ១(គ) និងគោលការណ៍ជាមូលដ្ឋាននៃភាពត្រឹមត្រូវទៅលើដំណើរការនីតិវិធី ក្នុងការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសំណងនេះ។

ជាការគួរឲ្យភ្ញាក់ផ្អើលដែលថា សាលាដំបូងអាចយល់ច្រឡំទៅលើខ្លឹមសារនៃសំណើសុំនេះ ប្រសិន បើសាលាដំបូងលើកឡើងថា ខ្លួនមិនអាចឲ្យជនជាប់ចោទទទួលខុសត្រូវចំពោះសំណងនោះបាននោះ។ តាមពិតនៅក្រោមវិធានផ្ទៃក្នុងជនជាប់ចោទអាចត្រូវផ្តន្ទាទោសឲ្យទទួលខុសត្រូវចំពោះសោហ៊ុយសម្រាប់វិធានការ ដែលបានស្នើសុំនេះ ដូចជា ការផលិត ការផ្សព្វផ្សាយ និងសោហ៊ុយសម្រាប់ការថែទាំ។

[១១:៣៤:៤១]

លើសពីនេះទៅទៀត លក្ខខណ្ឌស្តីពីភាពជាក់លាក់ ដែលតម្រូវឲ្យមាននេះ គឺជាបន្ទុកមួយ--ដែលជាបន្ទុកមួយដែលមិនសមហេតុផលមកលើកូនក្តីរបស់យើងខ្ញុំ ដែលមិនទាំងមានមធ្យោបាយ ដើម្បីបញ្ជាក់លើសោហ៊ុយ និងការផលិត ឬដំណើរការផ្សព្វផ្សាយ ដោយសារលក្ខខណ្ឌតម្រូវមានការប៉ាន់ប្រមាណ តម្រូវឲ្យមានការប៉ាន់ប្រមាណពីវិស្វករ ឬអ្នកដទៃទៀតដែលមានជំនាញខាងផ្នែកសាងសង់។

សាលាដំបូងបានប្រើប្រាស់ពាក្យថា កង្វះភាពជាក់លាក់ ដោយយល់ឃើញថាជាមូលដ្ឋានគ្រប់ដណ្តប់ទៅលើការបដិសេធរបស់ខ្លួន ហើយការសម្រេចបែបនេះ គឺរំលោភទៅលើសិទ្ធិកាតព្វកិច្ចក្នុងការធានាដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានសំណង និងសំណងសមូហភាពនិងសំណងផ្លូវចិត្ត។

[១១:៣៥:២៩]

សំណើសុំទីប្រាំបី កូនក្ដីទាំង១៧នាក់របស់យើងខ្ញុំ បានស្នើសុំឲ្យការសាងសង់អាគារសាធារណៈចំនួន១៧ ដែលពួកគាត់ជាអ្នកជ្រើសរើសដាក់ឈ្មោះជនរងគ្រោះ និងដាក់បញ្ចូលការសាងសង់នេះជាមួយនិងការផ្សព្វផ្សាយជាសាធារណៈក្នុងពិធីបុណ្យផ្សេងៗ ដែលក្នុងនោះកាសែតវីដូអូថតចម្លងត្រូវបានរក្សាទុកនៅសារមន្ទីរទួលស្លែង ជើងឯក និងទីតាំងបូជនីយដ្ឋានថ្មី ដែលបានស្នើសុំឲ្យសាងសង់នូវព្រៃស។

សាលាដំបូងមិនបានដោះស្រាយសំណើសុំនេះទាល់តែសោះ។ យើងខ្ញុំសន្និដ្ឋានថា សាលាដំបូងមានបំណងដាក់បញ្ចូលការទាមទារនេះនៅក្នុងសាលក្រមរបស់ខ្លួនដែលមានចំណងជើងថា "វិធានការដោយរដ្ឋាភិបាល"។ ទោះបីជាចំណងជើងនេះ មិនស៊ីសង្វាក់ទៅនឹងការទាមទារនៅក្នុងសំណើសុំក៏ដោយ។

[១១:៣៦:១៤]

ដូចបានលើកឡើងនៅដើមដំបូងរួចមកហើយ សាលាដំបូងមិនត្រូវបានហាមឃាត់ មិនឲ្យចេញសេចក្ដីសម្រេចអំពីសំណង ដែលនៅក្នុងនោះ គឺទណ្ឌិតជាអ្នកទទួលបន្ទុកទៅលើសោហ៊ុយទាំងអស់ ហើយត្រូវមានជំនួយមិនមែនជាប្រាក់កាស ឬជាជំនួយរដ្ឋបាលពីរដ្ឋាភិបាល។

សំណើសុំទីប្រាំបួន ដែលជាសំណើសុំចុងក្រោយ។ នៅក្នុងការទាមទារនេះ យើងបានស្នើសុំឲ្យកាំង ហ្គេកអ៊ាវ សរសេរលិខិតចំហមួយច្បាប់ជូនទៅរាជរដ្ឋាភិបាលកម្ពុជា ដោយស្នើសុំឲ្យយកសោហ៊ុយដោយយកម្រៃទស្សនាសារមន្ទីរទួលស្លែង ជើងឯក ជំនួយមួយភាគបីសម្រាប់ជាការចូលរួមចំណែកផ្ដល់សំណងដល់ជនរងគ្រោះ មូលនិធិដល់ដើមបណ្ដឹងរដ្ឋប្បវេណី។

[១១:៣៧:០១]

ដោយការខកខានមិនបានសម្រេចទៅលើសំណើសុំនេះ សាលាដំបូង បានរំលោភវិធាន១០០ នៃវិធានផ្ទៃក្នុង។ ហើយការមិនមានភាពច្បាស់លាស់ គឺយើងសន្និដ្ឋ គ្រាន់តែអាចសន្និដ្ឋថា សាលាដំបូងបានដោះស្រាយសំណើនេះ អាចនៅក្រោមផ្នែកដែលមានចំណងជើងថា "សំណើសុំឲ្យផ្ដល់សំណងជាថវិកាដល់បុគ្គល ឬការបង្កើតមូលនិធិ" ឬអាចស្ថិតនៅក្រោមចំណងជើង ដែលថា "សំណើសុំឲ្យមានការចាត់វិធានការដោយរាជរដ្ឋាភិបាលកម្ពុជា"។ បើទោះបីជាសំណើនេះមានភាពច្បាស់លាស់ក៏ដោយក៏សាលាដំបូងបែរជាយល់ច្រឡំទាំងស្រុងចំពោះការទាមទារនេះ ដែលគ្រាន់តែស្នើសុំឲ្យជនជាប់ចោទសរសេរលិខិតចំហមួយច្បាប់ទៅការរាជរដ្ឋាភិបាលកម្ពុជា ដោយទុកកម្រៃចូលទស្សនាសារមន្ទីរទួលស្លែង

និងជើងឯក ចំនួនមួយភាគបីដើម្បីប្រើប្រាស់សម្រាប់ជាការផ្តល់មូលនិធិចំពោះសំណងដែលបានស្នើសុំនេះ។ សំណើសុំនេះពិតជាស្ថិតនៅក្នុងក្របខ័ណ្ឌនៃសំណងជាសមូហភាព និងសំណងផ្លូវចិត្តហើយ។

[១១:៣៧:៥៨]

ចុងបញ្ចប់ដើម្បី-- វិធីសាស្ត្រដ៏ចង្អៀតរបស់សាលាដំបូងអំពីបញ្ហាសំណងនេះ ខ្វះភាពច្បាស់លាស់ និងមិនគួរឲ្យពេញចិត្ត មិនគួរឲ្យទទួលយកបាន។ ដែលដើមបណ្តឹងរដ្ឋប្បវេណី មិនរំពឹងចង់បានអ្វីក្រៅពីអ្វីដែលខ្លួនស្នើសុំនោះទេ។

យោងតាមស្មារតីដែលថា អ.វ.ត.ក ជាតុលាការដែលមានចរិតលក្ខណៈអន្តរជាតិ ដោះស្រាយទៅលើឧក្រិដ្ឋកម្មដ៏ធំធេងនេះ។ ហើយដែលតាមរយៈនេះ តែតាមលទ្ធផលនេះ គឺថាកូនក្តីរបស់យើងខ្ញុំមិនអាចទទួលយកលទ្ធផលនៃសេចក្តីសម្រេចបានទេ ប្រសិនជា អ.វ.ត.ក បិទទ្វារមិនសម្រេចទៅលើសំណើសុំនេះទេ ហើយមិនបានបកស្រាយទៅលើពាក្យថា សំណងសមូហភាពនិងសំណងផ្លូវចិត្ត និងតម្រូវឲ្យមានភាពច្បាស់លាស់ក្នុងកម្រិតខ្ពស់បែបនេះ ដែលកូនក្តីរបស់យើងខ្ញុំមិនអាចអនុវត្តបាននោះ គឺសាលាដំបូងបានបដិសេធលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានសំណងនោះហើយ។ មានន័យថា សាលាដំបូងបានបដិសេធចំពោះសិទ្ធិដ៏សំខាន់ៗ។

[១១:៣៩:១១]

សេចក្តីសម្រេចរបស់សាលាដំបូងបង្ហាញឲ្យឃើញថា អ.វ.ត.ក កន្លងមកខកខានមិនបានបំពេញបេសកម្មពិសេសរបស់ខ្លួនទៅលើពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យហ្មត់ចត់ និងប្រកបដោយអត្ថន័យនោះទេ។ ក្នុងកម្រិតអន្តរជាតិ អ.វ.ត.ក ត្រូវបានផ្តល់ឱកាសឲ្យក្លាយជាតុលាការគំរូមួយសម្រាប់សាលាជម្រះក្តី និងតុលាការអន្តរជាតិដទៃទៀតក្នុងការដោះស្រាយឧក្រិដ្ឋកម្មដ៏ធំធេងនេះ ដោយការទទួលស្គាល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណឲ្យបានពេញលេញ រួមទាំងការចេញសេចក្តីសម្រេចអំពីសំណង ដែលប្រកបទៅដោយអត្ថន័យសម្រាប់ជនរងគ្រោះ ដោយឧក្រិដ្ឋកម្មយ៉ាងធ្ងន់ធ្ងរ ធំធេង និងឃោរឃៅនេះ ដែលដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានច្រើនទៅនេះ។ តែតាមពិត ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានច្រើនជាងនេះទៅទៀតនោះ។

[១១:៣៩:៥៦]

ជាសង្ខេប បើទោះបីជាការទាមទារទាំងអស់របស់យើងខ្ញុំដែលបានដាក់ជូន មានភាពច្បាស់លាស់ និងស្ថិតក្នុងក្របខ័ណ្ឌនៃសំណងសមូហភាពនិងសំណងផ្លូវចិត្តក៏ដោយ ក៏សំណើសុំទាំងនេះ ស្ទើរតែ

ទាំងអស់ត្រូវបានបដិសេធតាមរយៈកំហុសនៃវិធានផ្ទៃក្នុង ឬតាមរយៈកំហុសទៅលើអង្គហេតុ។ យើងខ្ញុំសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះតុលាការកំពូលដោះស្រាយបញ្ហាទាំងនេះ ដោយប្រកាសទទួលស្គាល់យកបណ្តឹងសាទុក្ខនេះ និងដោះស្រាយទៅលើសំណើទាមទារសំណងទាំងនេះឲ្យបានពេញលេញ។

សូមអរគុណលោក លោកស្រីចៅក្រម ចំពោះការយកចិត្តទុកដាក់ស្តាប់ប្រកបទៅដោយការយកចិត្តទុកដាក់។ តាមដែលខ្ញុំដឹង គឺខ្ញុំនៅសល់រយៈពេលខ្លះៗទៀត ហើយប្រសិនណាជាអង្គជំនុំជម្រះតុលាការកំពូលយល់ស្រប ខ្ញុំសូមចូលទៅចម្លើយតបនៃការអញ្ជើញរបស់តុលាការកំពូល។ សូមលើកឡើងអំពីចម្លើយតប។

[១១:៤១:១២]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញ!

**លោកស្រី ស៊ីលឃី ស្វូតហ្វ៊ីនស្គី៖**

យើងបញ្ជាក់ថា កូនក្តីរបស់ខ្ញុំចង់ឲ្យទទួលស្គាល់នៅក្នុងសាលក្រម យើងខ្ញុំស្នើថា ពាក្យសុំរបស់យើង គឺបង្ហាញអំពីគម្រោងដែលមាននៅក្នុងតុលាការនេះ ជាពិសេសបញ្ហាសំណងជាសមូហភាព និងផ្លូវចិត្ត។ លក្ខណៈជាក់លាក់នៃដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មធំធេងនេះ ហើយចំណុចទីបួន គឺទាក់ទងទៅនឹងលទ្ធភាព និងសមត្ថភាពរបស់កូនក្តីរបស់យើងក្នុងនាមជាបុគ្គល និងសមាជិកនៅក្នុងក្រុមជាជនរងគ្រោះសមូហភាព។ ប៉ុន្តែ មុនពេលនឹងលើកឡើងចំណុចហ្នឹង ខ្ញុំសូមលើកឡើងបញ្ជាក់កំណត់សំគាល់បឋមដោយឲ្យលោក លោកស្រីចៅក្រមពិចារណា។

[១១:៤២:១៦]

ចំណុចទីមួយ វិធានផ្ទៃក្នុង វិសោធនកម្មលើកទីបី បានផ្តល់ជាឧទាហរណ៍ចំពោះសំណងជាសមូហភាពនិងផ្លូវចិត្ត គឺការបោះពុម្ពផ្សាយសាលក្រមដោយជាការចេញសោហ៊ុយពីជនជាប់ចោទ ហើយផ្តល់មូលនិធិនូវសកម្មភាពមិនមែនជាថវិកាដែលជាប្រយោជន៍សម្រាប់ជនរងគ្រោះ។ យើងខ្ញុំសូមបញ្ជាក់ថា វាជាសំណងសមូហភាពនិងផ្លូវចិត្ត។ ដូច្នេះវាអាចបញ្ចូលលក្ខណៈថា សំណងសមូហភាពនិងផ្លូវចិត្តនេះជាការចេញសោហ៊ុយផងដែរ។

[១១:៤២:៥៣]

ចំណុចទីពីរ បុគ្គលដែលត្រូវបានចោទក្នុងការបង់សំណងជាថវិកានោះ អនុញ្ញាតឲ្យខ្ចីប្រាក់ពី

តតិយជនបាន ឬក៏ទទួលថវិកាតាមរយៈមធ្យោបាយដទៃៗទៀត។ មិនមានកាតព្វកិច្ចផ្លូវច្បាប់ណាមួយថា ពិរុទ្ធជនត្រូវចេញសំណងចំពោះបទល្មើស ដែលខ្លួនត្រូវចេញសោហ៊ុយដោយខ្លួនឯងនោះទេ។

ការកំណត់ទៅលើភាពក្រីក្រ មិនត្រូវផ្ដល់អានុភាពប៉ះពាល់ទៅដល់ការផ្ដល់សំណងនៅក្នុងនីតិវិធីតុលាការដែលជាលក្ខខណ្ឌទាមទារនៅចំពោះមុខ អ.វ.ត.ក។ ជាពិសេស ក្នុងលក្ខខណ្ឌនៃសំណងជាសមូហភាពនិងផ្លូវចិត្ត ហើយសំណងនេះគឺជាការរៀបចំឡើងដើម្បីជាប្រយោជន៍សម្រាប់ជនរងគ្រោះ។

[១១:៤៣:៤០]

សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ទៀតថា មិនមានកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងមិនមានចែងអំពីការអនុវត្តចំពោះសំណងនោះទេ។ វិធាន១០០(១៣)(១) ជាពិសេសវិសោធនកម្មលើកទីបី លើកឡើងអំពីការផ្ដួចផ្ដើមទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី។ ហេតុដូច្នេះ មាត្រា៥២៣ រហូតដល់៥៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាចជាបទដ្ឋានណែនាំបន្ថែមលើករណីនេះ។

ក្រោមច្បាប់កម្ពុជា នៅពេលអនុវត្តចំពោះសំណងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ពិរុទ្ធជនមិនចាំបាច់ធ្វើការចេញសំណងទេ ប៉ុន្តែគាត់អាចត្រូវចាប់បង្ខំដាក់ពន្ធនាគារដើម្បីជាការចេញសំណង។ នេះជាការដាក់សម្ពាធមួយទៅលើពិរុទ្ធជនដើម្បីព្យាយាមយ៉ាងណារកថវិកា ឬក៏ផ្នែកណាមួយចំពោះថវិកាក្រោយពេលដែលខ្លួនត្រូវបានចាប់បង្ខំដាក់ពន្ធនាគារ ដោយការអនុវត្តនេះវាស្របទៅតាមនីតិវិធីកម្ពុជា។

[១១:៤៤:៥៥]

សហមេធាវី គឺយើងលើកឡើងចំពោះករណីដើមបណ្ដឹងរដ្ឋប្បវេណី១៧នាក់។ ដូច្នេះយើងស្នើសុំតុលាការកំពូលឲ្យសម្រេចចំពោះករណី១៧នាក់នេះ ដូចតទៅ។ ខ្ញុំនឹងទុកជូនសំណើនេះ ឯកសារនេះជូនតុលាការកំពូលទៅតាមអ្វីដែលខ្ញុំបានអាន។ យើងស្នើសុំឲ្យតុលាការសម្រេចដូចតទៅ៖

កាត់ឲ្យជនជាប់ចោទនេះ សរសេរជាលិខិតចំហទៅកាន់រាជរដ្ឋាភិបាលកម្ពុជា។

ទីមួយ គឺស្នើសុំជាផ្លូវការឲ្យមានការសុំទោសដោយពិតប្រាកដ ជាក់ស្ដែង និងហ្មត់ចត់ ដែលចំពោះអំពើដែលខ្លួនបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយសុំឲ្យយកមួយភាគបីនៃលុយចូលមន្ទីរជើងឯក និងទួលស្លែងនោះ ដើម្បីយកមកធ្វើជាថវិកាអនុវត្តចំពោះសំណងដែលបានផ្ដល់ជូនដោយតុលាការនេះ។

កាត់ឲ្យជនជាប់ចោទរូបនេះ ចេញចំពោះ-- ជាបន្ទុកចេញលុយចំពោះសំណងមួយចំនួន។

ការចងក្រងចំពោះសេចក្តីថ្លែងសុំទោស ដែលបានលើកឡើងនៅក្នុងពេលសវនាការ ហើយយើងត្រូវតម្រូវឲ្យមើលប្រតិចារឹកក្នុងពេលសវនាការផងដែរ។ សេចក្តីថ្លែងសុំទោសនេះ គឺត្រូវធ្វើយ៉ាងណាចងក្រងជាការសុំទោសពីជនជាប់ចោទ។

[១១:៤៦:២៥]

ចំណុចទីពីរ ធ្វើការសង់ស្តូបនៅក្នុងទួលស្លែង ហើយជាពិសេសនោះ នៅខាងស្តាំផ្នែកនៃជើងឯក ហើយដែលស្តូបនោះ គឺគួរតែដាក់ឈ្មោះរបស់ជនរងគ្រោះ ហើយនិងអ្នកដែលទទួលរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយយើងប្រើថ្មពណ៌ស។ ថ្មស្តូបនោះ គឺរៀបរាប់សង្ខេបដោយលទ្ធផលនៃការជំនុំជម្រះនៅក្នុងសំណុំរឿង០០១ ដោយមិនហួសពី ៣០០ពាក្យ។ ថ្មពណ៌សនោះ គឺយើងត្រូវដាក់ថ្ងៃកំណត់កាលបរិច្ឆេទឲ្យបានច្បាប់ចំពោះអ្នកទោសដែលបានចូលនៅស-២១ និងថ្ងៃដែលគេត្រូវបានសម្លាប់។

[១១:៤៧:២២]

ចំពោះព័ត៌មានមួយចំនួនទាក់ទងទៅនឹងអត្តចរិត និងជីវិតរបស់ជនរងគ្រោះ ក៏ត្រូវតែបញ្ចូលទៅលើស្តូបនោះផងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីនានាត្រូវកំណត់ថាអត្ថបទទាំងអស់នោះ មិនត្រូវលើសពី ២០០ពាក្យ ចំពោះគ្រួសារជនរងគ្រោះរបស់គេនីមួយៗ។ អត្ថបទនោះ គួរតែសរសេរជាផ្លូវការរបស់តុលាការខ្មែរ អង់គ្លេស និងភាសាបារាំង ហើយត្រូវធ្វើការរៀបចំជាសោតទស្សន៍ផងដែរ។

ចំណុចទីបី ស្តូបនោះត្រូវធ្វើការកសាងនៅព្រៃស ហើយធ្វើវាទៅជាស្តូបមួយរំឭកវិញ្ញាណក្ខន្ធ ហើយស្តូបនោះត្រូវតែវាមានកម្ពស់ ៣៥ម៉ែត្រ ហើយមានទំហំជាក់លាក់។ ហើយស្តូបនោះត្រូវតែជាទីកន្លែងសម្រាប់គោរពសាសនាព្រះពុទ្ធផងដែរ។ ការប្រកួតប្រជែងខាងផ្នែកស្ថាបត្យកម្មអន្តរជាតិ ត្រូវតែរៀបចំឡើង ដើម្បីបំពេញចំពោះការកសាងស្តូបនោះ។ ពិធីសាសនាទាំងឡាយ និងពិធីសម្រាប់វប្បធម៌ទាំងឡាយត្រូវបានរៀបចំសម្រាប់ការគោរពស្តូបនោះផងដែរ។

[១១:៤៨:៤០]

ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យមានការប្រកួតផ្នែកស្ថាបត្យកម្មអន្តរជាតិ តាមរយៈសំឡេងភាគច្រើនដាច់ខាន។ ស្តូបនោះ គឺទុកជាកន្លែងសម្រាប់ពន្យល់អំពីតួនាទី និងការប្រើប្រាស់ទីតាំងព្រៃស។ ហើយដោយធ្វើឲ្យស្របទៅតាមការរកឃើញដោយសាលាដំបូង និងការស្រាវជ្រាវតាមរយៈលក្ខណៈវិទ្យាសាស្ត្រ។ ការតាំងពិពណ៌ ឬការបង្ហាញនោះត្រូវតែធ្វើឡើងរៀបចំជាភាសាផ្លូវការរបស់ អ.វ.ត.ក រួមទាំងជាខ្មែរអាត់សំឡេងផងដែរ។

តួនាទីនិងការទទួលខុសត្រូវរបស់ជនជាប់ចោទ គួរតែធ្វើការសរសេរបង្ហាញនៅលើផ្ទាំថ្មស្តូបនោះ។ ឈ្មោះជនរងគ្រោះនៅក្នុងសំណុំរឿង០០១ និងឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីក៏សរសេរទៅលើផ្ទាំងថ្មនោះដែរ។ ហើយរួមទាំងអត្ថបទនិងការពន្យល់ទាំងឡាយទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីក៏ត្រូវសរសេរលើផ្ទាំងថ្មនោះផងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីគួរតែមានសិទ្ធិសរសេរលើផ្ទាំងថ្មនោះ។

[១១:៥០:០០]

ភាគីត្រូវមានឱកាសក្នុងការមកធ្វើទស្សនកិច្ចនៅទីតាំងទាំងបីនោះបីដងក្នុងមួយឆ្នាំ ដោយមួយដងមានរយៈពេលបួនថ្ងៃ។

ដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើគាត់មិនមានលទ្ធភាពមកធ្វើទស្សនកិច្ចនោះទេ ត្រូវផ្តល់លទ្ធភាពនេះឲ្យបុគ្គលណាមួយដែលទទួលសិទ្ធិពីដើមបណ្តឹងរដ្ឋប្បវេណីនោះតាមការចាំបាច់។

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលនូវការព្យាបាលសុខភាព និងការអប់រំ រួមទាំងការគាំទ្រផ្នែកចិត្តសាស្ត្រ រួមទាំងភាពចាំបាច់ទាំងឡាយលើការដឹកជញ្ជូនផងដែរ។

យ៉ាងហោចណាស់ខ្សែភាពយន្តដោយសង្ខេបនៃកិច្ចសវនាការ និងការលើកឡើងពាក់ព័ន្ធទៅនឹងសាលក្រមគួរតែធ្វើការចែកជូននៅតាមវត្តនីមួយៗ តាមឃុំភូមិនានាដែលបានកំណត់។

ដើមបណ្តឹងរដ្ឋប្បវេណីគួរតែមានសិទ្ធិធ្វើការជ្រើសរើសមន្ទីរពេទ្យសាធារណៈណាមួយដែលខ្លួនអាចមានសិទ្ធិក្នុងការដាក់ឈ្មោះតំណាងឲ្យជនរងគ្រោះដែលខ្លួនតំណាង។

[១១:៥១:០៥]

ដំណើរការទាំងអស់នេះ គួរតែរួមទាំងការរំឭកវិញ្ញាណក្ខន្ធជាផ្លូវការរួមទាំងការបង្ហាញអំពីផ្ទាំងថ្ម អំពីប្រវត្តិរូបរបស់ជនរងគ្រោះនីមួយៗដែលទទួលរង។

ខ្ញុំនឹងផ្តល់ជូននូវសំណើរបស់យើងខ្ញុំនេះ ដែលយើងដាក់ជូនចំពោះមុខតុលាការកំពូលនៅពេលនេះ តាមរយៈក្រឡាបញ្ជីក្រោយពេលបញ្ចប់សវនាការនេះ។

ដូច្នេះ នៅពេលនេះ យើងខ្ញុំត្រៀមរង់ចាំការសួរសំណួរពីអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកចៅក្រមសួរសំណួរទៅលើមេធាវី។

សូមអញ្ជើញ!

[១១:៥២:០០]

**ចៅក្រម យ៉ា ណារិន៖**

បាទ, ខ្ញុំមានសំណួរមួយ ពាក់ព័ន្ធទៅនឹងការទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

ថាតើគ្រប់ភស្តុតាងដែលបានទទួលពីមន្ទីរស-២១ បានបញ្ជាក់អត្តសញ្ញាណឲ្យបានគ្រប់គ្រាន់ដែរឬទេ? ជាពិសេស ពាក់ព័ន្ធទៅនឹងរូបថតជនរងគ្រោះ ដែលអ្នកដាក់ពាក្យសុំយកមកធ្វើជាសំអាងនៅក្នុងពាក្យសុំ។ បាទ, សូមអរគុណ។

[១១:៥២:៥១]

**លោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្គី៖**

សូមអរគុណចំពោះសំណួររបស់លោកចៅក្រម, ខ្ញុំហាក់ដូចជាស្តាប់សំណួរមិនសូវច្បាប់លាស់ ដោយសារតែខ្ញុំកំពុងតែរៀបចំឯកសារ កំពុងរកឯកសាររបស់ខ្ញុំ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតសួរទៅកាន់លោកចៅក្រមឡើងវិញ សុំឲ្យលោកចៅក្រមបញ្ជាក់នៅសំណួរនេះម្តងទៀត។ សូមអរគុណ។

**ចៅក្រម យ៉ា ណារិន៖**

សំណួរ៖ថាតើគ្រប់ភស្តុតាងដែលទទួលបានពីមន្ទីរស-២១ បានបញ្ជាក់អត្តសញ្ញាណឲ្យបានគ្រប់គ្រាន់ដែរឬទេ? ជាពិសេសពាក់ព័ន្ធទៅនឹងរូបថតជនរងគ្រោះផ្ទាល់ ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីយកមកធ្វើជាសំអាងនៅក្នុងពាក្យសុំ។

[១១:៥៣:៥៤]

**លោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្គី៖**

សូមអរគុណចំពោះសំណួរដែលបានសួរពីលោកចៅក្រម។ យើងខ្ញុំសូមលើកឡើងថា ប្រសិនបើកូនក្តីរបស់យើងខ្ញុំរកឃើញរូបថតនៅក្នុងសារមន្ទីរទួលស្លែង ដែលជាឯកសាររកឃើញនៅស-២១ នោះហើយប្រសិនបើរូបថតនៃអ្នកទោសនោះវាបង្ហាញ ឆ្លុះបញ្ចាំងអំពីអ្នកទោសពិតប្រាកដនោះ។ ដូច្នេះយើងទទួលស្គាល់ថា រូបថតនោះ គឺជាជនរងគ្រោះ។

យើងសូមលើកឡើងថា មិនមានការបញ្ជាក់ណាមួយថា យើងបានប្រព្រឹត្តកំហុស ឬក៏អ្នកដាក់ពាក្យសុំតាំងខ្លួននោះបានបង្កើតជាកំហុសក្នុងការបង្ហាញអំពីរូបថតនោះឡើយ។ ហើយមិនមានការប្រព្រឹត្តកំហុសពីដើមបណ្តឹងរបស់យើងបង្ហាញថា អ្នកដែលនៅក្នុងរូបថតនោះមិនមែនជាសាច់ញាតិរបស់ខ្លួននោះឡើយ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំមានសំណួរចំនួនពីរ។ ទីមួយ ខ្ញុំចង់ចោទសួរអំពីការបង្ហាញពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសភាពត្រឹមត្រូវនៅក្នុងការតំណាងក្នុងកិច្ចដំណើរការនីតិវិធី។ ខ្ញុំសូមលើកឡើងអំពីលក្ខខណ្ឌនៃការស្ថិតនៅក្រោមបន្ទុក និងចំណាងជិតស្និទ្ធ។

ដូច្នេះ ខ្ញុំចង់សួរថាតើ ចំណុចលក្ខខណ្ឌនេះ ផ្អែកទៅលើមូលដ្ឋានដែលថាមិនបានជូនដំណឹងគ្រប់គ្រាន់ទៅដល់ភាគី ឬក៏យ៉ាងម៉េច? ដោយសារតែលក្ខខណ្ឌមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬក៏មិនមានការដាក់ជូននៅក្នុងពេលសវនាការ ឬក៏ដើមបណ្តឹងសាទុក្ខ ដែលជាភាគីនេះយល់យ៉ាងម៉េច? ថាវាជាលក្ខខណ្ឌមួយខុស ឬក៏យ៉ាងណា? ហើយវាជាលក្ខខណ្ឌមួយមិនគ្រប់គ្រាន់នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខយើងឬក៏យ៉ាងម៉េច?

[១១:៥៦:០៣]

សំណួរទីពីរ ទាក់ទងទៅនឹងសំណង ហើយនិងការស្នើសុំពីខាងក្រុមដើមបណ្តឹងរដ្ឋប្បវេណីទីពីរ។ ឧទាហរណ៍ថា តួនាទីរបស់តុលាការ គឺយើងធ្វើដោះស្រាយទៅលើរឿងរដ្ឋប្បវេណីផងដែរ ហើយផ្អែកទៅលើច្បាប់ដែលវាមានវិវាទរវាងគូភាគីដែលជាច្បាប់មួយចងកាតព្វកិច្ច។

ដូច្នេះ តុលាការ សេចក្តីសម្រេចរបស់តុលាការ គឺយ៉ាងណាក៏ដោយ តាមទ្រឹស្តីអាចអនុវត្តទៅបាន។ ហើយយើងនៅទីនេះមិនមែនធ្វើការពិភាក្សា ថាតើស្ថាប័នណាមួយជាអ្នកអនុវត្តទៅលើសំណង ឬសេចក្តីសម្រេចនោះទេ។

ដូច្នេះ ខ្ញុំចង់សួរថាតើដើមបណ្តឹង ឬក៏ភាគីនេះគឺយល់យ៉ាងណាចំពោះការអនុវត្តទៅលើសំណងដែលតម្រូវឱ្យជនជាប់ចោទអនុវត្តសកម្មភាពមួយចំនួននោះ?

[១១:៥៧:០៣]

យើងដឹងហើយថា សកម្មភាពមួយចំនួន វាតម្រូវឱ្យមានការកសាងនូវស្តូបនៅលើដីរបស់តតិយជន ហើយដែលតម្រូវឱ្យមានក្របខ័ណ្ឌ និងការយល់ព្រមពីខាងរដ្ឋបាល ទាក់ទងទៅនឹងការដាក់ឈ្មោះផ្លូវផងដែរនោះ។ សូមអរគុណ។

**លោកស្រី ស៊ីលយ៉ីស្វេត ហ្សីនស្គី៖**

សូមអរគុណ។ ខ្ញុំសូមសួរទៅលោកប្រធានសិន។ នៅពេលនេះយើងដល់ពេលអាហារថ្ងៃត្រង់ហើយ ដូច្នេះថាតើយើងសម្រាកសិន ឬក៏ផ្តល់ឱកាសឱ្យខ្ញុំឆ្លើយតែម្តង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញឆ្លើយតប។

[១១:៥៧:៤៣]

**លោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្តី៖**

សូមអរគុណ។ ពាក់ព័ន្ធទៅនឹងសំណួរទីមួយ អនុញ្ញាតឲ្យខ្ញុំឆ្លើយតបដូចតទៅ៖

យើងឃើញអំពីចំណងសាច់ញាតិ និងលក្ខខណ្ឌនៃចំណងជិតស្និទ្ធ ដែលជាលក្ខខណ្ឌនៃការបញ្ជាក់មួយខុសគ្នា។ ដែលក្នុងនេះតម្រូវឲ្យជនរងគ្រោះបង្ហាញ ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ជនរងគ្រោះត្រូវតែបង្ហាញថា ខ្លួនទទួលរងផ្លូវចិត្តដែលជាព្យសនកម្ម ហើយព្យសនកម្មនោះជាផលវិបាកដោយផ្ទាល់នៃបទល្មើស។ ដែលបទល្មើសនោះស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការនេះ។

[១១:៥៨:៣៧]

ខ្ញុំសូមរៀបរាប់នៅក្នុងសារណារបស់ខ្ញុំ។ គិតថាទឡ្ហីករណ៍នេះ ជាទឡ្ហីករណ៍លើកឡើងពីរដំណាក់កាល។ ទីមួយ គឺមិនបានជូនដំណឹងមកកាន់អ្នកដាក់ពាក្យសុំ ហើយអ្នកដាក់ពាក្យសុំមិនបានដឹងអំពីការចង្អុលបញ្ជាក់ដូច្នេះទេ។

ចំណុចទីពីរ នៅក្នុងបណ្តឹងសាទុក្ខរបស់យើង យើងបានបង្ហាញថាកូនក្តីរបស់យើងនោះ បានបង្ហាញនិងដាក់ជូនឯកសារទាំងឡាយ ដែលឯកសារទាំងអស់នោះ បង្ហាញអំពីអត្ថិភាពនៃចំណងជិតស្និទ្ធ ពិសេស។ ដូច្នេះ ចង់សួរថាតើការសន្និដ្ឋានរបស់លោក លោកស្រីចៅក្រមយ៉ាងម៉េច? យើងដឹងហើយថាលក្ខខណ្ឌនោះមិនបានជូនដំណឹងតាមរយៈការបញ្ជាក់វិធានផ្ទៃក្នុងនោះទេ ហើយនៅចុងក្រោយយើងខ្ញុំបានបំពេញទៅតាមលក្ខខណ្ឌទាំងអស់នេះរួចរាល់ចប់សព្វគ្រប់រួចហើយ។

[១១:៥៩:៣៨]

ខ្ញុំសូមឆ្លើយតបទៅនឹងសំណួរបន្ទាប់។ សំណួរទីពីរ ដែលសួរទៅនឹងក្រុមទីមួយ សួរទៅលើក្រុមទីមួយ ហើយដែលវាពាក់ព័ន្ធទៅនឹងក្រុមទាំងអស់នៅដំណាក់កាលចុងក្រោយ។ ជាពិសេសសំណួរដែលពាក់ព័ន្ធទៅនឹងមាត្រា៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលក្រមនេះមានលក្ខណៈស្រដៀងនឹងវិធាន ១០០ នៃវិធានផ្ទៃក្នុង។

សំណួររបស់លោកចៅក្រមចោទសួរទៅលើចំណុចនេះ។ យើងមានការភ្ញាក់ផ្អើល នៅពេលដែលយើងឃើញមានការចេញសេចក្តីសម្រេចជាលើកទីពីរនៅក្នុងសាលក្រម។ សិទ្ធិដែលមានចែងនៅ

ក្នុងច្បាប់កម្ពុជា តុលាការកម្ពុជាមានបញ្ជាក់យ៉ាងច្បាស់លាស់។

[១២:០០:៣២]

ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមពិចារណា និងពិនិត្យទៅលើសេចក្តីសម្រេច ដែលធ្វើឡើងដោយអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ដូចតទៅៈ

ខ្ញុំសូមដកស្រង់ចេញពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថា វិធានផ្ទៃក្នុងគឺជាវិធានមួយដែលជាវិធានបញ្ជាក់អំពីនីតិវិធី ហើយវាបង្ហាញអំពីករណីដែលកើតឡើងនៅអ.វ.ត.ក ហើយវិធាននេះគឺបង្កើតឡើងដោយកិច្ចប្រជុំពេញអង្គ។ ហើយវិធានផ្ទៃក្នុងមិនមានលក្ខណៈផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ។ ប៉ុន្តែ គោលបំណងនៃវិធានផ្ទៃក្នុងគឺមានលក្ខណៈខុសគ្នាបន្តិចបន្តួចទៅនឹងប្រតិបត្តិការ ឬក៏ការអនុវត្តក្រមនីតិវិធីរបស់កម្ពុជាដែលមានជាធរមាន។

[១២:០១:២៧]

ដូច្នេះ យើងឃើញនៅក្នុងនោះមានសេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ ហើយលោក លោកស្រីចៅក្រមជាចៅក្រមមានវិជ្ជាជីវៈ ហើយយល់ទៅលើចំណុចនេះ។

ដូច្នេះ វិធានផ្ទៃក្នុងបង្កើតជាលិខិតុបករណ៍មួយដែលយើងគួរតែជាយល់ថា ជាបទដ្ឋានណែនាំក្នុងការកំណត់ការងារនៅក្នុងអ.វ.ត.ក។ នៅពេលមានវិវាទរវាងវិធានផ្ទៃក្នុង និងក្រមព្រហ្មទណ្ឌកម្ពុជា ក្រមព្រហ្មទណ្ឌកម្ពុជាគួរតែអនុវត្តក្នុងករណីដែលមានចែងក្នុងវិធានផ្ទៃក្នុងតែប៉ុណ្ណោះ។

លោក លោកស្រីចៅក្រមបានដឹងរួចហើយថា យើងគួរចាត់ទុកសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះនៅក្នុងករណី នួន ជា។ ដូច្នេះ សម្រាប់ការកត់ត្រាប្រតិចារឹក ខ្ញុំសូមលើកឡើងបញ្ជាក់ឯកសារលេខឯកសារនេះ គឺឯកសារលេខD54/1/8, ERN ជាភាសាអង់គ្លេសគឺ 00 (សូមអភ័យទោស) 00219322 ដល់លេខ 00219333។ គឺក្នុងកថាខណ្ឌ១៤ និង១៥ នៃសេចក្តីសម្រេចនៃសាលដីការបស់អង្គបុរេជំនុំជម្រះ។

[១២:០៣:០១]

ខ្ញុំគិតថា យើងជាដើមបណ្តឹងរដ្ឋប្បវេណីបានតវ៉ាផ្នែកនៃសេចក្តីសម្រេច ហើយយើងខ្ញុំស្នើសុំឲ្យមានការពិចារណាឡើងវិញ ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេច។

អង្គបុរេជំនុំជម្រះបានតម្កល់សេចក្តីសម្រេច។ ហេតុដូច្នេះហើយ ខ្ញុំសូមលើកឡើងដោយដោយសង្ខេប យើងជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងដឹងហើយថា មិនមានចន្លោះប្រហោង

ទេ វិធានផ្ទៃក្នុងមានចែងយ៉ាងច្បាស់លាស់រួចទៅហើយ។ នៅក្នុងវិធាន១០០ ដែលចែងអំពីការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយសេចក្តីសម្រេចនោះត្រូវតែសម្រេចនៅក្នុងសាលក្រម។

ដូច្នេះ យើងឃើញថាវិធានផ្ទៃក្នុងគឺជាបទប្បញ្ញត្តិ ជាប្រភពទីមួយដែលយើងត្រូវយកមកអនុវត្ត។

ខ្ញុំសូមលើកឡើងបន្តទៅមុខទៀត ប្រសិនបើលោកប្រធានយល់ព្រម ខ្ញុំសូមឆ្លើយតបទៅនឹងសំណួរទាក់ទងទៅនឹងសំណង។ ថាតើសំណងនោះ យើងអនុវត្តតាមរបៀបណាដែលកំណត់នៅក្នុងសាលក្រម។

[១២:០៤:២៤]

យើងខ្ញុំសូមលើកឡើងថា ខ្ញុំមិនចង់និយាយឡើងវិញទេ នូវអ្វីដែលយើងខ្ញុំបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខ និងនៅក្នុងថ្ងៃនេះរួចទៅហើយ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា សំណើរបស់ខ្ញុំ យើងខ្ញុំទាំងអស់បានបញ្ជាក់យ៉ាងជាក់លាក់ ហើយមានភាពចាំបាច់ ហើយអាចអនុវត្តទៅបាន។

ចំពោះការស្នើរបស់អ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសំណើរបស់យើងខ្ញុំ គឺមិនតម្រូវឲ្យយក ឲ្យដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកអនុវត្តនោះទេ។

យើងស្នើសុំតុលាការកំពូលឲ្យធ្វើការពិចារណាទៅលើលទ្ធភាពថ្មីមួយ ហើយកុំយកយុត្តាធិការជាតិ និងបទពិសោធន៍ជាតិយកមកពិចារណា។ ដោយសារតែនៅអ.វ.ត.ក នេះ គឺជាវេទិកាថ្មីមួយ ដែលដោះស្រាយទៅលើសំណង។ ដូចដែលខ្ញុំបានលើកឡើង ឧទាហរណ៍ដែលស្រដៀងគ្នាបំផុតនោះ គឺវាទាក់ទងទៅនឹងតុលាការអន្តរអាមេរិកាំង ដោយសារតែនៅទីនោះ គេបានលើកឡើងអំពីដំណាក់កាលចំនួនពីរ ប៉ុន្តែគេលើកឡើងជាលក្ខណៈទូទៅ អំពីលក្ខណៈទូទៅនៃសេចក្តីសម្រេច។ អាចធ្វើការជួសជុលទៅលើព្យសនកម្ម និងការខូចខាតរបស់ជនរងគ្រោះ។

[១២:០៦:០៨]

ហេតុដូច្នេះ ខ្ញុំគិតថា ដូចដែលខ្ញុំបានគូសបញ្ជាក់ ខ្ញុំសូមលើកឡើងថា សំណើរបស់យើងខ្ញុំអាចអនុវត្តទៅបាន ហើយមានលក្ខណៈជាក់លាក់។

ហើយចំពោះការសុំអនុញ្ញាត ឧទាហរណ៍ថា ការសុំអនុញ្ញាតពីកម្មសិទ្ធិករនៃដីធ្លីនោះ ខ្ញុំយល់ឃើញថា ចំពោះមតិខ្ញុំផ្ទាល់រដ្ឋាភិបាលមានកាតព្វកិច្ច និងភារកិច្ចចំពោះប្រជាពលរដ្ឋក្នុងការជួយជ្រោមជ្រែងលើករណីនេះ។ ហើយវាមិនមែនជាវិធីសាស្រ្តមួយដាក់បន្ទុកទៅដល់រដ្ឋាភិបាលនោះទេ គ្រាន់តែឲ្យរដ្ឋាភិបាលជួយទៅដល់ជនរងគ្រោះនៅក្នុងលក្ខណៈជារដ្ឋ។

ចម្លើយតបរបស់ខ្ញុំទៅនឹងសំណួររបស់ខ្ញុំ គឺមានតែប៉ុណ្ណឹងឯង។

[១២:០៧:២០]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណលោកស្រីមេធាវី។

**លោក ខារីម ខាន៖**

លោកប្រធាន សូមអនុញ្ញាត។ ខ្ញុំសូមលើកឡើងពាក់ព័ន្ធទៅនឹងសំណួររបស់លោកស្រីចៅក្រម មីឡាត ចំពោះបទដ្ឋានដែលកំណត់ឡើងដោយអង្គបុរេជំនុំជម្រះ ទាក់ទងទៅនឹងលក្ខខណ្ឌនៃចំណងជិតស្និទ្ធ និងការស្ថិតនៅក្នុងបន្ទុក។

យើងដឹងហើយថា វាជាបញ្ហាមួយដែលយើងគួរតែពិចារណា។ ប៉ុន្តែយើងខ្ញុំសូមបង្ហាញជំហរថា លក្ខខណ្ឌដែលបានកំណត់នោះ គឺមិនមានការគាំទ្រណាមួយពីយុត្តាធិការរបស់តុលាការអន្តរជាតិនៅក្នុងលូប៉ែងហ្គា ករណី លូប៉ែងហ្គា តុលាការអន្តរជាតិបានធ្វើការបកស្រាយមួយលក្ខណៈទូលំទូលាយទៅលើសញ្ញាណនៃគ្រួសារ។

[១២:០៨:១៩]

អ្វីដែលអង្គបុរេជំនុំជម្រះបានធ្វើឡើងនៅក្នុងការដកចេញបញ្ជាក់អំពីទស្សនទាននៃទំនាក់ទំនងនៃសេចក្តីស្រឡាញ់ជិតស្និទ្ធ និងភាពក្នុងបន្ទុកនោះ យើងឃើញថា យើងត្រូវតែយកមកបកស្រាយក្នុងវប្បធម៌កម្ពុជា។ យើងឃើញហើយនៅក្នុងករណីចំនួនពីរ ដែលពាក់ព័ន្ធទៅនឹងចំណងនៃសេចក្តីស្រឡាញ់ពិសេសនោះ ដែលវាតម្រូវថា ជនរងគ្រោះដោយមិនផ្ទាល់នោះ រស់នៅជាមួយនឹងជនរងគ្រោះ។

ខ្ញុំសូមលើកឡើងនៅកថាខណ្ឌ២៨ នៃសារណារបស់យើងខ្ញុំ លេខជើងទំព័រលេខ៤៤ ដែលនៅក្នុងសាលក្រមរបស់សាលាដំបូងលើកឡើងអំពី តូច មុន្និន ដែលគាត់បាត់បង់បងប្អូនជីដូនមួយរបស់គាត់។

[១២:០៩:១៦]

ដូច្នេះ នៅពេលដែលយើងមើលលើករណីដើមបណ្តឹងរដ្ឋប្បវេណី គឺវាមានលក្ខណៈកម្រិត ហើយ

យើងត្រូវបកស្រាយក្នុងលក្ខណៈប្រទេសកម្ពុជា។ ដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ដែលខ្ញុំតំណាង ជេហ្វ្រើ ចេមស៍ និង រ៉ូនាល គឺជាអ្នកដែលរស់រានមានជីវិត គឺជាសាច់ញាតិ ដែលរស់រានមានជីវិតដែលពូរបស់ខ្លួនស្លាប់ និងទទួលមរណភាព ហើយភស្តុតាងរបស់អ្នកទាំងពីរបានបង្ហាញអំពីទំនាក់ទំនងជិតស្និទ្ធរវាងពួកគេ។

ហើយដូច្នេះ នៅពេលដែលយើងពិចារណាទៅលើបទដ្ឋាន ថាតើបទដ្ឋាននេះអនុវត្តយ៉ាងម៉េចនៅក្នុងសាលក្រម? យើងខ្ញុំសូមបញ្ជាក់ថា បទដ្ឋាននោះមិនបានពិនិត្យឲ្យបានហ្មត់ចត់ និងពេញលេញអនុលោមទៅតាមច្បាប់នោះឡើយ ហើយវាបានយកមកអនុវត្តដោយមិនមានការពិចារណាអំពីម៉ូវ៉េ ទំនៀមទម្លាប់ ឬក៏វប្បធម៌នោះឡើយ។ ជាពិសេសចំពោះដើមបណ្តឹងរដ្ឋប្បវេណីពីររូបដែលជាជនជាតិអាមេរិកដែលខ្ញុំតំណាងនោះ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចសម្រាក និងចូលមកវិញនៅវេលាម៉ោងមួយសាមសិបនាទី ហើយបង្គាប់ឲ្យមន្ត្រីពន្ធនាគារនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង ហើយនាំមកវិញ នៅវេលាម៉ោងមួយសាមសិបនាទី។

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោយឈរ!

*(សវនាការសម្រាកពីម៉ោង១២:១១នាទី ដល់ម៉ោង ១៣:៣៥នាទី)*

[១៣:៣៥:០០]

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

បាទ, អង្គតុលាការជំនុំជម្រះតុលាការប្រកាសបន្តសវនាការ។ ជាបន្ទាប់ទៅនេះជាសារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣។ ខ្ញុំសូមជម្រាបផងដែរ ចំពោះសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ គឺពីម្សិលមិញខ្ញុំក៏បានទទួលនូវសារណាបន្ថែមស្តីពីសំណងមួយច្បាប់ដែរ ហើយដែលបន្ថែមមកតុលាការកំពូល ហើយយើងខ្ញុំបានទទួលនូវសារណានេះ ហើយនឹងដាក់បញ្ចូលទៅក្នុងឧបសម្ព័ន្ធ ហើយដើម្បីធ្វើការពិចារណា។ ដូច្នេះ សូមអញ្ជើញលោកសហមេធាវីធ្វើសារណាស្តីពីបណ្តឹងសាទុក្ខ។

បាទ, សូមអញ្ជើញ!

[១៣:៣៧:១៨]

**លោកស្រី ម៉ុច សុវណ្ណារីៈ**

សូមអរគុណឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ នាងខ្ញុំសូមសម្តែងការគោរពជាដំបូងដល់ឯកឧត្តមប្រធាន និងលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូលនៅទីនេះ។

នាងខ្ញុំមេធាវី ម៉ុច សុវណ្ណារី ជាមេធាវីជាតិម្នាក់តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុម៣ ជាមួយនិងសហភាតារបស់នាងខ្ញុំ លោកមេធាវី គីម ម៉េងឃី និងមេធាវីបរទេសលោកស្រី ម៉ាទីន ហ្សាកកាំង និងលោកមេធាវី ហ្វីលីព កាណុន។ នៅពេលនេះខ្ញុំនឹងនិយាយធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ទាក់ទងទៅនឹងបណ្តឹងសាទុក្ខរបស់កូនក្តីខ្ញុំ ដោយមានការបែងចែកគ្នា។

នាងខ្ញុំនឹងនិយាយតែសង្កត់ធ្ងន់តែទៅលើចំណុចនៃបណ្តឹងសាទុក្ខ ដែលទាក់ទងជាមួយនឹងការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានប្រកាសដកឋានៈជាដើមបណ្តឹងរបស់កូនក្តីនាងខ្ញុំចំនួនប្រាំបីនាក់ ហើយនាងខ្ញុំនិងផ្ទេរផ្នែកដទៃទៀតនៃបណ្តឹងសាទុក្ខនេះទៅសហភាតារបស់នាងខ្ញុំនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបន្ត។

[១៣:៣៨:២៣]

នាងខ្ញុំមកដល់នេះ នៅពេលដែលនាងខ្ញុំបានសម្លឹងទៅលើមុខកូនក្តីរបស់នាងខ្ញុំ ខ្ញុំបានទទួលនូវស្នាមញញឹមរបស់គាត់ ហើយពេលនោះខ្ញុំទទួលបានអារម្មណ៍មួយថា គាត់ប្រាប់ខ្ញុំថា "លោកស្រីមេធាវីសូមពាំនាំសំឡេងរបស់ខ្ញុំទៅដល់អង្គជំនុំជម្រះសាលាដំបូងផង"។ ដូច្នេះ មុនពេលដែលនាងខ្ញុំធ្វើការវិភាគលម្អិតទៅលើសំណុំរឿងនីមួយៗរបស់កូនក្តី ការវ័ន្តច្រឡំដែលសាលក្រមដោយអង្គជំនុំជម្រះរបស់សាលាដំបូងបានធ្វើ នាងខ្ញុំសូមជម្រាបជូនដល់អង្គជំនុំជម្រះតុលាការ ក៏ដូចជាសាធារណជនដែលកំពុងតែមានវត្តមានទីនេះទាំងអស់ថា ទាំងអស់គ្នាសុទ្ធតែបានឃើញនូវវត្តមានរបស់ពួកគាត់ដែលជាអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាជនរងគ្រោះ។ ពេលនេះពួកគាត់នៅទីនេះ តើប៉ុន្មាននាក់ បានដឹងថាពួកគាត់ត្រូវតស៊ូយ៉ាងណា? ហើយពួកគាត់ត្រូវជម្នះគ្រប់ឧបសគ្គប៉ុន្មានដង? ប៉ុន្មានវគ្គ? នៅក្នុងការបំបែកការស្មៀមស្ងាត់នូវឧក្រិដ្ឋកម្មដែលបានធ្វើទៅលើរូបគាត់ផ្ទាល់ ក៏ដូចជាសាច់ញាតិជាទីស្រឡាញ់របស់គាត់ដែលបានកើតឡើងរយៈពេលជាង៣០ឆ្នាំនេះ នៅក្នុងមន្ទីរសន្តិសុខស-២១ របស់ខ្មែរក្រហម។

ហើយថាតើគាត់ត្រូវការសេចក្តីក្លាហានប៉ុនណា នៅក្នុងការឈរនៅទីនេះ នៅថ្ងៃនេះ ប្រឈរមុខជាមួយនឹងតុលាការនេះ? ដើម្បីចូលរួមចំណែកស្វែងរកការពិតនូវអ្វីដែលបានកើតឡើងនៅសម័យនោះ។

[១៣:៣៩:៤៦]

នាងខ្ញុំសូមជម្រាបជូនផងដែរថា នៅក្នុងរបបខ្មែរក្រហម នៅពេលដែលមនុស្សស្ទើរតែទូទាំងពិភពលោកគេរីករាយជាមួយនឹងសេរី គេរីករាយជាមួយនឹងសេចក្តីសុខសាន្ត គេទទួលនូវការគោរពពីអ្នកឯទៀត និងការជួបជុំជាមួយនឹងគ្រួសារ និងសាច់ញាតិជាទីស្រឡាញ់របស់ពួកគេ។ ប្រជាជនខ្មែរទូទាំងប្រទេសត្រូវទទួលរងទុក្ខដោយរបបគ្រប់គ្រងដោយគ្មានមនុស្សធម៌។ ដើមបណ្តឹងសាទុក្ខដែលមានវត្តមាននៅទីនេះ ត្រូវទទួលរងទុក្ខដោយផ្ទាល់ដោយការធ្វើទុក្ខបុកម្នេញ ដោយការធ្វើទារុណកម្ម ដោយការកាប់សម្លាប់ ហើយសាច់ញាតិរបស់ពួកគេមួយចំនួនត្រូវបានធ្វើទារុណកម្ម និងកាប់សម្លាប់នៅមន្ទីរសន្តិសុខស-២១ របស់របបខ្មែរក្រហម។ ហើយនៅពេលនេះជាថ្មីម្តងទៀត នៅពេលដែលមនុស្សជាទូទៅគេខំប្រឹងប្រែងស្ថិតស្ថាញនូវក្នុងការរស់នៅរបស់ពួក ចិញ្ចឹមបីបាច់ថែរក្សាកូនរបស់ពួកគេ រកស៊ីប្រកបរបបរបស់ពួកគេ តែពួកគាត់បែរជាដើរត្រឡប់ទៅអតីតកាលដ៏ឈឺចាប់ ដោយពួកធ្វើបែបនេះនៅក្នុងគោលបំណង គឺចង់ចូលរួមចំណែកនៅក្នុងការបំបែកភាពស្ងៀមស្ងាត់ ស្វែងរកការពិតជាមួយនឹងតុលាការ ហើយនិងស្វែងរកយុត្តិធម៌សម្រាប់សាច់ញាតិជាទីស្រឡាញ់របស់ពួកគាត់។

[១៣:៤០:៥៦]

នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យពួកគាត់ដាក់ភស្តុតាងបន្ថែម ដើម្បីនឹងគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ ដែលការតម្រូវនេះវាហួសអំពីស្តង់ដារនៃភស្តុតាងដែលបានកំណត់ដោយវិធានទាំងឡាយ ដែលអាចមានប្រសិទ្ធភាពអនុវត្តនៅចំពោះមុខតុលាការនេះ។ ពួកគាត់ត្រូវបោះជំហានសាជាថ្មី ចូលទៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ពួកគាត់ត្រូវចូលពីក្លោងទ្វារសារមន្ទីរទាំងអស់នោះ ពួកគាត់ត្រូវចូលទៅក្នុងអគារនីមួយៗពិនិត្យមើលពីរូបថតមួយ ពីរូបថតមួយទោះបីជារូបថតនោះមិនមានអត្តសញ្ញាណ តែពួកគាត់ត្រូវពិនិត្យយ៉ាងពិច័យ។ មើលរូបថតមួយទៅរូបថតមួយ ពីក្តារខៀនមួយទៅក្តារខៀននៃសារមន្ទីរនោះ ពីអគារមួយទៅអគារមួយ។ តើយើងអាចទទួលបានអារម្មណ៍នូវការឈឺចាប់ និងការតក់ស្លុតថា តើពួកគាត់ទទួលរងប៉ុនណា? ថាតើវាបានវាយលុក វាយប្រហារផ្លូវចិត្តរបស់គាត់ប៉ុនណា នៅពេលដែលពួកគាត់ត្រឡប់ទៅកន្លែងដែលតក់ស្លុតនោះឡើងវិញ ដើម្បីស្វែងរកភស្តុតាងបន្ថែមទាំងអស់នេះ? ហើយខ្ញុំសូមជម្រាបជូនបន្តទៀតថា ទោះបីជា

មានអ្នកខ្លះក្នុងចំណោមពួកគាត់មិនអាចរកឃើញនូវភស្តុតាង ដែលបញ្ជាក់ថាសាច់ញាតិជាទីស្រឡាញ់របស់ពួកគាត់ត្រូវបានចាប់ខ្លួន និងធ្វើទារុណកម្មសម្លាប់នៅទីនោះក៏ដោយ តែពួកគាត់នៅតែមិនបោះបង់ចោល។ ពីព្រោះពួកគាត់ដឹងថា អ្វីដែលគាត់ធ្វើគឺចូលរួមចំណែកនៅក្នុងការស្វែងរកការពិត ហើយមានសារៈតម្លៃ។

[១៣:៤២:២០]

ហើយនាងខ្ញុំសូមជម្រាបទៀតថា ប្រសិនបើយើងមើលកម្លាំងរបស់ពួកគាត់ គាត់គ្មានកម្លាំងនៅក្នុងការធ្វើការអស់ទាំងនេះទេ តែអ្វីដែលជំរុញឲ្យគាត់គឺកម្លាំងចិត្តខាងក្នុងរបស់គាត់ ហើយនិងជំនឿចិត្តដែលមានចំពោះតុលាការនេះថា តុលាការនេះអាចផ្តល់យុត្តិធម៌ឲ្យគាត់។ ហើយខ្ញុំសូមជម្រាបជូនបន្ថែមទៀតថា ពួកគាត់គឺជាមនុស្សដែលមានតម្លៃបំផុតសម្រាប់សង្គមខ្មែរនេះ ហើយសម្រាប់ពិភពលោកទាំងមូល ហើយពួកគាត់គឺជាភស្តុតាងដ៏រស់និងពិតប្រាកដ។ ហើយព័ត៌មានដែលពួកគាត់បានផ្តល់ឲ្យ គឺជាភស្តុតាងដ៏រស់ ហើយពិតប្រាកដនឹងអាចជឿជាក់បាន។ នេះគឺជាសារសំខាន់នូវវត្តមានរបស់ពួកគាត់នៅក្នុងដំណើរការក្តីព្រហ្មទណ្ឌនេះ។

[១៣:៤២:៥៧]

នាងខ្ញុំសូមកត់សម្គាល់ទៀតអំពីការលំបាកទាំងឡាយដែលពួកគាត់ជួបប្រទះនៅក្នុងការស្វែងរកភស្តុតាងដែលតម្រូវដោយមិនត្រឹមត្រូវនេះ។ យើងគួរកត់សម្គាល់ឃើញថាឯកសារទាំងឡាយនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងមិនមែនជាឯកសារដែលពេញលេញឡើយ មានឯកសារជាច្រើនត្រូវបានបំផ្លាញចោលមុនរបបនេះដួលរលំ ហើយនិងមានការបាត់បង់ជាច្រើនទៀត។ ទោះបីជាឯកសារទាំងអស់នេះ គឺជាមូលដ្ឋានចម្បងមួយដែលធ្វើឲ្យសហការិយាល័យសហព្រះរាជអាជ្ញា គាត់អាចនឹងចងក្រងនូវបញ្ជីអ្នកទោសមួយក៏គាត់ទទួលស្គាល់ខ្លួនឯងថា បញ្ជីឈ្មោះនោះមិនពេញលេញលក្ខណៈឡើយ។ ហើយនិងយើងត្រូវពិនិត្យទៅមើលស្ថានភាព ប្រវត្តិសាស្ត្រ វប្បធម៌ ចំណេះដឹងរបស់ជនរងគ្រោះនៅក្នុងការដែលគាត់យល់ដឹងថា តើឯកសារដែលត្រូវមានហ្នឹង វាមានសារៈសំខាន់ប៉ុនណាសម្រាប់ដំណើរការក្តីនេះ? ដូច្នេះ នាងស្នើសុំឲ្យតុលាការពិចារណាអំពីការលំបាកទាំងឡាយរបស់ពួកគាត់នូវក្នុងការស្វែងរកភស្តុតាងនេះ។

[១៣:៤៣:៥៥]

ជាបន្តទៅទៀតនេះ ខ្ញុំនឹងចូលទៅដល់ការវិភាគនៃសំណុំរឿងនីមួយៗ។ ខ្ញុំនិយាយនៅពេលនេះ

សម្រាប់កូនក្តីដែលមានឈ្មោះថា ឡាយ ចាន់ គាត់បានអះអាងថា គាត់គឺជាជនរងគ្រោះដែលគាត់រស់រានមានជីវិតពីមន្ទីរសន្តិសុខស-២១។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា "គេជឿ ពួកគាត់ជឿថា លោក ឡាយ ចាន់ ត្រូវបានគេចាប់ខ្លួន ហើយនិងឃុំខ្លួន" ក៏ប៉ុន្តែ ពួកគាត់បានអះអាងថា មិនមានភស្តុតាងណាមួយបញ្ជាក់ថា លោក ឡាយ ចាន់ ត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ឡើយ។ ហេតុដូច្នេះហើយ គាត់មិនបានបោះបង់ចោលទេ ហើយគាត់បានស្វែងរកភស្តុតាងបន្ថែមទៀត ដែលក្រុមមេធាវីរបស់យើងខ្ញុំបានដាក់ឯកសារនោះរួចទៅហើយទៅដល់អង្គជំនុំជម្រះតុលាការកំពូល ហើយអង្គជំនុំជម្រះនេះក៏បានទទួលស្គាល់ដែរ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានបញ្ចាំងនូវរូបថតមួយ ទាក់ទងទៅនឹងសំណុំរឿងរបស់គាត់ គឺរូបថត F2/1.7 ដែលបង្ហាញអំពីថា ពិតជាមានបន្ទប់ឃុំឃាំងនៅក្រោមជណ្តើរពិតប្រាកដមែន។ នេះគឺជារូបថតបន្ទប់តូចមួយនៅក្រោមជណ្តើរដែលយើងថតចេញពីសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។

រូបនេះ គឺត្រូវត្រឡប់មកខាងឆ្វេងវិញ ដើម្បីដឹងថា ពីលើទៅក្រោម។

ដូច្នេះ នាងខ្ញុំសូមដាក់ឯកសារនេះឲ្យតុលាការដើម្បីធ្វើការពិចារណាថា ឯកសារនេះនឹងគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់។

[១៣:៤៥:១៩]

បន្តមកទៀត នាងខ្ញុំសូមចូលទៅដល់ជនរងគ្រោះឈ្មោះ ភោគ ខន ដែលគាត់ក៏បានអះអាងថា គាត់គឺជាជនដែលរស់រានមានជីវិតពីមន្ទីរស-២១ ដែរ ក៏ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានបដិសេធគាត់ដោយគិតថា គាត់គ្មានភស្តុតាងនៅមន្ទីរស-២១។ ដូច្នេះ នាងខ្ញុំក៏បានដាក់នូវឯកសារភស្តុតាងបន្ថែមទាក់ទងជាមួយនឹងភរិយារបស់គាត់ឈ្មោះ ពិន លាភ ឬក៏ ទិន លាភ ដែលគាត់បានអះអាងថាបានស្លាប់នៅមន្ទីរស-២១ ដែលគាត់ទើបតែរកឃើញ។ នាងខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីបញ្ចាំងនូវឯកសារដែលមានលេខកូដ F2/1.5។

នាងខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារដែលមានលេខ F2/1.5 ដែលឯកសារនេះ គឺរូបថតរបស់ភរិយារបស់លោក ភោគ ខន ដែលលោកបានអះអាងថា ត្រូវបានសម្លាប់នៅមន្ទីរស-២១។

ហើយមួយទៀត គឺ F2/1.6 នេះគឺជារូប *ហ្វូម* ចេញពីរូបថតលើជញ្ជាំងអម្បាញ់មិញ។

យើងមើលឃើញថា រូបថតទាំងអស់នេះ គឺវាអត់មានអត្តសញ្ញាណទេ ក៏ប៉ុន្តែខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថា មានរូបថតច្រើនណាស់បន្សល់ទុកនៅលើជញ្ជាំងនៃសារមន្ទីរជាតិទួលស្លែងនេះ ដែល

មានអត្តសញ្ញាណ គ្មានឈ្មោះ គ្មានលេខកូដអ្វីទាំងអស់។ ក៏ប៉ុន្តែ តាមរយៈរូបថតដំបូង ដែលនាងខ្ញុំបានបង្ហាញយើងឃើញថា រូបថតនេះពិតជាបានដកស្រង់ចេញពីជញ្ជាំងនៃមន្ទីរ ជញ្ជាំងនានាដែលមាននៅក្នុងអគារសារមន្ទីរប្រល័យពូជសាសន៍មែន។

[១៣:៤៧:១៣]

ហើយនាងខ្ញុំសូមអនុញ្ញាតបញ្ចាំងភស្តុតាងមួយទៀត ទាក់ទងជាមួយនឹងការស្លាប់របស់ឪពុកមារបស់គាត់ និងភរិយារបស់លោក ភោគ ខន។ សូមបញ្ចាំងឯកសារលេខ F2/1.1 បន្តទៀត F2/1.2 ។ F2/1.2 នេះគឺជារូបថតម្តាយមីងរបស់លោក ភោគ ខន។ បន្ទាប់មកទៀត F2/1.3 នេះគឺជារូបថតឪពុកមាបង្កើតរបស់លោក ភោគ ខន។

សូមបញ្ចាំងរូបថតមួយទៀត F2/1.4 នេះជារូប *ហ្គូម* ចេញពីក្តារខៀនដែលមាននៅក្នុងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។ ដូច្នេះ នាងខ្ញុំសូមដាក់ភស្តុតាងទាំងអស់នេះដល់អង្គជំនុំជម្រះ ដើម្បីពិចារណាគាំទ្រដល់ពាក្យសុំរបស់គាត់។

[១៣:៤៨:២២]

នាងខ្ញុំសូមបន្ត ចូលជាមួយនឹងសំណុំរឿងរបស់លោកស្រី សូ សូង។ លោកស្រីបានដាក់អំពីភស្តុតាងទាក់ទងជាមួយនឹងឪពុកមារបស់លោកស្រី ដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខស-២១ ក៏ប៉ុន្តែចៅក្រមសាលាដំបូងបានបដិសេធថា ភស្តុតាងនេះមិនមានអត្តសញ្ញាណ រូបថតនេះមិនមានអត្ត-សញ្ញាណមិនអាចទទួលយកបាន។ មិនតែប៉ុណ្ណោះ គាត់បានដាក់ភស្តុតាងបញ្ជាក់អំពីចំណងញាតិជាមួយនឹងឪពុកមារបស់គាត់ តែអង្គជំនុំជម្រះសាលាដំបូងបានបដិសេធទៀត។

ហេតុដូច្នេះហើយ អ្វីដែលខ្ញុំបានចង់ជម្រាបជូនអង្គជំនុំជម្រះនៅពេលនេះថា មានរូបថតច្រើនណាស់ដែលមិនអាចកំណត់អត្តសញ្ញាណបាន តែយើងមិនអាចនិយាយថា ពួកគេមិនបានរងគ្រោះនៅទីនោះ នោះទេ។ ដូចជារូបថតដែលបានបង្ហាញអម្បាញ់មិញនេះជាដើម។

[១៣:៤៩:០៦]

ហើយមួយទៀត ចៅក្រមសាលាដំបូងបានបកស្រាយភ័ន្តច្រឡំទាក់ទងជាមួយនឹងសញ្ញាណនៃសាច់ញាតិ ចំណងនៃសេចក្តីស្រឡាញ់ពិសេស។ ខ្ញុំសូមរំឭកឡើងវិញថា ពាក្យថាគ្រួសារនៅក្នុងសង្គមកម្ពុជា គឺមានអត្ថន័យទូលំទូលាយ វារាប់បញ្ចូលទាំងម្តាយមីង ទាំងគ្រប់គ្នា ពីព្រោះថា នៅក្នុងប្រទេសកម្ពុជា ភាគច្រើនប្រជាជនគឺរស់នៅជុំគ្នាច្រើននៅដំបូលតែមួយ គ្រួសារជាទ្រង់ទ្រាយធំ។

ខ្ញុំចង់ទាញចំណាប់អារម្មណ៍របស់តុលាការ ដើម្បីមើលនៅក្នុងប្រតិចារឹកមួយដែលជាសម្ដីរបស់អ្នកជំនាញចិត្តសាស្ត្ររបស់លោកវិជ្ជបណ្ឌិតចិត្តសាស្ត្រ ឈឹម សុធារ៉ា។ នៅក្នុងប្រតិចារឹកចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ត្រង់ទំព័រទី៣៧ និង៣៨ គាត់បានឲ្យអត្ថន័យយ៉ាងជ្រៅទាក់ទងនឹង-- យ៉ាងទូលំទូលាយទាក់ទងនឹងគ្រួសារ ទាក់ទងជាមួយនឹងការឈឺចាប់ដែលកើតចេញពីចំណងដ៏ពិសេសនេះ ហើយដែលក្នុងរាប់មានទាំងបងថ្លៃ ប្អូនថ្លៃ ជាមួយគ្នា ដូចគ្នាដែរ។ ហើយនាងខ្ញុំសូមបញ្ជាក់ថា តើមានពាក្យសម្ដីណាដែលគួរឲ្យជឿជាងពាក្យសម្ដីរបស់អ្នកជំនាញចិត្តសាស្ត្រ ដែលគាត់និយាយពីអទិភាពនៃការឈឺចាប់ដ៏ពិតប្រាកដនេះ? តើមានពាក្យសម្ដីណាគួរឲ្យជឿក្នុងការនិយមន័យពីសញ្ញាណនៃគ្រួសារ និង សាច់ញាតិ ច្រើនជាងជនជាតិខ្មែរដែលរស់នៅក្នុងបរិបទនៃសង្គមនេះ?

[១៣:៥០:២៥]

អ៊ីចឹងដូច្នេះ នាងខ្ញុំសូមស្នើសុំតុលាការពិចារណាឡើងវិញនូវការភ័ន្តច្រឡំទាំងឡាយនៅក្នុងការពិនិត្យភស្តុតាង ដែលអង្គជំនុំជម្រះសាលាដំបូងទាក់ទងជាមួយនឹងកូនក្ដីម្នាក់នេះ។ ហើយអំណះអំណាងដូចគ្នាទាក់ទងនឹងចំណងសាច់ញាតិនេះដែរ នាងខ្ញុំសូមស្នើសុំឲ្យមានការអនុវត្តអំណះអំណាងដូចគ្នាជាមួយនឹងកូនក្ដីដែលមានឈ្មោះ សឹម ពៅ គាត់បានប្ដឹងដោយសារតែប្អូនថ្លៃ បងថ្លៃរបស់គាត់ត្រូវបានសម្លាប់នៅស-២១ ដែរ។ ហើយនាងខ្ញុំសូមបញ្ជាក់ថា សេចក្ដីពិតមួយដែលអ្នកទាំងអស់គ្នាត្រូវដឹង នៅពេលដែលប្រុសមួយរៀបការជាមួយនឹងនារីម្នាក់ គាត់ក្លាយជាសាច់ឈាមតែមួយ។ អ៊ីចឹង ពួកគាត់អ្នកម្នាក់ឈឺ ម្នាក់ទៀតក៏ឈឺ អ្នកណាម្នាក់សប្បាយ ម្នាក់ទៀតក៏សប្បាយ។ អ៊ីចឹង ក្នុងនាមយើងប្អូនរបស់បងស្រីម្នាក់ នៅពេលដែលគេទុក្ខបងថ្លៃរបស់យើង បងស្រីយើងក៏ឈឺ យើងក៏ឈឺដែរ។ ដូច្នេះ ការឈឺផ្លូវចិត្តនេះ គឺមានពិតប្រាកដមែន។

[១៣:៥១:១៥]

ទាក់ទងជាមួយនឹងកូនក្ដីឈ្មោះ ឃួន សារិន ខ្ញុំសូមទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះថា គាត់ត្រូវបានទទួលស្គាល់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ឈ្មោះរបស់គាត់ត្រូវបានដាក់ពេញលេញជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដីកាដំណោះស្រាយ ទំព័រទី១ នៃឯកសារD99។ ហើយម្យ៉ាងវិញទៀត នៅពេលសវនាការអង្គជំនុំជម្រះសាលាដំបូង មេធាវីការពារមិនបានជំទាស់ជាមួយនឹងពាក្យសុំរបស់គាត់ទេ ក៏ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង បែរជាលើកមកពិចារណា ហើយបដិសេធឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ទៅវិញ។ ដូច្នេះ នាងខ្ញុំសូមសំណូមពរអង្គជំនុំជម្រះពិចារណាឡើងវិញ ពី

ការភ័ន្តនេះ។

មួយទៀត ទាក់ទងជាមួយនឹងសំណុំរឿងរបស់លោកស្រី ចាន់ យឿង។ លោកស្រី ចាន់ យឿង បានដាក់ពាក្យបណ្ដឹងដោយសារការសម្លាប់ឪពុកមារបស់គាត់ ដែលឪពុកមារបស់គាត់គឺជាមេស្រុកដ៏ល្អម្នាក់នៅស្រុករវៀង ក្នុងខេត្តព្រះវិហារ។ គាត់គ្មានភស្តុតាងណាបញ្ជាក់ថា បានឃើញរូបថតឪពុករបស់គាត់នៅមន្ទីរស-២១។ នេះជាមូលហេតុដែលសាលក្រមបានបដិសេធគាត់។ ក៏ប៉ុន្តែ ខ្ញុំសូមជម្រាបជូនថាព័ត៌មានដែលគាត់បានផ្ដល់ឲ្យនោះ គឺគួរឲ្យជឿ គឺវាទាក់ទងជាមួយនឹងការបោសសម្អាតផ្ទៃក្នុង។

[១៣:៥២:២២]

ដូចគ្នាផងដែរ ជាមួយនឹងករណីរបស់អ្នកស្រី ប៉ាន់ ប៉ិច ហើយនិងករណីរបស់លោក ម៉ន សុធា ដែលពេលនោះ លោក ម៉ន សុធា បានអះអាងថាម្ដាយរបស់គាត់ជាមន្ត្រីរាជការម្នាក់ធ្វើការនៅស្ថានទូតហ្វីលីពីន ប្រចាំនៅប្រទេសកម្ពុជា។ គាត់ជាបញ្ញវន្តម្នាក់ នៅសម័យខ្មែរក្រហម ខ្មែរក្រហមបានជម្លៀសគាត់ចេញពីភ្នំពេញដល់ពាក់កណ្ដាលផ្លូវគាត់បានប្រកាសយ៉ាងឱឡារិកថា របបនេះជារបបដែលផ្ដាច់ការអមនុស្សធម៌ របបឃោរឃៅ គាត់មិនចុះចូលជាមួយនឹងរបបនោះទេ ខ្មែរក្រហមបានចាប់គាត់ ហើយយកគាត់ទៅសម្លាប់ចោលនៅមន្ទីរគុកទួលស្លែង។

[១៣:៥២:៥៧]

យើងទាំងអស់គ្នាសុទ្ធតែដឹងមន្ត្រីទូត បុគ្គលិកទូត សូម្បីតែមិនថានៅក្នុងប្រទេសខ្មែរ សូម្បីតែនៅប្រទេសខ្មែរក្រហមហៅមក ហើយយកមកសម្លាប់នៅគុកទួលស្លែងទាំងអស់។ ដូច្នេះ គ្រប់ព័ត៌មានដែលគាត់គឺសុទ្ធស៊ីសង្វាក់ទាំងអស់ជាមួយនឹងអង្គហេតុដែលតុលាការបានរកឃើញ ហើយនៅក្នុងសាលាក្រមរបស់តុលាការ តុលាការបានប្រកាសថ្វីត្បិតតែព័ត៌មានរបស់លោក ម៉ន សុធា ឲ្យហ្នឹង វាគួរឲ្យជឿមែន តែគ្មានភស្តុតាងជាឯកសារ។

ខ្ញុំសូមជម្រាបអង្គជំនុំជម្រះឡើងវិញថា មិនមានវិធានណាមួយនៃវិធានផ្ទៃក្នុងតម្រូវឲ្យយើងត្រូវតែដាក់ឯកសារភស្តុតាងៗជាឯកសារទំនើបទទួលយកបាននោះទេ។ នៅក្នុងរឿងព្រហ្មទណ្ឌភស្តុតាងគឺត្រូវដាក់ជូនដោយសេរី។

[១៣:៥៣:៣៤]

ដូច្នេះ ខ្ញុំសូមអង្គជំនុំជម្រះពិចារណាឡើងវិញ អំពីករណីទាំងអស់នេះ។ ដើម្បីបញ្ចប់ នាងខ្ញុំមានឯកសារថ្មីមួយដែលលោក ម៉ន សុធា គាត់ទើបឲ្យខ្ញុំព្រឹកមិញនេះ គឺជារូបថតរបស់ម្ដាយរបស់គាត់នៅ

មន្ទីរស-២១ ជាមួយនឹងលិខិតបញ្ជាក់របស់សាក្សីដែលបញ្ជាក់ថា គាត់មានចំណងញាតិជាមួយនឹងម្តាយរបស់គាត់ ហើយដែលខ្ញុំមិនពេលនៅក្នុងការបកប្រែ ព្រោះខ្ញុំទើបតែទទួលបាន ហើយខ្ញុំសូមស្នើសុំអង្គជំនុំជម្រះដើម្បីទទួលយកវានៅពេលនេះ ហើយដាក់បញ្ចាំងជាលើកចុងក្រោយ។ ប្រសិនបើ ខ្ញុំទទួលបានការអនុញ្ញាតពីលោកប្រធាន ខ្ញុំសូមឲ្យមានការបញ្ចាំងរូបទាំងអស់នេះ។ រូបថតមួយនេះ។

[១៣:៥៤:១២]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញដាក់មក។

លោកស្រីបើកមីក្រូហ្វូនផង។

**លោកស្រី ម៉ុច សុវណ្ណារី៖**

អរគុណលោកប្រធាន។ អ៊ីចឹងសូមឲ្យគាត់បញ្ចាំងឯកសារដើម រួចហើយខ្ញុំបានថតចម្លងឯកសារចម្លងចែកដល់ភាគីផ្សេងទៀត។ លោកប្រធានជាមួយនឹងការអនុញ្ញាតរបស់លោកប្រធាន នាងខ្ញុំសូមស្នើថា បើសិនជាមានការចំណាយពេលយូរ វាធ្វើខាតពេលនៅក្នុងធ្វើសេចក្តីសន្និដ្ឋានបន្ត នាងខ្ញុំសូមអនុញ្ញាតបញ្ចាំងវានៅក្រោយពេលដែលពួកខ្ញុំបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋាន។

**ប្រធានអង្គជំនុំ៖**

បើសិនជាអាចបញ្ចាំងមិនបានទេ ចាំយើងហ្វូតូទៅ ហើយយើងចែកទៅឲ្យខាងភាគីទៅ ហើយអ៊ីចឹងលោកស្រីបន្តទៅទៀតចុះ។

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស, អ៊ីចឹងខ្ញុំសូមអរគុណលោកប្រធាន។ អ្វីដែលខ្ញុំចង់និយាយជំនួសកូនក្តីរបស់ខ្ញុំនៅពេលនេះគឺចប់ត្រឹមហ្នឹង។ ហើយខ្ញុំសូមអរគុណ និងអង្គចៅក្រមទាំងអស់ដែលយកចិត្តទុកនៅក្នុងការស្តាប់ ហើយជាបន្តទៅទៀតនេះ នាងខ្ញុំសូមអញ្ញាតលោកប្រធានផ្ទេរវេទិកានេះ ជូនទៅដល់សហភាតារបស់នាងខ្ញុំ លោកមេធាវី គីម ម៉េងឃី ដើម្បីនឹងសេចក្តីសន្និដ្ឋានបន្ត ទាក់ទងជាមួយនឹងសំណួរដែលសួរទាក់ទងជាមួយនឹងទម្រង់ជាក់លាក់មួយនៃសំណង។ សូមអរគុណ។

[១៣:៥៦:៤៥]

**លោក គីម ម៉េងឃី៖**

សូមគោរពឯកឧត្តមប្រធាន សូមគោរពលោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល

និងអស់លោក លោកស្រីដែលមានវត្តមាននៅទីនេះទាំងអស់ ជាទីគោរព។

តាងនាមឲ្យមេធាវីក្រុម៣ ដែលនឹងតបតាមការអញ្ជើញរបស់តុលាការកំពូលដែលបង្គាប់ឲ្យក្រុមសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដាក់នូវសារណាបន្ថែម ប្រសិនបើមានពាក់ព័ន្ធទៅនឹងគម្រោងលម្អិតស្តីអំពីសំណង។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ សូមដាក់នូវសារណាបន្ថែមដែលមានលេខសម្គាល់ F25 ហើយនិងមានឧបសម្ព័ន្ធស្តីអំពីគម្រោងការណ៍លម្អិត ដែលរៀបចំដោយសមាគមជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ហៅកាត់ថា "សមាគមក្សេមក្សាន្ត" ជូនអង្គតុលាការកំពូលដើម្បីពិនិត្យពិចារណានិងសម្រេច។

[១៣:៥៧:៤៥]

នៅពាក់ព័ន្ធទៅនឹងចំណុចដែលក្រុមមេធាវីក្រុម៣ បានដាក់លើកជូននូវអង្គតុលាការកំពូលនេះ គឺដោយសារថា ទីមួយ ចំណុចពាក់ព័ន្ធទៅនឹងសំណងផ្លូវចិត្តដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ជូនចំពោះដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈមិនគ្រប់គ្រាន់ ដូចជា ការសរសេរឈ្មោះជនរងគ្រោះនៅលើនៅក្នុងសាលក្រម ហើយបង្ហោះលើអ៊ីនធឺណេត ការចងក្រងសេចក្តីសារភាព សូមអភ័យទោសរបស់ជនជាប់ចោទ ដែលជាបន្តបន្ទាប់មក ជនរងគ្រោះទាំងអស់យល់ឃើញថា ការសុំអភ័យទោសនេះ គឺជាការសុំអភ័យទោសមិនស្មោះត្រង់ ហើយការបង្ហោះឈ្មោះលើអ៊ីនធឺណេតនេះ គឺមិនអាចទទួលយកបានដោយជនរងគ្រោះ ដែលជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនតែម្តង។

[១៣:៥៨:៤១]

ជាសរុបមក គឺថាសំណងផ្លូវចិត្តនៅក្នុង-- នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺគ្មានន័យនិងស្មើនឹងសូន្យ។ លើសពីនេះ គឺថាពាក់ព័ន្ធទៅនឹងសំណងសមូហភាពក៏ដូច្នោះដែរ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលទាំងស្រុងនូវសំណើសុំរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុង។

កត្តាហេតុនេះហើយ យើងឃើញថាថ្វីត្បិតតែអង្គជំនុំជម្រះសាលាដំបូងបានរកឃើញពិរុទ្ធនៃជនជាប់ចោទក៏ដោយ ក៏ប៉ុន្តែការសះជាផ្លូវចិត្ត ឬក៏ការប៉ះប៉ូវសំណងណាមួយដល់ជនរងគ្រោះ គឺគ្មានទាល់តែសោះ។ បានន័យថា សំណងសមូហភាពគឺនៅកម្រិតក្រោមសូន្យទៅទៀត។

[១៣:៥៩:៣៦]

នៅក្នុងចំណុចនេះ ខ្ញុំសូមទាញចំណាប់អារម្មណ៍ចំពោះអង្គជំនុំជម្រះតុលាការមេត្តាជ្រាបថាសមាគមជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលហៅកាត់ថា "សមាគមក្សេមក្សាន្ត" គឺជា

សមាគមជនរងគ្រោះដែលបង្កើតឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០១ ហើយសមាគមនេះមានគោលបំណងនៅក្នុងការ-- ក៏បានចុះ (សុំទោស) សមាគមនេះក៏បានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ និងនៅចំពោះមុខអង្គជំនុំជម្រះនៃតុលាការកំពូល (សុំទោស) អង្គជំនុំជម្រះនៃសាលាក្តីខ្មែរក្រហមយើងនេះ ហើយសមាគមគឺថាបានរៀបចំដែលទាក់ទងទៅនឹងការសាងសងគ្រឹះស្ថានចារឹកឈ្មោះជនរងគ្រោះ ហើយដើម្បីពន្យល់អំពីគម្រោងពាក់ព័ន្ធរបស់សមាគមជនរងគ្រោះដោយរបបកម្ពុជាប្រជាធិបតេយ្យ ហៅកាត់ថា "សមាគមក្សេមក្សាន្តនេះ" ខ្ញុំសូមអនុញ្ញាតពីលោកប្រធានមេត្តាចាត់ឲ្យលោកមន្ត្រីតុលាការដើម្បីបញ្ចាំងរូបភាពមួយចំនួនដែលយើងខ្ញុំបានដាក់នៅក្នុងសារណារបស់យើងខ្ញុំរួចហើយ។

[១៤:០១:០៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអំមិញហ្នឹង ក្រែងយើងបញ្ចាំងអត់បានទេអី? អំមិញហ្នឹងក្រែងលោនៅក្នុងម៉ាស៊ីនហ្នឹងវាបញ្ចាំងអត់បាន ហើយបើមាននៅក្នុង-- ដែលមាននៅក្នុងកុំព្យូទ័រអត់អីទេ ប៉ុន្តែបញ្ចាំងក្រៅគឺបញ្ចាំងអត់បានទេ។ ដូច្នេះ សូមលោកធ្វើបន្តទៅ ហើយឯកសារជារូបថតហ្នឹងអាចធ្វើការហ្វូតូទៅដើម្បីចែកជូនខាងភាគី។

**លោក គីម ម៉េងឃី៖**

បាទ, សូមអរគុណលោកប្រធាន។ ពាក់ព័ន្ធទៅនឹងរូបភាពទីមួយ គឺសូមបើកនូវឯកសារ F25.1 ដែលមានលេខ ERN ជាភាសាខ្មែរ 00657059 និងឯកសារដដែល មានលេខ ERN ជាភាសាបារាំង 00656527។

បន្ទាប់មកទៀត គឺឯកសារទីពីរ គឺមានលេខ F25.1 ដដែល គឺ00657060 ERN ជាភាសាខ្មែរ និងលេខ 00656528 ERN ជាភាសាបារាំង។ ពាក់ព័ន្ធទៅនឹងគម្រោងនេះ ខ្ញុំបាទសូមជម្រាបជូនអង្គជំនុំជម្រះតុលាការកំពូលមេត្តាជ្រាបថា "សមាគមក្សេមក្សាន្ត" មិនបានជំទាស់ទៅនឹងសំណើ ឬក៏មិនបានទៅបដិសេធទៅលើសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងដែលបានលើកពីមុន ឬក៏លើកនៅពេលដែល នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ។ ក៏ប៉ុន្តែ ការលើកជាគម្រោងនេះ គឺក្នុងគោលបំណងដើម្បីរកមធ្យោបាយណាមួយធ្វើឲ្យគម្រោងនេះអាចសម្រេចទៅបាន ហើយនិងដើម្បីផ្សះផ្សានូវផ្លូវចិត្តដែលជនរងគ្រោះ ដែលជាសមាជិករបស់សមាគមនោះបានទទួលរង។

[១៤:០៣:៣៨]

ពាក់ព័ន្ធទៅនឹងគម្រោងនេះដែរ គឺថា “សមាគមក្សេមក្សាន្ត” បានស្នើសុំការដាក់គ្រឹះស្ថានចារឹកឈ្មោះនៃជនរងគ្រោះមន្ទីរស-២១ នៅក្នុងទីតាំងនៃបរិវេណនៃមន្ទីរទួលស្លែង។ ការសុំឲ្យដាក់នៅក្នុងមន្ទីរទួលស្លែងនេះ គឺមានពន្យល់នៅក្នុងសារណា និងឯកសារឧបសម្ព័ន្ធ ហើយគោលបំណងដែលសំខាន់បំផុត គឺជាការឆ្លាក់ឈ្មោះជនរងគ្រោះទាំងអស់ដែលចេញអំពីបញ្ជីនៃបញ្ជីចម្លើយសារភាព និងឈ្មោះរបស់ជនរងគ្រោះដែលនៅទីនោះ ដោយគ្មានការរើសអើង ដោយគ្មានការប្រកាន់ពូជសាសន៍ ដោយគ្មានប្រកាន់អំពីអតីតភាព ថាអ្នកនោះជាអតីតមេដឹកនាំខ្មែរក្រហម ឬក៏ជាជនរងគ្រោះ ឬក៏ជាប្រជាជនថ្នាក់មូលដ្ឋានឡើយ។

[១៤:០៤:២៧]

លើសពីនេះទៀត គឺថាគម្រោងដែលត្រូវបានដាក់ដោយ “សមាគមក្សេមក្សាន្ត”មានបញ្ជាក់អំពីប្លង់បច្ចេកទេស មានបញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទដែលអាចធ្វើបាន ហើយតាមការប៉ាន់ស្មានតម្លៃដែលធ្វើក៏មិនច្រើនដែរ គឺអាចប៉ាន់ស្មាននៅក្នុងចន្លោះពី ១០ម៉ឺនដុល្លារឡើងទៅ។ ហើយលើសពីនេះទៀត គឺថា “សមាគមក្សេមក្សាន្ត” បានទទួលការគាំទ្រនៅលើគម្រោងនេះ គឺដោយអង្គការយូនីស្កូទាក់ទងទៅនឹងការទុកដាក់កន្លែងចងចាំនៃពិភពលោក ហើយក៏មានការគាំទ្រអំពីគ្រប់មជ្ឈដ្ឋានទាំងអស់ទោះជាអង្គការក្រៅរដ្ឋាភិបាលក្តី ទោះជាជនរងគ្រោះក្តី ទោះស្ថាប័នឯកជនក្តី។

[១៤:០៥:២៦]

សរុបមក គឺថាគោលបំណងដែលសមាគមជនរងគ្រោះលើកឡើងនេះ ការធ្វើ និងការកសាងសង់នេះ គឺធ្វើយ៉ាងម៉េចដើម្បីឲ្យបាននូវសំណងមួយដែលអាចធ្វើទៅបាន ហើយសំណងនោះនឹងនាំមកនូវការផ្សះផ្សាជាតិ សំណងនោះនឹងនាំទៅដល់នូវការបង្ហាញដល់ក្មេងជំនាន់ក្រោយ មិនថាអ្នកនោះជាប្រជាជនខ្មែរ ឬក៏មនុស្សជាតិនៅក្នុងពិភពលោកនោះទេ។

អាស្រ័យហេតុនេះ តាំងនាមឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលឲ្យតំណាងកូនក្តីរបស់យើងខ្ញុំដែលជាសមាជិករបស់សមាគមផង និងតំណាងឲ្យផលប្រយោជន៍រួមនៃដើមបណ្តឹងរដ្ឋប្បវេណីផង។ សហមេធាវីក្រុម៣ សុំស្នើគោរពដល់អង្គជំនុំជម្រះតុលាការកំពូល មេត្តាទទួលយកគម្រោងនេះដើម្បីដាក់ចូលនៅក្នុងសេចក្តីសម្រេច ហើយនិងអាចធ្វើអន្តរាគមន៍ឲ្យគម្រោងនេះបានជោគជ័យទៅថ្ងៃអនាគត។

សូមអរគុណ។

**លោក ហ្វីលីព កាណុន៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម លោក និងលោកស្រីសហព្រះរាជអាជ្ញាជាទីគោរព សហភាតាទាំងអស់ជាទីគោរព។ ខ្ញុំឈ្មោះ ហ្វីលីព កាណុន អង្គជំនុំជម្រះតុលាកាតកំពូលជាទីគោរព ខ្ញុំនិយាយនេះដើម្បីការពារផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី។

[១៤:០៧:១៥]

បាទ, ខ្ញុំនឹងព្យាយាមមិននិយាយដដែលៗនូវអ្វីដែលបានលើកឡើងកាលពីព្រឹកមិញនេះទេ។ ប៉ុន្តែសូមតុលាការមេត្តាយល់ថា ជាការចាំបាច់ហើយនិងជាការមិនអាចចៀសរួចបាន គឺថានឹងមានការកាត់នូវសេចក្តីសង្កេតរបស់យើងរៀងៗខ្លួន។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើបណ្តឹងសាទុក្ខនេះ លោកស្រីចៅក្រម មីឡាត បានស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀតនូវការរំពឹងចង់បានរបស់ខ្លួន ហើយនឹងផ្តល់ជូននូវអង្គជំនុំជម្រះនូវគម្រោងសុំសំណងជាក់លាក់ ដូចដែលពួកគេចង់ឲ្យអង្គជំនុំជម្រះតុលាការកំពូលលដាក់បញ្ចូលគម្រោងនេះនៅក្នុងសាលដីកាលើបណ្តឹងសាទុក្ខ។

[១៤:០៨:១៣]

ពួកយើងទាំងអស់គ្នាបានបែងចែកភារកិច្ចគ្នាជានឹងសហភាតាកម្ពុជារបស់យើងខ្ញុំ គឺមេធាវី គឹម ម៉េងឃី គាត់ទើបតែបានលើកឡើងនូវរបៀបនៃសំណងដែលអាចធ្វើទៅបាន។ នៅពេលនេះតួនាទីរបស់ខ្ញុំ គឺចង់បញ្ជាក់ជូនអង្គជំនុំជម្រះតុលាការកំពូលនូវមូលហេតុដែលយើងខ្ញុំចង់ឲ្យមាននូវការទទួលស្គាល់សិទ្ធិពេញលេញនិងទាំងស្រុងរបស់យើងខ្ញុំទាំងអស់គ្នា។ ខ្ញុំក៏ត្រូវពន្យល់ជូនអង្គជំនុំជម្រះផងដែរថា តើហេតុអ្វីបានជាយើងខ្ញុំមានអារម្មណ៍ថាមិនអាចធ្វើអ្វីកើតនៅចំពោះមុខនីតិវិធីដែលកំពុងតែប្រព្រឹត្តទៅនៅចំពោះមុខតុលាការនេះ?

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំនឹងចាប់ផ្តើមដោយការកត់សម្គាល់មួយគឺថា អត្ថបទច្បាប់ដែលបង្កើត អ.វ.ត.ក មិនបានជួយយើងច្រើនអ្វីនោះទេ។ ហើយអត្ថបទនេះក៏មិនបានជួយអ្វីច្រើនទៅដល់ចៅក្រមនោះដែរ។ វិធាន២៣ នៃវិធានផ្ទៃក្នុងចែងអំពីគោលការណ៍ផ្តល់សំណងជាសមូហភាពនិងជានិមិត្តរូប។ វិធាននេះច្រានចោលនូវសំណងជាលក្ខណៈបុគ្គលនិងជាប្រាក់កាស។ យើងខ្ញុំយល់អំពីគោលការណ៍នេះ ហើយអ្នកណាក៏ដឹងអំពីគោលការណ៍នេះដែរ។

[១៤:១០:០០]

ប៉ុន្តែ នៅថ្ងៃនេះ គឺគេបានប្រាប់ឲ្យយើងខ្ញុំមានគំនិតច្នៃប្រឌិតដើម្បីរៀបចំនូវគម្រោងជាក់លាក់

មួយ។ យើងខ្ញុំពិតជាអាចមានគំនិតច្នៃប្រឌិតបាន។ យើងដឹងថាយើងត្រូវដើរតាមផ្លូវណា? ហើយយើងខ្ញុំថែមទាំងអាចបង្កើតនូវគម្រោងដែលមានមហិច្ឆតាខ្ពស់បានថែមទៀត ប៉ុន្តែមហិច្ឆតារបស់យើងគឺមានព្រំដែនកំហិតច្រើនណាស់។ តើយើងខ្ញុំមានមធ្យោបាយអ្វីខ្លះទៅ? ហើយថា តើអ្នកណានឹងទទួលបន្ទុកសម្រេចគម្រោងរបស់យើងទាំងអស់នោះទៅ? យើងមានសេចក្តីសង្ឃឹមយ៉ាងខ្លាំង ក៏ប៉ុន្តែយើងគ្មានអ្វីសោះក្រៅពីបាតដៃទទេ គឺទទេស្អាតតែម្តង។ ចំណែកឯចៅក្រមវិញ តើពួកគាត់អាចកំណត់អំពីទម្រង់នៃសំណងស្ពាពរយ៉ាងដូចម្តេចនៅក្នុងការតាក់តែងសេចក្តីសម្រេចរបស់ខ្លួន ដើម្បីឲ្យវាមានភាពច្នៃប្រឌិតខ្ពស់នោះ? ដូច្នេះ ចៅក្រមក៏មានព្រំដែនកំហិតដូចជាយើងជាមេធាវីដែរថា តើត្រូវតម្រូវឲ្យអ្នកណាជាអ្នកចេញសំណង?

[១៤:១១:៣២]

លោកប្រធាន លោកចៅក្រមទាំងអស់ គឺថាមិនមានបញ្ហាច្បាប់ដែលយើងមិនត្រូវលាក់បាំងនោះទេ។ គឺថាអត្ថបទបានកំណត់នូវក្រមខ័ណ្ឌជាទូទៅមួយ ប៉ុន្តែវាគឺជាក្របខ័ណ្ឌដែលទទេស្អាត។ គឺថា ខ្ញុំចង់រំឭកថា គឺមានភាពទទេស្អាតខាងផ្នែកគតិយុត្តិ ខាងផ្នែកច្បាប់។ គឺថាយើងត្រូវតែមានភាពប្រាកដនិយម យើងមិនត្រូវស្រមើស្រមៃនោះទេ។ ដូច្នេះ ខ្ញុំនឹងព្យាយាមយ៉ាងដាក់ខ្លួនក្នុងការកំណត់នូវផ្លូវបី--ផ្លូវដើរបីដែលអាចធ្វើទៅបាន។

[១៤:១២:១៧]

ផ្លូវទីមួយ គឺការសូមអភ័យទោស។ សាលាក្រមចុះថ្ងៃទី២៦ កក្កដា ២០១០ បានប្រកាន់យកនូវការកំណត់ប្រភេទនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ហើយកាលពីព្រឹកថ្ងៃចន្ទ នៅពេលបើកសវនាការនេះ ឯកឧត្តមប្រធានបានរំឭកអំពីបញ្ជីនៃបទឧក្រិដ្ឋដែលបានសម្រេចយក។ ហើយសហព្រះរាជអាជ្ញាបានបង្ហាញយ៉ាងច្បាស់ថា ជនរងគ្រោះមិនបានទទួលនូវការអាណិតអាសូរ ពួកគេបានទទួលរងនូវការធ្វើបាបយ៉ាងសាហាវឃោរឃៅ នៅខណៈដែលពួកគេគឺជាជនដែលងាយរងគ្រោះបំផុតនោះ។

នៅក្នុងលក្ខខណ្ឌទាំងអស់នេះហើយ សំណងទីមួយដែលយើងរំពឹងចង់បាននោះ គឺការសុំអភ័យទោស ហើយបន្ទាប់មកទៀតគឺប្រហែលជាការអភ័យទោសឲ្យជនជាប់ចោទ។

[១៤:១៣:៣២]

ខ្ញុំបានទន្ទឹងរង់ចាំនឹងសង្ឃឹមថា ជនជាប់ចោទនឹងថ្លែងនូវការអាណិតអាសូរសម្តីងមើល ស្រែកបង្ហាញការពិតនឹងទទួលស្គាល់នូវទំនួលខុសត្រូវរបស់ខ្លួន។ ទាំងអស់នេះហើយគឺអាចជាលក្ខខណ្ឌនៃ

ការផ្សះផ្សាជាតិ។ ប៉ុន្តែ មិនមានអ្វីកើតឡើងនោះទេ ខ្ញុំបានឮជនជាប់និយាយពាក្យទាំងអស់នេះតែប៉ុន្មានមាត់តែប៉ុណ្ណោះ។ ហើយបានការពារខ្លួននៅក្រោមលេសថា ខ្លួនមានការលំបាកខាងផ្នែកច្បាប់ដើម្បីទុកឲ្យមេធាវីការពារក្តីរបស់ខ្លួន ដោយមិនទាំងងាករកទៅមើលជន និងមិនទាំងសម្លឹងមើលជនរងគ្រោះផង។

បន្ទាប់មកទៀត ខ្ញុំបានឮគេនិយាយអំពីបញ្ហាបច្ចេកទេស គឺបញ្ហាច្បាប់សុទ្ធសាធហើយនិងបញ្ហាបកស្រាយវិធាននីតិវិធី។ ក៏ប៉ុន្តែ ខ្ញុំមិនដែលឮគេនិយាយអំពីបញ្ហាមនុស្សជាតិទាស់តែសោះ។ គ្មានអ្នកណាជឿតាមការបញ្ចុះបញ្ចូលរបស់មេធាវីការពារក្តីថា ឌុច គ្រាន់តែជាអ្នកអនុវត្តធម្មតានោះទេ។ ហើយការប៉ុនប៉ងរបស់មេធាវីការពារក្តីនេះ គឺមានភាពហួសហេតុពេក ប៉ុន្តែខ្ញុំចង់បាននូវការសោកស្តាយខ្លះៗគ្រាន់តែពាក្យសម្តីល្ងងលោមចុងមាត់ចុងក ដែលមេធាវីការពារក្តីបាននិយាយប្រាប់យើងខ្ញុំ គឺថាបានបញ្ជាក់យ៉ាងច្បាស់ថា ទោះបីជាចង់ក៏ដោយ ក៏មេធាវីការពារមិនអាចលាក់បាំងនូវអំពើសាហាវព្រៃផ្សៃដែលបានប្រព្រឹត្តនោះឡើយ។

[១៤:១៥:៣៤]

តាមផ្លូវច្បាប់ដែលហៅថាមេធាវីការពារក្តីនិយាយអំពីច្បាប់ គឺនៅទីនេះគឺវាត្រូវតែនិយាយអ៊ីចឹង។ អ្វីទាំងអស់នោះ គឺថាផ្តល់នូវគំនិតច្បាស់លាស់អំពីឋានៈដែលលោកមេធាវីការពារក្តីបានផ្តល់ទៅឲ្យជនរងគ្រោះនៅក្នុងសវនាការពិភាក្សាដេញដោល។ ក៏ប៉ុន្តែ ខ្ញុំបានឮជនជាប់ចោទនិយាយពាក្យសុំអភ័យទោសនៅពេលបើកសវនាការនៅអង្គជំនុំជម្រះតុលាការសាលាដំបូង។ គឺវាកន្លងហួសទៅយូរយារណាស់មកហើយ។ តើ ឌុច នៅឯណាឥឡូវនេះ សព្វថ្ងៃនេះ? ហើយតើ ឌុច វង្វេងវង្វាន់នៅក្នុងអន្លង់ជ្រៅណាមួយ? តើហេតុអ្វីបានជា ឌុច សម្រេចជ្រើសយក ជ្រើសរើសយក ឡូហ្សិក សម្លាប់ដល់ថ្នាក់ហ្នឹង? ការមិនទទួលស្គាល់ការពាក់ព័ន្ធរបស់ខ្លួនក្នុងឋានៈជាអ្នកទទួលខុសត្រូវខ្ពស់បំផុត បង្ហាញថា ឌុច ផ្តាច់នូវរាល់ទំនាក់ទំនងជាមួយជនរងគ្រោះ និងបញ្ជូនជនរងគ្រោះទៅរកភាពទទេស្អាត និងមរណភាពម្តងទៀត។

**លោក ការ សាវុត្ថ៖**

សូមគោរព អង្គសវនាការទាំងមូល មេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណី ពេលនេះមានសិទ្ធិត្រឹមតែពីរចំណុចទេ។ ទីមួយ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ទីពីរ ពាក់ព័ន្ធទៅនឹង អាន៉ែ គេហៅថាសំណងរដ្ឋប្បវេណី។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនអាចនិយាយពាក់ព័ន្ធអារឿងទោសកំហុសរបស់កូនក្តីខ្ញុំបានទេ។ ដូច្នេះ សូមឯកឧត្តមប្រធានមេត្តាជួយណែនាំ។ សូមអរគុណ។

**លោក កង ឫទ្ធារី៖**

ខ្ញុំសូមបន្ថែមបន្តិចសិនបាទ។ ដោយការយោគយល់គ្នាទៅវិញទៅមក ហើយថា ឧក្រិដ្ឋកម្មនេះ វាសាហាវព្រៃផ្សៃណាស់ ក៏ប៉ុន្តែសូមឲ្យលោកមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណី ប្រយ័ត្នសម្តីបន្តិច ទាក់ទងទៅនឹងការអុជអាលឲ្យមានកំដៅសង្គមនៅឯបរិយាយកាសខាងក្រៅ ហើយវាអាចកៀបសង្កត់នូវស្មារតីនៃចៅក្រមជំនុំជម្រះនៅទីនេះបាន។ ខ្ញុំក៏ដូចជាជនរងគ្រោះដទៃទៀតដែរ ខ្ញុំក៏ជាជនរងគ្រោះនៃរបបនោះដែរ។ ប៉ុន្តែ ខ្ញុំព្យាយាមមកទីនេះ ដោយតាំងចិត្តយ៉ាងអង់អាចក្លាហាន ហើយដាក់ចិត្តថា យើងកំពុងតែប្រតិបត្តិការច្បាប់នៅទីនេះទាំងអស់គ្នា។ សូមប្រយ័ត្នសម្តីដើម្បីកុំឲ្យសង្គមខ្ញុំបាក់បែកតទៅទៀត។ អរគុណ។

[១៤:១៧:៥៨]

**ប្រធានអង្គជំនុំ៖**

មេធាវីបន្ត ហើយសូមផ្តង់ផ្តោតតែសំខាន់ទៅលើបញ្ហាសំណងបាទ។ សូមអញ្ជើញ!

**លោក ហ្វីលីព កាណូន៖**

បាទ, ខ្ញុំនឹងកម្រិតនូវអ្វីដែលខ្ញុំនឹងនិយាយ គឺថាបញ្ហាស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសំណង។ សូមឲ្យខ្ញុំ-- ចាំឲ្យខ្ញុំបញ្ចប់ឃ្លារបស់ខ្ញុំសិន។ គឺខ្ញុំៗសូមស្នើសុំឲ្យសំណងរបៀបទីមួយ គឺការសូមអភ័យទោស ហើយយើងដឹងថារបៀបនៃទម្រង់នៃសំណងនោះគឺថា បានបិទផ្លូវចំពោះយើង។ បាទ ខ្ញុំមិននិយាយអ្វីផ្សេងទៀតទេ។

[១៤:១៨:៥០]

ផ្លូវទីពីរ នៃសំណងនោះគឺ ការចងចាំឈ្មោះ។ តើយើងខ្ញុំត្រូវយល់ឃើញថា ការទាមទាររបស់ជនរងគ្រោះនឹងត្រូវរឹតត្បិតមកត្រឹមតែការចារឹកឈ្មោះរបស់ជនរងគ្រោះ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលាក្រម និងការបោះពុម្ពផ្សាយសាលក្រមនេះនៅក្នុងតែរយៈពេលប៉ុន្មានថ្ងៃនៅលើវេបសាយរបស់ អ.វ.ត.ក ដែរឬទេ? ទេ យើងមិនគិតឃើញបែបនេះទេ។

ខ្ញុំសូមជម្រាបជូនតុលាការថាហេតុអ្វីបានជាខ្ញុំនិយាយបែបនេះ? នៅពេលដែលតុលាការអនុញ្ញាតឲ្យជនរងគ្រោះតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានន័យថា ជាស្វ័យប្រវត្តិគឺពួកគាត់ក្លាយទៅជាភាគីនៃរឿងក្តីដោយពេញច្បាប់។ ដូច្នេះ ការចារឹកឈ្មោះរបស់ជនរងគ្រោះនៅក្នុងសាលក្រមមិនបានផ្តល់ផលប្រយោជន៍ពិសេសណាមួយទៅដល់ពួកគាត់ជាជនរងគ្រោះនោះទេ។ នេះវាមិនមែនជាសំណងទេ។

វាគ្រាន់តែជាការកត់សម្គាល់នូវអ្វីដែលគេដឹងច្បាស់គ្រប់គ្នាតែប៉ុណ្ណោះ។

[១៤:២០:១០]

ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះដោយស្មោះត្រង់ និងដោយមិនលាក់លៀមថា ការសម្រេចយកទម្រង់នៃសំណងបែបនេះ ជាទម្រង់ចម្បងសំខាន់នោះបានបណ្ដាលឱ្យជនរងគ្រោះមានការខកចិត្តយ៉ាងខ្លាំង។ ហើយការសម្រេចបែបនេះ គឺមិនបានគិតគូរទៅដល់លក្ខណៈជាប្រវត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះទេ ដែលគឺថាកម្ពុជា និងសហគមន៍អន្តរជាតិ គឺតែងប្រាថ្នាចង់បាន។

យើងទាំងអស់គ្នាដឹងហើយថា ការជំនុំជម្រះក្ដីនេះមានលក្ខណៈប្រវត្តិសាស្ត្រតាមផ្លូវពីរ។ លើផ្លូវច្បាប់នេះ គឺជាលើកទីមួយហើយដែលជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យចូលតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមិនបាននិយាយអ្វីដែលសហភាតារបស់ខ្ញុំបានលើកឡើងកាលពីព្រឹកមិញនោះទេ។ ទាំងអស់នេះយើងដឹងទាំងអស់គ្នាហើយ។ ក៏ប៉ុន្តែតុលាការយើងនេះ នឹងជាគំរូទៅថ្ងៃក្រោយ វាជាមន្ទីរពិសោធន៍មួយដែលខ្ញុំប្រើពាក្យនេះ នៅក្នុងន័យវិជ្ជមាន អ.វ.ត.ក និងជាគំរូដល់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅថ្ងៃអនាគតជាមួយនឹងសមាសភាពជាតិភាគច្រើន។ ក៏ប៉ុន្តែ មានស្តង់ដារអន្តរជាតិ ហើយនិងការបូកបញ្ចូលគ្នានៃប្រព័ន្ធពីរគឺ ប្រព័ន្ធស៊ីវិលឡ ហើយនិងប្រព័ន្ធខំមិនឡ។

[១៤:២២:០៣]

សព្វថ្ងៃនេះ យើងកំពុងតែឆ្លងកាត់នៃការប្រែប្រួលការវិវឌ្ឍន៍នៃប្រព័ន្ធយុត្តិធម៌អន្តរជាតិ។ ខ្ញុំមិនមែននៅក្នុងយុត្តិធម៌ឆ្នៃប្រឌិតនោះទេ។ ក៏ប៉ុន្តែ បើនៅថ្ងៃអនាគតសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវបានគេទទួលស្គាល់នោះ ហើយនឹងទទួលបានសំណងនោះ ហើយនិងពិរទ្ធជននឹងត្រូវបានសងជាបុគ្គល ឬក៏ជាស្ថាប័ន ឬក៏ជានយោបាយ ហើយនិងដោយមានប្រសិទ្ធភាពនោះ។ នេះវាហាក់ដូចជាថ្មមួយដុំដែលយើងយកមកសង់អគារមួយអ៊ីចឹង។ ខ្ញុំមិនទៅជឿថា ការបង្កើតតុលាការអន្តរជាតិនេះអាចបញ្ឈប់នៃការប្រព្រឹត្តអំពើអាក្រក់ទៅដោយមនុស្សឆ្កួតលីលាមួយចំនួនដែលមានកូនទាហានក្មេងខ្ចី ហើយនិងត្រូវបានបញ្ចុះបញ្ចូលដោយមនោគមវិជ្ជានោះទេ។ នេះគ្រាន់តែជាការស្រមើស្រមៃប៉ុណ្ណោះ។ ក៏ប៉ុន្តែផ្ទុយទៅវិញ ខ្ញុំជឿថា ការផ្ដល់ឱកាសឱ្យដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយនេះ គឺអាចធ្វើឱ្យមានការផ្លាស់ប្ដូរបាន។ ហើយវាមិនដូចពីមុននោះទេ បើសិនជាយើងដើរទៅមុខ ទៅដល់ទិសដៅហើយមិនឈប់តាមផ្លូវ និងបង្កើតច្បាប់ថ្មីមួយ។

[១៤:២៣:៤៦]

ឥឡូវនេះ ចូលដល់ផ្លូវមនុស្សជាតិ។ បើការផ្តល់ឱកាសទៅដល់ជនរងគ្រោះ គឺជាការសងគាត់វិញនូវភាពថ្លៃថ្នូររបស់គាត់ ហើយការដែលមិនធ្វើឲ្យអ្នកដែលសម្លាប់គាត់នោះ អ្នកធ្វើឧក្រិដ្ឋកម្មនោះចាត់ទុកគាត់ជាមនុស្សវិញ។ ហើយជាទូទៅគេមិនបង្ខំមិនឲ្យនិយាយ ហើយនិងខំបំបិទមាត់អ្នកដែលបានទទួលការឈឺចាប់នោះ។ ប្រវត្តិសាស្ត្របង្រៀនយើងឲ្យដឹងថា ការដាក់ឲ្យទៅជាទាសករ ហើយនិងការបំបាក់ស្មារតីនោះ វាមានខ្លាំងដល់កម្រិតណា ហើយគ្មានអ្វីគ្រោះថ្នាក់ខ្លាំងជាងការប៉ះបោររបស់ទាសករ ឬគ្មានអ្វីដែលខ្លាំងជាងការប្រយុទ្ធអ្នកដែលត្រូវបានគេបន្ទាបបន្ថោក ហើយក៏គ្មានអ្វីដែលខ្លាំងជាងចម្លើយរបស់អ្នកដែលគេបដិសេធថាពុំមានជីវិតនៅក្នុងពិភពលោកនោះទេ។

អំណាចនយោបាយអាចមានការប៉ុនប៉ងរុញច្រានពួកគាត់ចេញឲ្យឆ្ងាយបាន។ ក៏ប៉ុន្តែ អំណាចតុលាការមិនអាចធ្វើយ៉ាងដូច្នេះបានទេ ពីព្រោះថា អំណាចតុលាការឈរលើមូលដ្ឋានធ្វើឲ្យស្រាកស្រាន្ត ហើយនិងមិនមែនជាការសងសឹក ហើយនិងមានគុណធម៌គរុកោសល្យ។

[១៤:២៥:០៦]

ភាគីការពារក្តី ខ្ញុំសូមជម្រាបថា សំណូមពររបស់យើងគ្រាន់តែជាសំណូមពរសុំភាពស្រាកស្រាន្តតែប៉ុណ្ណោះ។ អ្នកស្រី និងលោកសហព្រះរាអាជ្ញា យើងបានផ្តល់តម្លៃខ្ពស់ទៅដល់គុណធម៌ ហើយនិងភាពមោះមុតដែលអស់លោកបានលើកឡើងថា វាមានភាពចាំបាច់នៃការមិនអាចបោះបង់ប្រជាជនកម្ពុជាចោលបាន ហើយយើងយល់ស្របទាំងស្រុកចំពោះការយល់ឃើញរបស់លោកសហព្រះរាជអាជ្ញា។

[១៤:២៥:៤៣]

ម្សិលមិញលោកបាននិយាយអំពីការកំណត់ទោស ប៉ុន្តែ ក្នុងឋានៈខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមិនអាចបញ្ចេញយោបល់អំពីការកំណត់ទោសនោះបានទេ។ ប៉ុន្តែការសុំសំណងនេះតាមផ្លូវស៊ីវិលសូមលោកជ្រាបថា យើងស្វាគមន៍ដោយគោរពចំពោះការយល់ឃើញបែបនេះរបស់លោកសហព្រះរាជអាជ្ញា។ ប្រជាជនកម្ពុជា ស័ក្តិសមនឹងទទួលបានការយកចិត្តទុកដាក់ ករណីយកិច្ចជាមេធាវីរបស់យើងខ្ញុំគឺជួយជនរងគ្រោះដោយមិនគិតកម្រៃដើម្បីប្រយោជន៍សាធារណៈ រហូតដល់ចប់កិច្ចការដំណើរនីតិវិធីដោយមិនខកខាន និងមិនធ្វើការរិះគន់ចំពោះតុលាការដែលខំប្រឹងប្រែងពីមួយថ្ងៃទៅមួយថ្ងៃដើម្បីឲ្យច្បាប់វិវឌ្ឍន៍ទៅមុខ និងក្នុងបរិបទដ៏លំបាកលំបិននេះ។

[១៤:២៦:៤៨]

អស់លោកដឹងស្រាប់ហើយពាក្យសម្តីយើងទាំងអស់គ្នាថ្ងៃក្រោយគេនឹងបំភ្លេចចោល ការជជែក

តវ៉ាវាហាក់ដូចជាធ្លាក់នៅលើទឹកកកអ៊ឹចឹង ហើយនៅពេលដែលធ្លាក់ហើយភ្លាមវារលាយបាត់ទៅហើយ។ ក៏ប៉ុន្តែ អ្វីដែលស្ថិតនៅរហូតនោះ គឺការទទួលស្គាល់សិទ្ធិទទួលបានសំណង និងការទទួលស្គាល់នូវទម្រង់នៃសំណង ហើយនេះគឺស្ថិតនៅគង់វង្សរហូតដូចជាគេឆ្លាក់នៅលើថ្មម៉ាបអ៊ីចឹង។ សហភាតាកម្ពុជារបស់ខ្ញុំបានផ្តល់ផែនការដែលអាចធ្វើទៅបាន អង្គជំនុំជម្រះនឹងវាយតម្លៃលើទ្រង់ទ្រាយ លើកភាពដែលអាចធ្វើទៅបាននៃគម្រោងទាំងនេះ។ ភាពជាម្ចាស់កម្មសិទ្ធិរបស់ប្រជាជនកម្ពុជានឹងផ្តល់ធម្មានរូបដល់គម្រោងទាំងនេះ។ យុវជនកម្ពុជាមិនខ្សោយនោះទេ ដូច្នេះគេនឹងមានចក្ខុវិស័យនៃអនាគត។

[១៤:២៧:៥៨]

ដើម្បីបញ្ចប់ខ្ញុំសូម ខ្ញុំនឹងបញ្ចប់នៅក្នុងរយៈពេលបីនាទីទៀតនេះលោកប្រធាន។ ខ្ញុំសូមជម្រាបជូនអស់លោកទាំងអស់គ្នាថា ទាក់ទងនឹងទម្រង់នៃសំណងនេះ ថ្ងៃនេះខ្ញុំសប្បាយ ខ្ញុំពេញចិត្តនឹងអ្វីដែលគេកំពុងធ្វើនេះទាក់ទងនឹងសំណង។ គឺថាដោយសារថាគម្រោងនេះនៅថ្ងៃ-- នៅចុងបញ្ចប់នោះគឺថាត្រូវបានផ្សព្វផ្សាយ ហើយនិងភាពល្បីរន្ទឺនៅតាមរយៈសារព័ត៌មានជាតិ និងអន្តរជាតិ បានធ្វើឱ្យគេស្គាល់អង្គហេតុ ធ្វើឱ្យគេស្គាល់ច្បាប់សិទ្ធិទទួលបានសំណងនៅពេលដែលខ្ញុំឃើញការបោះពុម្ពសៀវភៅរឿង អក្សរសិល្ប៍ ឬក៏រឿងល្ខោនមួយ ឬក៏រឿងកុនមួយដែលទាក់ទងទៅនឹងរឿងសំណងនេះបាទ។ គឺខ្ញុំពេលនោះខ្ញុំនិយាយថា ខ្ញុំសូមអភ័យទោសដែលខ្ញុំនិយាយនេះវាហាក់ដូចជានិយាយច្រើនពេក។

ខ្ញុំថានៅពេលដែលខ្ញុំឃើញយុវជននៅតាមសាលា នៅតាមអនុវិទ្យាល័យ តាមវិទ្យាល័យមកចូលរួមក្នុងសវនាការនេះ យើងបានផ្តល់សារមួយដ៏ពិតប្រាកដដែលគួរឱ្យចាប់អារម្មណ៍។ ហើយខ្ញុំសូមបញ្ចប់ត្រឹមនេះ ដើម្បីគោរពពេលវេលាដែលគេចែកមកឱ្យខ្ញុំនោះ។

[១៤:២៩:៤២]

បាទ, នៅពេល ខែ១១ ឆ្នាំ២០០៩ ខ្ញុំបានបញ្ចប់ការជជែកតវ៉ាខ្ញុំយ៉ាងដូច្នេះ។ ខ្ញុំនិយាយថា ពាក្យសម្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចជាស្ពានមួយ អាចជាស្ពានចម្លងទៅរកការផ្សះផ្សាដែលយើងទាំងអស់គ្នារំពឹងរង់ចាំ។ ខ្ញុំបាននិយាយផងដែរ ថាការជម្រះសេចក្តីនេះនឹងមានគុណធម៌ដ៏សម្បើម ហើយនិងផ្តល់មកប្រទេសកម្ពុជាវិញនូវភាពទូលំធំ ហើយនិងអតីតកាលដ៏មហារុងរឿងរបស់ខ្លួន។ បាទ, ហើយខ្ញុំពេញចិត្តនឹងបុព្វកថានៃរដ្ឋធម្មនុញ្ញកម្ពុជា រដ្ឋធម្មនុញ្ញនេះនិយាយអំពីអរិយធម៌ខ្មែរ ហើយដែលប្រើពាក្យពេចន៍ដូចតទៅនេះ៖

គឺថាវប្បធម៌ខ្មែរនេះរីកចិញ្ចែងចិញ្ចាំងដូចពេជ្រពណ្ណរាយ។ ខ្ញុំស្រមើស្រមៃថា ពេជ្រនេះនឹងជា

អមតៈ។ អស់លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំសូមអង្វរៗដោយស្មោះស្ម័គ្រថា សូមផ្តល់មកដល់យើងនូវសំណាងដែលយើងសុំ ហើយយើងនិងឆ្លើយតបទៅនឹងសំណួររបស់អស់លោក លោកស្រីដោយខ្ញុំសូមអង្វរជាថ្មី។ សូមអង្វរថា ធ្វើយ៉ាងណាកុំឱ្យគេចវេសពីប្រវត្តិសាស្ត្រ ហើយនិង គេចវេសពីការពិត។ ខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញចៅក្រមមានសំណួរដល់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

[១៤:៣១:៥៨]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

អរគុណលោកប្រធាន។ បន្ទាប់ពីលោកមេធាវីរៀបរាប់អម្បាញ់មិញគឺថា ពិបាកនឹងសួរសំណួរទៀតផង។ ប៉ុន្តែ ខ្ញុំសូមត្រឡប់ទៅចំណុចលម្អិតវិញ ហើយនិងចំណុចបច្ចេកទេសសំណួរដែលខ្ញុំចង់សួរនោះ គឺថាតើតាមពាក្យពេចន៍ចុងក្រោយរបស់លោកថា មិនដឹងថាយើងយល់ ឬក៏មិនយល់ទាក់ទងទៅនឹងគម្រោងនៃសំណាងដែលលោកបានស្នើសុំឱ្យតុលាការកំពូល ឬក៏ស្នើសុំឱ្យអនុវត្តនូវគំនិតយោបល់ដែលទើបតែបានសម្រេចនៅក្នុងសេចក្តីវិសោធនកម្មទាក់ទងនឹងសិទ្ធិទទួលបាននូវសំណាងនេះ? បើនិយាយតាមផ្លូវបច្ចេកទេសវិញ គឺវាអាចអនុវត្តទៅបាន ដោយយោងទៅតាមភាសាដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនោះ។

**លោក ហ្វីលីព កាណុន៖**

បាទ, ខ្ញុំសូមអភ័យទោសដែលខ្ញុំនិយាមិននូវច្បាស់លាស់ម្សិលមិញ។ អង្គជំនុំជម្រះជាអ្នកកំណត់របស់របៀបសំណាង ហើយខ្ញុំនេះ ខ្ញុំមិនមានសិទ្ធិអ្វីធ្វើនោះទេ។ ជាអកុសល។ សំណួរដែលអ្នកស្រីបានចោទមកជាលាយលក្ខណ៍អក្សរនោះ ខ្ញុំសូមធ្វើយ៉ាងម៉េចកុំឱ្យបំប្លែងសំណួរនោះ អ្នកស្រីបានសួរខ្ញុំថា សូមផ្តល់ជូននូវពាក្យពេចន៍ទាក់ទងទៅនឹងទម្រង់នៃសំណាង ដែលអាច ប្រសិនជាសំណើយើងដែលអាចទទួលបាននោះ ដែលអាចឆ្លើយតបទៅនឹងសេចក្តីរំពឹងរង់ចាំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ យើងទាំងអស់គ្នាមានឧបសគ្គទាំងអស់នៅក្នុងសំណុំរឿងនេះ ចម្លើយរបស់ខ្ញុំដូចតទៅនេះ៖

[១៤:៣៤:១០]

តើអ្នកស្រីចៅក្រមអាចប្រាប់បានទេ ថាលោកស្រីចៅក្រមអនុញ្ញាតឱ្យរាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ឬក៏ក្រុម ឬក៏សមាគមដើមបណ្តឹងរដ្ឋប្បវេណីដែលស្របច្បាប់នោះ អាចអនុញ្ញាតឱ្យ

ពួកគាត់ស្នើសុំដីទៅដល់ម្ចាស់កម្មសិទ្ធិដី ពីព្រោះថាយើងមិនអាចសុំដីទៅម្ចាស់កម្មសិទ្ធិដីនោះទេ។ សូមការអនុញ្ញាតដើម្បីសាងសងជញ្ជាំងមួយ ជញ្ជាំងបី ដែលនៅក្នុងជញ្ជាំងនោះ--

**អ្នកបកប្រែ៖**

សូមអភ័យទោស អ្នកបកប្រែអត់ស្តាប់ឮទេពីព្រោះគាត់នៅឆ្ងាយពេក។

**លោក ហ្វីលីព កាណុន៖**

...នៅក្នុងៗ យើងអាចបង្កើតជាស្តូបមួយ ដែលនៅលើនោះយើងអាចចារពាក្យពេចន៍ ដែលជាឈ្មោះជនរងគ្រោះទាំងអស់ របស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលបានទទួលយក។ នេះគ្រាន់តែជាសំណើ ហើយដូច្នេះយើងថាសុំការអនុញ្ញាតពីលោកចៅក្រម ដើម្បីទៅសុំការអនុញ្ញាតអំពីអាជ្ញាធរ។ នេះហើយគំនិតវាបែបនេះហើយ។ វាពិបាកនឹងបង្កើតណាស់ ពីព្រោះរហូតដល់ពេលនេះ អ្វីដែលយើងរកឃើញនោះ គឺថាមានតែប៉ុណ្ណឹង ហើយខ្ញុំអាចទៅសារមន្ទីរជាតិ ហើយខ្ញុំបង្ហាញអ្វីៗច្រើនទៀត ក៏ប៉ុន្តែវាមិនគួរឲ្យជឿ។ ដូច្នេះ សំណើខ្ញុំ វាជាសំណើមួយដែលវាមានលក្ខណៈមិនផ្ទាល់។

[១៤:៣៦:០៥]

**ប្រធានអង្គជំនុំ៖**

បាទ, ខ្ញុំមានសំណួរមួយដែរដើម្បីសួរទៅខាងសហមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣នេះ។

អំមិញនេះ គឺលោកស្រីបានជម្រាបជូនមកខាងអង្គជំនុំជម្រះថា អង្គជំនុំជម្រះសាលាដំបូង គឺបានកំណត់ស្តង់ដារខ្ពស់ហួសហេតុពេក ក្នុងការកំណត់ទទួលយកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងបរិបទសាលាក្តីយើងនេះ។ តើទាក់ទងនឹងបញ្ហាស្តង់ដារនៃការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងកម្រិតជាតិ និងក្នុងកម្រិតអន្តរជាតិ មានយ៉ាងណាខ្លះដែលលោកគួរតែពន្យល់អំពីបញ្ហាហ្នឹង?

[១៤:៣៦:៥៦]

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

ខ្ញុំសូមមានការកត់សម្គាល់លើបញ្ហានេះ ដែលទាក់ទងទៅនឹងបញ្ហាភស្តុតាង ដែលបានត្រូវលើកឡើងដោយអ្នកស្រីចៅក្រម មីឡាត។ ខ្ញុំសូមធ្វើការពិចារណាដូចតទៅនេះ។

ក្នុងតាំងនាមឲ្យក្រុមទី៣ នៅពេលដែលយើងនិយាយអំពីការបង្កើតតុលាការនេះ យើងឃើញថាមានកិច្ចព្រមព្រៀង យើងឃើញថា មានច្បាប់មាន-- នៅក្នុងមាត្រា៣៥ ទាក់ទងទៅនឹងភស្តុតាង

ទាក់ទងទៅនឹងការបង្ហាញភស្តុតាងដាក់បន្ទុក ហើយនិងដោះបន្ទុក។ ហើយយើងឃើញថា មាត្រា៨៧ នៃវិធានផ្ទៃក្នុង ដែលខ្ញុំបានលើកឡើងហើយនោះ ដែលខ្ញុំយល់ឃើញថា វាជាការសំខាន់ទាក់ទងទៅនឹង ដំណើរការតុលាការនេះ។ ហើយមានលក្ខណៈច្បាស់លាស់។ ហើយខ្ញុំនូវទាក់ទងទៅនឹងក្រមព្រហ្មទណ្ឌ ទាក់ទងទៅនឹងសហព្រះរាជអាជ្ញាអង្គជំនុំជម្រះត្រូវតែមានជំនឿជឿជាក់ ហើយក៏មានរំឭកផងដែរថា ភស្តុតាងទាំងនេះត្រូវតែពិភាក្សាគ្នានៅក្នុងសវនាការ ហើយនិងភស្តុតាងត្រូវតែដកចេញពីសំណុំរឿង ហើយនឹងត្រូវនិយាយនៅក្នុងសវនាការ។

[១៤:៣៨:២៥]

ហើយក៏គាត់រំឭកផងដែរនូវការចោទប្រកាន់ ហើយនិងគាត់បាន-- អ្វីដែលខ្ញុំចង់និយាយនៅពេល នេះ គឺថាជឿជាក់ ជំនឿជឿជាក់របស់ចៅក្រម--

**អ្នកបកប្រែ៖**

លោកចៅក្រម វាគ្មិននិយាយលឿនពេកអ្នកបកប្រែបកអត់ទាន់ទេ។ បាទ, លោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

សូមទោស សូមលោកស្រី យឺតបន្តិចកុំលឿនពេក។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

...មានជំនឿជាក់។ នេះគឺជារបបភស្តុតាង ដែលត្រូវអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ជាតិ។ ក៏ប៉ុន្តែ មិនមែនជាប្រព័ន្ធសាកលនោះទេ វាមានតុលាការមួយចំនួនដែលមិនមានដំណើរការទៅឲ្យ-- ដែលឈរ លើមូលដ្ឋាននៃជំនឿជឿជាក់របស់ចៅក្រមនោះទេ។ ក៏ប៉ុន្តែ លើគោលការណ៍ភស្តុតាងជាទម្រង់ ហើយ ឬក៏ភស្តុតាងជាសម្ភារៈ។

ទោះបីជាចៅក្រមមានជំនឿជឿជាក់នោះក៏ដោយ ក៏មិនអាចរក្សាទុកនៅក្នុងសាលក្រមរបស់ ខ្លួនបាននៅពេលដែលពុំមានភស្តុតាងសម្ភារៈនោះ ដែលជាមូលដ្ឋាននៃជំនឿជឿជាក់របស់ខ្លួននោះដែរ។ តុលាការនេះបានកំណត់គោលការណ៍ ទាក់ទងនឹងភស្តុតាងនេះ។ របបភស្តុតាងនេះត្រូវបានបរិយាយ នៅក្នុងវិធានផ្ទៃក្នុងយ៉ាងច្បាស់លាស់ថា ដែលយើងអាចគិតថា ដើម្បីប្រយោជន៍របស់ជនជាប់ចោទ។ ក៏ប៉ុន្តែយើងមិនអាចចំណុះបានទេ នៅពេលដែលយើង-- បើពុំដូច្នោះយើងមិនអាចគោរពបទដ្ឋានយុត្តិធម៌ នោះទេ។ ដូច្នេះ គាត់មានសិទ្ធិទទួលបានរបបភស្តុតាងនេះបាន។

[១៤:៤០:៤១]

ហេតុអ្វីបានខ្ញុំលើកឡើងរឿងទាំងអស់នេះ? ពីព្រោះថា ខ្ញុំសូមរំឭកថា តាំងពីដើមនៃការ-- ដំបូងនៃការជម្រះសេចក្តីនេះ និងកាលពីឆ្នាំ២០០៨ វាមានការពិបាកនៅក្នុងភាគីទីមួយៗនេះ ដើម្បីសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះស្ថានភាពនេះពុំមានបញ្ហាទៀតទេ ប៉ុន្តែពេលនោះមានបញ្ហាច្រើន។

សហភាតារបស់ខ្ញុំបានលើកឡើងអម្បាញ់មិញនេះថា សូមឲ្យមានការផ្សះផ្សាជាតិ ហើយសព្វថ្ងៃនេះស្ថានភាពនេះ ហាក់ដូចជាមានភាពស្រាកស្រាន្តជាងមុន នៅតែមានការភ័យដដែល ក៏ប៉ុន្តែវាតិចតួច ហើយនៅពេល-- ហើយយើងយល់ឃើញថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាសេចក្តីក្លាហាន នៅពេលដែលគាត់ស្ម័គ្រចិត្តថា មកចូលនិយាយជាចំហនៅចំពោះមុខអង្គជំនុំជម្រះ ហើយនិងបង្ហាញពីអតីតកាលរបស់ខ្លួន។ យើងមានដើមបណ្តឹងរដ្ឋប្បវេណីតិចជាង១០០នាក់ ហើយយើងមានជនរងគ្រោះទៅដល់ជាង១០.០០០នាក់។ មន្ទីរស-២១ លើសពី១០.០០២នាក់ ដែលត្រូវបានមាន-- ដែលមានអត្តសញ្ញាណច្បាស់លាស់ ហើយយើងមានរូបថតភាគច្រើនទៀតផង ហើយយើងមានសេចក្តីសារភាពភាគច្រើនទៀតផង។

ហើយនៅក្នុង-- យើងដឹងថាមានវាលពិឃាដ ក៏ប៉ុន្តែយើងមិនដឹងថា តើនៅមន្ទីរស-២១ ដែលថាជាមន្ទីរមួយដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដែលមិនមែនជាករណីរបស់តុលាការផ្សេងទៀត ហើយជនរងគ្រោះនោះ កាលនោះក៏ដោយ ក៏គេមានកំណត់អត្តសញ្ញាណច្បាស់លាស់ ហើយនិងមានចំណារ ហើយមានថតរូប ថតអីទៀតផង។

[១៤:៤២:៥១]

ហេតុអ្វីបានជាសព្វថ្ងៃនេះ យើងមានទទួលតែមនុស្ស១០០នាក់ មកចូលរួម ដែលនៅលើក្នុងចំណោមមនុស្សជាង១០.០០០នាក់នោះ? អ្នកក្រុមគ្រួសារផ្សេងៗទៀតនោះគាត់មិនមានអារម្មណ៍ទទួលការឈឺចាប់ ដែលថាគាត់បាត់កូនចៅ ឪពុកម្តាយនោះទេ។ មិនដូច្នោះទេ គាត់មិនតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ មិនឲ្យគេស្គាល់នោះ ដោយសារគាត់ភ័យ គាត់ខ្លាច គាត់មិនត្រូវបានគេបំភ័យនោះទេ។ ក៏ប៉ុន្តែ គាត់ភ័យខ្លួនឯងនៅក្នុងអារម្មណ៍តែម្តង ដោយសារគាត់បានរស់នៅក្នុងអតីតកាលពីឆ្នាំ១៩៧៥ ដល់ ១៩៧៩។

[១៤:៤៣:៣៤]

សព្វថ្ងៃនេះយើងអាចនិយាយនៅប្រទេសកម្ពុជា អ្វីដែលកើតឡើងពី ៧៥ ដល់ ៧៩។ យើងកាលនៅឆ្នាំ២០០៦ គេមិនបាននិយាយ មិនហ៊ាននិយាយនោះទេ។ គោលជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណី

នោះ គឺថាកាលនោះៗ ត្រូវមានភាពក្លាហានច្រើន។ សព្វថ្ងៃនេះយើង-- ឥឡូវនេះគេជំទាស់ថា គាត់ត្រូវមានសមស្របតាមច្បាប់ត្រឹមត្រូវដើម្បីឲ្យចូលរួមក្នុងដំណើរការនីតិវិធីបាន។ ហើយ អ៊ីចឹងហើយបានខ្ញុំសុំឲ្យលោកចៅក្រម អនុញ្ញាតផ្តល់ជូនទៅដល់ជនរងគ្រោះទាំងអស់នេះ ទាក់ទងនឹងរបបភស្តុតាងនេះ សុំឲ្យលោកចៅក្រម គឺថាបើសិនជាពួកគាត់ពុំអាចទទួលបានទេ ដូច្នេះពុំមានភស្តុតាង ពុំមានសម្ភារៈ ពុំមានលុយកាក់ គាត់ខំមកចូលរួមដំណើរការនីតិវិធី ហើយគាត់មកទាំងវេទនា ហើយជិះឡានមក ជិះម៉ូតូមក។

[១៤:៤៤:៥៩]

ដូច្នេះ គាត់មានតម្រូវការច្បាស់លាស់មួយ គឺថាគាត់ត្រូវការឲ្យគេទទួលស្គាល់ផ្លូវចិត្ត ហើយនិងទទួលស្គាល់ការប៉ះពាល់របស់គាត់ ហើយគាត់ខំតស៊ូមកតាម ចូលតាមដំណើរការនីតិវិធីជាងពីរឆ្នាំមកហើយ។ ខ្ញុំឃើញគាត់អស់កម្លាំង ឃើញគាត់ចូលរួមក្នុងដំណើរការនីតិវិធីនេះ ហើយខ្ញុំឃើញថា-- ហើយខ្ញុំសោកស្តាយដែលគេនិយាយថា គាត់ពុំមានសិទ្ធិទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារគាត់ពុំមានចំណងពាក់ព័ន្ធ ហើយថាមានអ្វីដែលបញ្ជាក់ពីរឿងនេះ ថាមាន ឬមិនមាននោះ?

វាអត់មានឯកសារអ្វីទាំងអស់ ហើយត្រង់នេះហើយ ដែលថាសូមពិចារណាឡើងវិញអំពីរបបភស្តុតាង ហើយសុំឲ្យអង្គជំនុំជម្រះទាក់ទងធ្វើម៉េចគិតពីប្រយោជន៍ដើម្បីបណ្តឹងរដ្ឋប្បវេណី ដែលថាជាផ្នែកមួយនៃការជម្រះសេចក្តី។ ហេតុដូច្នេះ សូមឲ្យអនុវត្តយ៉ាងដូច្នេះចំពោះភាគីទាំងអស់នៅក្នុងដំណើរការនីតិវិធី។

**លោកស្រី ម៉ុច សុវណ្ណារី៖**

ជាមួយនឹងការអនុញ្ញាតរបស់លោកប្រធាន នាងខ្ញុំសូមបន្ថែមទៅអ្វីដែលសហភាតារបស់នាងខ្ញុំខាងអន្តរជាតិបានលើកឡើង។ វាគឺជាឧទាហរណ៍មួយដែលខ្ញុំចង់ដាក់ជូនអង្គជំនុំជម្រះដើម្បីពិចារណាទាក់ទងជាមួយនឹងកម្រិតនៃភស្តុតាងនេះ។ កូនក្តីរបស់យើងខ្ញុំមួយចំនួនដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធ ដោយសារថាគ្មានភស្តុតាងបញ្ជាក់ពីចំណងញាតិ គ្មានភស្តុតាងបញ្ជាក់ថា គាត់មិនបានជាប់ឃុំនៅមន្ទីរ-- សាច់ញាតិរបស់គាត់មិនបានជាប់ឃុំនៅមន្ទីរសន្តិសុខស-២១។ ក៏ប៉ុន្តែ ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះនៅពេលនេះថា នៅពេលដែលសំណុំរឿងរបស់គាត់ ត្រូវបានផ្ទេរចូលទៅសំណុំរឿងទីពីរ ០០២ សហចៅក្រមស៊ើបអង្កេត គាត់បានសម្រេចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ ដោយបញ្ជាក់អំពីមូលហេតុនៃដីកាទទួលយករបស់ពួកគាត់ ជាដើមបណ្តឹងរដ្ឋប្បវេណីថា ពួកគាត់ពិតជា

បានទទួលរងនូវការឈឺចាប់ផ្លូវចិត្ត ដែលបណ្តាលមកពីឧក្រិដ្ឋកម្មដែលបានកើតឡើងចំពោះសាច់ញាតិរបស់ពួកគាត់នៅមន្ទីរស-២១ ពិតមែន។

[១៤:៤៦:៥៧]

នាងខ្ញុំលើកឡើងនេះគ្រាន់តែជាឧទាហរណ៍តូចមួយដើម្បីនឹងបង្ហាញ សូម្បីតែនៅក្នុងអង្គជំនុំជម្រះនេះ ការវាយតម្លៃ ការអនុវត្តវិធាននៃភស្តុតាង គឺមិនដូចគ្នា។ ខ្ញុំដឹងៗ ថាសេចក្តីសម្រេចមួយនេះរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងទីពីរនេះ មិនចំអង្គជំនុំជម្រះទេ តែនាងខ្ញុំគ្រាន់តែចង់លើកឧទាហរណ៍ជាក់ស្តែងមួយ ដើម្បីបង្ហាញអង្គជំនុំជម្រះពិចារណាបន្ថែមទៅលើអ្វីដែលលោកស្រីមេធាវី ម៉ាទីន ហ្សាកកាំង លើករួចមកហើយ។

ចាស, សូមអរគុណ។

[១៤:៤៧:៣០]

**ប្រធានអង្គជំនុំៈ**

បាទ, សូមអញ្ជើញសហមេធាវីការពារជនជាប់ចោទ ធ្វើសេចក្តីថ្លែងតបទៅនឹងសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ទាំងបីក្រុមតែម្តង។ សូមអញ្ជើញ!

**លោក កង ឫទ្ធារីៈ**

ជាបឋម សូមអរគុណលោកប្រធានតុលាការកំពូល និងអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃនេះទាំងអស់។ ហើយក៏សូមលំឱនកាយគោរពសូមទោសក្នុងនាមកូនក្តីរបស់ខ្ញុំជាថ្មីម្តងទៀត ដែលដូចជាគាត់ធ្លាប់បានសូមទោសម្តងមកហើយ ចំពោះគ្រួសារពិតប្រាកដនៃជនរងគ្រោះក្នុងមន្ទីរស-២១។ គ្មានពាក្យពេចន៍ណាមួយដែលបានភូតកុហកដោយកូនក្តីរបស់ខ្ញុំបាទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលថា ស-២១ គ្មានឧក្រិដ្ឋកម្មនោះទេ។ គាត់ថែមទាំងបានថ្លែងថ្កោលទោសទៅលើបក្សកម្មុយនីស្តកម្ពុជាទៀតផង ថាជាមាគ៌ារបស់បក្ស។

[១៤:៤៨:២៣]

ប៉ុន្តែ មុននឹងខ្ញុំឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីទាំងបីក្រុម ខ្ញុំបានដាក់សំណួរជាទូទៅមួយថា តើខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមែនឬទេ? នេះជាចំណោទបញ្ហា ដែលក្រោយពីសង្ខេបសារណាទាំងបីក្រុមមក គឺថាបញ្ហាសំខាន់ គឺថាចៅក្រមនឹងសួរថា អ្នកមានគុណភាពជាដើមបណ្តឹងរដ្ឋប្បវេណីមែនឬទេ? ហើយយកបទដ្ឋានណាមកពិនិត្យ?

[១៤:៤៨:៥៣]

បើតាមបទដ្ឋានអន្តរជាតិ គឺច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំដែលមានការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងសវនាការ ហើយក៏ពុំធ្លាប់បង្គាប់ឲ្យរដ្ឋណាដែលប្រព្រឹត្តឧក្រិដ្ឋកម្ម រាប់តាំងពីតូក្យូ, នូរ៉ឹមប៊ឺក, យូហ្គោស្លាវី, រវ៉ាន់ដា, សៀរ៉ាឡេអូន ឲ្យសងសំណងរដ្ឋប្បវេណីទៅកាន់ជនរងគ្រោះនោះទេ។ ប៉ុន្តែ នៅទីនេះខ្ញុំមិនបដិសេធឡើយ ពីព្រោះហេតុអ្វី? ពីព្រោះវាមានចែងនៅក្នុងវិធាន១០០ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ស្តីពីអំពីការសម្រេចផលប្រយោជន៍ផ្នែករដ្ឋប្បវេណី និងមានចែងនៅក្នុងមាត្រា ២១ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ស្តីអំពីបណ្តឹងរដ្ឋប្បវេណីអាចធ្វើឡើងប្រឆាំងទៅនឹងជនទាំងឡាយណាដែលត្រូវជួសជុលព្យសនកម្ម ដែលបណ្តាលមកពីបទល្មើសរួមមាន៖ ១) ចារី ឬសហចារី នៃបទល្មើស ២) អ្នកផ្តើមគំនិត អ្នកសមគំនិត។ ៣) អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

[១៤:៥០:០០]

អស់លោកជាទីគោរព, នៅពេលដែលខ្ញុំលើកអំពីវិធានទាំងនេះមកបង្ហាញនៅអង្គសវនាការទាំងមូល នោះបានន័យថា ខ្ញុំតាងនាមឲ្យជនជាប់ចោទទទួលយកនូវអ្វីដែលជាព្យសនកម្ម ដែលកើតមាននៅស-២១ រួចទៅហើយ ប្រសិនបើរកឃើញថា កាំង ហ្គេកអ៊ាវ ហៅ ឌុច ពិតជាមានពិរុទ្ធភាពមែននោះ។

សំណួរទីពីរ ខ្ញុំសួរខ្លួនឯងថាតើនរណាជាអ្នកសងសំណងរដ្ឋប្បវេណី? បើយោងតាមមាត្រា២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអម្បាញ់មិញ ដែលយើងមើលនៅលើចំណុចទីបី ស្តីអំពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ហើយខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានរួមនៅពេលក្រោយ។

សំណួរទីបី ឆ្លើយតបទៅនឹងលោកមេធាវីក្រុម៣ ថាតើមានសំណងអ្វីខ្លះ ដែលគាត់និយាយថាមានមធ្យោបាយបី នោះគឺជាសំណួរដែលខ្ញុំត្រូវសួរហើយនិងត្រូវឆ្លើយដោយខ្លួនឯងចំពោះអង្គសវនាការថាតើវាមានសំណងរបៀបណាខ្លះ?

[១៤:៥០:៥៧]

បាទ, រំឭកឡើងវិញ ទីមួយ តើខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមែនទេ? ទីពីរ នរណាជាអ្នកសងសំណងរដ្ឋប្បវេណីបើសិនជាគេរកឃើញថា ជនជាប់ចោទមានពិរុទ្ធភាព? ទីបី តើមានសំណងអ្វីខ្លះ?

ឆ្លើយតបទៅនឹងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ គឺមានកង្វះខាតច្រើនអំពីភស្តុតាងបង្ហាញទៅលើភស្តុតាងគួរឲ្យជឿជាក់បាន ដែលថាភស្តុតាងត្រូវបង្ហាញនៅទីនេះ ត្រូវតែហួសពីវិមតិ

សង្ស័យទាំងរដ្ឋធម្មនុញ្ញកម្ពុជា ទាំងវិធានថែងអំពីភស្តុតាង។ ហេតុនេះហើយ ដើមបណ្ដឹងរដ្ឋប្បវេណីព្យាយាម ដើម្បីផលប្រយោជន៍របស់ខ្លួនត្រូវតែរកឲ្យឃើញ ឲ្យបាន ឲ្យមាន និងធ្វើឲ្យប្រាកដថាការសម្រេចរបស់ចៅក្រមពិតជាពឹងផ្អែកទៅលើភស្តុតាង ដែលគ្មានវិមតិសង្ស័យ ថាខ្លួនពិតជាមានគុណភាពជាដើមបណ្ដឹងរដ្ឋប្បវេណីមែន។

[១១:៥១:៥៥]

ការថ្លែងអំពីទុក្ខសោកវេទនា ឬក៏ការលំបាកក្នុងការរកស្វែងរកភស្តុតាង ប្រហែលជាគ្មានតម្លៃច្រើនពេកទេក្នុងការកំណត់និយមន័យអំពីភស្តុតាង ដែលទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការនៅពេលនេះ។ ខ្ញុំបើកវង់ក្រចកបន្តិចដែរ ខ្ញុំសុំអធ្យាស្រ័យដល់អង្គជំនុំជម្រះទាំងមូលថាខ្ញុំនិយាយនេះគ្មានចេតនាវាយប្រហារ ឬរុញច្រានឲ្យដើមបណ្ដឹងរដ្ឋប្បវេណីគ្មានមធ្យោបាយតបតនោះទេ ពីព្រោះខ្ញុំក៏មានគុណភាពជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ដូចតែគ្នាហ្នឹង ហើយប្រជាជនខ្មែរទាំង១៤លាននាក់ ក៏សុទ្ធតែមានគុណភាពជាដើមបណ្ដឹងរដ្ឋប្បវេណីដូចគ្នា ប៉ុន្តែករណីស-២១ ជារឿងមួយផ្សេង។

[១៤:៥២:៤៤]

ទីពីរ តាមស្តង់ដារអន្តរជាតិ គឺគេមិនអនុញ្ញាតឲ្យប្រើនិក្ខេបបទ ប្រតិនិក្ខេបបទធ្វើជាភស្តុតាងឡើយ។ ខ្ញុំទើបតែនឹងទទួលបានលិខិតបញ្ជាក់របស់អធិការដ្ឋាននគរបាលស្រុកមង្គលបុរី ប៉ុស្តិ៍រដ្ឋបាលភ្នំស្រួច លេខ១៤២/០១១ ន.ប.ប៉.ភ.ត ហើយដែលបញ្ជូនដោយក្រុមសហមេធាវីការពាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១។ លិខិតនេះដូចជាគ្មានលក្ខណៈតម្លៃឲ្យយើងអាចចងភ្ជាប់ភស្តុតាងណាមួយរវាងជនរងគ្រោះនៅស-២១ ទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែលកំពុងតែតាំងខ្លួនធ្វើជាដើមបណ្ដឹងរដ្ឋប្ប-វេណីទេ។

ខ្ញុំក៏សម្ដែងនូវការអាណិតអាសូរ ប្រសិនបើគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីមែន ប៉ុន្តែគាត់គ្មានភស្តុតាងបង្ហាញ ដូចដែលអ្នកស្រីមេធាវីបានលើកឡើង។ ប៉ុន្តែនៅទីនេះ យើងអនុវត្តបទដ្ឋានត្រួតពិនិត្យលើភស្តុតាងដែលមានកំណត់ជាក់លាក់នៅក្នុងច្បាប់។ យើងមិនអាចយកបេះដូង ឬមនោសញ្ចេតនារបស់យើងមកធ្វើការវាយតម្លៃបានទេ។ ដូច្នេះ ប្រតិបត្តិនិក្ខេបបទបែបនេះត្រូវបានទាត់ចោល ហើយក្នុងច្បាប់ស្រុកក៏ដូចគ្នាដែរ។ ហេតុនេះខ្ញុំសុំឲ្យតុលាការទាត់ចោលនូវភស្តុតាងមួយនេះ។

[១៤:៥៤:១៣]

ឆ្លើយតបទៅនឹងសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ដែលនិយាយអំពីភស្តុតាងភ្ជាប់ទៅនឹងសាច់ញាតិ។ ប្រសិនបើយើងអាចរកឃើញថា ជាសាច់ញាតិណាមួយនោះក្នុងថ្នាក់ណាមួយនោះ យើងគួរគប្បីសម្លឹងមើលទៅលើក្រមរដ្ឋប្បវេណីប្រទេសកម្ពុជា ឬច្បាប់អាពាហ៍ពិពាហ៍រដ្ឋកម្ពុជា ដែលអាចនឹងដាក់ជូនមកដល់អង្គជំនុំជម្រះបាន ជាជាងការនិយាយអំពីក្តីអាណិតស្រឡាញ់ ឬមនោសញ្ចេតនា ដែលធ្វើឱ្យយើងហូរទឹកភ្នែកបានគ្រប់គ្នានោះ គឺមិនអាចជាភស្តុតាងទទួលយកបានទេ។

ហើយរូបថតវិញទៀត ខ្ញុំបាទសូមសួរថា រូបថតដែលលើកឡើងនេះតើជារូបថតនៅស-២១ ខ្ញុំសូមឱ្យលោកប្រធានមេត្តាអនុញ្ញាតឱ្យអ្នកម្ចាស់ខាងភស្តុតាងឆ្លើយភ្លាមដើម្បីកុំឱ្យខាតពេលវៀងខ្លួន។ វាបានមកពីស-២១ ឬក៏បានពីផ្ទះ ឬក៏បានមកពីទីកន្លែងដែលអ្នកដើមបណ្តឹងរដ្ឋប្បវេណីនោះតាំងខ្លួនបាទ? ដើម្បីខ្ញុំធ្វើការសន្និដ្ឋានជូនភ្លាម។

[១៤:៥៥:១៤]

**ប្រធានអង្គជំនុំ៖**

មេធាវីបង្ហាញបន្តិចមើល៍!

**លោកស្រី ម៉ុច សុវណ្ណារី៖**

រូបថតនេះ-- អរគុណលោកប្រធាន។ រូបថតនេះ គឺកូនក្តីរបស់ខ្ញុំបានប្រគល់ឱ្យខ្ញុំកាលពីព្រឹកមិញ រួចហើយខ្ញុំទើបតែឃើញរូបថតហ្នឹង។ រួចហើយខ្ញុំបញ្ជាក់គាត់ថារូបថតហ្នឹងយកមកពីណា? គាត់ថារូបហ្នឹង គឺជារូបថតដែលគាត់ថតចម្លងពីរូបថតនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។

ហេតុដូច្នេះហើយ បានជាខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីបញ្ចាំងទៅលើអេក្រង់នេះ ពីព្រោះមានចំណុចមួយ ដែលចង់ឱ្យអង្គសវនាការទាំងមូលពិនិត្យមើល ដើម្បីបញ្ជាក់ថា វាជារូបថតយកមកពីសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។ ដូច្នេះ បើសិនយើងបញ្ចាំងរូបថតដើមហ្នឹង យើងនឹងឃើញទាំងអស់គ្នា។

ដូច្នេះ បើសិនជាលោកប្រធានអនុញ្ញាត ហើយយើងចង់ដឹងច្បាស់ទាល់តែយើងបញ្ចាំងរូបថតហ្នឹង ហើយនាងខ្ញុំនឹងបង្ហាញ។

[១៤:៥៦:០៣]

**លោក កង ឫទ្ធារី៖**

បាទ, ខ្ញុំសូមបន្ត សូមលោកប្រធានមេត្តាអនុញ្ញាតឱ្យខ្ញុំបន្តទៀតទៅ ព្រោះខាតម៉ោងខ្ញុំ។ ខ្ញុំបន្ត

ហើយឆ្លើយតទៅវិញ។

**ប្រធានអង្គជំនុំ៖**

បាទៗ, សូមអញ្ជើញអង្គុយចុះ!

**លោក កង ឫទ្ធារី៖**

ជាអកុសលណាស់ដែលខ្ញុំបានទទួលចម្លើយអំពីអ្នកស្រីមេធាវី កញ្ញា ឬក៏អ្នកស្រី? បាទសុំទោសអ្នកស្រី។ អ្នកស្រីមេធាវី ប្រសិនបើរូបថតនេះ ខ្ញុំក៏មានចេតនាព្យាយាម ដូចដែលខ្ញុំជួយជ្រោមជ្រែងឲ្យមានការស្វែងរកយុត្តិធម៌នៅទីនេះបានដូចតែគ្នាហ្នឹង ខ្ញុំគ្មានចេតនាលាក់បាំងនូវអំពើឧក្រិដ្ឋដែលកើតឡើងនៅគុកទួលស្លែងទេ។ ដូចតែកូនក្តីខ្ញុំអ៊ីចឹង។ គាត់គ្មានចេតនាលាក់បាំងទេ គាត់សារភាពទាំងអស់។ ប្រសិនបើរូបភាពនេះ យើងយកបានពីផ្ទះសម្បែង ឬជាទ្រព្យផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងយកទម្រង់មុខនេះទៅផ្ទឹមជាមួយនឹងទម្រង់មុខដែលយើងរកបាននៅឯមន្ទីរស-២១ តាមវិធីសាស្ត្រ យើងអាចពឹងផ្អែកលើផ្នែកកោសល្យវិច័យ អាចធ្វើការវិភាគបាន ប្រហែលជាមានតម្លៃឲ្យអស់លោក អាចភ្ជាប់ខ្លួនមកជាដើមបណ្តឹងរដ្ឋប្បវេណីបាន។ នេះហើយជាវិធានភស្តុតាងដែលលោកត្រូវបង្ហាញ។ ខ្ញុំគ្មានចេតនាណែនាំចំណេះដឹងវិជ្ជាជីវៈទៅដល់ក្រុមមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀតទេ។ ប៉ុន្តែបើយកពីស-២១ ហើយគ្រាន់តែចង្អុលរូបថតថា នេះជាបងខ្ញុំ នោះបងខ្ញុំ នេះអ៊ីចេះ នោះអ៊ីចុះ ហើយមកទារលុយ តើវាត្រឹមត្រូវដែរឬទេ? គ្មាននរណាម្នាក់ជឿយើងបានទេ ទោះជាយើងឈឺចាប់យ៉ាងណាក៏ដោយ។

[១៤:៥៧:២៧]

ក្រុមទី២ បានសុំសំណងរដ្ឋប្បវេណី ជាបន្ទុករបស់ទណ្ឌិតផង ជាសមូហភាព ជាសហគមន៍ ឬតាមផ្លូវចិត្ត។ ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ មានការសុំសំណូមពរមានលក្ខណៈជាក់លាក់ គឺសំដៅឲ្យរដ្ឋសង មិនសុំឲ្យបុគ្គល កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាចារីសងទេ។ ប៉ុន្តែ ផ្ទុយទៅវិញក្រុម២ មានលក្ខណៈច្របូកច្របល់ ម្តងសុំឲ្យរដ្ឋចេញសង ម្តងសុំឲ្យចារីគឺ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចេញសង ហើយព្យាករណ៍ទុកទៀត បើថ្ងៃនេះក្រ ថ្ងៃក្រោយមានត្រូវចេញសងគេ។ វាដូចជាគ្មានបទដ្ឋានណាមួយថាតម្រូវឲ្យចៅក្រមពិចារណា ថាតើគួរឲ្យសងដោយរបៀបណា? ក្នុងករណីរកឃើញពិរុទ្ធភាព។ ពីព្រោះថា តាមមាត្រា២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងមនុស្សបីក្រុម។

ដូច្នេះ មួយណា ឬមួយក៏ចារីឲ្យសង ឬមួយក៏អ្នកសមគំនិតឲ្យសងត្រូវសង ឬមួយក៏អ្នកទទួល

ខុសត្រូវសំណងរដ្ឋប្បវេណី។ តាមច្បាប់យើងដឹងហើយ អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី គឺជាអ្នកណា។ ខ្ញុំគ្មានការធ្វើអត្ថាធិប្បាយលើរបៀបសង ដូចដែលលោក ហ្វីលីព កាណុន បានលើកឡើងនោះទេ។ វាជាមធ្យោបាយមួយដែលថា ខ្ញុំគិតថា អង្គចៅក្រមអាចពិចារណាបាន។

[១៤:៥៩:00]

តទៅនេះ ខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានតបរួមទៅនឹងក្រុមទាំងបីតែម្ដង។ ដោយហេតុថា ការលើកឡើងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងតែនឹងអត្តសញ្ញាណរបស់ជនរងគ្រោះ ហេតុនេះមេធាវីការពារជនជាប់ចោទ គ្មានចេតនានឹងទំទាស់ទេ គឺទុកឲ្យតុលាការជាអ្នកសម្រេច។ ភស្តុតាងដែលខ្ញុំបានជំទាស់ គឺជំទាស់រួចហើយ ឯភស្តុតាងផ្សេងទៀត ដែលខ្ញុំមិនបានជំទាស់ គឺទុកឲ្យឆន្ទានុសិទ្ធិរបស់ចៅក្រមជាអ្នកសម្រេចអំពីវិធាននៃភស្តុតាង។ ដូច្នេះ ខ្ញុំជំទាស់តែពីរអម្បាញ់មិញទេ ដោយសារវាបាត់តម្លៃនៃស្តង់ដារដែលយើងត្រូវត្រួតពិនិត្យអំពីភស្តុតាង។ ហេតុនេះនៅសល់ទាំងប៉ុន្មានដែលខ្ញុំគ្មានឯកសារ ខ្ញុំមិនចង់បង្កភាពល្អក់កករ នៃនីតិវិធីជម្រះក្ដីនៅទីនេះទេ។ សូមទុកឲ្យតុលាការជាអ្នកសម្រេចចុះ។

[១៤:៥៩:៥៥]

សំណុំរឿង០០១ ដែលមានជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាប្រធានសន្តិបាលនៃមន្ទីរសន្តិសុខស-២១ ជាគុកសម្ងាត់យោធា ដែលមានក្រុមអគ្គសេនាធិការ គឺមាន សុន សេន ជាអ្នកគ្រប់គ្រងក្នុងរបបរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានបង្កើតឡើង និងដាក់ឲ្យអនុវត្តនូវគោលនយោបាយពង្រឹងផ្នែកសន្តិសុខជាតិ និងការបោសសម្អាតផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា ដែលជាដើមហេតុបង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរដល់ជនរងគ្រោះជាអ្នកទោសនៅស-២១។

សេចក្ដីថ្លែងខ្ញុំនៅពេលនេះ មិនមានអ្វីខ្វែងទៅនឹងសេចក្ដីសារភាពប្រកបដោយវិប្បដិសារី របស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅពីក្រោយខ្នងខ្ញុំនេះទេ។ ហើយដែលវាបញ្ច្រាសទៅនឹងអ្វីដែលជាសេចក្ដីថ្លែងរបស់លោកមេធាវី ហ្វីលីព កាណុន ដែលនិយាយថា ការសុំទោសនោះវាមានលក្ខណៈចុងមាត់ចុងក។

[១៥:00:៥៥]

លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច គ្រាន់តែជាភ្នាក់ងារសន្តិសុខរដ្ឋមួយរូប ហើយរាល់សកម្មភាពអនុវត្តទាំងឡាយរបស់គាត់ក្នុងនាមជាប្រធានសន្តិបាលនៅស-២១ គឺប្រព្រឹត្តស្របតាមគោលនយោបាយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងបទបញ្ជាធម្មានុរូបពីថ្នាក់លើរបស់គាត់តែប៉ុណ្ណោះ មិនមែនជា

សកម្មភាពទាំងនោះមិនតំណាងឲ្យឆន្ទៈរបស់គាត់ទេ ហើយគាត់ក៏មិនដែលបានទទួលដោយខុសច្បាប់នូវទ្រព្យសម្បត្តិពីជនរងគ្រោះនៅស-២១ ដែរ។ បានន័យថា អំពើដែលគាត់ធ្វើគាត់ធ្វើតាមអំណាច និងគោលនយោបាយរបស់រដ្ឋ ដែលដាក់ចេញដោយបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់មិនដែលបានទទួលផលប្រយោជន៍អំពីសកម្មភាពគាត់ ឬក៏គាត់យកចាប់យកនូវទ្រព្យសម្បត្តិរបស់ជនរងគ្រោះនៅស-២១ ដោយខុសច្បាប់នោះទេ។ ហេតុនេះ ខ្ញុំសុំឲ្យមើលផង អំពីវិធាន១០០ នៃវិធានក្នុងរបស់ អ.វ.ត.ក មាត្រា២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន៨៧ នៃវិធានផ្ទៃក្នុង ស្តីអំពីភស្តុតាងនៃច្បាប់ អ.វ.ត.ក។

[១៥:០២:០៧]

ហេតុនេះ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាអ្នកទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះនៅស-២១ យោងតាមមាត្រាទី២១(៣) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងអំពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ បានន័យថា នីតិបុគ្គល គឺរបបកម្ពុជាប្រជាធិបតេយ្យជាអ្នកចេញគោលនយោបាយ បណ្តាលឲ្យស្លាប់ប្រជាជនទូទាំងប្រទេសនិងរងគ្រោះនៅទូទាំងប្រទេស ហើយនិយាយដោយឡែកគឺនៅស-២១ ក្នុងយុត្តាធិការនៃស-២១ ក៏មានជនរងគ្រោះដោយសារតែគោលនយោបាយនេះដែរ។ ដូច្នេះ អ្នកដែលដាក់ចេញ អ្នកដែលផ្តើមគំនិត ចេញជាគោលនយោបាយបង្កជាព្យសនកម្មនៅស-២១ ជាអ្នកទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណី។

[១៥:០២:៥៣]

យោងតាមសន្ធិសញ្ញាក្រុងវីយែន ស្តីអំពីច្បាប់សន្ធិសញ្ញា គឺចងភ្ជាប់កាតព្វកិច្ចរវាងរដ្ឋនិងរដ្ឋចំពោះសន្ធិសញ្ញាអន្តរជាតិ ហើយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសន្ធិសញ្ញាក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៩ គឺត្រូវឋិតនៅក្រោមយុត្តាធិការនៃច្បាប់អន្តរជាតិ។ ហេតុនេះ សន្ធិសញ្ញានេះមិនចងកាតព្វកិច្ចឲ្យបុគ្គលទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីឡើយ ឬការជួសជុលព្យសនកម្មណាមួយដែលកើតចេញពីគោលនយោបាយរបស់រដ្ឋទេ។ ដូចដែលខ្ញុំបានលើកហើយ គឺថា ច្បាប់នេះដែល--ឧក្រិដ្ឋកម្មដែលចោទប្រកាន់លើកូនក្តីរបស់ខ្ញុំជាឧក្រិដ្ឋកម្មអន្តរជាតិ។ បើឧក្រិដ្ឋកម្មអន្តរជាតិ ត្រូវអនុវត្តដោយច្បាប់អន្តរជាតិ ហើយច្បាប់អន្តរជាតិអនុវត្តតែទៅលើរដ្ឋទេ។ ដូច្នេះ មានតែរដ្ឋទេជាអ្នកទទួលខុសត្រូវផ្នែកសំណងរដ្ឋប្បវេណី។ តាមសន្ធិសញ្ញាក្រុងវីយែន ស្តីអំពីសិទ្ធិអំណាចរបស់រដ្ឋស្នង តាមមាត្រា២(បេ) មាត្រា២(សេ) មាត្រា២(ដេ) ខ្ញុំសូមទោសខ្ញុំអានជាបារាំងបន្តិច។ វាធ្លាប់មាត់បន្តិចដែរ

ហើយ។

[១៥:០៣:៥៨]

បាទ, សូមម្តងទៀត តាមសន្ធិសញ្ញាក្រុងវីយែន ស្តីអំពីសិទ្ធិអំណាចរបស់រដ្ឋស្នង *សាក់សេស សិន ស្តេត* (និយាយភាសាអង់គ្លេស) តាមាត្រា២(ប៊ី) ២(ស៊ី) ២(ឌី) គឺថា ក្រោយពេលដួលរលំនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ហើយរហូតមកដល់បច្ចុប្បន្ននេះ គឺរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ជាអ្នកទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះទាំងឡាយណាដែលជាជនរងគ្រោះពីការអនុវត្តគោលនយោបាយរបស់រដ្ឋនៅស-២១។ នេះបើសិនជាច្បាប់តម្រូវ ឲ្យមានសំណងរដ្ឋប្បវេណី។ មិនមែនខ្ញុំទាមទារឲ្យធ្វើដូច្នេះទេ ប្រសិនបើចៅក្រមរកឃើញថាទារឲ្យសង គឺមិនមែនទាមទារឲ្យ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះសងទេ គឺនីតិបុគ្គលដែលបញ្ជាគាត់គឺ រដ្ឋ។ ដូច្នេះ រដ្ឋាភិបាលស្នង គឺរដ្ឋាភិបាលបច្ចុប្បន្នជាអ្នកសង សងចុះសង់ៗប៉ុន្មានជាន់ អគារប៉ុន្មានឲ្យតែអស់លោកចៅក្រមសម្រេចទៅ លោកមេធាវីរីករាយនឹងទទួលហើយ។ អាចសង់ជាមន្ទីរពេទ្យសាលារៀន ដូចតែគ្នាហ្នឹង។ អានេះវាជារឿងរបស់រដ្ឋ មិនមែនជារឿងរបស់កូនក្តីខ្ញុំបាទទេ។ តម្រូវឲ្យសងសំណងរដ្ឋប្បវេណីហ្នឹង បើសិនជារកឃើញថា ជនជាប់ចោទពិតជាមានពិរុទ្ធភាពប្រាកដមែន។

[១៥:០៥:២២]

ត្បិតថាជនជាប់ចោទគ្រាន់តែបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខរដ្ឋ អនុវត្តតាមគោលនយោបាយរដ្ឋាភិបាលតែប៉ុណ្ណោះ។ ហើយបុព្វហេតុនេះការបង្កជាព្យសនកម្មដល់ជនរងគ្រោះនៅស-២១ គឺជាគោលនយោបាយរបស់រដ្ឋាភិបាល ហើយជនជនជាប់ចោទមិនដែលបានទទួលនូវទ្រព្យសម្បត្តិពីរងគ្រោះនៅស-២១ ម្តងណាទេ។

ជាថ្មីម្តងទៀត ខ្ញុំបាទសូមរំឭកថា តាមច្បាប់ជំនៀមទម្លាប់អន្តរជាតិ ដែលអស់លោកខ្លះតែងតែចង់យកមកប្រើពេកនោះ គឺធ្វើឲ្យបាត់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីវិញទេ។ តាមទំនៀមទម្លាប់អន្តរជាតិ គឺមិនអនុញ្ញាតឲ្យ គឺមិនដែលមិនមែនមិនអនុញ្ញាត គឺមិនដែលមាន ឬផ្តល់ឲ្យជនរងគ្រោះនូវការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយទទួលបាននូវសំណងរដ្ឋប្បវេណីទេ មិនដែលទាល់តែសោះ។ នេះជាប្រវត្តិសាស្ត្រលើកទី១ នៃសាលាជម្រះក្តីកម្រិតថ្នាក់ក្នុងជាតិ ប៉ុន្តែស្តង់ដារអន្តរជាតិ។ ទីមួយ ដែលផ្តល់ឱកាសឲ្យជនរងគ្រោះតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយទារសំណងបាន។ ហើយខ្ញុំសំណូមពរសូមឲ្យពិនិត្យមើលវិធាន១០០ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ផងដែរ។

បាទ, សូមបញ្ចប់សេចក្តីថ្លែងតែត្រឹមប៉ុណ្ណោះ និងសូមជូនវេទិកានេះទៅកាន់សហភាតាខ្ញុំ បើសិនជាគាត់ត្រូវការ។

**លោក ការ សាវុត្ថៈ**

សូមអរគុណ ហើយសូមគោរពឯកឧត្តមប្រធានសាជាថ្មី និងសូមគោរពអង្គជំនុំជម្រះ។

សូមទោស តើខ្ញុំនៅប៉ុន្មាននាទីទៀត ខាងខ្ញុំ?

**ប្រធានអង្គជំនុំៈ**

ម៉ោងបីដប់ប្រាំនាទីបញ្ចប់ហើយ។

**លោក ការ សាវុត្ថៈ**

សូមគោរពសាជាថ្មី។ ហើយទីមួយ ខ្ញុំសូមលើកឡើងអំពីការពាក់ព័ន្ធតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ តាំងពីនៅសាលាដំបូងរហូតមកដល់ពេលនេះ កូនក្តីខ្ញុំ កាំង ហ្គេកអ៊ាវ ហៅ ឌុច រង់ចាំតែទទួលដោយស្វាគមន៍បំផុតចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ ឲ្យតែដាក់ពាក្យមកបានត្រឹមត្រូវអាចឲ្យជឿបានថា ជាជនរងគ្រោះមែន ទទួលភ្លាមដោយដៃពីរ។ ប៉ុន្តែ កន្លងមក ខ្ញុំឃើញថា មានខ្លះដែលដាក់ពាក្យបណ្តឹងមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយពុំអាចឲ្យជឿបាន។ ហេតុនេះហើយបានជាសាលាដំបូងរដ្ឋធានីភ្នំពេញបានទាត់ចោល បានជាសហចៅក្រម អ.វ.ត.ក-- សុំទោសមិនមែនរដ្ឋធានីភ្នំពេញទេ វាធ្លាប់តែនៅឯនោះ វាចេះតែជ្រុលមាត់។ ហេតុនេះហើយបានជាសាលដំបូង អ.វ.ត.ក បានទាត់ចោលនូវការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន។

[១៥:០៨:២៨]

ខ្ញុំយល់ឃើញថា ការទាត់ចោលរបស់សាលាដំបូង គឺពិតជាត្រឹមត្រូវ។ ហេតុអីបានខ្ញុំយល់ថាត្រឹមត្រូវ? ខ្ញុំលើកតែមួយករណីមកជូនអង្គជំនុំជម្រះទេ។

ឧទាហរណ៍ ដូចអ្នកស្រី ណាំ ម៉ុន គាត់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនៅពេលសវនាការសាលាដំបូង ខ្ញុំបានសួរគាត់ថាតើគាត់កើតនៅឆ្នាំណា? គាត់ថា គាត់កើតនៅឆ្នាំ១៩៦៩ មិនដឹង៧០មិនដឹងទេកាលនុំង។ អ៊ីចឹង នៅឆ្នាំ៧៥ គាត់ទើបអាយុ៥ឆ្នាំ។ គាត់អាយុ៥ឆ្នាំ គាត់ជាបុគ្គលិកពេទ្យនៅស-២១ តើជឿបានទេ? អាហ្នឹងជាចំណុចទីមួយ។

ចំណុចទីពីរ បុគ្គលិកពេទ្យស-២១ មានទាំងអស់បីនាក់ ហើយក្នុងចំណោមបីនាក់ហ្នឹង មានម្នាក់គេនៅរស់។ ដល់ទៅយកម្នាក់នៅរស់មក ថាស្គាល់ ណាំ ម៉ុន ទេ គេថា អត់ស្គាល់ផង។ អ្ហូក! ពេទ្យ

គ្នាគាត់ហ្នឹង គាត់មិនទាំងស្គាល់ផង។ ដូច្នេះ ឲ្យខ្ញុំនែ ឲ្យ កាំង ហ្កេកអ៊ាវ ហៅ ឌុច នេះទទួលស្គាល់កើត គាត់កើតទេ? ជាការមិនអាចទទួលយកបាន។ នេះចំពោះការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលខ្ញុំសូមលើកឡើងតែប៉ុណ្ណោះ ហើយទុកអ្វីៗទៀតទុកជូនតុលាការ ជាអ្នកសម្រេច។

[១៥:០៩:៤៧]

ចំពោះពាក់ព័ន្ធនឹងសំណងរដ្ឋប្បវេណី អ្នកស្លាប់នៅស-២១ មានចំនួន១២.២៧០នាក់ បើតុលាការរកឃើញថា កាំង ហ្កេកអ៊ាវ ហៅ ឌុច នេះ បានដើរទៅចាប់គេតាមចិត្តរបស់ខ្លួន ដោយគ្មានបញ្ជាពីបក្សកុម្មុយនីស្តកម្ពុជា ដោយគ្មានបញ្ជាពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ បើរកឃើញអ៊ីចឹង ខ្ញុំថា កាំង ហ្កេកអ៊ាវ ពិតជាត្រូវទទួលខុសត្រូវរឿងជាប់សំណងរដ្ឋប្បវេណី។ ក៏ប៉ុន្តែ កន្លងមកតុលាការបានរកឃើញហើយ ថាអ្នកបញ្ជាឲ្យសម្លាប់ គឺបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ជាអ្នកបញ្ជាឲ្យយកទៅសម្លាប់។ បើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាអ្នកបញ្ជា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ត្រូវតែទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណី មិនមែន កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលគ្រាន់តែជាប្រធានឆ្នាំគុក ចាំតែអនុវត្តតាមបញ្ជានោះទេ។

នេះជាការលើកឡើងរបស់ខ្ញុំប៉ុណ្ណោះ ហើយខ្ញុំសូមបញ្ចប់ ពីព្រោះថាអ្វីទាំងប៉ុន្មាន គឺថាសហមេធាវីបានលើកអស់ហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះតុលាការកំពូល ប្រកាសសម្រាកហើយម៉ោងដប់ប្រាំ សែសិបប្រាំនាទី យើងបន្តទៅទៀត ហើយសូមអញ្ជើញលោកមន្ត្រីពន្ធនាគារ នាំជនជាប់ចោទទៅសម្រាក។

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៥:១២ នាទី ដល់ម៉ោង ១៥:៤២ នាទី)*

[១៥:៤១:៥៥]

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។ ជាបន្តទៅទៀតនេះ គឺចម្លើយតបរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ ក្រុមពីរ និងក្រុមបី។ ខ្ញុំសូមជម្រាបដែលថា មួយក្រុមគឺមានរយៈពេលដប់នាទី។ សូមអញ្ជើញឡើងធ្វើសេចក្ដីសន្និដ្ឋាន។ សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ នាងខ្ញុំសូមធ្វើការឆ្លើយទៅនឹងសំណួរមួយសំណួររបស់មេធាវីការពារក្ដី ពាក់ព័ន្ធទៅនឹងតម្លៃនៃលិខិតដែលខាងក្រុមនាងខ្ញុំបានដាក់កាលព្រឹកមិញ។ ទាក់ទងទៅនឹងសំណួរនេះដែរ នាងខ្ញុំក៏មានចម្ងល់ផងដែរថា មិនដឹងថាតើលោកមេធាវីដែលបានលើកជាសំណួរនេះឡើង ធ្លាប់បានធ្វើការសិក្សាទៅលើឯកសាររបស់កូនក្ដីរបស់ខ្ញុំតាំងពីដំណាក់កាលដំបូងនៃសវនាការមករហូតមកដល់ពេលបច្ចុប្បន្នហើយឬនៅ?

[១៥:៤៣:៤៩]

ដូច្នេះ នាងខ្ញុំសុំឲ្យលោកមេធាវីការពារក្ដីធ្វើការពិចារណា-- អឺ! ធ្វើការសិក្សាទៅលើសំណុំឯកសាររបស់កូនក្ដីខ្ញុំសារឡើងវិញ បើសិនជាមានឱកាស។

ទាក់ទងទៅនឹងលិខិតដែលខ្ញុំបានដាក់ពីព្រឹកមិញ សួរថាតើលិខិតមួយហ្នឹងអាចមានតម្លៃដែលឲ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកដើម្បីធ្វើការពិចារណាបាន ឬក៏អត់?

នាងខ្ញុំសូមឆ្លើយថា លិខិតនេះ ពិតជាលិខិតដែលមានតម្លៃដែលដល់-- ដើម្បីដាក់ជូនអង្គជំនុំ--

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីបញ្ជាក់អំពីលិខិតហ្នឹងផង ដើម្បីឲ្យខាងគេកត់ប្រតិចារឹកដើម្បីកត់បាន តែខំកត់អត់បានទេ។ បាទ, សូមអញ្ជើញបញ្ជាក់ឲ្យបានច្បាស់។

**លោកស្រី ទី ស្រ៊ីនណា៖**

លិខិតដែលខ្ញុំកំពុងតែលើកឡើងនេះ គឺជាលិខិតដែលធ្វើឡើងដោយអធិការនគរបាលស្រុកមង្គលបុរី ដែលមានលេខ១៤២/០១១ ធ្វើឡើងដោយអនុសេនីយ៍ទោ ឱម សុផៃ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០១១។

នាងខ្ញុំសូមឆ្លើយថា លិខិតនេះពិតជាមានតម្លៃដល់អង្គជំនុំជម្រះតុលាការកំពូលយកទៅពិចារណាថាតើកូនក្តីរបស់ខ្ញុំ លី ហ៊ី ហើយនិង អ៊ា ហ៊ារ ជាមនុស្សតែម្នាក់ ឬក៏យ៉ាងណា?

នាងខ្ញុំសូមបញ្ជាក់ថា លិខិតនេះ គឺជាលិខិតផ្លូវការដែលបានធ្វើឡើងដោយអធិការនគរបាលស្រុកមង្គលបុរី។ ដែលកូនក្តីរបស់-- នៅឯលំនៅដ្ឋានដែលកូនក្តីរបស់ខ្ញុំរស់នៅសព្វថ្ងៃ។

[១៥:៤៥:៣៩]

លិខិតនេះផងដែរ គឺជាលិខិតដែលសំខាន់មួយ សម្រាប់បញ្ជាក់បន្ថែមទៅលើការអះអាងរបស់កូនក្តីរបស់នាងខ្ញុំកន្លងមក។ ដែលការអះអាងរបស់កូនក្តីរបស់នាងខ្ញុំកន្លងមកត្រូវបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង។

ដូច្នេះ វាគឺជាលិខិតផ្លូវការមួយដែលមានតម្លៃ ដែលអាចឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការពិចារណាបាន។

ចំណុចមួយទៀត ដែលខ្ញុំបានអះអាងថា លិខិតនេះ គឺជាលិខិតដែលមានតម្លៃនោះ គឺនៅក្នុងលិខិតនេះ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងលិខិតនេះមានចំណុចមួយចំនួនអាចឲ្យអង្គជំនុំជម្រះតុលាការកំពូលលើកយកមកពិចារណាដើម្បីធ្វើការប្រៀបធៀបជាមួយនឹងចម្លើយសារភាពរបស់កូនក្តីរបស់ខ្ញុំ នៅមន្ទីរស-២១។ ដោយចម្លើយសារភាពនុំង គឺមានឯកសារដែលមានលេខ E2/61.2។

[១៥:៤៦:៥១]

នាងខ្ញុំគិតថា លិខិតនេះ គឺជាលិខិតមួយដែលមានចំណុចពិសេសក្នុងការបំពេញបន្ថែមទៅឲ្យឯកសារទាំងឡាយដែលមាននៅក្នុងសំណុំរឿងស្រាប់។

ដូច្នេះនាងខ្ញុំសូមឲ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាពិនិត្យ និងពិចារណាដោយយកលិខិតនេះដោយទទួលយកនូវលិខិតនេះ។ សូមអរគុណ។

**លោក ហុង គីមសួន៖**

ដោយសារលោកឯកឧត្តមប្រធានមានប្រសាសន៍ឲ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ក្រុម២ ក្រុម៣ ធ្វើការឆ្លើយតបមានរយៈពេលដប់នាទី ខ្ញុំបានតំណាងឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរសូមធ្វើការកត់សម្គាល់ទៅលើការឆ្លើយតបរបស់សហមេធាវីការពារជនជាប់ចោទ។

បើតាមប្រសាសន៍របស់មេធាវី កង ឫទ្ធារី ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច គួរជាការទទួលយកបាននូវសម្តីសុភាពរាបសាច្រើនណាស់។ ដោយលោកបានដាក់តឿនដល់

លោក ហ្វីលីព កាណុន ពីពេលមុនបន្តិចនេះ។ ក៏ប៉ុន្តែ អ្វីដែលលោកបានលើកឡើងអំពីទាក់ទងជាមួយនឹងការបង្ហាញភាព ឬក៏សេចក្តីស្រឡាញ់ ស្រឡាញ់ពិសេស ឬការបង្ហាញពីភាពទំនាក់ទំនង ដូចដែលលោកលើកឡើងទាក់ទងជាមួយនឹងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឬយើងហៅថាស្តង់ដារ នៃការបង្ហាញភស្តុតាងនៅក្នុងតុលាការក្នុងសម័យបច្ចុប្បន្ននេះ។

ខ្ញុំសូមជម្រាបជូនថា កូនក្តីរបស់ខ្ញុំបាទដែលជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានច្រានចោលទាំងប្រាំនាក់ ទីមួយមានឈ្មោះ លៀង កន, ទីពីរ ណាំ ម៉ុន, ទីបី ហុង សាវ៉ាត, ទីបួន ឈឹម ស៊ីថា, និងទីប្រាំ ឈ្មោះ ញិប គីមស្រ៊ា។

[១៥:៤៨:៥៣]

ខ្ញុំបាទ សូមជម្រាបថា បើសិនជាយកការភាពទាក់ទងគ្នា ឬភាពច្បាស់លាស់បែបធ្វើកោសល្យវិច័យវិញនោះ តុលាការនេះមិនអាចធ្វើអ្វីទៅរួចទេ។ ទៅគាស់ខ្មោចពីរបីកន្លែង រាប់ពាន់ រាប់ម៉ឺនយកមកធ្វើកោសល្យវិច័យសិនទើបយកមកធ្វើកាត់ក្តីបាន។

អ៊ីចឹង សួរថាជនរងគ្រោះទាំងអស់នេះ ដែលលោកមេធាវី កង ឫទ្ធារី គាត់លោកមានប្រសាសន៍មកអម្បាញ់មិញនេះ។ គាត់មិនចង់ឲ្យមានភាពញុះញង់ទេ ប៉ុន្តែកន្លែងហ្នឹងបើមិននិយាយទៅគឺមិនបាន។ តើមានកោសល្យវិច័យហើយឬនៅតុលាការនេះ ថាអ្នកដែលស្លាប់ទៅជាមួយនឹងរូបថត បង្ហាញទៅជាមួយជនរងគ្រោះដែលបានភស្តុតាងមកដាក់តុលាការថា នេះហើយជាឈាមប្រភេទអា ប្រភេទបេ ឬអាបេ ឬអូ នោះ។ ជឿជាក់ថាអ្នកហ្នឹងបងប្អូនទេ? ជាប់សាច់ឈាមទេ? នោះវាទៅមិនរួចទេ។

[១៥:៤៩:៣៧]

អ៊ីចឹង គេយកស្អីយកមកធ្វើជាមូលដ្ឋាន? គឺទីមួយ បើសិនជាភស្តុតាងមាននៅក្នុងគុកទួលស្លែង ឬមន្ទីរស-២១ មានភាពទាក់ទងមិនមែនអាស្រ័យលើលោកមេធាវីគ្រាន់តែបដិសេធហ្នឹងបានការទេ គឺសំអាងទៅលើអង្គជំនុំជម្រះនៃតុលាការជាអ្នកសម្រេច។

អ៊ីចឹង សូមបងប្អូនដែលជាជនរងគ្រោះកុំអន់ចិត្ត កុំបាក់ស្មារតី មិនមែននាទីនេះមេធាវីការពារគាត់ជាអ្នកសម្រេចទេ។ ព្រោះអម្បាញ់មិញមានកូនក្តីខ្ញុំពីរនាក់ហើយដែលដួលសម្លាប់យំស្រែកដោយសារឈឺចាប់នឹងសម្តីដែលលើសពីការញុះញង់ទៅទៀត។

អ៊ីចឹង អ្វីដែលខ្ញុំលើកឡើងនេះ គ្រាន់តែចង់បញ្ជាក់ថា ភាពបង្ហាញនូវភាពស្រឡាញ់នោះ តើស្តង់ដារមួយណាដែលបង្ហាញភាពនៃសេចក្តីស្រឡាញ់ពិសេស។ នេះដែលលោកប្រធានបានជម្រាប បាន

សួរមកលើខាងយើងខ្ញុំ ឲ្យបង្ហាញពីភាពស្រឡាញ់ ឬក៏លក្ខខណ្ឌដែលថា សាលាដំបូងគាត់ធ្វើការលើកឡើងខ្ពស់ពេក ដែលយើងផ្តល់មិនបាននោះ។ យកមួយណាជាស្តង់ដារ?

[១៥:៥០:២៨]

ទោះបីស្តង់ដារបែបតុលាការព្រហ្មទណ្ឌអន្តរជាតិមិនទាន់មានក៏ដោយ ប៉ុន្តែនេះក៏តុលាការកូនកាត់មួយដែរ។ យកភស្តុតាងទាំងឡាយដែលគួរយកជាការបាន អាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេច។

ទីពីរ ទាក់ទងជាមួយនឹងមេធាវី ការ សារុត្ត ដែលលោកលើកឡើងទាក់ទងជាមួយកូនក្តីខ្ញុំបាទម្នាក់ទៀតឈ្មោះ ណាំ ម៉ុន ដែលលោកយកពាក្យប្រហែលជាឆ្នាំ៦៩ ឬ៧០គត់។ បើនិយាយតាមច្បាប់មាត្រាទី៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាវិញ វិមតិសង្ស័យ ឬភាពមិនច្បាស់លាស់ទាត់ចោលដូចគ្នា។ អ៊ីចឹងកុំយកពាក្យប្រហែលយកមកនិយាយ វាអត់ប្រយោជន៍ដូចគ្នា។

អ៊ីចឹង បន្តិចទៀតមេធាវី ស៊ីលឃីស្វូត ហ្សីនស្គី នឹងធ្វើការឆ្លើយតបបន្តទៀត។ សូមអរគុណ។

[១៥:៥១:១៧]

**លោកស្រី ស៊ីលឃីស្វូត ហ្សីនស្គី៖**

ខ្ញុំសូមឆ្លើយតបទៅនឹងមេធាវីការពារក្តី។ មុននឹងចាប់ផ្តើម ខ្ញុំសូមលើកឡើងនូវ សូមឆ្លើយតបទៅនឹងមេធាវីការពារក្តី ហើយខ្ញុំសូមមេត្តាយកចិត្តទុកដាក់នៅពេលដែលខ្ញុំនិយាយ ទាំងអ្នកនៅក្នុងបន្ទប់សវនាការខាងក្នុងនេះ ក៏ដូចជានៅបន្ទាប់សាធារណៈខាងក្រៅនេះ គឺខ្ញុំចង់ឲ្យទាក់ទងទៅនឹងឥរិយាបថរបស់មេធាវីការពារ គឺម្នាក់បានស្រែក និងឮៗ ហើយម្នាក់ស្រែក ម្នាក់ញញឹម។

អ៊ីចឹង ខ្ញុំសូមថា ធ្វើឥរិយាបថប្រកបដោយសេចក្តីថ្លៃថ្នូរ ខ្ញុំសូមលើកឡើងនូវកំណត់សម្គាល់មួយចំនួនដែលខ្ញុំបានសង្កេតឃើញថា សារណា គឺនៅក្នុងសារណានេះ គឺថាមានការបដិសេធទៅលើការទទួលខុសត្រូវ។ ហេតុម៉េចបានជាដូច្នេះ?

នៅពេលដែលយើងនិយាយទៅដល់បញ្ហាសំណង ខ្ញុំបានកត់សម្គាល់ឃើញថា ការទទួលខុសត្រូវចំពោះសំណង គឺបានទម្លាក់បន្ទុកទៅឲ្យបក្សកុម្មុយនីស្តកម្ពុជា ដែលយើងហៅថា “អង្គការ” ហើយជនជាប់ចោទបានបដិសេធមិនទទួលខុសត្រូវនៅក្នុងបញ្ហាសំណងនេះ។ ហើយយោងទៅតាមវិធានផ្ទៃក្នុងអ្នកដែលត្រូវទទួលខុសត្រូវ ប្រឈមមុខនឹងទទួលខុសត្រូវដើម្បីចំណាយទៅលើសំណងដែលយើងបានស្នើសុំនេះ។

[១៥:៥៣:២៧]

ក្រៅពីចំណុចទាំងប៉ុន្មាននេះ ជាការពិតណាស់មានការទទួលខុសត្រូវរបស់រដ្ឋ ហើយជាពិសេស គឺរដ្ឋស្នងនេះតែម្តង ដែលយោងទៅតាមគោលការណ៍ជាមូលដ្ឋាន និងយោងទៅលើគោលការណ៍ជាមូលដ្ឋានសម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្មដ៏ធំធេងនេះ។ សម្រាប់ឲ្យរដ្ឋស្នងបង្កើតនូវថវិកាជាតិណាមួយ ឬក៏ចារីនៃបទល្មើសចំណាយចំនួនទឹកប្រាក់ទៅតាមសំណងដែលបានទាមទារនេះ។ ហើយនេះដោយសារថា ចំណុចនេះគឺវាលើសពីអ្វីដែលបានផ្តល់ឲ្យនៅក្នុងវិធានផ្ទៃក្នុង ដែលបានអនុញ្ញាតនៅក្នុងវិធានផ្ទៃក្នុង។

និយាយអំពីការទទួលខុសត្រូវរបស់រដ្ឋវិញ គឺយើងនិយាយអំពីជំនួយដែលយើងបានស្នើសុំឲ្យរដ្ឋជួយ គឺរាជរដ្ឋាភិបាលកម្ពុជានេះឯងផ្តល់ជំនួយផ្សេងៗ។

[១៥:៥៤:៣៨]

ចំណុចបន្ទាប់របស់ខ្ញុំគឺពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី ណាំ ម៉ុន ដែលខ្ញុំបានរំពឹងហើយថា មេធាវីការពារក្តីនឹងបន្តជំទាស់ពាក្យសុំនេះតទៅទៀត ហើយព័ត៌មានសំខាន់មួយសម្រាប់មេធាវីការពារក្តីនោះ គឺលោកស្រី ណាំ ម៉ុន ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ គឺដោយសំអាងទៅលើមូលដ្ឋាននៃមន្ទីរសន្តិសុខស-២១ នេះឯង។

ចំណុចបន្ទាប់ដែលទាក់ទងទៅនឹងលោកស្រី ណាំ ម៉ុន នេះ គឺ-- ខ្ញុំដឹងថាជនជាប់ចោទបានបដិសេធយ៉ាងដាច់អហង្ការទៅលើពាក្យសុំនេះ ដោយសារថាលោកស្រី ណាំ ម៉ុន សក្ខីកម្មរបស់អ្នកស្រី ណាំ ម៉ុន ដែលបានផ្តល់ទាក់ទងអំពើប្រព្រឹត្តផ្ទាល់ អំពើកាប់សម្លាប់របស់ជនជាប់ចោទ ដែលជនជាប់ចោទបានបដិសេធគ្រប់ពេល។ ហើយជនជាប់ចោទ បានឆ្លើយថាលោកស្រី ត្រូវបានផ្លាស់ប្តូរពីស-២១ នេះទៅស-២៤ ហើយលោកស្រីថាដូច្នេះ តែជនជាប់ចោទក៏បានបដិសេធទៀត។

[១៥:៥៦:០២]

ទាក់ទងទៅនឹងថ្ងៃកំណើតរបស់លោកស្រី គឺបានបញ្ជាក់ហើយនៅក្នុងសវនាការសាលាដំបូងដែលថាលោកស្រីកើតនៅក្នុងឆ្នាំ១៩៦០ ដូច្នេះមិនមានអ្វីគួរឲ្យមន្ទិលសង្ស័យទេថា ឯកសារនេះក៏ដូចជាអត្តសញ្ញាណប័ណ្ណ គឺបានបង្ហាញ ឬក៏ផ្តល់ជូន-- ក៏ដូចជាព័ត៌មានដែលសាច់ញាតិរបស់គាត់បានផ្តល់ជូន គឺវាមានមិនស្របទៅតាមតថភាពពិតនេះ ប៉ុន្តែវាជាចំណុចពិសេសណាស់នៅពេលដែលអ្នកណាម្នាក់គឺថាមិនអាចស្វែងរកឯកសារឲ្យបានគ្រប់គ្រាន់ដើម្បីបង្ហាញជូននេះ។ ខ្ញុំយល់ស្របចំណុចនេះ។ ប៉ុន្តែ

ខ្ញុំបដិសេធចំពោះសេចក្តីថ្លែងរបស់មេធាវីការពារក្តីដែលបានលើកឡើងនេះ ទាក់ទងទៅនឹងលោកស្រី ណាំ ម៉ុន។

ខ្ញុំសូមបញ្ចប់ត្រឹមហ្នឹងទៅចុះ ហើយសូមប្រគល់នាទីនេះទៅសហភាតារបស់ខ្ញុំខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣។ សូមអញ្ជើញ!

[១៥:៥៧:០៧]

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

ខ្ញុំសូមឆ្លើយតបទៅនឹងសេចក្តីសង្កេតការពារក្តី នឹងដើម្បីផលប្រយោជន៍ក្រុម៣។ ខ្ញុំសូមលើកនូវចំណុចមួយចំនួន ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្ញុំ។ ខ្ញុំសូមរំឭកអំពីការសង្ឃឹមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះក្តីនេះ ហើយខ្ញុំសូមរំឭកថា នេះគឺជាការផ្តន្ទា ឌុច ថាជាពិរុទ្ធភាពដែលបង្កើតនូវភាពសាហាវឃោរឃៅនៅសម័យនោះ។ គឺថាសាច់ញាតិរបស់ពួកគេ គឺជាអ្នករងគ្រោះ ដូច្នេះប្រសិនបើ ឌុច មិនត្រូវបានវិនិច្ឆ័យទោស គឺពួកគេមិនអាចជាពីការសះស្បើយនូវទុក្ខវេទនាដែលពួកគេបានទទួលនេះទេ។

[១៥:៥៧:៥៤]

ខ្ញុំសង្កេតឃើញថា មនុស្សម្នាក់ដែលស្នើសុំនូវការសុំអភ័យទោស ហើយបានប្រែខ្លួនទៅជាកាន់សាសនាគ្រិស្តនោះ គឺថាយើងមានមុខទីពីររបស់បុគ្គលតែមួយនៅទីនេះ។ គឺថា គឺមនុស្សដែលកំសាកដែលបានបដិសេធនូវការទទួលខុសត្រូវរបស់ខ្លួន ហើយបានការពារខ្លួននៅពីក្រោយការស្ងៀមស្ងាត់ គឺបានលាក់បាំងខ្លួននៅក្រោយពីមេធាវីរបស់ខ្លួន។ គឺយើងមិនបំភ្លេចនូវការសោកស្តាយដែលបានសម្តែងដោយ ឌុច នៅពេលបើសវនាការដំបូង។

នៅសម័យនោះ គឺថាយើងមានសង្ស័យមួយចំនួនពាក់ព័ន្ធទៅនឹងការសួរថា តើ ឌុច ការសោកស្តាយរបស់ ឌុច ពាក់ព័ន្ធទៅនឹងអ្វីដែលគេបានឃុំខ្លួន? ឌុច មិនបាននិយាយអំពីសារភាពពិតប្រាកដនោះដើមបណ្តឹងរដ្ឋប្បវេណី គឺថាចង់ឃើញឲ្យបុរសនោះ ដែលបានការពារនូវជំនឿជាក់ខាងនយោបាយនៅសម័យនោះ ទោះបីវានាំទៅដល់នូវវិនាសកម្មដែលមិនអាចស្រមៃឃើញនៅក្នុងប្រទេសក៏ដោយ។ គឺថាវាមានភាពរន្ធត់ចំពោះពួកគេទាំងអស់គ្នា ហើយយើងអាចយល់អំពីការបញ្ជាក់នូវអំពើទាំងអស់នេះ គឺថាពេជ្ឈឃាដនេះបានការពារខ្លួននៅក្រោមការភ័យខ្លាចទៅលើឋានុក្រមនៅក្នុងសម័យនោះ ហើយគាត់គឺបានបង្កើតនូវភាពសាបព្រោះនូវភាពភ័យខ្លាច។ ហើយគាត់បង្កើតនូវម៉ាស៊ីនសម្រាប់ការធ្វើទារុណកម្ម

នៅសម័យខ្មែរក្រហម។ គាត់បានបង្កើតនៅវិធីសាស្ត្រក្តៅនិងវិធីសាស្ត្រត្រជាក់ ហើយគាត់បានសរសេរនូវសៀវភៅតូចមួយដើម្បីបង្រៀន ហើយនឹងអាចបញ្ជូនបន្តទៅដល់អ្នកជំនាន់ក្រោយនឹងអាចអនុវត្តបាន។

[១៥:៥៩:៣០]

ហើយចំណុចនេះមិនមែនជាការចៃដន្យទេ គឺវាជាវិធីសាស្ត្រធ្វើការងារដ៏ស៊ីជម្រៅមួយរបស់ ឌុច ដែលនៅក្នុងវិស័យមួយដែលមិនអាចស្រមើស្រមៃបាន គឺការធ្វើទារុណកម្ម។ តើឌុច គាត់ចង់និយាយអ្វីទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលដែល ឌុច ប្រឈមមុខនឹងដើមបណ្តឹងរដ្ឋប្បវេណី? ប្រសិនបើគាត់រក្សាការស្ងៀមស្ងាត់មិននិយាយអ្វីនោះ គឺថាមានតែសេចក្តីសម្រេចរបស់តុលាការតែប៉ុណ្ណោះ ដែលអាចឆ្លើយតបទៅនឹងការទន្ទឹមចង់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ហើយគឺថា មិនតិចជាង១០០នាក់ដើមបណ្តឹងរដ្ឋប្បវេណីទេ គឺថាគាត់នៅតែទន្ទឹមរង់ចាំនៅសេចក្តីសម្រេច ដែលមានលក្ខណៈជាអន្តរជាតិ។

[១៦:០០:១៦]

ហើយយើងត្រូវតែគិតឃើញទៅដល់រយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំនៃឆ្នាំ៧៥ ដល់ឆ្នាំ៧៩ ដែលជារបបសាហាវព្រៃផ្សៃ។ ដូច្នេះ មន្ទីរស-២១ គឺជាការសម្រេចនូវប្រព័ន្ធដ៏សាហាវឃោរឃៅ ហើយបុគ្គលទាំងអស់ដែលបានចូលទៅក្នុងមន្ទីរស-២១ គឺត្រូវតែសម្លាប់ចោល។ មន្ទីរស-២១ សព្វថ្ងៃនេះចំពោះដើមបណ្តឹងរដ្ឋប្បវេណី គឺជាកន្លែងដែលរស់រវើកនៃអនុស្សាវរីយ៍របស់ពួកគេ។ ហេតុដូច្នេះ ហើយបានជាដើមបណ្តឹងរដ្ឋប្បវេណីទទូចចង់បានកន្លែងនេះ គឺជាកន្លែងដែលមិនអាចរំលោភបាន ហើយគឺបានស្នើសុំនូវរូបមន្តផ្សេងៗ ដើម្បីបង្កើតស្តូបអនុស្សាវរីយ៍ដើម្បីជាការរំឭក។

[១៦:០០:៥៨]

ក្រុម៣ គឺបានផ្តល់ឲ្យយើងជាអ្នកនាំពាក្យក្នុងការលើកឡើងនូវគម្រោងរបស់ "សមាគមក្សេមក្សាន្ត" ដែលមានជនរងគ្រោះរាប់ពាន់នាក់ដែលបានចូលរួមនៅក្នុងសមាគមនេះ។ ហេតុនេះហើយបានជាសហភាតារបស់ខ្ញុំ គឺមិនបានទទួលនូវពាក្យសុំនេះ គឺថាដោយសារតែមានបញ្ហាខាងផ្នែកបច្ចេកទេស ហើយខ្ញុំចង់ឲ្យរូបភាពទាំងអស់នេះគឺថាត្រូវបានបញ្ចាំងនៅក្នុងអេក្រង់ ដើម្បីឲ្យយើងមានលទ្ធភាពនៅក្នុងការទទួលស្គាល់នូវនឹងគម្រោងនេះ ដែលការសាងសង់ស្តូបនៅមន្ទីរស-២១។ ដើម្បីជាការរំឭកទៅដល់ជនរងគ្រោះ ហើយដើម្បីឲ្យកន្លែងនេះក្លាយជាកន្លែងស័ក្តិសិទ្ធិដែលមិនអាចរំលោភ ហើយក្លាយជាកន្លែង ដែលជាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ទោះបីជាកន្លែងនេះជាកន្លែងដែលឈឺចាប់កាលពីមុនក៏ដោយ។

[១៦:០១:៥២]

បើអ៊ីចឹង ខ្ញុំសូមចង់ឲ្យផ្នែកសោតទស្សន៍បញ្ចាំងផ្សាយរូបថតទាំងអស់ ទាំងបីនេះ។ ខ្ញុំសូមបញ្ចប់ថា នៅក្នុងលក្ខខណ្ឌកំហិតនៃបទប្បញ្ញត្តិដែលមានលក្ខណៈកម្រិតនោះ ប៉ុន្តែសេចក្តីសម្រេចនោះគឺថាអាចបង្កើតឲ្យមានស្ថានភាពនោះបាន។ គឺថា គឺជាការជំរុញមួយដែលមានលក្ខណៈផ្លូវចិត្ត ហើយក៏មានលក្ខណៈនយោបាយដែរ ហើយវាគឺជាអ្វីដែលមានប្រសិទ្ធភាព។ គឺថាយើងអាចធ្វើឲ្យជនរងគ្រោះដែលជាជនរងគ្រោះផ្ទាល់នៅមន្ទីរស-២១ មានសុវត្ថិភាព ហើយគាត់ដឹងថាកន្លែងទាំងអស់នេះ គឺថាមិនត្រូវបាន-- នៅថ្ងៃអនាគត គឺថាមិនអាចបំផ្លាញចោលបានឡើយ។ អ៊ីចឹង សូមឲ្យបញ្ចាំងផ្សាយរូបទាំងនេះ។

[១៦:០២:៥៧]

**លោក គឹម ម៉េងឃី៖**

សូមគោរពលោកប្រធាន, សូមអនុញ្ញាតអំពីលោកប្រធានមេត្តាចាត់ឲ្យមន្ត្រីតុលាការ ដើម្បីធ្វើបញ្ចាំងរូបនេះនៅក្នុងគោលបំណងបង្ហាញឲ្យភាគីបានឃើញរូបភាពនៅក្នុងអេក្រង់ទូរទស្សន៍ផង និងគោលបំណងបង្ហាញឲ្យអ្នកដែលបានចូលរួមបាននេះបានដឹងគ្រប់គ្នាផង--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសូមអញ្ជើញធ្វើសេចក្តីសន្និដ្ឋាននេះទៅ ហើយលោកខាងតុលាការគឺសូមអញ្ជើញដាក់ទៅដើម្បីទាន់ពេលវេលា។

[១៦:០៣:២៤]

**លោក គឹម ម៉េងឃី៖**

បាទ, គឺថាគម្រោងរបស់ "សមាគមក្សេមក្សាន្ត" រូបភាពទី១ នេះ គឺពាក់ព័ន្ធទៅនឹងទីតាំងនៃការស្នើសុំឲ្យដាក់ស្តូបក្សេមក្សាន្ត គឺមានទីតាំងនៅក្នុងបរិវេណនៃសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនេះ ហើយអស់លោកនឹងឃើញនៅក្នុងរូបនេះហើយ គឺថាគឺមានដាក់អក្សរថា "ស្តូបក្សេមក្សាន្ត" នេះ។ ពាក្យថា "ក្សេមក្សាន្ត" ពាក្យខ្មែរយើងមបានន័យថា សេចក្តីស្ងប់សុខចាកផុតពីទុក្ខទោះបីក្នុងជាតិនេះរហូតទៅដល់ជាតិមុខក៏ដោយ។ នេះហើយគឺជាទិសដៅរបស់សមាគមន៍ជនរងគ្រោះ ដែលស្នើសុំឲ្យមានស្តូបមួយជាប្រវត្តិសាស្ត្រ សម្រាប់ក្មេងជំនាន់ក្រោយ ក៏ដូចជាមនុស្សជាតិទាំងអស់ ដើម្បីឲ្យជនរងគ្រោះទាំងអស់បានមានសេចក្តីសុខទៅអនាគតនៅក្នុងបច្ចុប្បន្នជាតិ និងអនាគតជាតិ។

[១៦:០៤:២២]

សុំដាក់រូបទី២ គឺរូបនេះ គឺរូបទី២៧ គឺបង្ហាញអំពីរូបរាងស្តូប ដែលគូសឡើងដោយលោក វ៉ាន់ ណាត ដែលជាអ្នករស់រានមានជីវិតមន្ទីរស-២១ ហើយមានការចូលរួមអំពីអតីតអ្នករស់រានមានជីវិតទាំងអស់ ហើយនិងការយល់ព្រមអំពីដើមបណ្តឹងរដ្ឋប្បវេណី ទាំងក្នុងសំណុំរឿង០០១, ០០២ និងមតិមហាជនជាទូទៅចំពោះការគាំទ្រនូវរូបនេះ ហើយធ្វើបែបនេះ គឺមិនមានការប្រកាន់នូវពូជសាសន៍ រើសអើង ឬក៏កំណត់ដាក់កំហិតថា ឈ្មោះអ្នកណាមួយដែលត្រូវឆ្លាក់ទេ គឺឲ្យតែជនរងគ្រោះនៃមន្ទីរស-២១ គឺយើងឆ្លាក់ទាំងអស់។ ហើយពាក់ព័ន្ធទៅនឹងរូបភាពនេះដែរ គឺថា គឺជាស្នាដៃដំបូងបង្អស់ដែលជនរងគ្រោះបានធ្វើឡើងក្នុងគោលបំណងប៉ះប៉ូវនូវព្យសនកម្ម ដែលគាត់បានទទួលរងនៃឧក្រិដ្ឋកម្មនៅក្នុងមន្ទីរស-២១។

[១៦:០៥:៤០]

ជាចុងក្រោយ គឺខ្ញុំគ្រាន់តែសុំបង្ហាញរូបភាពទី៣ គឺជា-- សូមបង្ហាញរូបភាពទី៣។ រូបភាពទី៣ គឺបង្ហាញពីរូបភាពពិតដែលយើងបានថតនៅសារមន្ទីរទួលស្លែង គឺការដាក់ស្តូបនេះ គឺមានកម្ពស់ត្រឹមតែ ១២ម៉ែត្រ ហើយមានទទឹងតូចត្រឹមតែ ១៣ម៉ែត្រទេ។ ក៏ប៉ុន្តែ ការធ្វើនេះ គឺយើងបានគិតអំពីបច្ចេកទេស មិនឲ្យប៉ះពាល់ដល់សោភ័ណភាព ឬក៏រូបភាពដើមនៃសារមន្ទីរទួលស្លែងឡើយ។

អ៊ីចឹង ជាចុងក្រោយយើងខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះតុលាការកំពូលអំពីពិចារណាសំណើច្បាស់លាស់របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុង-- ពាក់ព័ន្ធទៅនឹងបញ្ហាស្តូបនេះ។ បាទ, សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, បើគ្មានអីបន្ថែមទៀតទេ គឺសូមអញ្ជើញសហមេធាវីការពារជនជាប់ចោទ ដើម្បីធ្វើសេចក្តីថ្លែងបញ្ចប់ទាក់ទងទៅនឹងបណ្តឹងសាទុក្ខទាំងអស់តែម្តង។ សូមអញ្ជើញ!

**លោក កង ឫទ្ធារី៖**

ខ្ញុំបាទសូមគោរពលោកប្រធាន។ ប៉ុន្តែ ខ្ញុំឡើងមកបកស្រាយប្រហែលជាពីរនាទីទេ ដើម្បីចៀសវាងការភ័ន្តច្រឡំរបស់លោកមេធាវី ហុង គីមសួន។ ខ្ញុំអត់បានបដិសេធទៅលើរឿងកូនក្តីរបស់លោកទេ ខ្ញុំបដិសេធទៅលើភស្តុតាងពីរដែលមានក្នុងដៃ។ ខ្ញុំជាមេធាវីអាជីពម្នាក់ ខ្ញុំនឹងមិននិយាយអ្វីដែលគ្មានហេតុផលទេ។ តាមលិខិតបញ្ជាក់នេះ វាបញ្ជាក់អំពីលំនៅដ្ឋាន បញ្ជាក់ថា បុគ្គលឈ្មោះ លី ហ៊ី ហ៊្មឹង ពិតជាប្រជាពលរដ្ឋរស់នៅក្នុងភូមិភ្នំតូច ឃុំភ្នំតូច ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យប្រាកដមែន។ មានទៅពាក់ព័ន្ធអ្វីទៅនឹងឋានៈបុគ្គល--

[១៦:០៧:៤២]

**លោក ហុង គឹមសួនៈ**

ណូ១! សុំទោសមិនមែនប្រឆាំងហ្នឹងទេ ខ្ញុំនិយាយមេធាវីលោក ការ សាវុត្ថ និយាយ ណាំ ម៉ុន ទេ ហ្នឹង ខ្ញុំអត់ប្រកែកទេ។

**លោក កង ឫទ្ធារីៈ**

បាទ១ ឈប់ខ្ញុំប្រាប់សិនឲ្យចប់សិន។ បើសិនជាចង់បានរបៀបនេះ ខ្ញុំមិនមែនថាធ្វើមេធាវីដូចគ្នា ហើយណែនាំគ្នាទៅវិញទៅមកនៅមុខអង្គជំនុំជម្រះតុលាការដំបូង ដែលមានមេធាវីអន្តរជាតិ ហើយនិងចៅក្រមអន្តរជាតិអ៊ីចឹងទេ។ អ្នកស្រីមេធាវីត្រូវដឹងថា មានច្បាប់មួយទៀត ដែលមានអទិភាពនៅក្នុងប្រទេសយើងនេះ គឺច្បាប់កំណត់អត្តសញ្ញាណបុគ្គល ឬក៏កំណត់ឋានៈបុគ្គល។ បើបុគ្គលហ្នឹងមានឈ្មោះមួយ ឬពីរ ឬក៏ត្រូវជាកូនអ្នកណានោះ ត្រូវប្ដឹងទៅតុលាការថ្នាក់ជាតិ សុំឲ្យគាត់ចេញសាលក្រមដើម្បីកំណត់អត្តសញ្ញាណបុគ្គលហ្នឹងសិន។ ប្រសិនបើរកអាហ្នឹងបាន ប្រហែលជាតុលាការហ្នឹងទទួលយកហើយ ខ្ញុំណែនាំដោយបំណងល្អតើ ខ្ញុំមានណែនាំបំណងអាក្រក់ពីអង្គាល់ណា?

[១៦:០៨:២៩]

ទីពីរ រូបថតនេះ ខ្ញុំក៏ផ្តល់ការណែនាំគាត់ដោយបំណងល្អដូចគ្នា។ ខ្ញុំថា បើសិនជារូបថតនេះរកបានពីផ្ទះជនរងគ្រោះ ឬក៏សាច់ញាតិណាមួយ យើងអាចយកវាទៅផ្ទឹមជាមួយនឹងរូបថតនៅឯស-២១ អាចឲ្យអ្នកធ្វើកោសល្យវិច័យ គេធ្វើកោសល្យវិច័យបាន។ ប្រហែលជាមានពន្លឺ ឬជាទម្ងន់ដាក់ទៅឲ្យអង្គជំនុំជម្រះតុលាការកំពូលពិនិត្យសាឡើងវិញនូវភស្តុតាងទាំងនេះ។ បើសិនជាយើងដាក់មករបៀបនេះ តើយកជាភស្តុតាងកើតទេ? ដល់ថ្នាក់ហ្នឹងហើយបានខ្ញុំបដិសេធ។ បាទ, តែប៉ុណ្ណឹងទេ ក្រៅពីហ្នឹងខ្ញុំទុកជូនឲ្យសហភាតាខ្ញុំវិញ។

[១៦:០៩:០៥]

**លោក ការ សាវុត្ថៈ**

សូមគោរពឯកឧត្តមប្រធាន សូមគោរពចៅក្រមជាតិនិងអន្តរជាតិ និងសូមគោរពអង្គសវនាការ។ នៅចុងបញ្ចប់នៃអង្គសវនាការតុលាការកំពូលនាពេលនេះ មេធាវីការពារជនជាប់ចោទសូមអនុញ្ញាតលើឡើងនូវមតិមួយចំនួនដូចតទៅៈ

ការណែនាំមួយក្នុងចំណោមការណែនាំនានា ក្នុងការស៊ើបអង្កេត និងដំណើរការក្តីព្រហ្មទណ្ឌ គឺ

ត្រូវគិតគូរពីកំហុសរបស់ជនត្រូវចោទ ពីព្រោះបុគ្គលនេះត្រូវទទួលរងនូវការទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ មាត្រា២៤ ក្រមព្រហ្មទណ្ឌ។ តែ ឌុច អនុវត្តតាមបញ្ជា ដែលមិនមែនជាអំពើផ្ទាល់ខ្លួននោះទេ។

[១៦:១០:០៨]

ចំណុចទី២ ការគិតគូរពីកំហុសរបស់ជនត្រូវចោទ-- របស់ជនជាប់ចោទ ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម និងបុព្វហេតុនៃអំពើឧក្រិដ្ឋ ត្រូវផ្អែកលើព្រឹត្តិការណ៍មួយចំនួនដែលពាក់ព័ន្ធទៅនឹងករណីព្រហ្មទណ្ឌនីមួយៗ ដែលចងដោយច្បាប់ជាតិ និងអន្តរជាតិ ដែលនៅជាធរមាន។

ចំណុចទី៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងពីការគិតគូរ ពីទោសកំហុសរបស់ជនជាប់ចោទ ទៅតាមសារៈសំខាន់ជាមូលដ្ឋានដែលបានកំណត់ថា "ជនជាប់ចោទពីបទប្រព្រឹត្តអំពើឧក្រិដ្ឋគ្រប់រូប ត្រូវចាត់ទុកជាជនគ្មានទោស ដ៏រាបណាទោសកំហុសរបស់ខ្លួនមិនទាន់ត្រូវបានបើកបង្ហាញភស្តុតាង ស្របតាមនីតិវិធីច្បាប់កំណត់ និងមិនទាន់ត្រូវបានតុលាការធ្វើការកាត់ទោសជាស្ថាពរនៅឡើយ" មាត្រា៣៨ រដ្ឋធម្មនុញ្ញកម្ពុជា។

[១៦:១១:២៥]

ព្រឹត្តិការណ៍ពាក់ព័ន្ធទាំងអស់នេះ អាចជួយដោះស្រាយចំណោទបញ្ហានានា ដូចតទៅ៖

- ថាតើបុគ្គលដែលបានប្រព្រឹត្តអំពើនោះស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬទេ?
- ថាតើបុគ្គលនោះបានប្រព្រឹត្តអំពើឧក្រិដ្ឋដែលមានចែងក្នុងច្បាប់ជាតិ និងអន្តរជាតិដែរឬទេ?
- តើការប្រព្រឹត្តអំពើឧក្រិដ្ឋនោះ មានបទប្បញ្ញត្តិចែងអំពីទោសដែរឬទេ?

ដូច្នេះការបង្ហាញការពិត ពីបទល្មើសត្រូវស្របទៅតាមទម្រង់ទោសកំហុសដែលបានប្រព្រឹត្តនៅក្នុងករណីជាក់ស្ដែង ដែលកំណត់ដោយច្បាប់ជាតិជាធរមាន។

[១៦:១២:២១]

ប៉ុន្តែ ចំណុចទី៤ នេះ គឺជាការលំបាក ដោយការបំពានលើទ្រឹស្ដី ស្ដីពីការបង្កើតច្បាប់ជំនុំជម្រះក្រោយអង្គហេតុ និងការអនុវត្តដែលកើតមានភាគច្រើន គឺបកស្រាយបទប្បញ្ញត្តិច្បាប់មាត្រា១ និងមាត្រា២(ថ្មី) ច្បាប់ អ.វ.ត.ក ស្ដីពីការទទួលខុសត្រូវជាបុគ្គល នៃបទឧក្រិដ្ឋដែលសំដៅទៅលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម។ គឺជាតម្រូវការចាំបាច់ដែលត្រូវគិតគូររបស់អង្គជំនុំជម្រះតុលាការកំពូល ព្រមទាំងការបង្ហាញព្រឹត្តិការណ៍ដទៃទៀត

ដែលបញ្ជាក់លក្ខណៈបុគ្គលជាប់ចោទក្នុងនាមជាចារី កថាខណ្ឌ២៥៦ នៃសាលក្រម។

[១៦:១៣:២៥]

ចំណុចទី៥ យើងដឹងហើយថា យុត្តាធិការក្នុងសាលាជម្រះក្តីជាទូទៅមានសមាសធាតុចំនួនបួន គឺយុត្តាធិការបុគ្គល យុត្តាធិការដែនដី យុត្តាធិការពេលវេលា និងយុត្តាធិការសម្ភារៈ។

អ៊ីចឹងបើប្រសិន ជាចំណុចទី៦ បើសិនបើសាលាក្តីត្រូវបានបញ្ចប់និទណ្ឌភាព សាលាក្តីចាំបាច់ត្រូវតែពិចារណាយកចិត្តទុកដាក់អំពីយុត្តាធិការខាងលើ ហើយដែលយុត្តាធិការទាំងនេះ មានចែងកម្រិតក្នុងមាត្រា១ និងមាត្រា២ នៃច្បាប់ អ.វ.ត.ក ស្រាប់ហើយ។

ចំណុចទី៧ ការកំណត់ដែនវិសាលភាពយុត្តាធិការបុគ្គលរបស់សាលាជម្រះក្តីព្រហ្មទណ្ឌ អ.វ.ត.ក មានសារៈសំខាន់ណាស់ ដោយហេតុថា ចំណុចនេះអាចមានផលប៉ះពាល់ដល់ធម្មានុរូបផង និងប្រសិទ្ធភាពរបស់សាលាក្តីផង។

[១៦:១៤:៣៤]

អាស្រ័យហេតុផលទាំងនេះ និងដោយយោងទៅលើមាត្រា១២៩(ថ្មី) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងដោយយោងទៅលើកថាខណ្ឌ៥ នៃសេចក្តីសម្រេចលេខ១៥៣៤ របស់ក្រុមប្រឹក្សាសន្តិសុខ ដែលបានកំណត់លក្ខណៈវិនិច្ឆ័យអំពីកម្រិតថ្នាក់ជាន់ខ្ពស់ និងដោយយោងទៅលើវិធាន១១ស្ទួន យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិយូហ្គោស្លាវី។ មេធាវីការពារក្តីនៅតែយល់ថា ម្ចាស់ឧក្រិដ្ឋកម្មនៅ ស-២១ មិនមែន កាំង ហ្គេកអ៊ាវ ហៅ ឌុច ទេ។ ម្ចាស់ឧក្រិដ្ឋកម្មនៅ ស-២១ គឺបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មិនមែន កាំង ហ្គេកអ៊ាវ ទទួលទោសជំនួសអ្នកបញ្ជានោះទេ។

ទីពីរ យើងឃើញថាមេគុកទាំង១៩៥ គុកទៀតជាចារី ត្រូវនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក មិនត្រូវបានយកមកកាត់ទេ ទោះបីគុកនោះសម្លាប់ប្រជាជនអស់រាប់សិបដង លើស ឌុច ក៏ដោយ។ ហើយស-២១ ក៏ជាគុកដូច១៩៥គុក ឯទៀតដែរ ត្រូវតែជាចារីដូចគ្នា។ ត្រូវនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក ដូចគ្នានោះទើបយុត្តិធម៌ដែលអាចទទួលយកបាន។ មេគុក១៩៥ ទៀត បានសម្លាប់ប្រជាជនកម្ពុជាតាមបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា និងតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដូចគ្នានឹងគុក ស-២១ ដែរ តែ អ.វ.ត.ក មិនបានរកយុត្តិធម៌ឲ្យទេ។

[១៦:១៦:៤០]

ដូច្នេះ បើគិតជាភាគរយនៃចំនួនប្រជាជនដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង

ចំនួនអ្នកដែលស្លាប់នៅស-២១ មានចំនួន១២.២៧០ នាក់ ឃើញថា អ.វ.ត.ក រកយុត្តិធម៌ឲ្យប្រជាជនបានតែមិនដល់មួយភាគរយផង បានតែជិតមួយភាគរយប៉ុណ្ណោះ។ អ៊ីចឹងនៅ៩៩ភាគរយ មិនទាន់បានរកយុត្តិធម៌ទេ។

រួមសេចក្តីមក មេធាវីការពារក្តីនៅតែចាត់ទុកថា ការឃុំខ្លួនកន្លងមកលើរូប កាំង ហ្កេកអ៊ាវ ហៅ ឌុច គឺជាវិធានការការពារសាក្សីមានសក្តានុពល សម្រាប់ចង្អុលបង្ហាញមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មផងដែល ហើយសូមចាត់ទុកសាលក្រមសំណុំរឿងលេខ០០១ ជាមោឃៈ និងសុំដោះលែងឲ្យឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច មានសេរីភាពឡើងវិញ ដោយតុលាការពិនិត្យឃើញថា កាំង ហ្កេកអ៊ាវ ហៅ ឌុច ក៏ដូចជាប្រធានគុកទាំង ១៩៥គុកទៀតដែរ វាជាចារី វាត្រូវនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។

ដូច្នេះ គុក ស-២១ កាំង ហ្កេកអ៊ាវ ក៏នៅក្រៅយុត្តាធិការ អ.វ.ត.ក ដូចគ្នាដែរ។ ហេតុនេះ សុំឲ្យតុលាការកំពូលមេត្តាពិចារណា ដោយយុត្តិធម៌បំផុត។ សូមអរគុណ។

[១៦:១៨:២៨]

**ប្រធានអង្គជំនុំ៖**

លោកសហមេធាវីមានបំណងនឹងធ្វើបន្ថែមទេ?

**លោក កង ឫទ្ធារី៖**

ខ្ញុំដូចអត់មានអីទៀតទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងជាបន្តទៅទៀតនេះ បើជនជាប់ចោទមានបំណងនឹងថ្លែងបញ្ចប់ សូមអញ្ជើញធ្វើសេចក្តីថ្លែង។ អ៊ីចឹងសូមអញ្ជើញមកកន្លែងនេះ។

**ជនជាប់ចោទ៖**

ខ្ញុំសូមគោរព អរគុណអង្គជំនុំជម្រះតុលាការកំពូលដែលអនុញ្ញាតឲ្យខ្ញុំថ្លែងនៅក្នុងចុងបញ្ចប់នេះ។

សេចក្តីថ្លែងបញ្ចប់៖

១) បំណងរបស់ខ្ញុំ គឺសុំអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ និងពិចារណា អំពីយុត្តាធិការបុគ្គល គឺសុំតុលាការទទួលស្គាល់ថា រូបខ្ញុំស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក ដែលត្រូវតែបានដោះលែង។ ករណីច្បាស់លាស់ណាស់ដែលហៅថា អ្នកទទួលខុសត្រូវខ្ពស់បំផុត គឺគេទេ មិនមែនខ្ញុំទេ។ ទី១

បើឈរលើគោលគំនិត ដែលកំណត់ថា មេដឹកនាំ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត គឺសំដៅយកអ្នកណាដែលមានសិទ្ធិបង្កើតមាគ៌ា កែប្រែមាគ៌ា និងលុបមាគ៌ា គឺគេ មិនមែនខ្ញុំ។ ប្រតិចារឹកថ្ងៃ៣១ មីនា ២០០៩ E1/6.1 ពីបន្ទាត់១៣ ទំព័រ៥២ រហូតដល់បន្ទាត់ទី៦ ទំព័រ៥៨ និងរូបគំនូរដែលមានចំណងជើងថា ថ្ងៃអង្គារបស់បក្សកុម្មុនីស្តកម្ពុជា ឯកសារ E36 ទំព័រ ERN00294001 ជាភស្តុតាងស្រាប់។

[១៦:២១:៤៤]

ខ្ញុំយល់ថា ការកំណត់បែបនេះយ៉ាងហោចណាស់ក៏ឯកភាពជាមួយនឹងប្រទេសចិន សម័យមហាបដិវត្តវប្បធម៌ដែរ។ ចិន គេកំណត់យក្រុមបួននាក់ ថាជាមេដឹកនាំជាន់ខ្ពស់ និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុត។ ហេតុការណ៍នេះត្រូវបានដឹងឮជាសាកល។ វចនាក្រមបារាំង *ឡឺពីទី ឡារ៉ូស អ៊ីលស្រ្តេ* (និយាយភាសាបារាំង) ឆ្នាំ២០០៨ ទំព័រ១១៥១ បានចុះឈ្មោះពួកអស់នេះ និងអវសាននៃជីវិតនយោបាយរបស់ពួកនេះ ត្រង់ពាក្យថា "*បង់ដឺស ដេកាត្រឺស*"។

២) បើកំណត់យកអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ថាជាមេដឹកនាំជាន់ខ្ពស់ និងកំណត់យកបុគ្គលទាំងឡាយដែលមានសិទ្ធិសម្រេចកម្មេស ថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត។ នោះក៏គេ មិនមែនខ្ញុំ។ ខ្ញុំបានវិភាគបញ្ហាជូនអង្គជំនុំជម្រះសាលាដំបូងតាមអត្ថបទរបស់ខ្ញុំ ដែលមានចំណងជើងថា "អំពីការកាប់សម្លាប់ ដែលបក្សកុម្មុយនីស្តកម្ពុជា បានប្រព្រឹត្តជាហូរហែ" ឯកសារ E159/10 ពីទំព័រ ERN00404775 សូមទោស 785។ ខ្ញុំអានម្តងទៀត ERN00404785 ដល់ ERN00404817។ ឯកសារនេះ ក៏មាននៅក្នុងការកំណត់ត្រារបស់ប្រតិចារឹក E1/80.8 ថ្ងៃ២៥ វិច្ឆិកា ២០០៩ ពីទំព័រ ERN00406926 ពីបន្ទាត់២ រហូតដល់ ERN00406850 បន្ទាត់៣។

[១៦:២៤:១៤]

តទៅនេះ ខ្ញុំសូមបញ្ជាក់ជូនអង្គជម្រះតុលាការកំពូលថា ការកំណត់ក្របខ័ណ្ឌអ្នកដែលមានសិទ្ធិសម្រេចកម្មេចមានចែងច្បាស់ក្នុងឯកសារផ្លូវការ និងសម្ងាត់របស់អចិន្ត្រៃយ៍មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាតែម្តង គឺឯកសារដែលយើងមានទម្លាប់ហៅថា ឯកសារថ្ងៃទី៣០ មីនា ១៩៧៦។

កថាខណ្ឌទី១ នៃឯកសារនេះ ត្រូវបានសហចៅក្រមស៊ើបអង្កេតយកមកប្រើ។ កថាខណ្ឌទី៣៥ និង៣៦ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ D99 ជាភស្តុតាងស្រាប់។ អង្គជំនុំជម្រះសាលាដំបូង ក៏បានប្រើឯកសារនេះ កថាខណ្ឌ១០២ និង១០៣ នៃសាលក្រម ថ្ងៃ២៦ កក្កដា ២០១០ E188 ជាភស្តុតាងស្រាប់។

បន្ទាប់ទាំងនេះ ខ្ញុំសូមបញ្ជាក់ថា ទឡ្ហីករណ៍ដែលសហមេធាវីការពារក្តីរបស់ខ្ញុំទាំងពីរនាក់បានថ្លែងនៅពេលមុននេះ អំពីយុត្តាធិការបុគ្គលក៏ឈរលើស្មារតីនៃឯកសារនេះ គឺឯកសារថ្ងៃ៣០ មីនា ១៩៧៦ ត្រង់កថាខណ្ឌ១។

ទាំងអស់នេះ ជាហេតុផលដែលយើងខ្ញុំទាំងបីនាក់លើកឡើងជូនអង្គជំនុំជម្រះតុលាការកំពូលថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មកម្ពុជា ជានរណា?

ដើម្បីជាប្រយោជន៍ក្នុងការរកយុត្តិធម៌ជូនប្រជាជនកម្ពុជាទូទាំងប្រទេស ដែលរងទុក្ខវេទនា និងវិនាសហិនហោចគ្រប់វិស័យ គិតត្រឹមតែការបាត់បង់ជីវិតទៅចុះ ក៏មានពីមួយលានប្រាំពីរសែន ទៅពីរលាន់ពីរសែននាក់។ អដ្ឋិធាតុរបស់ប្រជាជនយើងនៅរាយប៉ាយពេញផ្ទៃប្រទេស។

[១៦:២៦:៣៩]

តទៅនេះ ខ្ញុំសូមរាយការណ៍បញ្ជាក់បន្ថែមអំពីតួនាទីរបស់ ស-២១ និងតួនាទីរបស់ផ្ទាល់ខ្លួនខ្ញុំ។ តួនាទីរបស់ ស-២១ ខ្ញុំបានសរុបរាយការណ៍ជូនអង្គជំនុំជម្រះសាលាដំបូងក្នុងឯកសារ E159/10 រួចហើយ។ ខ្ញុំនៅតែទទួលស្គាល់គ្រប់បញ្ហាទាំងអស់ដែលខ្ញុំបានលើកឡើង គឺ ស-២១ មិនមានតួនាទីគ្រប់ដណ្តប់ទៅលើមន្ទីរសន្តិបាលផ្សេងទៀតទេ។

២) គឺ ស-២១ ក៏ដូចជាមន្ទីរសន្តិបាលផ្សេងទៀតដែរ សុទ្ធតែបង្ខំឲ្យប្រើទារុណកម្ម។ ពេលនេះខ្ញុំសូមលើកភស្តុតាងពីរ ដែលសហចៅក្រមស៊ើបអង្កេតបានផ្តល់ឲ្យខ្ញុំពន្យល់ក្នុងឱកាសសួរចម្លើយក្រោយថ្ងៃ២៧ វិច្ឆិកា ២០០៩ គឺក្រោយថ្ងៃបញ្ចប់សវនាការនៃសំណុំរឿងលេខ០០១។

ភស្តុតាងទីមួយ គឺលិខិត របស់ ហួត ហេង ហៅ ប៉ាល់ អនុលេខាភូមិភាគបស្ចិម បញ្ជូនអ្នកស្រី អ៊ុំ ណេន ហៅ លី ប្រពន្ធ ជូ ជេត ហៅ ស៊ី ដែលជាអតីតលេខាភូមិភាគបស្ចិមមកអង្គការ គឺមក ប៉ុល ពត តាមរយៈមន្ទីរ ក-៧ គឺ មន្ទីរនីរសារមជ្ឈិម។ ភស្តុតាងនេះ វាបញ្ជាក់កាន់តែច្បាស់ឡើងថា ការបញ្ជូនមនុស្សពីភូមិភាគមកស-២១ គឺជាអំណាចនិងបទបញ្ជារបស់អចិន្ត្រៃយ៍មជ្ឈិមបក្ស។ ពោលគឺមិនមែនជាអំណាចរបស់ ស-២១ ទេ។

[១៦:២៨:២៩]

ភស្តុតាងទីពីរ ឯកសាររាយការណ៍ចម្លើយរបស់ស-២១ ដែលមិត្តអ្នកសួរគេចារ គេបានថា គេចារ គេថាបានធ្វើទារុណកម្ម បន្ទាប់ពីពេលគេប្រើវិធីត្រជាក់មិនបានផល។ នៅពេលនោះ ខ្ញុំបានពន្យល់សហចៅក្រមស៊ើបអង្កេតថា ទារុណកម្មជាគោលការណ៍តម្រូវចំពោះមន្ទីរសន្តិបាលទូទាំងប្រទេស។

កំណត់សួរចម្លើយខ្ញុំ កំណត់ហេតុសួរចម្លើយខ្ញុំ ដោយសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿងលេខ០០២ ជាភស្តុតាងស្រាប់។

[១៦:២:០៨]

តទៅនេះខ្ញុំសូមនិយាយអំពីសិទ្ធិសម្រេចកម្ទេច។ សិទ្ធិសម្រេចកម្ទេច ជាគោលការណ៍ដែលខ្ញុំគោរពយ៉ាងម៉ឺងម៉ាត់ដាច់ខាត។ ឧទាហរណ៍ អ្នកសួរចម្លើយបានបំពានលើអវៈយវៈភេទរបស់អ្នកគ្រូខ្ញុំ។ វាជាការមួយដែលខ្ញុំមានការឈឺចាប់ខ្លោចផ្សាឥតឧបមា តែសិទ្ធិអំណាចរបស់ខ្ញុំ គឺរាយការណ៍ជូនមេទ្ធូវហេតុការណ៍ជាក់ស្តែង។ មេជាអ្នកសម្រេច។ ខ្ញុំគ្មានសិទ្ធិទាមទារចាប់ទេ ព្រោះបើកាលណាចាប់ ត្រូវតែកម្ទេច។ បើខ្ញុំចៀសគឺ ខ្ញុំរំលោភលើសិទ្ធិអំណាចរបស់មេខ្ញុំ។

ខ្ញុំសូមរាយការណ៍ជូនតុលាការថា អ្នកដែលល្មើសនឹងសិទ្ធិអំណាចសម្រេចកម្ទេចនេះ ពិតជាត្រូវបក្សកម្ទេចចៀសមិនរួច ដូចយ៉ាង កុយ ធួន និង អ៊ិន លន ហៅ ណាត ជាដើម។

ខ្ញុំជឿថា ខ្ញុំដែលរស់រានមានជីវិតរហូតថ្ងៃនេះ គឺដោយសារខ្ញុំគោរពគោលការណ៍នេះតាំងពីថ្ងៃ២០ កក្កដា ១៩៧១ យ៉ាងម៉ឺងម៉ាត់។ ថ្ងៃ២០ កក្កដា ១៩៧១ គឺថ្ងៃដែលបក្សកុម្មុយនីស្តកម្ពុជាតម្រូវឲ្យខ្ញុំធ្វើប្រធាន ម-១៣។

[១៦:៣០:៣៥]

នៅចុងបញ្ចប់នេះ ខ្ញុំសូមបញ្ជាក់ថា ការងារសន្តិបាលនេះ ជាការងារដែលខ្ញុំធ្វើទាំងអួសដៃ អួសជើង ចាប់តាំងពីថ្ងៃ២០ កក្កដា ១៩៧១ រហូតមក។ ឆ្នាំ១៩៧៣ ពេលដែលអ្នកជាប់ឃុំនៅ ម-១៣ វាយគុករត់រួចទាំងអស់គ្នា ខ្ញុំបានសុំ វន វ៉េត ឲ្យគាត់អនុវត្តវិន័យលើខ្ញុំ។ ក្រោយ១៧ មេសា ១៩៧៥ ខ្ញុំបានសុំបក្សទៅនៅជាមួយ ចេង អន គឺនៅខាងឧស្សាហកម្ម។ ក្រោយដែលពេលដក ណាត សុំទោស ក្រោយដែលបក្សដក ណាត ខ្ញុំបានសុំបក្ស សុំដាក់ ឆាយ គឹមហ៊ ហៅ ហុក មកធ្វើប្រធាន ស-២១។ ខ្ញុំសុំនៅធ្វើជាអនុប្រធានដដែល។ ការសុំរបស់ខ្ញុំជាបន្តបន្ទាប់កន្លងមកនេះសុទ្ធតែមិនបានផល ពីព្រោះគោលការណ៍របស់បក្ស ភារកិច្ចអីដែលបក្សប្រគល់ឲ្យត្រូវតែធ្វើ។ អ្នកឯងមិនធ្វើមិនបានៗ។

[១៦:៣១:៤៩]

ចំណែកការងារប្រចាំថ្ងៃនៅស-២១ វិញ ខ្ញុំពិតជាត្រូវបានជំរុញ ឬយើងហៅថា កៀបសង្កត់ ក៏បាន។ គឺគាបសង្កត់ជាប់ជាប្រចាំរបស់មេ តាមរយៈទូរស័ព្ទសម្ងាត់ផង តាមការហៅទៅធ្វើការណែនាំផ្ទាល់ផង។ ម្យ៉ាងទៀត ចំណែកធាតុពិតនៃការអនុវត្តរបបផ្តាច់ការទាំងងងឹតងងុលបែបនេះ ខ្ញុំចាប់

អារម្មណ៍ថាមិនល្អចាប់តាំងពីថ្ងៃ២០ កក្កដា ១៩៧១ មកម្ល៉េះ ពោលគឺ ខ្ញុំចាប់អារម្មណ៍នឹងគោលការណ៍ដែលកំណត់ថា ឲ្យតែប្រជាជនចូលមកតំបន់រំដោះ ត្រូវតែចាត់ទុកថាខ្មាំង ដែលត្រូវតែកម្ទេច។ ខ្ញុំពិតជាមិនស្របនឹងមាគ៌ានេះ ម្លោះហើយខ្ញុំបានរក្សាទុកមនុស្សឲ្យនៅរស់បង្កបង្កើនផល ព្រមទាំងបានពុះពារសុំដោះលែងមួយចំនួន ហើយសុំដោះលែងជាដាក់ស្តែងមួយចំនួនផង។

សូមបញ្ជាក់ថា ពួកអ្នកដែលវាយគុករត់រួចនៅឆ្នាំ១៩៧៣ គឺជាពួកអ្នកដែលខ្ញុំបានរក្សាទុកសម្រាប់បង្កបង្កើនផលនេះឯង។

[១៦:៣៣:១៥]

ដោយឡែកនៅឆ្នាំ១៩៧៣ ខ្ញុំតក់ស្លុតនូវការចាប់ចង កាប់សម្លាប់នៅ អមលាំង ដែលជាមូលដ្ឋានបង្អែករបស់បក្សតាំងពីយូរមកហើយ ដែលជាការបោសសម្អាត ដែលបក្សភូមិភាគនិរតីបានសម្រេចបញ្ជា បានតាមដាន និងបានដឹកនាំចលនាបោសសម្អាតនេះដោយផ្ទាល់។

បញ្ហានេះ ខ្ញុំបានរាយការណ៍នៅក្នុងសេចក្តីរាយការណ៍របស់ខ្ញុំជូនអង្គជំនុំជម្រះសាលាដំបូងរួចហើយ។ បន្ទាប់មកនៅថ្ងៃ៣១ មករា ១៩៧៧ ខ្ញុំតក់ស្លុតបំផុត ក្នុងការដែលបក្សបានសម្រេចចាប់កម្មាភិបាលឧត្តរ ដោយខ្ញុំយល់ថា អ្នកស្នេហាជាតិ ស្នេហាប្រជាជន លះបង់អ្វីទាំងអស់ដើម្បីជាតិ ដើម្បីប្រជាជន បែរជាមកស្លាប់នៅស-២១។ មន្ទីរដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ ដែលមានកំណើតនៅភូមិភាគឧត្តរដែរ។

[១៦:៣៤:២៥]

ក្រោយពេលដែលចាប់ ង៉ែត យូ ហៅ ហុង, សូ ជា និង សូ យក់ ធ្វើឲ្យខ្ញុំ តក់ស្លុតនឹងជីវិតខ្លួនឯង ពោលគឺរស់បានមួយថ្ងៃ ជឿថារួចខ្លួនមួយថ្ងៃ។ ចាប់ វន វ៉េត ចាប់ ឆាយ គឹមហ៊ី សុទ្ធតែមានបច្ច័យអាក្រក់ខាងផ្លូវចិត្តដល់ខ្ញុំយ៉ាងជ្រាលជ្រៅ រហូតដល់អស់សង្ឃឹមធ្វើការអ្វីលែងកើត។ ដែលអស់សង្ឃឹមមែនទែន គឺនៅពេលដែលបក្សណែនាំឲ្យដកអ្នកជាប់ឃុំនៅមន្ទីរស-២១ យកទៅកម្ទេចឲ្យអស់នៅមុនថ្ងៃ៦ មករា ១៩៧៩។

៣) តុលាការជាទីគោរព, បន្តទៅនេះខ្ញុំសូមរាយការណ៍អំពីស្មារតីសហការរបស់ខ្ញុំ។ មេធាវីរបស់ខ្ញុំបានរាយការណ៍ច្បាស់លាស់អស់ហើយ អំពីការដែលខ្ញុំបានសហការជាមួយតុលាការ។ តទៅនេះខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានសហការជាមួយសហប្រជាជាតិដោយស្មោះត្រង់ទៀតផង។ ខ្ញុំបានត្រូវគ្រីស្ទូ ប៉េស្ទូ ដែលកាលនោះជាអនុប្រធានការិយាល័យសិទ្ធិមនុស្សសហប្រជាជាតិប្រចាំកម្ពុជា ហៅ

យកទៅសួរចម្លើយនៅសណ្ឋាគារមនោរម្យ ខេត្តបាត់ដំបង ពីថ្ងៃ២៩ មេសា ១៩៩៩ រហូតដល់ថ្ងៃ០៤ ឧសភា ១៩៩៩។ ទោះបីពេលនោះខ្ញុំតូចចិត្តនឹង ប៉េស៊ូ ដែលមិនព្រមសហការជាមួយអជ្ញាធររដ្ឋាភិបាល ដែលខ្ញុំធ្លាប់និយាយថា ប៉េស៊ូ ធ្វើដូចចោរ។

បន្ទាប់មកជាមួយ ភីតធឺឡឺប្រ៊ិច អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ បានទៅជួបសម្ភាសន៍ខ្ញុំនៅពន្ធនាគារអយ្យការយោធា ថ្ងៃ១៧ វិច្ឆិកា ២០០៦ អ្នកកាសែតអ៊ីតាលី ម្នាក់គឺ វ៉ាល់ឡារីយ៉ូ ហ្វីលីពចារ៉ូ។ បន្ទាប់មកនៅថ្ងៃ៧ មិថុនា ២០០៧ ជាមួយទូរទស្សន៍ជប៉ុន។ បន្ទាប់មកថ្ងៃ១៥ មិថុនា ២០០៧ ជាមួយទូរទស្សន៍អ៊ីតាលី។ ទាំងអស់នេះសុទ្ធ តែទទួលបានការអនុញ្ញាតត្រឹមត្រូវពីក្រសួងការបរទេស។

[១៦:៣៦:៥៩]

ខ្លឹមសារដែលខ្ញុំលើកឡើង គឺឧក្រិដ្ឋទាំងអស់ ឧក្រិដ្ឋកម្មទាំងអស់នៅកម្ពុជា ជាឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបងទី១ ប៉ុល ពត ជាលេខា បងទី២ នួន ជា ជាអនុលេខ បងទី៣ អ៊ីង ធៀរី ហៅ ម៉ុក ជាអនុលេខាទីបី បន្ទាប់មកជាអនុលេខាទីពីរ បានលាតត្រដាងថា ជាឧក្រិដ្ឋកម្មរបស់យួន។

ខ្ញុំលាតត្រដាងយ៉ាងនេះ ដូច្នេះ ខ្ញុំលាតត្រដាងយ៉ាងនេះក្នុងបរិយាកាសនយោបាយមួយដែលកំពុងដឹកនាំនយោបាយទាំងបីរូបរបស់បក្សកុម្មុយនីស្តកម្ពុជាទម្លាក់កំហុសទៅវៀតណាម។

សូមបញ្ជាក់ថា បងទី៣ អ៊ីង ធៀរី ហៅ ម៉ុក នៅអយ្យការយោធាក៏ដោយ ក៏នៅតែស្តីឲ្យខ្ញុំថា មាគ៌ាមកពីណាឲ្យសារភាព មាគ៌ា តាឌុច ឬអី? ថ្ងៃមួយនោះ បងទី៣ អ៊ីង ធៀរី ហៅ ម៉ុក ស្រែកឡូឡាតាមទម្លាប់របស់គាត់ដែលជាមនុស្សនិយាយឮៗថា យួនវាទិញក្បាលអស់ហើយនៅសល់តែមួយទេ។

[១៦:៣៨:០៩]

បច្ចុប្បន្ននេះក៏ដោយ ក៏បងទី២ នួន ជា ពេលដែលគាត់មកដល់មន្ទីរឃុំឃាំងនេះដំបូងភ្លាម គាត់ណែនាំថា យើងកុំភ្លេចធាតុពិតរបស់យើងជាអ្នកស្នេហាជាតិវាយយួន។ បន្តបន្ទាប់មកទៀត គាត់ចេះតែឆ្លៀតឱកាសអូសទាញខ្ញុំខាងទស្សនៈគោលជំហរថា ឧក្រិដ្ឋកម្មនៅកម្ពុជា ទោះបីក្នុងរយៈកាលយុត្តាធិការក៏ដោយក៏ជាឧក្រិដ្ឋកម្មរបស់យួន។

បន្តទៅនេះ ខ្ញុំសូមបញ្ជាក់អំពីគោលជំហររបស់ខ្ញុំចំពោះប្រជាជនកម្ពុជាទូទាំងប្រទេស។

បញ្ជាក់ទីមួយ គឺខ្ញុំនៅតែរក្សាគោលជំហរខាងផ្លូវច្បាប់ចំពោះជនរងគ្រោះនៅមន្ទីរស-២១ និងទទួលខុសត្រូវខាងផ្លូវចិត្តចំពោះជនរងគ្រោះទូទាំងប្រទេស។ ខ្ញុំនៅតែរក្សាគោលជំហរសុំខមាលទោស

ចំពោះវិញ្ញាណក្ខន្ធជនរងគ្រោះទាំង ១២.២៧៣នាក់ ដែលបានស្លាប់បាត់បង់ជីវិតនៅស-២១ ព្រមទាំងសុំគ្រួសារអស់លោកទាំងនោះអនុញ្ញាតឲ្យខ្ញុំសុំចូល សុំទោសនៅថ្ងៃណាមួយសមរម្យ។

[១៦:៣៩:៣៣]

ទន្ទឹមនេះ ខ្ញុំជឿជាក់ថា ប្រជាជនកម្ពុជាដែលជាអតីតខ្មែរក្រហម រាប់តាំងពីអតីតយុទ្ធជនរហូតអតីតកម្មាភិបាលជាន់ខ្ពស់ប៉ុនណាក៏ដោយ ត្រូវតែប្រកាន់គោលជំហរមួយឲ្យរឹងប៉ឹង គឺត្រូវទទួលស្គាល់ថា យើងទាំងអស់គ្នាបានចូលរួមការតស៊ូបដិវត្តន៍ដើម្បីជាតិប្រជាជនកម្ពុជាក៏ពិតមែនហើយ តែមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជាជាមាគ៌ាមហាឧក្រិដ្ឋ ដែលចម្លងពីមាគ៌ាមហាឧក្រិដ្ឋរបស់ក្រុមបួននាក់របស់មហាបដិវត្តវប្បធម៌ចិន។ ខ្ញុំយល់ថា បើអតីតយុទ្ធជន អតីតកម្មាភិបាលអនុវត្តបានជ្រួតជ្រាបនូវគោលជំហរនេះជាសរសៃញ្ញាក់ ពិតជាអំណោយដល់ចលនាផ្សះផ្សាជាតិ។

[១៦:៤០:៣៥]

ខ្ញុំលើកបញ្ហានេះឡើងជូនតុលាការ ក្នុងគោលបំណងសុំតុលាការពិចារណា និងរកវិធានការយ៉ាងណាកំណត់ក្នុងសាលដីកា តម្រូវឲ្យខ្មែរក្រហមគ្រប់រូបទទួលស្គាល់ខាងផ្លូវចិត្តថា ទោះបីជាយើងជាអ្នកស្នេហាជាតិ ស្នេហាប្រជាជន ហ៊ានលះបង់អ្វីៗគ្រប់យ៉ាងរហូតដល់ត្រៀមលះបង់ជីវិតក៏ដោយ ក៏មាគ៌ាបក្សយើង វាជាមាគ៌ាឧក្រិដ្ឋ ព្រោះបក្សយើងអនុវត្តផ្តាច់ការវណ្ណៈអធន ងងឹតងងុលជ្រុលហួសហេតុពេក ប្រើគ្រប់មធ្យោបាយដើម្បីកៀបសង្កត់ឲ្យយើងអនុវត្តមាគ៌ាគេ។ បើយើងមិនអនុវត្ត ឬអនុវត្តដោយខ្ជីខ្ជា យើងពិតជារងគ្រោះថ្នាក់ដល់ជីវិត។

ក្រោមពាក្យស្លោកថា ក្រោមការចោទប្រកាន់ថា "ប្រឆាំងបក្ស ប្រឆាំងមាគ៌ា" ខ្ញុំសូមសម្តែងយ៉ាងមុតមាំ ជំនឿយ៉ាងមុតមាំចំពោះអង្គជំនុំជម្រះតុលាការកំពូល ដែលមានសុភវិនិច្ឆ័យក្នុងការរកយុត្តិធម៌ជូនប្រជាជនកម្ពុជាទាំងអស់ ទាំងប្រជាជនដែលរងគ្រោះ និងប្រជាជនដែលជាអតីតខ្មែរក្រហម។

[១៦:៤១:៤៥]

ក្នុងការរៀបចំបញ្ហានេះ ដើម្បីសុខសន្តិភាពផ្លូវចិត្តរបស់ប្រជាជនកម្ពុជា នៅខាងចុងនេះ ខ្ញុំសូមអនុញ្ញាតអំពីកិច្ចដំណើរការដោះស្រាយនៅចិន ដើម្បីជាការយល់ដឹងទូទៅមួយដែលខ្ញុំសូមរាយការណ៍ជូនអង្គជំនុំជម្រះតុលាការកំពូល។ ព្រោះសភាពការណ៍នៅចិនជំនាន់នោះ វាជាប្រភពដើមនៃសភាពការណ៍នៅកម្ពុជាជំនាន់ឆ្នាំ១៩៧៥-១៩៧៩ មហាបដិវត្តវប្បធម៌នៅចិន វាកើតឡើងតាំងពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៧៦។ នៅឆ្នាំ១៩៧៦ ក្រុមបួននាក់ត្រូវចាប់ខ្លួន និងត្រូវបានជំនុំជម្រះឲ្យមានទោសមួយជីវិត។ ដោយ

ឡែកតែ ជៀន ឈិញ មុនដំបូងៗត្រូវបានកាត់ទោសប្រហារជីវិត ដល់ឆ្នាំ១៩៧៩ ក៏ត្រូវបានបញ្ចុះទោសមកនៅមួយជីវិត។

[១៦:៤២:៥៦]

ខ្ញុំសូមបញ្ជាក់ថា នៅចិនគេនៅរក្សាប្រហារជីវិតរហូតបច្ចុប្បន្ន។ នៅឆ្នាំ១៩៧៩ ដដែល តេង សៀវភីង គាត់បានទៅថ្លែងវិយោគកថា គោរពវិញ្ញាណក្ខន្ធខន្ធ លី សាវឈី និងវិញ្ញាណខក្ខន្ធអតីតយុទ្ធជននិងកម្មាភិបាលដែលបានស្លាប់បាត់បង់ជីវិតក្នុងអំឡុងមហាបដិវត្តវប្បធម៌នេះ ព្រមទាំងបានផ្តល់ភាពស្អាតស្អំ គឺភាពគ្មានពិរុទ្ធភាពដល់អ្នករងគ្រោះទាំងអស់មាន លី សាវឈី ជាប្រមុខ ឈ្មោះ លី សាវឈី ក៏មានចុះនៅក្នុងវចនានុក្រុមបារាំង *"លើពើទី ឡារូស អេលុយស្ត្រេយ៍"* (និយាយភាសាបារាំង) ឆ្នាំ២០០៨ ផ្នែកខាងអសាធារណរដ្ឋនាម។ ត្រង់ឈ្មោះ លី សាវឈី ដែលផ្តើមឡើងដោយអក្សរ អិល-អ៊ី-អ៊ុយ។

[១៦:៤៣:៥១]

តុលាការជាទីគោរព, ដោយមានបំណងផ្សះផ្សាជាតិ តាមគោលការណ៍ផ្សះផ្សារបួសស្នាម ក្នុងចំណោមប្រជាជនខ្ញុំ ខ្ញុំបានសុំបណ្ឌិត ឈឹម សុធារ៉ា ទាក់ទងនឹងគាត់ក្រែងលោ ខ្ញុំមានលទ្ធភាពរួមចំណែកផ្សះផ្សារបួសស្នាមខាងផ្លូវចិត្តជូនប្រជាជនខ្ញុំបាន។

សេចក្តីបញ្ចប់ៈ

តុលាការជាទីគោរព, នៅចុងបញ្ចប់នេះ ខ្ញុំសូមត្រឡប់និយាយ អំពីគោលការណ៍មូលដ្ឋានរបស់យើងខ្ញុំគឺ សូមអង្គជំនុំជម្រះតុលាករកំពូលពិចារណា និងសម្រេចអំពីលក្ខណៈក្រៅយុត្តាធិការ អ.វ.ត.ក របស់រូបខ្ញុំ ពីព្រោះវាជាគោលការណ៍សំខាន់មួយ សម្រាប់រកយុត្តិធម៌ជូនប្រជាជនកម្ពុជាទូទាំងប្រទេស ក៏ដូចជាអាចការពារអតីតខ្មែរក្រហមឲ្យផុតពីហានិភ័យផងដែរ។ សំខាន់អតីតកម្មាភិបាលមធ្យមរបស់ខ្មែរក្រហម ដែលមិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។

ខ្ញុំសូមចប់។

**ប្រធានអង្គជំនុំៈ**

ហើយជាទីបញ្ចប់នេះ គឺខ្ញុំសូមធ្វើការ-- កិច្ចពិភាក្សាដេញដោលនៃសវនាការក្នុងរយៈពេលបីថ្ងៃនេះគឺ ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ ត្រូវបានប្រព្រឹត្តទៅដោយមានការចូលរួមធ្វើសេចក្តីថ្លែងការណ៍ អំពីទឡ្ហីករណ៍នានាទាក់ទងនឹងផ្លូវច្បាប់របស់ព្រះរាជអាជ្ញា សហមេធាវីការពារជន

ជាប់ចោទ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបីក្រុម ជូនអង្គជំនុំជម្រះតុលាការកំពូល។ ហើយមានការចូលរួមធ្វើសេចក្តីថ្លែងបញ្ចប់របស់សហមេធាវីការពារជនជាប់ចោទ និងសេចក្តីថ្លែងបញ្ចប់របស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច តាមកាលវិភាគដែលយើងបានគ្រោងទុកក្នុងរយៈពេលបីថ្ងៃនេះ។

ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ប្រកាសបិទកិច្ចពិភាក្សាដេញដោលនាពេលនេះ ហើយការបរិច្ឆេទនៃការប្រកាសសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល តុលាការកំពូលនឹងជូនដំណឹងនាពេលក្រោយ ហើយសូមបង្គាប់ដល់មន្ត្រីពន្ធនាគារ នាំជនជាប់ចោទទៅមន្ទីរឃុំឃាំងវិញ។

[១៦:៤៦:៤៥]

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

តុលាការ សូមប្រកាសបិទសវនាការ៕

*(សវនាការបញ្ចប់នៅម៉ោង ១៦:៤៧ នាទី)*